ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារជំនួយ

# វិធីសាស្ត្របង្រៀន

# ពលរដ្ឋវិជ្ជា

## ថ្នាក់ទី១០ និងទី១១

២០១៨

ឯកសារជំនួយ

# វិធីសាស្ត្របង្រៀន ពលរដ្ឋវិទ្យា

## ថ្នាក់ទី១០ និងទី១១

ក្រសួងអប់រំ យុវជន និងកីឡា

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ២១៦០ **អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារជំនួយ «វិធីសាស្រ្តបង្រៀនពលរដ្ឋវិជ្ជា ថ្នាក់ទី១០ និងទី១១»
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេច លេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារជំនួយ «វិធីសាស្រ្តបង្រៀនពលរដ្ឋវិជ្ជា សម្រាប់ថ្នាក់ទី១០ និងទី១១» ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀន និងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ [illegible] ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៨

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ
- ឯកសារ នា.អកស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# បុព្វកថា

បច្ចុប្បន្ន សង្គម និងសេដ្ឋកិច្ចមានការអភិវឌ្ឍដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំដើម្បីឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់ពិភពលោក។ នៅដើមសតវត្សរ៍ទី២១នេះ សង្គម និងសេដ្ឋកិច្ចឈានដល់បរិបទថ្មីមួយ ដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកបើកចំហឱ្យមានការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន។ ទោះបីជាការអប់រំជំរុញឱ្យមានការរីកចម្រើនលើវិស័យសេដ្ឋកិច្ច និងវិទ្យាសាស្ត្រក៏ដោយ ក៏គេមិនអាចមើលរំលងការអប់រំភាពជាពលរដ្ឋបានដែរ។

ការអប់រំ " ពលរដ្ឋវិជ្ជា " គឺការអប់រំសិស្សឱ្យស្គាល់ពីតម្លៃមនុស្ស តម្លៃសង្គម-វប្បធម៌ មានការទទួលខុសត្រូវលើសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន មានចំណេះដឹងផ្នែកសិទ្ធិមនុស្ស ចេះគោរពច្បាប់របស់ប្រទេស ដើម្បីចូលរួមជួយថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់ និងអភិវឌ្ឍសង្គមដោយវៀរចាកអំពើអវិជ្ជមានដែលសង្គមស្អប់ខ្ពើម។ ជាពិសេសនោះព្រមទាំងបានចូលរួមកសាងវប្បធម៌សន្តិភាពសម្រាប់មនុស្សជាតិទាំងអស់ និងអប់រំសិស្សឱ្យក្លាយជាពលរដ្ឋល្អក្នុងនាមជាអ្នកកសាង និងអភិវឌ្ឍសង្គមឱ្យមានភាពជឿនលឿនក្នុងបែបបទប្រជាធិបតេយ្យ។ ចំពោះលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជានេះ ក៏ត្រូវដើរតួនាទីជាជនគំរូដោយមានការគោរព អនុវត្តច្បាប់ គោរពឱ្យតម្លៃដល់អ្នកដទៃ ចេះអត់ធ្មត់ និងដោះស្រាយបញ្ហាដោយសន្តិវិធី។ល។

មធ្យោបាយដើម្បីសម្រេចបានគោលបំណងនៃការអប់រំពលរដ្ឋវិជ្ជា គឺការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។ គោលវិធីនេះ មិនត្រឹមតែឱ្យសិស្សធ្វើសកម្មភាពរៀនយ៉ាងសកម្ម និងសប្បាយដើម្បីស្វែងរកចំណេះដឹង បំណិន តម្លៃដោយខ្លួនឯងផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យសិស្សចេះទទួលខុសត្រូវលើអ្វីដែលខ្លួនបានធ្វើ ចេះរស់នៅជាមួយគ្នា សហការជួយគ្នា បង្កើនសាមគ្គីភាព និងមានស្មារតីស្មោះត្រង់ទៀតផង។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់វិធីសាស្ត្របង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌលចាប់តាំងពីឆ្នាំ១៩៩៧ ដោយបានជ្រើសរើសវិធីបង្រៀនល្អៗ មកដាក់បញ្ចូលនៅក្នុងឯកសារសម្រាប់បំប៉នសមត្ថភាពគ្រូ ក្នុងការប្រើប្រាស់កម្មវិធី និងសៀវភៅសិក្សានៅគ្រប់កម្រិតថ្នាក់។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយមូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរដើម្បីរៀបចំចងក្រងឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជាសម្រាប់គ្រូថ្នាក់ទី១០ និងថ្នាក់ទី១១ ដោយផ្តោតជាសំខាន់ទៅលើសារសំខាន់នៃការអប់រំសិស្សអំពីចំណេះដឹងភាពជាពលរដ្ឋ វិធីសាស្ត្របង្រៀន និងសកម្មភាពបង្រៀន។ ឯកសារជំនួយវិធីសាស្ត្របង្រៀននេះ គឺជាឯកសារជំនួយបន្ថែមទៅលើសមត្ថភាព បច្ចេកទេស និងវិធីបង្រៀនដែលលោកគ្រូ អ្នកគ្រូមានស្រាប់រួចមកហើយ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណចំពោះមូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer) មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា គណៈកម្មការបច្ចេកទេសទាំងភាគីជាតិ ទាំងភាគីអន្តរជាតិដែលបានជួយឧបត្ថម្ភ និងបានយកចិត្តទុកដាក់ស្រាវជ្រាវ ចងក្រងឯកសារនេះឡើង សម្រាប់ជាគុណប្រយោជន៍ដ៏ធំធេងដល់ការរួមចំណែកកំណែទម្រង់វិស័យអប់រំ និងការអប់រំសិស្សានុសិស្សឱ្យក្លាយជាពលរដ្ឋល្អរបស់សង្គមជាតិ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# សេចក្តីថ្លែងអំណរគុណ


មុខវិជ្ជាពលរដ្ឋវិជ្ជា គឺជាមុខវិជ្ជាដ៏សំខាន់មួយសម្រាប់ការកសាងអភិវឌ្ឍធនធានមនុស្សឱ្យយល់អំពីភាពជាពលរដ្ឋល្អ គោលការណ៍លទ្ធិប្រជាធិបតេយ្យ ការត្រិះរិះពិចារណា និងការសម្រេចចិត្តជាដើមដែលចំណុចទាំងអស់នេះ មានភាពចាំបាច់សម្រាប់ការកសាងសង្គមទំនើបមួយ។

ក្នុងនាមមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ នៃប្រទេសអាល្លឺម៉ង់ ប្រចាំប្រទេសកម្ពុជានិងអង្គការដៃគូសហការ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ព្រមទាំងអ្នកជំនាញ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡាដែលបានផ្តល់កិច្ចសហការយ៉ាងល្អក្នុងការពង្រឹងការងារចងក្រងឯកសារនេះឡើង ដើម្បីចូលរួមលើកកម្ពស់ការអប់រំភាពជាពលរដ្ឋល្អនៅតាមគ្រឹះស្ថានមធ្យមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពគ្រូបង្រៀនក្នុងការបង្រៀនមុខវិជ្ជាពលរដ្ឋវិជ្ជានៅកម្រិតមធ្យមសិក្សា។ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡាបានបង្កលក្ខណៈឱ្យយើងខ្ញុំមានឱកាសចូលរួមជួយអភិវឌ្ឍធនធានមនុស្សតាមរយៈការអភិវឌ្ឍឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជាសម្រាប់ផ្តល់ជូនលោកគ្រូ អ្នកគ្រូបង្រៀននៅថ្នាក់ទី១០និងទី១១។ក្នុងនោះដែរក្រសួងអប់រំ យុវជននិងកីឡាបានផ្តល់អ្នកជំនាញមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាមកពីនាយកដ្ឋានជំនាញដើម្បីជួយពិនិត្យ កែលម្អ ផ្តល់យោបល់លើខ្លឹមសារ ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លាប្រយោគ រូបភាពទម្រង់ឱ្យសមស្របទៅតាមកម្មវិធីសិក្សាថ្មីនិងកំណែទម្រង់វិស័យអប់រំ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាសភាពសមាជិកគណៈកម្មការដឹកនាំគម្រោង ក្រុមការងារសម្របសម្រួលថ្នាក់ខេត្ត ក្រុមការងារអនុវត្តគម្រោង និងអង្គការដៃគូសហការក្នុងកិច្ចដំណើរការសម្ភាសដើម្បីប្រមូលព័ត៌មាន និងបទពិសោធន៍ជាក់ស្តែងរបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សក្នុងការបង្រៀន និងរៀនពលរដ្ឋវិជ្ជាដើម្បីតាក់តែងជាឯកសារមួយនេះឡើង។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងផ្តល់ជាអត្ថប្រយោជន៍ដល់លោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា។ លោកគ្រូ អ្នកគ្រូអាចយកទៅប្រើប្រាស់ជាឯកសារជំនួយដោយជ្រើសរើសយកវិធីសាស្ត្រដែលសមស្របយកទៅបង្រៀនឱ្យបានកាន់តែប្រសើរឡើង។

**មូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ**

បណ្ឌិត **Daniel Schmücking**

ប្រធានប្រចាំប្រទេសកម្ពុជា

មូលនិធិខុនរ៉ាដអាដិណៅអ៊ែរ

# អារម្ភកថា

ឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជាដែលនៅក្នុងដៃលោកគ្រូ អ្នកគ្រូ លោក លោកស្រី និងអ្នកអប់រំកំពុងអាននេះ បានកើតឡើងពីការរៀបរៀងចងក្រង កែសម្រួលដោយមានការច្របាច់បញ្ចូលគ្នារវាងវិធីបង្រៀនមុខវិជ្ជាពលរដ្ឋវិជ្ជារបស់ប្រទេសផ្សេងៗនិងវិធីបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តរួចមកហើយ។

ដោយសារមើលឃើញពីកង្វះខាតវិធីសាស្ត្របង្រៀនមុខវិជ្ជាពលរដ្ឋវិជ្ជាដែលពុំទាន់មានភាពសកម្មក្នុងការបង្រៀនសិស្ស ទើបគណៈកម្មការនិពន្ធដែលមានសមាសភាពមកពីមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ និងមន្ត្រីជំនាញមកពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ បានតាក់តែងសេចក្តីព្រាងឯកសារវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជានេះឡើងតាំងពីឆ្នាំ២០១៦ និងពុំទាន់បានទទួលការអនុម័តពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដើម្បីយកទៅផ្សព្វផ្សាយនៅតាមសាលារៀន ទើបមកដល់ពាក់កណ្តាលឆ្នាំ២០១៨នេះ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ បានសហការជាមួយមន្ត្រីជំនាញមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជានៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដើម្បីជួយពិនិត្យ កែលម្អឯកសារវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជានេះ ធ្វើយ៉ាងណាឱ្យកាន់តែមានភាពល្អប្រសើរ។ ឯកសារនេះ ក៏ត្រូវបានចូលរួមជួយពិនិត្យ ផ្តល់យោបល់ពីមន្ត្រីអប់រំមកពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានធានាគុណភាពអប់រំ គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកគ្រូ អ្នកគ្រូដែលជាប្រធានក្រុមបច្ចេកទេសបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា។

ឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជាថ្នាក់ទី១០និងថ្នាក់ទី១១នេះ ត្រូវបានរៀបរៀងឡើងសម្រាប់ប្រើប្រាស់ជាជំនួយដល់លោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ឯកសារនេះ មានរៀបរាប់អំពីបញ្ញត្តិពលរដ្ឋវិជ្ជា គោលវិធីសិស្សមជ្ឈមណ្ឌល វិធីបង្រៀនជាច្រើនសម្រាប់ជួយដល់លោកគ្រូ អ្នកគ្រូក្នុងការត្រៀមសកម្មភាពបង្រៀននិងរៀន មានគំនិតច្នៃប្រឌិតរៀបចំសកម្មភាពបង្រៀនរបស់ខ្លួនឱ្យទទួលបានជោគជ័យ ។ វិធីបង្រៀនទាំងនេះ ជួយជំរុញលើកទឹកចិត្តសិស្សឱ្យមានសេចក្តីក្លាហាន ហើយក៏ជួយរៀបចំអត្តចរិតសិស្សឱ្យធ្វើអ្វីមួយដោយចៀសវាងកំហុសឆ្គងដែលអាចកើតមានឡើងជាយថាហេតុ។

ទោះបីការរៀបរៀង ចងក្រង ពិនិត្យកែសម្រួលដោយមានការយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏យើងខ្ញុំជឿជាក់ថា ឯកសារនេះប្រាកដជានៅមានចំណុចខ្វះខាតដោយអចេតនាជា មិនខាន។

យើងខ្ញុំសូមរង់ចាំការចូលរួមមតិកែលម្អ ស្ថាបនា ពីសំណាក់លោកគ្រូ អ្នកគ្រូ អស់លោក លោកស្រី អ្នកអប់រំ និងអ្នកស្រាវជ្រាវទាំងអស់ដោយក្តីសោមនស្សជានិច្ច។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

២. ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

៣. លោកស្រីបណ្ឌិត **ឃួន ទិត្ថិភា**

## គណៈកម្មការនិពន្ធ

១. លោកបណ្ឌិត គួន វ៉ាន់ស៊ី

២. លោក ប៉ុង ភក្តីបូរ៉ាមី

## គណៈកម្មការរៀបរៀង

១. លោកបណ្ឌិត ហេង មណីចិន្តា

២. កញ្ញា ប៊ិន រស្មីកណិកា

៣. មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

៤. អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

## គណៈកម្មការពិនិត្យ

១. លោក មាស ជុតិមា

២. លោក ង៉ែត ធឿន

## គណៈកម្មការផ្តល់យោបល់

១. កញ្ញា. ជិត ចាន់វន្នី អគ្គនាយកដ្ឋានអប់រំ

២. លោក. ម៉ៅ វាសនា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ

៣. លោក.មួង សុផាត នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៤. លោក.សាយ ប៉ូលីដា នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៥. លោក. សាម សារុំ នាយកដ្ឋានធានាគុណភាពអប់រំ

៦. លោក. ឡុច ចាន់ថន វិទ្យាស្ថានជាតិអប់រំ

៧. ប្រធានក្រុមបច្ចេកទេស បង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១. ក្រសួងអប់រំ យុវជន និង កីឡា

២. មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

# មាតិកា


ប្រកាស....ii
បុព្វកថា....iii
សេចក្តីថ្លែងអំណរគុណ....iv
អារម្ភកថា....v
គណៈកម្មការ....vi
មាតិកា....vii
**១. ការអប់រំពលរដ្ឋវិជ្ជា**....១
១.១ តើអ្វីជាពលរដ្ឋវិជ្ជា? ....២
១.២ លទ្ធផលនៃការសិក្សាពលរដ្ឋវិជ្ជា ....២
១.៣ បទពិសោធន៍នៃការបង្រៀនពលរដ្ឋវិជ្ជានៅប្រទេសអភិវឌ្ឍ....៣
១.៤ ហេតុអ្វីសិស្សត្រូវសិក្សាពលរដ្ឋវិជ្ជា ?....៥
១.៥ គោលបំណងនៃការកសាងឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា....៧
១.៦ ក្របខ័ណ្ឌ ក ខ គ (ABC) ....៩
១.៧ រចនាសម្ព័ន្ធឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា....១០
១.៨ ការណែនាំប្រើប្រាស់ឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា....១១
**២. វិធីសាស្ត្របង្រៀន**....១២
២.១ ការសិក្សារបស់យុវជន ....១៣
២.២ ការគ្រប់គ្រងថ្នាក់រៀន....១៣
២.៣ កិច្ចតែងការបង្រៀន....២២
២.៤ ការវាយតម្លៃការបង្រៀននិងការរៀន....២៦
២.៥ វិធីបង្រៀន....៣៧
១.វិធីបង្រៀន ៣-២-១ ....៣៧
២.វិធីបង្រៀន ឱ្យមួយបានមួយ (Give one Get one) ....៣៨
៣.វិធីបង្រៀន ខ្ញុំស្រាវជ្រាវ (I Search) ....៤០
៤.វិធីបង្រៀន ជីក ស (Jigsaw) ....៤២
៥.វិធីបង្រៀន ខ្ញុំដឹងអ្វី /ខ្ញុំចង់ដឹងអ្វី /ខ្ញុំបានរៀនអ្វី(KWL)....៤៤
៦.វិធីបង្រៀន បន្ទាត់តម្លៃ(Value Line) ....៤៦
៧.វិធីបង្រៀន អត្ថបទចំពោះអត្ថបទ អត្ថបទចំពោះខ្លួន អត្ថបទចំពោះពិភពលោក.៤៨

៨.វិធីបង្រៀន ការវិភាគបញ្ហា ( COPE)....៥០
៩.វិធីបង្រៀន ការអានជាដៃគូ/ការសង្ខេបជាដៃគូ....៥២
១០.វិធីបង្រៀន ការអានផ្ទាល់(Directed Reading Activity DRA) ....៥៣
១១.វិធីបង្រៀន ការពិភាក្សាជាសំបុកពីងពាង/ បណ្ដាញពិភាក្សា....៥៥
១២.វិធីបង្រៀន ការរួមគ្នាគិតជាដៃគូ(Think Pair Share) ....៥៧
១៣.វិធីបង្រៀន ដើមឈើបញ្ហា (Problem Tree) ....៥៨
១៤. វិធីបង្រៀន ការកត់ត្រាពាក្យគន្លឹះនិងខ្លឹមសារសំខាន់ៗ(Frayer )....៦០
១៥.វិធីបង្រៀន ការធ្វើប័ណ្ណស្រង់ព័ត៌មាន....៦២
១៦.វិធីបង្រៀន ការការពារគំនិត(Debate) ....៦៤
១៧.វិធីបង្រៀន ការបង្កើតសំណួរចម្លើយ(Jeopardy) ....៦៦
**៣. វិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា ថ្នាក់ទី១០ ទី១១**....៦៩
សិទ្ធិនិងករណីយកិច្ច....៧០
ការសម្ដែងមតិ....៧៤
កិច្ចការពារសិទ្ធិរបស់ខ្លួន....៧៩
សេរីភាព....៨៥
ឯករាជភាព....៩៤
តម្លាភាព....៩៩
លទ្ធិប្រជាធិបតេយ្យ....១០៥
សិទ្ធិពលរដ្ឋ....១១៦
សិទ្ធិនិងការទទួលខុសត្រូវ....១២២
ច្បាប់ការងារ....១២៨
ច្បាប់ភូមិបាល....១៤១
រដ្ឋបាលសាធារណៈ....១៥៥
គណបក្សនយោបាយនិងតួនាទី....១៦២
ការឈរឈ្មោះនិងការបោះឆ្នោត....១៦៩
រឿងមហាឫសីប្រស់ខ្លា....១៧៦
**៤.សេចក្ដីសន្និដ្ឋាន**....១៧៨
៥. ពាក្យគន្លឹះ....១៨១
ឯកសារយោង....១៨៥

# ១.ការអប់រំពលរដ្ឋវិជ្ជា



## ១.១ តើអ្វីជាពលរដ្ឋវិជ្ជា?

ពលរដ្ឋវិជ្ជាត្រូវបានគេឱ្យនិយមន័យខុសៗគ្នា ដូចជាការអប់រំប្រជាធិបតេយ្យ (Democracy Education)ការអប់រំពលរដ្ឋសកម្ម (Active Citizen) ការអប់រំឱ្យមានការចូលរួមពីប្រជាពលរដ្ឋ(Civic Engagement)។ល។ ប៉ុន្តែន័យរួមពលរដ្ឋវិជ្ជាគឺសំដៅទៅលើការផ្តល់ព័ត៌មាននិងការអប់រំប្រជាពលរដ្ឋ ដើម្បីជួយពង្រឹង និងលើកកម្ពស់សមត្ថភាពពួកគេឱ្យចូលរួមនៅក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ[1]។ និយាយជារួម គោលដៅធំៗក្នុងការអប់រំពលរដ្ឋវិជ្ជា គឺជួយប្រជាជនឱ្យយល់ដឹងអំពីក្បួនច្បាប់ ប្រព័ន្ធនយោបាយបែបប្រជាធិបតេយ្យ ពីសិទ្ធិនិងការអនុវត្តសិទ្ធិតាមបែបប្រជាធិបតេយ្យ ជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យនយោបាយ គាំទ្រអភិបាលកិច្ចល្អក្នុងស្មារតីប្រជាធិបតេយ្យ បណ្តុះតម្លៃក្នុងការគោរពច្បាប់ ការរាប់អាន ការជឿទុកចិត្តគ្នា ការអត់ធ្មត់ និងការដោះស្រាយបញ្ហាដោយសន្តិវិធីជាដើម [2] ។

## ១.២ លទ្ធផលនៃការសិក្សាពលរដ្ឋវិជ្ជា

លទ្ធផលរំពឹងទុកនៃការសិក្សាមុខពលរដ្ឋវិជ្ជាមានបីសំខាន់ៗគឺ ចំណេះដឹងទាក់ទងនឹងពលរដ្ឋ បំណិនទាក់ទងនឹងពលរដ្ឋ និងតម្លៃទាក់ទងនឹងពលរដ្ឋ។ចំណេះដឹងទាក់ទងនឹងពលរដ្ឋសំដៅលើការយល់ដឹងនិងសមត្ថភាពក្នុងការវិភាគ ការវាយតម្លៃរបស់ពលរដ្ឋទៅលើប្រព័ន្ធនយោបាយ សិទ្ធិនិងកាតព្វកិច្ចរបស់ពលរដ្ឋ (សិទ្ធិបញ្ចេញមតិ សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត កាតព្វកិច្ចក្នុងការគោរពច្បាប់ សិទ្ធិនិងផលប្រយោជន៍អ្នកដទៃ)ជាដើម។ បំណិនទាក់ទងនឹងពលរដ្ឋ សំដៅលើសមត្ថភាពក្នុងការប្រើចំណេះដឹងដើម្បីចូលរួម និងបំពេញតួនាទីជាពលរដ្ឋល្អនៅក្នុងសង្គមប្រជាធិបតេយ្យ។ ចំណែកតម្លៃទាក់ទងនឹងពលរដ្ឋសំដៅលើអត្តចរិតដែលទាមទារឱ្យមាននៅក្នុងរបបប្រជាធិបតេយ្យ ដូចជាការអត់ធ្មត់ ការតម្កល់តម្លៃសាធារណៈជាធំ ការប្រកាន់យកការរស់នៅប្រកបដោយសុជីវធម៌និងសីលធម៌ ការឱ្យតម្លៃលើការចេះពិចារណារកហេតុផលត្រឹមត្រូវ ការចេះស្តាប់ ការចរចាសម្របសម្រួលជាដើម។

នៅក្នុងការសិក្សា[3]គេបានរកឃើញថា ការបណ្តុះបណ្តាលពលរដ្ឋវិជ្ជាគឺត្រូវផ្តោតជាសំខាន់ទៅលើបទពិសោធន៍ផងដែរ។ បទពិសោធន៍នៅទីនេះសំដៅដល់សកម្មភាព

[1] (Jennifer Rietbergen-McCracken)

[2] (Office of Democracy and Governance, 2002)

[3] Leila et al., (no date)

ចូលរួមផ្តល់សេវាកម្មសហគមន៍ ការបង្កើតទំនាក់ទំនងល្អជាមួយបណ្តាញនានា ការរៀបគម្រោងផែនការ ការរៀបចំប្រជុំពិភាក្សាគ្នារិះរកមធ្យោបាយដោះស្រាយ ឬកែតម្រូវបញ្ហា និងបទពិសោធន៍ក្នុងរដ្ឋបាលសាធារណៈជាដើម។

## ១.៣ បទពិសោធន៍នៃការបង្រៀនពលរដ្ឋវិជ្ជានៅប្រទេសអភិវឌ្ឍ

លទ្ធិប្រជាធិបតេយ្យមិនអាចមានត្រឹមតែប្រព័ន្ធប្រជាធិបតេយ្យទេ។ លទ្ធិប្រជាធិបតេយ្យក៏ត្រូវការអ្នកប្រជាធិបតេយ្យផងដែរ ។ ប៉ុន្តែអ្នកប្រជាធិបតេយ្យមិនមែនកើតឡើងដោយឯកឯងនោះទេ ដូច្នេះហើយទើបមុខវិជ្ជាពលរដ្ឋវិជ្ជាត្រូវបានគេយកទៅបង្រៀនយ៉ាងទូលំទូលាយដើម្បីបណ្តុះឱ្យមានអ្នកប្រជាធិបតេយ្យ។ នៅក្នុងសហគមន៍អឺរ៉ុប ការបង្រៀនទាមទារឱ្យបង្កើតបរិយាកាសរៀនសូត្រដែលបង្កលក្ខណៈឱ្យសិស្សអាចរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ គ្រូត្រូវធ្វើយ៉ាងណារកមើលវិធីសាស្ត្របង្រៀន និងរៀនដែលអនុញ្ញាតឱ្យសិស្សប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួន មិនថានៅក្រៅថ្នាក់ ឬនៅក្នុងថ្នាក់ព្រោះសិស្សមិនមែនរៀនត្រឹមតែសិទ្ធិចូលរួមប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវប្រើសិទ្ធិក្នុងទិដ្ឋភាពជាក់ស្តែងផងដែរ។ សិស្សត្រូវអនុញ្ញាតឱ្យចូលរួមក្នុងការរៀបចំ និងសម្រេចចិត្តលើកិច្ចការខ្លះៗនៅក្នុងសាលារៀនដែលអាចជួយសិស្សឱ្យយល់ដឹង និងឱ្យតម្លៃលើសិទ្ធិសេរីភាព និងទំនួលខុសត្រូវរបស់ខ្លួន។ នៅក្នុងការអប់រំមុខវិជ្ជានេះ គ្រូត្រូវដើរតួជាជនគំរូដែលគោរពនិងឱ្យតម្លៃលើអ្នកដទៃ ចេះអត់ធ្មត់ និងដោះស្រាយបញ្ហាដោយសន្តិវិធី។ ដូចគ្នានេះដែរ នៅក្នុងប្រទេសអាមេរិក មុខវិជ្ជានេះត្រូវបានគេចាត់ទុកជាមុខវិជ្ជាស្នូលក្នុងការជួយជំរុញយុវជនឱ្យយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចក្នុងការថែរក្សាលទ្ធិប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ប្រទេសជាតិរបស់ពួកគេផងដែរ។នៅឆ្នាំ២០១៤ **ហ្គីលហ្វ៊ល** និង **ដេលេនឌើ** (Guilfoile and Delander) បានធ្វើការសិក្សាស្រាវជ្រាវពីបទពិសោធន៍ក្នុងការបង្រៀនពលរដ្ឋវិជ្ជាដល់សិស្ស។ពួកគាត់បានរកឃើញបទពិសោធន៍ល្អៗក្នុងការបង្រៀនចំនួន៦៖

១. បង្រៀនត្រូវតែជាប់ពាក់ព័ន្ធគ្នានិងជាទីចំណាប់អារម្មណ៍របស់សិស្ស

២.យកព្រឹត្តិការណ៍ឬបញ្ហាសំខាន់ថ្មីៗដែលកើតមាននៅក្នុងសហគមន៍ នៅក្នុងប្រទេស ឬអន្តរជាតិឱ្យសិស្សសិក្សាស្រាវជ្រាវ ពិភាក្សាយ៉ាងសកម្មនិងធ្វើបទបង្ហាញ ជាពិសេសគឺព្រឹត្តិការណ៍ឬបញ្ហាដែលមានសារៈសំខាន់ ឬផ្សារភ្ជាប់នឹងជីវភាពរស់នៅ

៣.អនុញ្ញាតឱ្យសិស្សអាចយកអ្វីដែលពួកគេបានរៀននៅក្នុងថ្នាក់ ទៅអនុវត្តជាក់ស្តែងនៅក្នុងការផ្តល់សេវាកម្ម និងការអភិវឌ្ឍសហគមន៍។ ឧទាហរណ៍

ការចុះធ្វើគម្រោងសម្អាតបរិស្ថាន ការបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សា និងការរៀបចំបង្ការគ្រោះមហន្តរាយជាដើម

៤.ផ្តល់ឱកាសឱ្យសិស្សបានចូលរួមក្នុងសកម្មភាពក្រៅថ្នាក់ដូចជាការចុះធ្វើកម្មសិក្សា

៥.ផ្តល់ឱកាសនិងជំរុញសិស្សឱ្យចូលរួមក្នុងសកម្មភាពនិងការសម្រេចចិត្តខ្លះៗទាក់ទងនឹងការរៀនសូត្រ ឬសាលារៀនតាមរយៈការចុះឈ្មោះធ្វើជាអ្នកតំណាងសិស្ស ក្រុមប្រឹក្សាសិស្ស និងគណៈកម្មការផ្សេងៗទៀតដែលសាលារៀនបានបង្កើត

៦.ជំរុញសិស្សឱ្យចូលរួមសកម្មភាពគ្រាប់តាមដំណើរការ ឬការសម្តែងតួ និងវិធីនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដូចជាការបោះឆ្នោត ការពិភាក្សា ការវិភាគ ការធ្វើបទបង្ហាញ និងការការពារសំណើរបស់ខ្លួនជាដើម។

នៅក្នុងប្រទេសអូស្ត្រាលី សិស្សដែលនឹងក្លាយទៅជាពលរដ្ឋត្រូវបានគេបង្ហាត់បង្រៀនឱ្យយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនតាមរយៈមុខវិជ្ជាពលរដ្ឋវិជ្ជានេះដែរ ។ សិស្សទាំងអស់មិនត្រឹមតែមានតួនាទីសំខាន់នៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានតួនាទីនៅក្នុងសាលារៀន និងនៅក្នុងសហគមន៍ថែមទៀតផង ។ នៅក្នុងសាលារៀន សិស្សត្រូវបានចាត់ទុកជាតួអង្គដ៏សំខាន់ក្នុងការរៀន និងការបង្រៀនបានជោគជ័យ។ ដូច្នេះហើយថ្នាក់រៀនត្រូវបានដំណើរការជាលក្ខណៈប្រជាធិបតេយ្យ។សិស្សត្រូវបានផ្តល់សិទ្ធិយ៉ាងសំខាន់ក្នុងការជួយរៀបចំថ្នាក់រៀន និងបរិយាកាសរៀនសូត្រ។ នៅក្នុងថ្នាក់រៀនបែបប្រជាធិបតេយ្យ គ្រូលែងសួរខ្លួនឯងថា តើចង់បង្រៀនអ្វីឱ្យសិស្សចេះនៅក្នុងមុខវិជ្ជានោះទៀតហើយប៉ុន្តែគ្រូគួរបង្រៀនអ្វីដែលសិស្សចង់ចេះនៅក្នុងមុខវិជ្ជានោះវិញ។ ដើម្បីធ្វើដូច្នេះបាន គ្រូត្រូវធ្វើការសង្កេតនិងរកមើលចំណេះដឹង បទពិសោធន៍ដែលសិស្សមាននិងតម្រូវការផ្សេងៗដែលពួកគេចង់បាន រួចកែតម្រូវវត្ថុបំណង និងវិធីសាស្ត្របង្រៀនទៅតាមតម្រូវការនោះ។ នៅក្នុងសាលារៀន សិស្សត្រូវបានលើកទឹកចិត្តឱ្យចូលរួមធ្វើសកម្មភាពនិងកាន់តួនាទីជាថ្នាក់ដឹកនាំនៅក្នុងគណៈកម្មការឬក្រុមប្រឹក្សានានាដែលអាចមានសិទ្ធិសម្រេចចិត្ត ដើម្បីជាប្រយោជន៍ដល់សិស្សទាំងអស់ក្នុងសាលារៀនផង។ចំពោះការងារសហគមន៍ ក៏មានការជំរុញឱ្យបង្កើតទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតរវាងសាលារៀននិងសហគមន៍ដែលអាចផ្តល់ជាប្រយោជន៍ឱ្យសិស្សអាចយកចំណេះដឹង បំណិនទាក់ទងនឹងពលរដ្ឋវិជ្ជា ទៅប្រើប្រាស់ដើម្បីចូលរួមអភិវឌ្ឍសហគមន៍។

សង្ខេបជារួម សាលារៀនជាច្រើននៅប្រទេសអូស្រ្តាលី ទាមទារឱ្យបញ្ចូលចំណុចសំខាន់៥យ៉ាងដើម្បីបង្រៀនពលរដ្ឋវិជ្ជាប្រកបដោយប្រសិទ្ធភាពដូចជា ៖

១.បង្កើតសកម្មភាពបង្រៀននិងរៀនដែលជួយសិស្សឱ្យទទួលបានចំណេះដឹងថ្មីទៅតាមលទ្ធផលរំពឹងទុក

២.ជំរុញសិស្សឱ្យចែករំលែកបទពិសោធន៍ ចំណេះដឹងដែលខ្លួនមានពីមុនមកជាមួយនឹងសិស្សដទៃ និងអាចជួយសិស្សឱ្យមានចំណាប់អារម្មណ៍ចង់ដឹងចង់យល់ថាតើចំណេះដឹង និងបទពិសោធន៍ទាំងនោះត្រឹមត្រូវឬមិនត្រឹមត្រូវគួររក្សាទុក ធ្វើសំយោគ ឬបោះបង់ចោល

៣.លើកទឹកចិត្តសិស្សឱ្យធ្វើការងារជាក្រុមតាមរយៈការធ្វើគម្រោងឬសកម្មភាពអ្វីមួយ

៤.ជួយសិស្សឱ្យចេះត្រិះរិះពិចារណាអំពីអ្វីដែលពួកគេបានរៀនកន្លងមក តើអាចយកទៅអនុវត្តជាក់ស្តែងបានដែរឬទេ? តើមានវិធីសាស្ត្រណាល្អក្នុងការអនុវត្តអ្វីដែលបានរៀនរួចមកហើយ?តើមានកត្តាប្រឈមអ្វីខ្លះ? តើមានតម្លៃអ្វីក្នុងការអនុវត្តឬប្រកាន់យកដែរឬទេ?

៥.ជំរុញសិស្សឱ្យចុះអនុវត្តដោយផ្ទាល់នូវចំណេះដឹង បំណិនដែលពួកគេបានរៀនសូត្រតាមរយៈការបង្កើតគម្រោងឬសកម្មភាពណាមួយ។

## **១.៤ ហេតុអ្វីសិស្សត្រូវសិក្សាពលរដ្ឋវិជ្ជា**?

ពលរដ្ឋវិជ្ជាដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំសិស្សឱ្យយល់ដឹងអំពីសិទ្ធិ តួនាទីកាតព្វកិច្ចជាពលរដ្ឋ និងច្បាប់សង្គម។ការយល់ដឹងខ្លឹមសារទាំងនេះ ទើបធ្វើឱ្យសិស្សម្នាក់ៗគោរពសិទ្ធិ សេរីភាព ច្បាប់ មានទំនួលខុសត្រូវ និងកាតព្វកិច្ចក្នុងការចូលរួមកសាងអភិវឌ្ឍខ្លួន គ្រួសារ សហគមន៍ សង្គមជាតិនិងពិភពលោកនៅក្នុងក្របខ័ណ្ឌលទ្ធិប្រជាធិបតេយ្យ។

ពលរដ្ឋវិជ្ជា ត្រូវបានដាក់ឱ្យសិស្សសិក្សាយ៉ាងទូលំទូលាយនៅក្នុង សាលារៀននានា ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ ទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាសហរដ្ឋអាមេរិក អឺរ៉ុប អូស្រ្តាលី អាហ្វ្រិកជាដើម។ ការដាក់ពលរដ្ឋវិជ្ជាទៅក្នុងសាលារៀនចំណេះទូទៅ គឺដោយសារវាមានសារៈសំខាន់ដែលទាមទារឱ្យសិស្សត្រូវយល់ដឹងដើម្បីក្លាយជាពលរដ្ឋល្អ ជួយកសាងជាតិ ជួយឱ្យប្រជាជនយល់ដឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ មុពលរដ្ឋវិជ្ជាមានបញ្ចូលប្រធានបទដូចជា សិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញ

ច្បាប់ផ្សេងៗ និងកាតព្វកិច្ចរបស់ពលរដ្ឋម្នាក់ៗក្នុងការចូលរួមចំណែកជួយអភិវឌ្ឍសហគមន៍។

ដោយឡែកនៅក្នុងប្រទេសកម្ពុជា មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាមានតួនាទីយ៉ាងសំខាន់ ដោយសារប្រទេសយើង ទើបបានទទួលសុខសន្តិភាពពេញលេញ ក្នុងអំឡុងតែប៉ុន្មានឆ្នាំចុងក្រោយនេះទេ។ ប្រទេសកម្ពុជាបានរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារភ្លើងសង្គ្រាមដែលបានរុញច្រានប្រទេសឱ្យធ្លាក់ចូលទៅក្នុងរបបប្រល័យពូជសាសន៍ មិនត្រឹមតែហេដ្ឋារចនាសម្ព័ន្ធទេដែលត្រូវបំផ្លិចបំផ្លាញ សូម្បីតែមនុស្សដែលជាធនធានដ៏សំខាន់ក៏ពួកវាបានកាប់សម្លាប់អស់ជិត២លាននាក់ផងដែរ។ ការងើបឡើងពីការបំផ្លិចបំផ្លាញស្ទើរគ្រប់វិស័យនេះ ធ្វើឱ្យប្រទេសកម្ពុជាជួបផលលំបាកជាច្រើន ជាពិសេសគឺការកសាងនីតិរដ្ឋ ការគោរពសិទ្ធិសេរីភាព និងការបំពេញកាតព្វកិច្ចជាពលរដ្ឋក្នុងការជួយកសាងជាតិ។ ទោះបីប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញ និងច្បាប់ល្អៗជាច្រើនក៏ដោយ ក៏គេនៅឃើញមានការរំលោភបំពានច្បាប់គួរឱ្យព្រួយបារម្ភ។ ការរំលោភច្បាប់ទាំងនោះរួមមានការបើកបរល្មើសច្បាប់ចរាចរណ៍ដែលនាំឱ្យមានមនុស្សស្លាប់ច្រើនជាងអ្នកស្លាប់ដោយសារជំងឺអេដស៍ ការធ្វើចំណាកស្រុកខុសច្បាប់ ការកេងប្រវ័ញ្ចន៍កម្លាំងពលកម្មនិងការជួញដូរពលកម្មកុមារ ការរំលោភបំពានផ្លូវភេទ ការទន្ទ្រានកាន់កាប់ដីសាធារណៈ និងការកាប់បំផ្លាញព្រៃឈើជាដើម។ ម្យ៉ាងវិញទៀត នៅក្នុងពេលដែលរាជរដ្ឋាភិបាលព្យាយាមជំរុញឱ្យប្រទេសកម្ពុជា មានដំណើរការប្រកបដោយលទ្ធិប្រជាធិបតេយ្យក៏នៅមានប្រជាជនខ្លះ ពុំទាន់បានយល់ដឹងពីសិទ្ធិសេរីភាព អំពីការចូលរួមចំណែករបស់ខ្លួនក្នុងការអភិវឌ្ឍសង្គមដែរ។ តាមការសិក្សាស្រាវជ្រាវមួយរបស់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ BBC Media Action Research (ឆ្នាំ២០១៤)បានឱ្យដឹងថា អ្នកចូលរួមសម្ភាសមិនដល់៥០ភាគរយផងបានឆ្លើយថាពួកគេមិនយល់ពីអត្ថន័យរដ្ឋសភា ក្រុមប្រឹក្សាឃុំ និងលទ្ធិប្រជាធិបតេយ្យឱ្យបានច្បាស់លាស់នៅឡើយទេ។ ចំណែកឯប្រជាជនមួយចំនួនទៀតនៅមិនទាន់បានបំពេញកាតព្វកិច្ចក្នុងការចុះឈ្មោះបោះឆ្នោតនៅឡើយ។ ប្រជាជនមួយចំនួនទៀតមិនត្រឹមតែយល់ថានយោបាយជារឿងអាក្រក់ដែលខ្លួនមិនចង់ពាក់ព័ន្ធប៉ុណ្ណោះទេ តែថែមទាំងហាមឃាត់ក្រុមគ្រួសារមិនឱ្យចូលរួមទៀតផង។

ដូច្នេះហើយ មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមជួយរាជរដ្ឋាភិបាលជំរុញឱ្យប្រទេសកម្ពុជាទទួលបានលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋមួយដ៏ពេញលេញ ព្រោះទាល់តែមានការចូលរួមពីប្រជាពលរដ្ឋ ទើបចាត់ទុកថាជាការអនុវត្តលទ្ធិប្រជាធិបតេយ្យ ។

## ១.៥ គោលបំណងនៃការគេសាងឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា

បើទោះបីជាពលរដ្ឋវិជ្ជាមានសារៈសំខាន់តែនៅប្រទេសកម្ពុជាក៏ជួបប្រទះបញ្ហាជាច្រើនក្នុងការបង្រៀនមុខវិជ្ជានេះដែរ។ ការបង្ហាត់បង្រៀនពលរដ្ឋវិជ្ជា ទាមទារឱ្យមានការប្រើប្រាស់វិធីសាស្ត្របង្រៀន និងប្រើប្រាស់សម្ភារឧបទេសផ្សេងៗជាច្រើន ធ្វើយ៉ាងណាឱ្យសិស្សងាយយល់ និងយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។ តាមបទពិសោធន៍នៃការបង្រៀនពលរដ្ឋវិជ្ជានៅប្រទេសអភិវឌ្ឍន៍ គេមិនត្រឹមតែដាក់បញ្ចូលការបង្រៀនមេរៀនទាក់ទងលទ្ធិប្រជាធិបតេយ្យទេប៉ុន្តែគេថែមទាំងបានរៀបចំថ្នាក់រៀនឱ្យមានដំណើរការទៅតាមលក្ខណៈប្រជាធិបតេយ្យផងដែរ។ សិស្សមិនត្រឹមតែចូលរួមក្នុងការជ្រើសរើសប្រធានថ្នាក់ដោយខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងអាចជ្រើសរើសតំណាងរបស់ខ្លួនក្នុងការចូលរួមទទួលព័ត៌មាន ការសម្រេចចិត្ត និងធ្វើសកម្មភាព ឬគម្រោងនានានៅក្នុងនិងក្រៅសាលារៀនថែមទៀតផង។ តាមបទពិសោធន៍ និងការសិក្សាស្រាវជ្រាវរបស់លោក**ប្រេធី**(Pretty)នៅឆ្នាំ១៩៩៥បានបង្ហាញថា យុវជនអាចរៀនបានល្អដោយសារពួកគេមានអារម្មណ៍ចង់រៀន មានការលើកទឹកចិត្ត មានការឱ្យតម្លៃលើចំណេះដឹង បទពិសោធន៍ដែលខ្លួនមានឬទទួលបាននៅក្នុងជីវិតរបស់ពួកគេ មានឱកាសផ្តល់ការចែករំលែកចំណេះដឹងនិងបទពិសោធន៍គ្នាទៅវិញទៅមកនៅក្នុងថ្នាក់ មានការអនុញ្ញាតិឱ្យពួកគេចូលរួមរៀបចំកម្មវិធីសិក្សាដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ពួកគេ ។គ្រូពុំគួរចាត់ទុកសិស្សថា ជាអ្នកដែលចាំទទួលយករាល់អ្វីដែលគ្រូបានចាក់បញ្ចូលទៅឱ្យពួកគេនោះទេ។ ម្យ៉ាងវិញទៀត គ្រូមិនត្រឹមតែបើកទូលាយឱ្យសិស្សចូលរួមចែករំលែក និងរៀនសូត្រពីគ្នាទាំងចំណេះដឹងទាំងបទពិសោធន៍តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតបរិស្ថានមួយដែលធានាឱ្យសិស្សហ៊ានបញ្ចេញមតិ ចែករំលែកអ្វីដែលខ្លួនចេះទៀតផង។ នៅក្នុងការអង្កេតរបស់**មេហ្សីរ៉ូវ** និង**ថៃលើ** (Mezirow & Taylor)នៅឆ្នាំ២០០៩និង២០១២បានបញ្ជាក់ថា វប្បធម៌ស្ងៀមស្ងាត់បានធ្វើឱ្យមនុស្សជាច្រើនមិនចង់បញ្ចេញមតិយោបល់ទាក់ទងនឹងចំណេះដឹង និងបទពិសោធន៍របស់ខ្លួនទេ។ បញ្ហានេះកើតឡើងជាប្រចាំក្នុងចំណោមសិស្សដែលជឿជាក់ថាអ្វីដែលគ្រូបានលើកឡើង គឺត្រឹមត្រូវដោយគ្មានការសង្ស័យអ្វីឡើយ។ដូច្នេះ នៅក្នុងបរិយាកាសរៀនសូត្រ គ្រូត្រូវតែសម្រួលនិងលើកទឹកចិត្តធ្វើយ៉ាងណាកុំឱ្យសិស្សភ័យខ្លាចក្នុងការបញ្ចេញមតិ។

នៅក្នុងការអប់រំនាសម័យដើម គ្រូបង្រៀនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ទេរចំណេះដឹងដល់សិស្ស។ ដោយសារតួនាទីនេះហើយ សង្គមបានផ្តល់តម្លៃទៅលើគ្រូបង្រៀនថាជាអ្នកចេះដឹង ចំណែកសិស្សប្រៀបដូចជាក្រដាសសស្អាត ពុំមានចំណេះដឹង

អ្វីឡើយ។ សិស្សត្រូវបានគេរំពឹងថាមានការគោរពកោតខ្លាច និងចាំទទួលយករាល់គំនិតយោបល់របស់គ្រូថា ជាគំនិតយោបល់ត្រឹមត្រូវហើយត្រូវធ្វើតាម។ ប្រការនេះ បានធ្វើឱ្យសិស្សពុំសូវមានសកម្មភាពចូលរួមក្នុងការពិនិត្យមើល តើចំណេះដឹងដែលបានរៀនមកពីគ្រូនោះ អាចយកមកអនុវត្តនៅក្នុងជីវភាពរស់នៅបានដែរឬទេ។ ការមិនយកចំណេះដឹងនោះមកត្រិះរិះពិចារណាបានបង្អាក់មិនឱ្យមានការបង្កើតអ្វីថ្មីៗដែរ។ បន្ថែមពីលើនេះ គ្រូនិងសិស្សច្រើនតែមានឱកាសបង្រៀននិងរៀនតែនៅក្នុងថ្នាក់រៀន។ប្រការនេះមិនបានធ្វើឱ្យគោលបំណងចម្បងនៃការអប់រំមុខវិជ្ជាពលរដ្ឋវិជ្ជាអាចជំរុញសិស្សឱ្យក្លាយជាពលរដ្ឋល្អចេះប្រាស្រ័យទាក់ទងគ្នា និងអភិវឌ្ឍសហគមន៍ទៅថ្ងៃអនាគតនោះបានឡើយ។

ដោយសារមើលឃើញចំណុចខ្វះខាតនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់វិធីសាស្ត្របង្រៀនពីគោលវិធីគ្រូមជ្ឈមណ្ឌល មកគោលវិធីសិស្សមជ្ឈមណ្ឌលនៅឆ្នាំ១៩៩៧។ វិធីសាស្ត្រនេះបានផ្តល់តម្លៃយ៉ាងសំខាន់ទៅលើចំណេះដឹងដែលមានស្រាប់ និងសកម្មភាពរៀនសូត្រយ៉ាងសកម្មរបស់សិស្សនៅក្នុងថ្នាក់។ គ្រូគ្រាន់តែដើរតួនាទីជាអ្នកសម្របសម្រួលឱ្យសិស្សផ្សារភ្ជាប់ចំណេះដឹងដែលមានស្រាប់ និងចំណេះដឹងថ្មីដោយប្រើប្រាស់ឯកសារ មេរៀន និងរៀនរិះគិតពិចារណាថាតើទាំងចំណេះដឹងមានស្រាប់ ទាំងចំណេះដឹងថ្មីត្រឹមត្រូវឬទេ អាចបដិសេធ ឬសំយោគយកមកប្រើប្រាស់ក្នុងជីវភាពរស់នៅឬប្រកបការងារបានដែរឬទេ។

នៅក្នុងការបង្រៀននិងរៀន គ្រូត្រូវផ្តោតលើចំណុចសំខាន់បីក្នុងវត្ថុបំណងដែលត្រូវផ្តល់ឱ្យសិស្សគឺវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការប្រើប្រាស់ក្របខ័ណ្ឌនេះ មានគោលបំណងមិនត្រឹមតែឱ្យសិស្សយល់ដឹងអំពីទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែពួកគេអាចយកទៅអនុវត្តក្នុងជីវភាពរស់នៅផង និងប្រកាន់យកឥរិយាបថល្អប្រកបដោយសីលធម៌និងការអធ្យាស្រ័យគ្នានៅក្នុងសង្គមផង។ ដើម្បីឱ្យក្របខ័ណ្ឌនេះអាចប្រព្រឹត្តទៅបាន គ្រូក៏បានទទួលការបណ្តុះបណ្តាល និងជំរុញឱ្យប្រើវិធីបង្រៀនជាច្រើនដូចជាការសង្កេត ការអានស្វាត់ ការសួរសំណួរចោទឆ្លើយ ការធ្វើលំហាត់ប្រតិបត្តិការពិសោធន៍ ការស្រាវជ្រាវ ការពិភាក្សា ការគ្រាប់តាមគំរូ ការសម្តែងតួ ល្បែងសិក្សាការអនុវត្ត ការសង្ខេបមេរៀន និងទស្សនកិច្ចសិក្សាជាដើម។ បន្ថែមពីលើនេះ ក្រសួងអប់រំ យុវជន និងកីឡាក៏តម្រូវឱ្យដំណើរការបង្រៀន គោរពនិងអនុវត្តតាមគោលការណ៍៥ជំហានដែលរួមមានការធ្វើរដ្ឋបាលថ្នាក់(ជំហានទី១) ការរំឭកមេរៀនចាស់(ជំហានទី២) ការចាប់ផ្តើមមេរៀនថ្មី(ជំហានទី៣)ការពង្រឹងចំណេះដឹង(ជំហានទី៤) និងការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ(ជំហានទី៥)។ ដើម្បីជួយសម្រួលដល់ការរៀបចំដំណើរការបង្រៀននេះ

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្រុមអ្នកបច្ចេកទេសនិងផលិតឯកសារជំនួយសម្រាប់គ្រូដោយជ្រើសរើសវិធីបង្រៀនល្អៗមកដាក់បញ្ចូលក្នុងឯកសារបណ្តុះបណ្តាលគ្រូ ធ្វើយ៉ាងណាឱ្យគ្រូបង្រៀនសិស្សឆាប់ចាប់បាន និងយល់មេរៀនដែលមាននៅក្នុងសៀវភៅសិក្សា ហើយអាចយកទៅប្រើប្រាស់នៅក្នុងជីវភាពរស់នៅនិងបំពេញការងារប្រចាំថ្ងៃបាន។

ដូចនេះដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់គុណភាពអប់រំ និងក្នុងកំណែទម្រង់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានរួមសហការជាមួយមូលនិធិខុនរ៉ាដ អាដិនណូអ៊ែរដើម្បីរៀបចំកសាងឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជាថ្នាក់ទី១០ទី១១ ផ្តល់ជាជំនួយដល់លោកគ្រូ អ្នកគ្រូសម្រាប់បំពេញបន្ថែមលើឯកសារដែលមានស្រាប់។

## ១.៦ ក្របខ័ណ្ឌ ក ខ គ (ABC)

នៅក្នុងឯកសារជំនួយវិធីសាស្ត្របង្រៀននេះ ក្របខ័ណ្ឌ ក ខ គ (ABC) ដែលបានតែងនិពន្ធដោយលោក**អេឡែន ក្រាវហ្វើដ** (Alan Crawford) ត្រូវបានយកមកដាក់បញ្ចូល។ ក្របខ័ណ្ឌនេះ បានបង្កើតឡើងដោយឈរលើទស្សនៈប្រៀបធៀបទៅនឹងសកម្មភាពនៃការដាំស្រូវ ដូចជាគ្រូគឺជាកសិករមានតួនាទីក្នុងការមើលថែគ្រាប់ពូជ និងជំរុញឱ្យមានការលូតលាស់។ គ្រូគួរយល់យ៉ាងច្បាស់ថាគ្រាប់ពូជត្រូវការដី ទឹក និងជីប្រភេទណា កម្រិតណា ទើបចាប់ផ្តើមស្រោចទឹក ដាក់ជីទៅតាមតម្រូវការនោះ។ ឯសិស្សគឺជាគ្រាប់ពូជ។ ថ្នាក់រៀននិងសម្ភារឧបទេសនានា គឺតំណាងឱ្យអាកាសធាតុ ទឹក និងជីដើម្បីជួយឱ្យគ្រាប់ពូជដុះបានល្អ។ ដើម្បីឱ្យសិស្សទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាទៅតាមវត្ថុបំណងនៅក្នុងមុខវិជ្ជាពលរដ្ឋវិជ្ជា ក្របខ័ណ្ឌ ក ខ គ( ABC Framework )បានបញ្ចូលវិធីសាស្ត្របង្រៀនថ្មីប្លែកៗ។ វិធីសាស្ត្រទាំងនេះ អាចជួយជំរុញសិស្សឱ្យចង់រៀនមិនថាជាបុគ្គលឬជាក្រុមនិងចូលរួមចែករំលែកចំណេះដឹងបទពិសោធន៍ ហើយយកចំណេះដឹងដែលខ្លួនបានរៀនទៅអនុវត្តជាក់ស្តែង។ក្របខ័ណ្ឌ ក ខ គ ( ABC) បានផ្តោតទៅលើដំណើរការបង្រៀនជាបីដំណាក់កាល៖

***១.ការរំឭក***

នៅក្នុងដំណាក់កាលនេះ សិស្សត្រូវបានដឹកនាំឱ្យគិតអំពីចំណេះដឹងដែលមានស្រាប់ ចំណេះដឹងដែលសិស្សបានរៀនកន្លងមកហើយមានជាប់ទាក់ទងមេរៀនដែលគេនឹងចាប់ផ្តើមរៀនបន្តទៀត។ ប៉ុន្តែការរំឭកនេះមិនមែនមានន័យថាសិស្សគ្រាន់តែលើកឡើងនូវអ្វីដែលពួកគេបានដឹងប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ត្រូវវាយតម្លៃអ្វីដែលពួកគេបានដឹងនោះផង

ដែរ។ នៅក្នុងដំណាក់កាលនេះ គ្រូនិងសិស្សអាចជជែកពិភាក្សាគ្នា ឬសួរជាសំណួរដែលអាចជួយឱ្យយល់ដឹងកាន់តែប្រសើរថែមទៀតថា អ្វីដែលសិស្សបានដឹងនោះត្រឹមត្រូវ ឬក៏ជាការយល់ខុស។ បន្ទាប់មក គ្រូនិងសិស្សនឹងបង្កើតគោលបំណងនៃការសិក្សាដោយផ្តោតទៅលើមេរៀនដែលនឹងចាប់ផ្តើមរៀន។ សកម្មភាពទាំងនេះនឹងដើរតួនាទីជាមូលដ្ឋានដើម្បីឈានទៅរកដំណាក់កាលទីពីរដែលជាដំណាក់កាលសិស្សរៀនចំណេះដឹងថ្មីឬមេរៀនថ្មី។

***២.ការរៀនចំណេះដឹងថ្មី មេរៀនថ្មី***

នៅក្នុងដំណាក់កាលនេះ គ្រូចាប់ផ្តើមសម្របសម្រួលសិស្សឱ្យរៀនមេរៀនថ្មីដែលនឹងផ្តល់ចំណេះដឹងថ្មីៗទាក់ទងនឹងប្រធានបទដែលពួកគេបានពិភាក្សាគ្នានៅក្នុងដំណាក់កាលទី១។ នៅក្នុងដំណាក់កាលនេះ សិស្សអាចរៀនសំយោគដោយខ្លួនឯងថា តើអ្វីដែលខ្លួនបានរៀនត្រូវគ្នាជាមួយនឹងអ្វីដែលខ្លួនបានដឹងដែរឬទេ ហើយថាតើខ្លួនគួរប្រកាន់យកចំណេះដឹង និងតម្លៃមួយណាដែរ?

***៣.ការពង្រឹងពុទ្ធិ***

នៅក្នុងដំណាក់កាលនេះ គ្រូធ្វើសកម្មភាពមួយចំនួនដូចជាការវាយតម្លៃសមត្ថភាពរបស់សិស្សដែលបានរៀនរួចមកហើយ ដើម្បីបញ្ជាក់ថា តើពួកគេបានរៀន និងបានយល់មេរៀនថ្មីនោះដែរឬទេ។

## ១.៧ រចនាសម្ព័ន្ធឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា

ឯកសារវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជាសម្រាប់ជំនួយគ្រូបានបង្កើតឡើងសម្រាប់ជួយគ្រូបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាថ្នាក់ទី១០ និងទី១១ ដើម្បីយកទៅប្រើប្រាស់ផ្គួបជាមួយនឹងសៀវភៅសិក្សាគោល(សៀវភៅសិស្ស)ដែលក្រសួងអប់រំ យុវជន និងកីឡាបានផលិតនិងចែកចាយនៅតាមសាលារៀន។ ឯកសារនេះបែងចែកជា៤ជំពូក។នៅក្នុងជំពូកទី១ មានបរិយាយអំពីនិយមន័យពលរដ្ឋវិជ្ជា អំពីចំណេះដឹង បំណិន និងតម្លៃដែលបានមកពីការសិក្សាពលរដ្ឋវិជ្ជា អំពីបទពិសោធន៍បង្រៀនល្អៗនៅក្នុងប្រទេសអភិវឌ្ឍនានាដូចជាសហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលីជាដើម។ នៅក្នុងជំពូកទី២ មានរៀបរាប់ពីវិធីបង្រៀនដែលជំរុញឱ្យសិស្សចេះត្រិះរិះពិចារណា ចេះដោះស្រាយបញ្ហា ចេះរៀនសូត្រពីគ្នាទៅវិញទៅមក ចេះសិក្សាស្រាវជ្រាវ ចេះធ្វើគម្រោង និងចេះសម្តែងតួផងដែរ។ នៅក្នុងជំពូកទី៣ មានសកម្មភាពបង្រៀនមេរៀនពលរដ្ឋវិជ្ជាថ្នាក់ទី១០ ទី១១ យ៉ាងលម្អិតតាំងពីការចាប់ផ្តើមមេរៀនរហូតដល់ការបញ្ចប់មេរៀន។ នៅក្នុងជំពូកទី៤

ដែលជាជំពូកចុងក្រោយ មានការសង្ខេបឡើងវិញពីនិយមន័យនិងការបង្រៀនពលរដ្ឋវិជ្ជា ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលផងដែរ។

**១.៨ ការណែនាំប្រើប្រាស់ឯកសារជំនួយវិធីសាស្ត្របង្រៀនពលរដ្ឋវិជ្ជា**

ដើម្បីប្រើប្រាស់សៀវភៅនេះឱ្យបានត្រឹមត្រូវ គ្រូគួរអានជំពូកទី២ជាមុនដែលមានពណ៌នាអំពីវិធីឬសកម្មភាពបង្រៀននីមួយៗ។ នៅក្នុងជំពូកនេះ បានបង្ហាញយ៉ាងច្បាស់អំពីគោលបំណងក្នុងការប្រើប្រាស់វិធីបង្រៀន អំពីជំហាននីមួយៗដែលគ្រូត្រូវប្រើដោយរៀបតាមលំដាប់លំដោយដើម្បីយកទៅបង្រៀនសិស្ស។ នៅក្នុងជំពូកនេះ ក៏មានបង្ហាញសម្ភារឧបទេស និងរយៈពេលបង្រៀនដែលត្រូវចំណាយនៅពេលប្រើប្រាស់វិធីបង្រៀននីមួយៗ។ បន្ទាប់ពីយល់ដឹងអំពីវិធីបង្រៀនទាំងនេះហើយ គ្រូទៅមើលជំពូកទី៣ដែលបានបង្ហាញជាគំរូក្នុងការបង្រៀនដោយប្រើវិធីបង្រៀននីមួយៗមាននៅក្នុងជំពូកទី២ដែលបង្ហាញជាឧទាហរណ៍ ដើម្បីឱ្យយល់ថាតើនៅក្នុងថ្នាក់រៀន គ្រូត្រូវបង្រៀន និងប្រើវិធីបង្រៀនទាំងនោះដោយរបៀបណា។លោកគ្រូ អ្នកគ្រូអាចអនុវត្តតាមវិធីបង្រៀននៅក្នុងជំពូកទី៣ឬអាចកែប្រែ សម្របសម្រួលតាមស្ថានភាពជាក់ស្តែងនៅតាមសាលារៀនរបស់លោកគ្រូ អ្នកគ្រូ។

# ២.វិធីសាស្ត្របង្រៀន



## ២.១ ការសិក្សារបស់យុវជន

ការសិក្សារបស់យុវជន ត្រូវបានគេបែងចែកដាច់ស្រឡះពីការសិក្សារបស់កុមារ។ ការសិក្សារបស់កុមារភាគច្រើនមានការពឹងផ្អែកទៅលើគ្រូ ឬអ្នកដទៃ។ កុមារច្រើនតែរៀនត្រាប់តាម ឬទន្ទេញ ទោះបីជាពេលខ្លះពួកគេមិនយល់ និងមិនដឹងថាតើយកទៅប្រើប្រាស់នៅក្នុងសង្គមយ៉ាងដូចម្តេចក្តី។ ប៉ុន្តែការសិក្សារបស់យុវជនត្រូវផ្តោតលើ ៖

- វត្ថុបំណងជាក់លាក់
- ការអនុវត្តជាក់ស្តែង ចៀសវាងអង្គុយចាំស្តាប់តែគ្រូ
- ការដោះស្រាយបញ្ហា
- ការផ្តល់ឱកាសក្នុងការធ្វើអ្វីមួយដោយឯករាជ្យឬដោយខ្លួនឯង
- ការផ្តល់ការលើកទឹកចិត្ត
- ការប្រើប្រាស់បទពិសោធន៍ឬចំណេះដឹងដែលពួកគេមានពីមុនមកដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃការរៀនចំណេះដឹងថ្មីៗ
- ការផ្តល់ឱកាសឱ្យធ្វើកិច្ចការដែលសម្រេចគោលដៅឬអាចដោះស្រាយបញ្ហាបាន
- ការពន្យល់អំពីមូលហេតុដែលពួកគេត្រូវរៀនអំពីអ្វីមួយ
- ការជំរុញឱ្យពួកគេយល់ពីតម្លៃរបស់ខ្លួនជាលក្ខណៈវិជ្ជមាន
- ការបង្ហាញពីការគោរពក៏ដូចជាការយល់ពីតម្រូវការផ្សេងៗគ្នារបស់ពួកគេ។

ដូច្នេះដើម្បីជួយសិស្សដែលជាយុវជនឱ្យរៀនសូត្របានល្អ គ្រូអាចវាយតម្លៃតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្សរួចបង្កើតវត្ថុបំណងសិក្សារៀនសូត្រយោងទៅលើតម្រូវការ ចំណាប់អារម្មណ៍និងបំណិនជាក់លាក់។ ម្យ៉ាងទៀត បរិយាកាសនៅក្នុងថ្នាក់រៀន គួរធ្វើយ៉ាងណាឱ្យសិស្សទាំងអស់អាចចូលរួមរៀនសូត្រឬចែករំលែកបទពិសោធន៍ចំណេះដឹងពីគ្នាទៅវិញទៅមកបាន។គ្រូក៏អាចច្នៃវិធីបង្រៀនមួយចំនួនដែលអាចឱ្យសិស្សអនុវត្តជាក់ស្តែងផង រៀនសូត្រឱ្យចេះដោះស្រាយបញ្ហាដោយឯករាជ្យផង។ គ្រូលើកទឹកចិត្តនិងជួយផ្តល់យោបល់នៅពេលសិស្សត្រូវការ និងអាចវាយតម្លៃទៅលើគុណភាពនៃការបង្រៀន ព្រមទាំងកែលម្អជាប្រចាំដើម្បីឱ្យស្របទៅតាមតម្រូវការរបស់សិស្ស។

## ២.២ ការគ្រប់គ្រងថ្នាក់រៀន

ការគ្រប់គ្រងថ្នាក់រៀន គឺសំដៅទៅលើសកម្មភាពរបស់គ្រូក្នុងការរៀបចំថ្នាក់រៀន និងសកម្មភាពរៀនសូត្ររបស់សិស្សនៅក្នុងថ្នាក់ឱ្យសម្រេចបានលទ្ធផលនៃការសិក្សា និងមានអត្តចរិតល្អ។ ការគ្រប់គ្រងថ្នាក់រៀន រួមមានការរៀបចំកម្មវិធីសិក្សា(កម្មវិធីសិក្សាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំឆ្នាំ)ការរៀបចំដំណើរការបង្រៀន ការប្រមូល

ធនធានជាឯកសារឬសម្ភារៈសម្រាប់បង្រៀន ការរៀបចំបរិស្ថានថ្នាក់រៀនឱ្យការបង្រៀនមានប្រសិទ្ធភាព ការត្រួតពិនិត្យការវិវត្តរបស់សិស្ស ការការពារនិងការដោះស្រាយបញ្ហាដែលមាននៅក្នុងថ្នាក់រៀន។

ដើម្បីសម្រេចបានការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព គ្រូគួរតែៈ

២.២.១ បង្កើតទំនាក់ទំនងមួយដែលធ្វើឱ្យសិស្សមានអារម្មណ៍ថា គ្រូបានយកចិត្តទុកដាក់និងចាំជួយពួកគេ។ ជាធម្មតា កាលណាទំនាក់ទំនងរវាងគ្រូ និងសិស្សកាន់តែល្អ ការចូលរួមក្នុងសកម្មភាពរៀនសូត្រក៏រឹតតែមានច្រើន។ ដូច្នេះ គ្រូត្រូវបង្ហាញឱ្យសិស្សដឹងថាគ្រូពិតជាគិតគូរ និងបារម្ភពីសិស្ស ហើយយកចិត្តទុកដាក់ចំពោះការរៀនសូត្ររបស់ពួកគេ ឧទាហរណ៍រាល់ពេលសិស្សធ្វើសកម្មភាពឬរៀនសូត្រអ្វីមួយ គ្រូត្រូវផ្តល់ការណែនាំឱ្យច្បាស់ពីសកម្មភាពដែលគ្រូដាក់ឱ្យសិស្សធ្វើជាជំហានៗ។ ក្នុងករណីដែលសិស្សនៅមិនទាន់យល់ គ្រូត្រូវព្យាយាមរកឧទាហរណ៍ និងពន្យល់ដោយយកចិត្តទុកដាក់។ ម្យ៉ាងវិញទៀត នៅក្នុងសាលារៀនជាច្រើន នៅមានការយល់ច្រឡំថាសិស្សមានបញ្ហាដូចគ្នានៅពេលពួកគេមករៀន តាមការពិតសិស្សមានបញ្ហាផ្សេងៗគ្នាដែលគ្រូត្រូវយកចិត្តទុកដាក់សង្កេត និងយកចិត្តទុកដាក់ជួយសិស្សក្នុងការដោះស្រាយបញ្ហារបស់ពួកគេ។ ដូចនេះ ការបង្កើតទំនាក់ទំនងរវាងគ្រូនិងសិស្ស គួរធ្វើឱ្យសិស្សមានអារម្មណ៍ថាពួកគេកំពុងរៀនក្នុងបរិយាកាសល្អដោយមានការបារម្ភនិងការយកចិត្តទុកដាក់ពីគ្រូ។

២.២.២ រៀបចំការបង្រៀន និងរៀនដោយប្រើវិធីយ៉ាងណាឱ្យសិស្សចាប់អារម្មណ៍រៀនសូត្រ និងសម្រេចបានលទ្ធផលនៃការរៀនសូត្ររបស់ពួកគេ។ នៅក្នុងការសិក្សាស្រាវជ្រាវរបស់**អេដហ្គាដេល**(Edgar Dale) បានបង្ហាញថា សិស្សអាចចងចាំបានតិចតួចណាស់ប្រសិនបើគ្រូគ្រាន់តែឱ្យគេអាន ស្តាប់ ឬទស្សនាអ្វីមួយនោះ។ តាមលទ្ធផលស្រាវជ្រាវរបស់អ្នកនិពន្ធខាងលើនេះ សិស្សអាចចងចាំបានរហូតដល់៩០%ប្រសិនបើវិធីបង្រៀននោះឱ្យពួកគេធ្វើការវិភាគបញ្ចេញទស្សនៈយល់ឃើញនិងការអនុវត្តជាក់ស្តែង។



លោក**អូលីវើ និងរេស្វលី**(Oliver, R. M.& Reschly, D.J. (2007) អ្នកនិពន្ធសៀវភៅអំពីការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពក៏បានលើកឡើងដែរថា សិស្សចាប់អារម្មណ៍រៀនសូត្រដោយសារៈ

- មេរៀនដែលសិស្សកំពុងរៀនសមស្របទៅនឹងកម្រិតនៃការរៀនសូត្ររបស់ពួកគេ
- ការរៀបចំការបង្រៀនមានលំដាប់លំដោយត្រឹមត្រូវពោលគឺពីកម្រិតទាបទៅកម្រិតខ្ពស់ ឬពីងាយស្រួលទៅលំបាក
- ការទទួលបានឱកាសជាញឹកញាប់ក្នុងការរៀនសូត្រនិងការអប់រំ។នៅក្នុងវប្បធម៌នៃសង្គមខ្លះ សិស្សមានភាពអៀនខ្មាស មិនចង់និយាយស្ដី ឬចូលរួមសកម្មភាពនៅក្នុងថ្នាក់រៀនទេ ដូច្នេះហើយគ្រូត្រូវរិះរកវិធីបង្រៀនណាដែលជួយសិស្សនៅក្នុងថ្នាក់បានចូលរួមទាំងអស់គ្នា។ ឧទាហរណ៍ គ្រូឱ្យសិស្សសរសេរចម្លើយដាក់លើក្រដាសនិងលើកឡើងព្រមគ្នា ឆ្លើយសំណួរខ្លីៗរួមគ្នាឬបង្កើតប័ណ្ណដែលសិស្សអាចលើកព្រមគ្នាថា ពួកគេ១)យល់ ២)មិនយល់ ត្រូវការពន្យល់បន្ថែមទៀត ឬ៣)និយាយលឿនពេកសូមនិយាយមួយៗជាដើម។ក្នុងការអប់រំ គ្រូអាចរកវិធីបង្រៀនដែលជួយសិស្សឱ្យបង្រៀនឬពន្យល់គ្នាទៅវិញទៅមក។ ការធ្វើបែបនេះគឺធ្វើឱ្យសិស្សអាចចូលរួមក្នុងសកម្មភាពរៀនសូត្រ និងបញ្ចេញមតិយោបល់របស់ខ្លួនបានដូចខាងក្រោមៈ
- ការទទួលឱកាសក្នុងការអនុវត្តអ្វីមួយដោយមានការណែនាំជានិច្ចកាលពីគ្រូ
- ការផ្ដល់មតិយោបល់ និងការកែកំហុស។

លោក**វ៉ៃស៍មេន**និង**ហាន់**(Wiseman, D. G. & Hunt)នៅឆ្នាំ២០១៤ បានផ្ដល់អនុសាសន៍ក្នុងការជួយសិស្សឱ្យចាប់អារម្មណ៍ពីការរៀនសូត្រដែរ។ អ្នកនិពន្ធពន្យល់ថាក្រៅពីការបង្រៀនសិស្សឱ្យយល់មេរៀន គ្រូត្រូវជួយសិស្សឱ្យមើលឃើញអ្វីដែលពួកគេកំពុងរៀនមានតម្លៃ មានន័យ មានខ្លឹមសារ អាចជួយពួកគេឱ្យយកទៅដោះស្រាយបញ្ហាទាក់ទងទៅនឹងជីវិតរស់នៅរបស់ពួកគេក្នុងពេលបច្ចុប្បន្ន និងអនាគត ហើយក៏ជួយពួកគេឱ្យទទួលបានជោគជ័យ។ ជាធម្មតា សិស្សចាប់អារម្មណ៍រៀនសូត្រលុះត្រាតែវិធីបង្រៀននោះឆ្លើយតបនឹងតម្រូវការរបស់សិស្សនិងជួយសិស្សឱ្យបានជោគជ័យក្នុងការសិក្សា។ ដូច្នេះ វិធីបង្រៀនដែលអាចទាក់ទាញសិស្សបានត្រូវៈ

- ឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់សិស្ស
- មានគោលដៅនៃការបង្រៀនច្បាស់លាស់

- មានកិច្ចតែងការបង្រៀនទាក់ទងនឹងសកម្មភាពរៀនសូត្រទាំងគ្រូទាំងសិស្សជាក់លាក់
- មានការរៀបចំសម្ភារឧបទេសគ្រប់គ្រាន់
- មានវិធីបង្រៀនដែលជួយសិស្សឱ្យសម្រេចបានគោលដៅនៃការសិក្សា
- មានការវាយតម្លៃទាំងការបង្រៀននិងរៀនថា តើបានសម្រេចទៅតាមវត្ថុបំណងដែរឬទេ។

២.២.៣ ជំរុញសិស្សឱ្យចូលរួមការងារគ្រប់គ្រងថ្នាក់រៀនផងដែរ ពោលគឺអនុញ្ញាតឱ្យសិស្សចូលរួមក្នុងការបង្កើតបទបញ្ជាផ្ទៃក្នុង វិន័យ និងការសម្រេចចិត្តសំខាន់ៗនៅក្នុងថ្នាក់រៀន។ នៅក្នុងការបង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូដើរតួនាទីជាអ្នកសម្របសម្រួល និងជួយសិស្សឱ្យរៀនសូត្រដោយខ្លួនឯង។ ប្រការនេះទាមទារឱ្យគ្រូប្រើប្រាស់វិធីបង្រៀនជាច្រើន ដើម្បីធ្វើយ៉ាងណាឱ្យបរិយាកាសរៀនសូត្រ បង្កលក្ខណៈឱ្យសិស្សមានអារម្មណ៍ថាពួកគេក៏ជាផ្នែកមួយដ៏សំខាន់នៅថ្នាក់រៀននោះដែរ។ តាមយោបល់របស់លោក**គ្លាសសើ** (Glasser) ការជំរុញសិស្សឱ្យមានលទ្ធភាពពេញលេញ អាចចូលរួមគ្រប់សកម្មភាពនៅថ្នាក់រៀន នោះគួររាប់បញ្ចូលចំណុចមួយចំនួនដូចជា៖

- គ្រូដើរតួនាទីជាមេដឹកនាំប្រជាធិបតេយ្យ
- សិស្សចូលរួមក្នុងដំណើរការសម្រេចចិត្ត
- សិស្សមានឱកាសក្នុងការចូលរួមធ្វើសកម្មភាពនានា
- សិស្សជាផ្នែកមួយដ៏សំខាន់ក្នុងការបង្កើតបរិយាកាសរីករាយនិងការទទួលជោគជ័យនៅថ្នាក់រៀន ឬសាលារៀន
- គោលការណ៍ឬវិន័យត្រូវបានបង្កើតឡើងនិងបញ្ហាត្រូវដោះស្រាយតាមរយៈការប្រជុំ ឬការសម្រេចចិត្តរួមគ្នារវាងគ្រូនិងសិស្ស ។

ដូចនេះហើយ គ្រូមិនមែនជាអ្នកបង្កើតវិន័យ បទបញ្ជាផ្ទៃក្នុងថ្នាក់រៀនតែម្នាក់ឯងទេ ប៉ុន្តែគ្រូក៏ជាអ្នកសម្របសម្រួលឱ្យសិស្សទាំងអស់ក្នុងថ្នាក់រៀន ចូលរួមបង្កើតវិន័យបទបញ្ជាផ្ទៃក្នុងទាំងអស់គ្នាហើយអនុវត្តរួមគ្នា។ ដើម្បីឱ្យសិស្សចូលរួមបង្កើតវិន័យបទបញ្ជាផ្ទៃក្នុងទាំងនោះ គ្រូត្រូវលើកទឹកចិត្ត ចាត់តាំងសិស្សឱ្យបង្កើតក្រុមតូចៗ ហើយបង្កើតវិន័យ បទបញ្ជាផ្ទៃក្នុង៥ចំណុចដែលពួកគេត្រូវធ្វើជានិច្ច និងវិន័យ៥ចំណុចដែលពួកគេមិនត្រូវធ្វើ និងការដាក់ទោសពិន័យដល់អ្នកប្រព្រឹត្តខុស។ បន្ទាប់ពីការបង្កើតហើយ សិស្សអាចសរសេរនៅលើក្តារខៀន ឬលើក្រដាសផ្ទាំងធំនិងពិភាក្សាគ្នាថាតើគួរយកវិន័យបទបញ្ជាផ្ទៃក្នុងណាខ្លះ និងគួរដាក់ទោសអ្វីខ្លះ។

ឧទាហរណ៍

| |
|---|
| ១) ការចូលរួមសកម្មភាពរៀនសូត្រជាមួយគ្រូនិងមិត្តរួមថ្នាក់ដោយសៀមស្ងាត់<br>២) ការគោរពសិទ្ធិនិងថែរក្សាទ្រព្យសម្បត្តិសាលារៀននិងអ្នកដទៃ<br>៣) ការបំពេញទំនួលខុសត្រូវជាសិស្ស៖<br>– អានសៀវភៅនិងធ្វើកិច្ចការដែលគ្រូដាក់ឱ្យ<br>– សុំជំនួយពេលត្រូវការ<br>– ធ្វើការងាររបស់ខ្លួនដោយខ្លួនឯង<br>– ប្រគល់កិច្ចការជូនគ្រូតាមពេលកំណត់<br>– ទទួលខុសត្រូវចំពោះលទ្ធផលនៃការសិក្សារបស់ខ្លួន។ |

២.២.៤ ជំរុញសិស្សឱ្យមានបំណិនផ្នែកសង្គម និងមានវិន័យល្អ(ទទួលខុសត្រូវចំពោះអាកប្បកិរិយារបស់ខ្លួនឯង)។កំហុសតែងតែកើតមានជានិច្ចកាលចំពោះសិស្សនៅក្នុងថ្នាក់ប៉ុន្តែគ្រូត្រូវរកវិធីសាស្ត្រសមរម្យធ្វើយ៉ាងណាឱ្យសិស្សកែប្រែជាជាងការដាក់ទណ្ឌកម្មដែលអាចនាំឱ្យមានការប្រឈមមុខដាក់គ្នារវាងគ្រូនិងសិស្ស ។

ដើម្បីជួយអប់រំអាកប្បកិរិយាសិស្ស គ្រូត្រូវ៖

- ចៀសវាងការចោទសិស្សថាអាក្រក់បែបនេះ ឬបែបនោះ
- ចៀសវាងប្រើពាក្យបញ្ឈឺ
- ពន្យល់ប្រាប់សិស្សថាពួកគេគ្មានបញ្ហាទេ ប៉ុន្តែអាកប្បកិរិយារបស់ពួកគេមានបញ្ហាដែលអាចធ្វើឱ្យគេពិបាកក្នុងការសម្របខ្លួនទៅនឹងសង្គម ឬបាត់បង់ផលប្រយោជន៍ពេលមនុស្សដទៃទៀតមិនយល់ស្របទៅនឹងអាកប្បកិរិយានោះ។ គ្រូគួរផ្តល់យោបល់ឱ្យសិស្សផ្លាស់ប្តូរអាកប្បកិរិយានោះ
- លើកឡើង ឬសរសើរអាកប្បកិរិយាគំរូ ការងារ ឬកិច្ចការដែលសិស្សបានធ្វើ ប៉ុន្តែត្រូវចៀសវាងសរសើរបុគ្គល ព្រោះការសរសើរបុគ្គលក៏អាចធ្វើឱ្យបុគ្គលនោះយល់ថាតម្លៃរបស់ខ្លួនបានមកពីអ្នកដទៃឬបែរជាមានផ្នត់គំនិតដែលគិតថាធ្វើអ្វីមួយដើម្បីតែការសរសើរ
- ទទួលយកការសុំទោសពីសិស្ស
- ជួយសិស្សកែតម្រូវអាកប្បកិរិយាមិនល្អ និងបង្កើតតម្លៃរបស់ខ្លួនឡើងវិញ ។

ដើម្បីការពារឬព្រមានជាមុន កុំឱ្យសិស្សប្រព្រឹត្តិខុសវិន័យធ្ងន់ធ្ងរ គ្រូអាចបង្កើតប័ណ្ណពីរប្រភេទគឺប័ណ្ណលឿង និងប័ណ្ណក្រហម។កំហុសតិចតួច គ្រូអាចឱ្យប័ណ្ណលឿងមួយទៅសិស្សប៉ុន្តែប្រសិនបើកំហុសនោះកើតឡើងម្តងទៀត សិស្សនោះនឹងទទួលប័ណ្ណ

លឿងមួយទៀត។ ប័ណ្ណលឿងពីរគឺស្មើប័ណ្ណក្រហមមួយ។ ប្រសិនបើសិស្សមិនកែ ឬប្រព្រឹត្តិខុសធ្ងន់ធ្ងរ ហើយទទួលបានប័ណ្ណក្រហមចំនួនបី(ឬពីរទៅតាមការព្រមព្រៀងរវាងគ្រូនិងសិស្ស) សិស្សនោះនឹងទទួលពិន័យ។

ដើម្បីជំរុញលើកទឹកចិត្តសិស្សឱ្យខំប្រឹងប្រកាន់យកអាកប្បកិរិយាល្អ គ្រូក៏អាចបង្កើតការលើកទឹកចិត្តតាមរយៈការសរសេរឈ្មោះសិស្សទាំងនោះថាជាសិស្សគំរូនៅក្នុងថ្នាក់ ឬចេញជាលិខិតសរសើរអំពីអាកប្បកិរិយាល្អនោះបាន។ ដើម្បីទទួលបានការលើកទឹកចិត្តនេះ គ្រូអាចបង្កើតជារូបផ្កាយផ្តល់ដល់សិស្ស។ ប្រសិនបើសិស្សធ្វើអ្វីមួយល្អ សិស្សអាចទទួលបានផ្កាយតូចមួយ។ ប្រសិនបើសិស្សនោះនៅតែប្រកាន់យកអាកប្បកិរិយាល្អនោះទៀត សិស្សនឹងទទួលបានផ្កាយតូចមួយទៀត។ផ្កាយតូចពីរស្មើនឹងផ្កាយកណ្តាលមួយ។ កាលណាសិស្សបានទទួលផ្កាយកណ្តាលបី (ឬពីរទៅតាមការព្រមព្រៀងគ្នារវាងគ្រូនិងសិស្ស) នោះសិស្សនឹងបានផ្កាយធំមួយ។ សិស្សដែលបានទទួលផ្កាយធំមួយនឹងត្រូវគ្រូសរសេរឈ្មោះ ឬចេញប័ណ្ណសរសើរថាជាសិស្សដែលមានអាកប្បកិរិយាគំរូ។

**សារៈសំខាន់នៃគោលវិធីសិស្សមជ្ឈមណ្ឌល**

| ល.រ | ផ្នែក | សារប្រយោជន៍ |
|---|---|---|
| ១ | សម្ភារៈ | • ទាំងសិស្ស ទាំងគ្រូមានសម្ភារៈសម្រាប់សង្កេត ពិនិត្យ ពិសោធន៍ និងអនុវត្ត។ |
| ២ | សកម្មភាព | • គ្រូជាអ្នកសម្របសម្រួល ដាក់បញ្ហា និងដឹកនាំសកម្មភាព<br>• សិស្សមានភាពក្លាហាន ធ្វើសកម្មភាពស្រាវជ្រាវ ពិភាក្សា ពិសោធ សង្កេត បញ្ចេញយោបល់ កត់ត្រា រាយការណ៍ជាបុគ្គល ឬតាមក្រុមដើម្បីកសាងចំណេះដឹង<br>• ថ្នាក់រៀនសកម្មជានិច្ច។ |
| ៣ | ខ្លឹមសារ | • សិស្សចងក្រងខ្លឹមសារមេរៀន កសាងចំណេះដឹងដោយខ្លួនឯងក្រោមការជួយណែនាំ និងកែលម្អពីសិស្ស និងគ្រូ។ |
| ៤ | អភិវឌ្ឍបុគ្គលិកលក្ខណៈ | • សិស្សចេះរៀនដោយខ្លួនឯង មានទំនុកចិត្តលើខ្លួនឯង ក្លាហាន ម្ចាស់ការ សហការ អធ្យាស្រ័យ មានការច្នៃប្រឌិត មានការបង្កើតថ្មី<br>• សិស្សយកចិត្តទុកដាក់លើការអនុវត្តដោយផ្សារភ្ជាប់ទៅនឹងទ្រឹស្តី។ |

| | | |
|---|---|---|
| ៥ | លទ្ធផលសិក្សារបស់សិស្ស | • សិស្សបានទទួលលទ្ធផលសិក្សាដ៏ល្អតាមរយៈសកម្មភាពផ្ទាល់ខ្លួន ឬតាមក្រុម<br>• សិស្សយល់ច្បាស់លាស់ ចាំបានយូរ<br>• សិស្សយកចំណេះដឹងទៅអនុវត្តដើម្បីបម្រើជីវភាពរស់នៅក្នុងគ្រួសារ សហគមន៍ និងសង្គម។ |
| ៦ | សន្និដ្ឋាន | ការរៀន និងការបង្រៀនដោយអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យសិស្សអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាបានល្អ ព្រោះថាពេលណាគេឮ១០០ដង ពុំទាន់ស្មើនឹងគេបានឃើញតែមួយដង ប៉ុន្តែប្រសិនបើគេបានឃើញ១០០ដង ក៏ពុំទាន់ស្មើនឹងគេបានអនុវត្តផ្ទាល់មួយដង។ |

២.២.៥ រៀបចំបន្ទប់រៀន

ការគ្រប់គ្រងថ្នាក់រៀនបានល្អ ក៏ទាមទារឱ្យមានការរៀបចំថ្នាក់រៀនបានល្អផងដែរ។ អាកប្បកិរិយាមិនសមរម្យរបស់សិស្សមួយចំនួនអាចបណ្តាលមកពីបន្ទប់រៀនមិនមានកន្លែងគ្រប់គ្រាន់សម្រាប់ទុកដាក់ឯកសារ ឬសម្ភារៈផ្សេងៗបានដែលជាហេតុបង្កឱ្យមានការមិនសប្បាយចិត្ត។ការរៀបចំថ្នាក់រៀន ការរៀបចំតុកៅអីបានត្រឹមត្រូវនៅក្នុងថ្នាក់រៀនមិនត្រឹមតែអាចឆ្លើយតបទៅនឹងវិធីបង្រៀនដែលគ្រូយកមកបង្រៀនប៉ុណ្ណោះទេ តែក៏ធ្វើឱ្យគ្រូងាយស្រួលក្នុងការចល័តទៅរកសិស្ស ដើម្បីឆ្លើយសំណួរ ឬពិនិត្យមើលអាកប្បកិរិយារបស់សិស្សបានដោយមិនឱ្យរំខានដល់សិស្សដទៃទៀតដែរ។ ម្យ៉ាងវិញទៀត ការរៀបចំតុ កៅអីបានត្រឹមត្រូវសម្រាប់សិស្ស មានសារៈសំខាន់ណាស់ ព្រោះបានធ្វើឱ្យពួកគេយល់ថាខ្លួនមានសិទ្ធិស្មើគ្នាអាចមានឱកាសចែករំលែកចំណេះដឹងស្មើគ្នានិងប្រកបដោយសេចក្តីក្លាហាន។

**<u>ការរៀបចំតុកៅអីសិស្ស</u>**

លោក**អាសមែន ម៉ាកូហា** និង **មីឆាអែល អុងវ៉ាអេ** (Asman Makokha & Michaela Ongwae) បានផ្តល់គំរូនៃការរៀបតុកៅអីដ៏គួរឱ្យចាប់អារម្មណ៍មួយចំនួនដែលអាចយកមកប្រើនៅក្នុងការបង្រៀនពលរដ្ឋវិជ្ជាបានដូចជា៖

- **ការរៀបចំតុកៅអីរាងអក្សរអ៊ុយ (U)**

គ្រូអាចរៀបចំតុ កៅអីជារាងអក្សរអ៊ុយឱ្យសិស្សអាចមើលគ្នាឃើញ និងអាចចែករំលែកគំនិតគ្នារៀងៗខ្លួនដោយស្មើភាពគ្នាបាន។ គ្រូក៏អាចដើរទៅកាន់សិស្ស និងឆ្លើយសំណួរសិស្សបានផងដែរ។ ការរៀបចំតុកៅអីរបៀបនេះ ក៏អាចជួយសិស្សកុំឱ្យមានការ

ភ័យខ្លាចប្រសិនបើនៅពេលពួកគេត្រូវបានអញ្ជើញឱ្យទៅចូលរួមប្រជុំព្រោះការរៀបចំនេះភាគច្រើនធ្វើឡើងនៅក្នុងពេលប្រជុំ។ ប៉ុន្តែការរៀបចំបែបនេះក៏មានចំណុចអវិជ្ជមានដែរ ពោលគឺមិនអាចដាក់សិស្សច្រើនអង្គុយបាននិងពិបាកក្នុងការធ្វើកិច្ចការក្រុមតូចៗ។





- **ការរៀបចំតុកៅអីរាងឆ្អឹងត្រី**

ការរៀបចំតុកៅអីជារាងឆ្អឹងត្រី ជួយសិស្សឱ្យអាចធ្វើការងារជាក្រុមពិភាក្សាតូចៗបាន។ ចំណែកឯគ្រូក៏អាចដើរទៅពិនិត្យមើលសកម្មភាពសិស្ស ឆ្លើយសំណួរ ឬក៏ផ្តល់យោបល់បន្ថែមបាន។ ប៉ុន្តែផលអវិជ្ជមានគឺមិនអាចដាក់សិស្សបានច្រើន ហើយសិស្សក៏មិនអាចមើលគ្នាឃើញទាំងអស់ដែរ។





- **ការរៀបចំតុកៅអីរាងរង្វង់ ឬពាក់កណ្តាលរង្វង់តូចៗ**

ការរៀបចំតុកៅអីរាងរង្វង់ឬពាក់កណ្តាលរង្វង់ជួយសិស្សឱ្យអាចបំបែកជាក្រុមតូចៗ ដើម្បីពិភាក្សាគ្នា និងអាចធ្វើទំនាក់ទំនងគ្នាយ៉ាងល្អនៅក្នុងក្រុម។ គ្រូក៏អាចងាយស្រួលដើរពិនិត្យមើល និងឆ្លើយសំណួរសិស្ស។ ប៉ុន្តែការរៀបចំតុកៅអីរបៀបនេះ ក៏មាន

បញ្ហាដូចគ្នានឹងការរៀបចំមុនៗដែរ ពោលគឺមិនអាចដាក់សិស្សបានច្រើនហើយក៏ពិបាកក្នុងការទុកដាក់សម្ភៀតសៀវភៅឬឯកសារផងដែរ។



- **ការរៀបចំតុកៅអីមានរាងជារង្វង់ធំ**

ការរៀបចំតុកៅអីមានរាងជារង្វង់ធំជួយឱ្យសិស្សទាំងអស់អាចធ្វើការងារជាក្រុមពិភាក្សាធំមួយនៅក្នុងថ្នាក់បាន។សិស្សមានសិទ្ធិស្មើគ្នាក្នុងការបញ្ចេញមតិយោបល់។



- **ការរៀបចំតុកៅអីសម្រាប់គ្រូ**

សម្រាប់ការរៀបចំតុកៅអីរបស់គ្រូ លោក**ម៉ាក្លេអូជច្យយ**(Mcleod Joyce)បានផ្តល់យោបល់ថា ការរៀបចំតុកៅអីសម្រាប់គ្រូ គឺដាក់នៅចំហៀង មិននៅពីមុខ ឬពីក្រោយទេ ដើម្បីឱ្យគ្រូអាចពិនិត្យមើលសកម្មភាពសិស្សដោយពុំមានការរំខាន ឬកុំឱ្យសិស្សមាន

អារម្មណ៍ថាពួកគេកំពុងតាមដានពីខាងក្រោយ។ នៅពីខាងក្រោយសិស្ស គ្រូត្រូវរៀបចំកន្លែងសម្រាប់ទុកដាក់សម្ភារៈ ឬសៀវភៅ ចៀសវាងការដាក់នៅលើតុ ព្រោះវាអាចរំខានដល់សិស្សពេលធ្វើសកម្មភាព ឬរៀនសូត្រ។ប៉ុន្តែប្រសិទ្ធភាពនៃវិធីរៀបចំនីមួយៗអាស្រ័យលើលទ្ធភាពជាក់ស្តែងទៅតាមសាលារៀននីមួយៗផងដែរ ពោលគឺគ្រូត្រូវព្យាយាមជ្រើសរើសការរៀបចំតុកៅអីទៅតាមស្ថានភាព និងធនធានជាក់ស្តែងនៅតាមថ្នាក់រៀន សាលារៀន របស់ខ្លួន។

## ២.៣ កិច្ចតែងការបង្រៀន

កិច្ចតែងការបង្រៀន មានសារៈសំខាន់ណាស់ក្នុងការកំណត់ពីភាពជោគជ័យនៃការបង្រៀន។ កិច្ចតែងការបង្រៀនជាគោលការណ៍រួមមាន វត្ថុបំណងក្នុងការរៀននិងបង្រៀន រយៈពេល វិធីបង្រៀន សកម្មភាព ឬកិច្ចការដែលគ្រូនិងសិស្សត្រូវធ្វើនៅក្នុងថ្នាក់ ការវាយតម្លៃ សម្ភារឧបទេស និងរួមទាំងបញ្ជីផ្សេងៗ សៀវភៅឬ អត្ថបទដែលសិស្សអាចអានបន្ថែម។

**២.៣.១ វត្ថុបំណងក្នុងការរៀននិងការបង្រៀន** ៖ ដើម្បីធ្វើកិច្ចតែងការបង្រៀនមួយអាចជួយសិស្សឱ្យរៀនបានល្អ ទាមទារគ្រូឱ្យធ្វើកិច្ចតែងការបង្រៀននោះមានវត្ថុបំណងជាក់លាក់ អាចវាស់វែងបាន អាចសម្រេចជាលទ្ធផល មានភាពប្រាកដប្រជាត្រឹមត្រូវទៅតាមពេលវេលាកំណត់ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សិស្ស ក៏ដូចជាគោលបំណងចម្បងនៃមេរៀនឬមុខវិជ្ជាទាំងមូលផងដែរ។

ដោយសារវត្ថុបំណងក្នុងការរៀននិងបង្រៀនមានសារៈសំខាន់ គ្រូគួរពិចារណាថាតើមេរៀនដែលនឹងយកមកបង្រៀននោះ ជួយសិស្សឱ្យមានចំណេះដឹង បំណិនអ្វីខ្លះជាមុនសិនទើបធ្វើឱ្យចំណេះដឹង បំណិនដែលសិស្សទទួលបានមកនោះទៅជាវត្ថុបំណងនៃការសិក្សារបស់សិស្ស។ ប៉ុន្តែគ្រូត្រូវធ្វើយ៉ាងណាជ្រើសរើសវត្ថុបំណងសិក្សាឱ្យជាក់លាក់និងអាចសម្រេចបាន ពោលគឺកុំឱ្យវត្ថុបំណងទាំងនោះទូលំទូលាយពេក ដែលពិបាកក្នុងការវាស់វែង និងសម្រេចបាន ឧទាហរណ៍ ចង់ឱ្យសិស្សចេះអំពីលទ្ធិប្រជាធិបតេយ្យ គ្រូកំណត់វត្ថុបំណងឱ្យបានជាក់លាក់ ដូចជាសិស្សប្រាប់បានអំពីនិយមន័យនៃលទ្ធិប្រជាធិបតេយ្យ សិស្សអាចពន្យល់អំពីសិទ្ធិពលរដ្ឋ សិស្សអាចរៀបរាប់អំពីការរៀបចំ និងដឹកនាំការប្រជុំដើម្បីសម្តែងមតិឬធ្វើការងារសហគមន៍ជាដើម។ វត្ថុបំណងទាំងនេះមានភាពជាក់លាក់ និងងាយស្រួលក្នុងការវាស់វែងបានទៅតាមពេលវេលាដែលបានកំណត់សម្រាប់បង្រៀន។

នៅក្នុងថ្នាក់រៀន សិស្សអាចមានកម្រិតយល់ដឹង និងបំណិនផ្សេងៗគ្នា ឬមិនស្មើគ្នា។ គ្រូអាចសង្កេតតាមដាន ឬអាចធ្វើតេស្តសាកល្បង ដើម្បីឱ្យដឹងថាតើសិស្សណាខ្លះមានតម្រូវការអ្វី ។ ការយល់ដឹងអំពីតម្រូវការផ្សេងៗគ្នានេះ ក៏អាចជួយឱ្យគ្រូរៀបចំកែសម្រួលវត្ថុបំណងធ្វើឱ្យសិស្សអភិវឌ្ឍការយល់ដឹង និងបំណិនរបស់គេផង និងឱ្យតម្លៃលើការសិក្សាផង ព្រោះវាមានជាប់ទាក់ទងនឹងខ្លួនរបស់ពួកគេ។ ឧទាហរណ៍ ប្រសិនបើរកឃើញថា សិស្សពុំសូវមានចំណេះដឹងខាងសរសេរ គ្រូអាចថែមវត្ថុបំណងមួយទៀតទាក់ទងនឹងការបង្កើនសមត្ថភាពរបស់សិស្សក្នុងការសរសេរ វិភាគជាដើម។

សម្រាប់វត្ថុបំណងគ្រប់មុខវិជ្ជានៅក្នុងក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស វត្ថុបំណងត្រូវបែងចែកជាបីផ្នែកពោលគឺ វិជ្ជាសម្បទា(ចំណេះដឹង) បំណិនសម្បទា(បំណិន) និងចរិយាសម្បទា(ឥរិយាបថ/តម្លៃ)។ វិជ្ជាសម្បទា(ចំណេះដឹង) គឺសំដៅលើការពង្រីកឬបង្កើនប្រាជ្ញារបស់សិស្សតាមរយៈការរៀន ការចេះពិចារណា និងការវិភាគ។ កិច្ចតែងការបង្រៀនក៏គួរផ្ដោតលើការបង្កើតជំនាញ(បំណិន)ឱ្យសិស្សចេះនិងយកទៅអនុវត្តតាមមេរៀនដែលពួកគេបានរៀននៅក្នុងស្ថានភាពជាក់ស្ដែង។ ដូច្នេះដើម្បីបង្កើតជំនាញ(បំណិន)ទាំងនេះ ការអនុវត្តជាក់ស្ដែងត្រូវការជាចាំបាច់ណាស់ដើម្បីជួយសិស្សឱ្យស្ទាត់ជំនាញ។ ចំណែកឯឥរិយាបថ(តម្លៃ)ជាចំណុចលំបាកក្នុងការអប់រំ ប៉ុន្តែវាមានសារៈសំខាន់ណាស់ព្រោះវាអាចជួយសិស្សឱ្យប្រកាន់អត្តចរិតថ្មី។ អនុលោមទៅតាមក្របខណ្ឌកម្មវិធីសិក្សានេះ មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាត្រូវបានតាក់តែងឡើងដើម្បីជួយសិស្សឱ្យយល់ដឹង ចេះត្រិះរិះពិចារណា វិភាគសំយោគ ប្រព័ន្ធនយោបាយ សិទ្ធិពលរដ្ឋ កាតព្វកិច្ចពលរដ្ឋ និងច្បាប់នានា។ សិស្សក៏មានបំណិនក្នុងការធ្វើការងារជាក្រុម ឬជាបុគ្គល ចេះពិភាក្សាចែករំលែក និងតស៊ូមតិ ការពារសិទ្ធិរបស់ខ្លួន និងអ្នកដទៃ ចេះការពារផលប្រយោជន៍រួម ចេះប្រើចំណេះដឹងចូលរួមក្នុងដំណើរការអភិវឌ្ឍសង្គមនិងរៀបចំគ្រប់គ្រងកិច្ចការប្រជុំ កិច្ចការសង្គម និងគម្រោងអភិវឌ្ឍន៍ផងដែរ។ សិស្សក៏ត្រូវបានបង្រៀនឱ្យយល់ដឹងថា តើតម្លៃអ្វីគួរប្រកាន់យក និងមិនគួរប្រកាន់យកនៅក្នុងលទ្ធិប្រជាធិបតេយ្យ ដូចជាការប្រកាន់យកការរស់នៅប្រកបដោយសុជីវធម៌ សីលធម៌ យុត្តិធម៌ តម្លាភាព ឯករាជភាព ការអត់ធ្មត់ តម្កល់តម្លៃរួមជាធំ ការបើកចំហទទួលយក និងចេះស្ដាប់ទស្សនៈអ្នកដទៃ ការចរចាសម្របសម្រួល និងការពិចារណារកហេតុផល។

| វត្ថុបំណង | |
|---|---|
| **វិជ្ជាសម្បទា (ចំណេះដឹង)** | យល់ដឹងអំពី ប្រព័ន្ធនយោបាយ សិទ្ធិពលរដ្ឋ (សិទ្ធិបញ្ចេញមតិ សិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត សិទ្ធិសេដ្ឋកិច្ច សិទ្ធិវប្បធម៌ ជាដើម) ។ |
| **បំណិន សម្បទា (បំណិន)** | ចេះធ្វើការជាក្រុមឬជាបុគ្គល ចេះតស៊ូមតិ ចេះការពារសិទ្ធិរបស់ខ្លួន និងអ្នកដទៃ ការពារផលប្រយោជន៍រួម ប្រើចំណេះដឹងចូលរួមក្នុងដំណើរការនយោបាយ និយាយប្រាស្រ័យទាក់ទងគ្នា រៀបចំនិងគ្រប់គ្រងកិច្ចការប្រជុំ កិច្ចការសង្គម គម្រោងអភិវឌ្ឍន៍ជាដើម។ |
| **ចរិយា សម្បទា (ឥរិយាបថ)** | រស់នៅប្រកបដោយសុជីវធម៌និងសីលធម៌ ប្រកាន់យកយុត្តិធម៌ តម្លាភាព ឯករាជ្យ អត់ធ្មត់ តម្កល់តម្លៃរួមជាធំ ឱ្យតម្លៃលើការពិចារណារកហេតុផលត្រឹមត្រូវ បើកចិត្តទូលាយទទួលយកនិងចេះស្តាប់ទស្សនៈអ្នកដទៃ ការចរចាសម្របសម្រួលនិងមានកាតព្វកិច្ចជាពលរដ្ឋ(ការគោរពច្បាប់ គោរពសិទ្ធិនិងផលប្រយោជន៍អ្នកដទៃ)។ |

**២.៣.២ រយៈពេល** ៖ ការគ្រប់គ្រងពេលវេលានៅក្នុងថ្នាក់រៀន ជាការកំណត់ភាពជោគជ័យនៃការបង្រៀនមុខវិជ្ជានីមួយៗ ព្រោះកាលណាពេលវេលាខ្លីពេក ការសិក្សាមិនអាចចប់ និងមិនសម្រេចទៅតាមវត្ថុបំណងឬពេលវេលាច្រើនពេកសិស្សមានពេលច្រើននឹងនាំឱ្យសិស្សបង្កភាពឥតសណ្តាប់ធ្នាប់នៅក្នុងថ្នាក់។ ជាគោលការណ៍គ្រូត្រូវចេះប៉ាន់ស្មានថាតើវិធីបង្រៀន ឬសកម្មភាពបង្រៀននិងរៀននីមួយៗ ត្រូវចំណាយពេលអស់ប៉ុន្មាន តើសមស្របទៅតាមពេលវេលាដែលក្រសួងអប់រំ យុវជន និងកីឡាបានបែងចែកឱ្យបង្រៀនដែរឬទេ តើសកម្មភាពណាសិស្សគួរតែធ្វើនៅផ្ទះ ឬកន្លែងផ្សេងក្រៅម៉ោងសិក្សា និងសកម្មភាពណាដែលសិស្សគួរធ្វើនៅក្នុងថ្នាក់ជាដើម។ ដើម្បីកំណត់រយៈពេលបានត្រឹមត្រូវ គ្រូគួរតែសង្កេតតាមដានរាល់សកម្មភាពរៀនរបស់សិស្សនិងសកម្មភាពបង្រៀនរបស់ខ្លួនរួចកែប្រែទៅតាមស្ថានភាពជាក់ស្តែង។ ប៉ុន្តែគ្រូគួរប្រុងប្រយ័ត្នក្នុងការកំណត់រយៈពេលផងដែរ ព្រោះមានការរិះគន់ថាការផ្តោតតែទៅលើការបង្រៀនឱ្យត្រូវទៅតាមរយៈពេលកំណត់មិនអាចផ្តល់ចំណេះដឹងទៅឱ្យសិស្សតាមការរំពឹងទុក។

**២.៣.៣ វិធីបង្រៀន** ៖ ដោយសារនៅក្នុងមេរៀននីមួយៗ មានវត្ថុបំណងផ្សេងៗគ្នា កិច្ចតែងការបង្រៀនក៏អាចកំណត់វិធីបង្រៀនខុសៗគ្នាដែរ។ ជាទូទៅ វិធីបង្រៀន រួមមានការបង្រៀនដោយផ្ទាល់ ដោយហ្វឹកហាត់ក្រោមការណែនាំពីគ្រូ ការបង្រៀនសិស្សឱ្យរៀនធ្វើកិច្ចការនិងចែករំលែកចំណេះដឹងដល់គ្នាទៅវិញទៅមក បង្រៀនសិស្សឱ្យចេះធ្វើ

ការងារដោយឯករាជ្យនិងរៀនអនុវត្ត។ វិធីបង្រៀនពលរដ្ឋវិជ្ជានៅក្នុងឯកសារនេះបានបញ្ចូលចំណុចខាងលើដែរដោយបង្រៀនសិស្សឱ្យចេះសរសេរតែងសេចក្តី សង្ខេបមេរៀន សរសេរប័ណ្ណព័ត៌មានតូចៗ ឡើងរាយការណ៍ ពិភាក្សា អានជាដៃគូ អានជាក្រុម សួរឆ្លើយ ធ្វើគម្រោង សម្តែងតួ និងវិភាគករណីសិក្សាជាដើម។ ដូចនេះ គ្រូគួរតែពិនិត្យមើលថាតើមេរៀននោះមានវត្ថុបំណងអ្វី? តើវិធីបង្រៀនណាខ្លះជួយសិស្សឱ្យទទួលបានលទ្ធផលសិក្សាតាមវត្ថុបំណង? តើវិធីបង្រៀននោះសមស្របទៅតាមរយៈពេលដែលបានកំណត់ដែរឬទេ?

**២.៣.៤ សកម្មភាព ឬកិច្ចការដែលគ្រូនិងសិស្សត្រូវធ្វើនៅក្នុងថ្នាក់**: ដោយសារកិច្ចតែងការបង្រៀនជាផែនទីចង្អុលផ្លូវសម្រាប់គ្រូប្រើក្នុងការបង្រៀន សកម្មភាពបង្រៀន និងរៀនត្រូវដាក់បញ្ចូលនៅក្នុងនោះផងដែរ។ សកម្មភាពបង្រៀន និងរៀនដែលស្របទៅនឹងពេលវេលាកំណត់នោះ អាចបែងចែកជាផ្នែកៗទៅតាមរចនាសម្ព័ន្ធមេរៀនពីដើមរហូតដល់ចប់ ឬបែងចែកទៅតាមវត្ថុបំណង ថាតើចង់ឱ្យសិស្សមានចំណេះដឹងអ្វី មានបំណិន(ជំនាញ)អ្វីនិងប្រកាន់ឥរិយាបថ(តម្លៃ)បែបណា។ ជាធម្មតា កិច្ចតែងការបង្រៀនបានបែងចែកជាបីខ្ទង់(Column)ខ្ទង់ទី១សម្រាប់សរសេរសកម្មភាពគ្រូ ខ្ទង់ទី២សម្រាប់សរសេរខ្លឹមសារមេរៀននិងខ្ទង់ទី៣សម្រាប់សរសេរសកម្មភាពសិស្សដោយមានបញ្ចូលចំនួននាទីដែលសកម្មភាពនីមួយៗត្រូវចំណាយពេលផងដែរ។

**២.៣.៥ ការវាយតម្លៃ** : ការវាយតម្លៃការសិក្សារបស់សិស្សជាការសំខាន់ ជាពិសេសសិស្សដែលជាយុវជន ព្រោះនៅក្នុងការអប់រំយុវជន ការផ្តល់មតិយោបល់ក្នុងការសិក្សានិងការតាមដានការវិវត្តរបស់សិស្សជាដំណាក់ៗ គឺមានសារៈសំខាន់ណាស់ក្នុងការទាក់ទាញឱ្យពួកគេចាប់អារម្មណ៍រៀនសូត្រ ដើម្បីជួយកែលម្អពួកគេបណ្តើរៗផង និងឱ្យសម្រេចលទ្ធផលសិក្សារបស់សិស្សផង។ ជាទូទៅ ការវាយតម្លៃធ្វើឡើងតាមបីដំណាក់កាល គឺមុនពេលបង្រៀន នៅពេលកំពុងបង្រៀន និងក្រោយពេលបង្រៀន។ នៅមុនពេលបង្រៀន គ្រូអាចវាយតម្លៃសិស្សដើម្បីឱ្យដឹងថាតើសិស្សមានចំណេះដឹងកម្រិតណាទាក់ទងទៅនឹងមេរៀន។ នៅក្នុងពេលកំពុងបង្រៀន គ្រូអាចវាយតម្លៃដើម្បីឱ្យដឹងថាតើសិស្សចាប់បានអ្វីដែលខ្លួនកំពុងបង្រៀនដែរឬទេ តើគ្រូគួរផ្តល់ការពន្យល់ ការបង្ហាញ លើកឧទាហរណ៍មកបញ្ជាក់បន្ថែម ឬបង្រៀនថែមទៀតដែរឬទេ។ ការវាយតម្លៃក្រោយពេលបង្រៀន គឺដើម្បីឱ្យដឹងថាតើសិស្សបានទទួលលទ្ធផលនៃការសិក្សាដូចការរំពឹងទុកដែរឬទេ។ គ្រូគួរតែរៀបចំឧបករណ៍វាយតម្លៃសិស្សជាមុនតាំងពីធ្វើកិច្ចតែងការបង្រៀនម្លេះ។

**២.៣.៦ សម្ភារឧបទេស** ៖ ក្នុងការបង្រៀន សម្ភារឧបទេសជាផ្នែកមួយដ៏សំខាន់។កង្វះសម្ភារឧបទេសអាចនាំឱ្យការបង្រៀនគ្មានប្រសិទ្ធភាព ឬមិនអាចប្រព្រឹត្តទៅបានល្អ។ ដូច្នេះគ្រូគួរគិតថា តើដើម្បីឱ្យការបង្រៀនរបស់ខ្លួនអាចសម្រេចបានទៅតាមវត្ថុបំណង តើគ្រូត្រូវការសម្ភារឧបទេសអ្វីខ្លះ។ សម្ភារឧបទេសត្រូវឆ្លើយតបទៅនឹងវិធីបង្រៀននិងសកម្មភាពរៀនរបស់សិស្សនៅក្នុងថ្នាក់។ សម្ភារឧបទេសត្រូវរៀបចំឱ្យរួចរាល់មុនពេលបង្រៀន និងមានចំនួនគ្រប់គ្រាន់សម្រាប់សិស្ស។

| **កិច្ចតែងការបង្រៀន** | | |
|---|---|---|
| ជំពូក | | |
| មេរៀនទី | | |
| ចំណងជើងមេរៀន | | |
| ការពណ៌នាសង្ខេបនៃមេរៀន | | |
| វត្ថុបំណង | | |
| រយៈពេល | | |
| សម្ភារឧបទេស | | |
| **ដំណើរការបង្រៀននិងរៀន** | | |
| សកម្មភាពគ្រូ៖ | ខ្លឹមសារមេរៀន៖ | សកម្មភាពសិស្ស៖ |
| ១. រដ្ឋបាលថ្នាក់/ការណែនាំ: | | |
| ២. ការរំឭកមេរៀនចាស់ | | |
| ៣. មេរៀនថ្មី | | |
| ៤. ការពង្រឹងពុទ្ធិ/ការវាយតម្លៃ | | |
| ៥. កិច្ចការផ្ទះ/ បណ្ដាំផ្ញើ (ឯកសារត្រូវមើលបន្ថែម) | | |

## ២.៤ ការវាយតម្លៃការបង្រៀននិងការរៀន

### ក. ការវាយតម្លៃការបង្រៀនរបស់គ្រូ

គ្រូដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សារបស់សិស្ស ព្រោះគ្រូមិនត្រឹមតែជាអ្នករៀបចំថ្នាក់រៀន និងជាអ្នកបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកដែលធ្វើការសិក្សា វិភាគរកមើលវិធីបង្រៀនថ្មីៗដែលអាចឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់សិស្ស លើកទឹកចិត្តសិស្ស រៀបចំកិច្ចតែងការបង្រៀន និងផ្ដល់ការណែនាំដល់សិស្ស ទាំងសកម្មភាពនៅក្នុង

ថ្នាក់ ទាំងក្រៅថ្នាក់ផងដែរ។ ដូច្នេះដើម្បីធានាបានថា គ្រូអាចបំពេញតួនាទីដ៏មានសារៈសំខាន់របស់ខ្លួនប្រកបដោយប្រសិទ្ធភាព នោះគ្រូចាំបាច់ត្រូវវាយតម្លៃលើការងារបង្រៀនរបស់ខ្លួនផងដែរ។ នៅក្នុងគំរូនៃការវាយតម្លៃដែលមាននៅក្នុងឯកសារនេះ ការវាយតម្លៃរបស់គ្រូផ្តោតទៅលើការធ្វើកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្ស និងការចែករំលែកបទពិសោធន៍នៃការបង្រៀនទៅឱ្យគ្រូដទៃទៀត។ ការវាយតម្លៃនេះមិនបានគិតចេញជាពិន្ទុ គ្រូណាបានពិន្ទុខ្ពស់ជាងគេ ឬគ្រូណាបានពិន្ទុទាបជាងគេនោះទេ ប៉ុន្តែការវាយតម្លៃនេះ មានគោលបំណងចង់ពញ្ញាក់ស្មារតីឱ្យគ្រូចងចាំ និងធ្វើសកម្មភាពសំខាន់ៗទាក់ទងនឹងការបង្រៀន ដើម្បីឱ្យដំណើរការបង្រៀនរបស់លោកគ្រូអ្នកគ្រូកាន់តែប្រសើរឡើង។

| **ល.រ** | **ការវាយតម្លៃការបង្រៀន** | **ចម្លើយ(✓)** |
|---|---|---|
| ក.កិច្ចតែងការបង្រៀន | | |
| ១ | ខ្ញុំតែងតែត្រៀមកិច្ចតែងការបង្រៀនមុននឹងមកបង្រៀន។ | ☐ |
| ២ | ខ្ញុំតែងតែត្រៀមសំណួរ និងចម្លើយដើម្បីវាយតម្លៃការរៀនរបស់សិស្ស។ | ☐ |
| ៣ | ដើម្បីគ្រប់គ្រងពេលវេលាបានល្អ ខ្ញុំតែងតែអនុវត្តការបង្រៀនទៅតាមពេលវេលាកំណត់នៅក្នុងកិច្ចតែងការបង្រៀន។ | ☐ |
| ខ.ការបង្រៀន | | |
| ៤ | ខ្ញុំតែងតែត្រៀមសម្ភារឧបទេសមុនមកបង្រៀនសិស្ស។ | ☐ |
| ៥ | ខ្ញុំតែងតែរំឭកមេរៀនមុននឹងខ្ញុំទៅបង្រៀនដើម្បីឱ្យច្បាស់ថាខ្ញុំចេះមេរៀននោះទាំងអស់។ | ☐ |
| ៦ | ខ្ញុំតែងតែសង្កេតមើល តើសិស្សណាមិនសូវយល់ ខ្ញុំនឹងពន្យល់សិស្សនោះឱ្យយល់បន្ថែមទៀត។ | ☐ |
| ៧ | ខ្ញុំលើកទឹកចិត្តសិស្សឱ្យចូលរួមផ្តល់មតិយោបល់គ្រប់ៗគ្នា។ | ☐ |
| ៨ | ខ្ញុំតែងតែស្រាវជ្រាវរកមើលឧទាហរណ៍បន្ថែមទៀតដើម្បីយកមកពន្យល់សិស្សឱ្យងាយយល់។ | ☐ |
| ៩ | ខ្ញុំតែងតែវាយតម្លៃការបង្រៀនរបស់ខ្ញុំបន្ទាប់ពីខ្ញុំបានបង្រៀនចប់។ | ☐ |
| ១០ | ខ្ញុំព្យាយាមកែលម្អចំណុចខ្សោយនៅក្នុងការបង្រៀនរបស់ខ្ញុំប្រសិនបើមាន។ | ☐ |

| | | |
|---|---|---|
| ១១ | ខ្ញុំតែងតែវាយតម្លៃការសិក្សារបស់សិស្ស ដើម្បីកំណត់ថាតើសិស្សបានសម្រេចតាមវត្ថុបំណងដែលកំណត់ទុកដែរឬទេ។ | ☐ |
| ១២ | ខ្ញុំចំណាយពេលក្រៅពីម៉ោងបង្រៀន ដើម្បីពន្យល់ដល់សិស្សណាដែលនៅឆ្ងល់ មិនទាន់យល់ពីមេរៀនឬកិច្ចការខ្ញុំដាក់ឱ្យធ្វើ។ | ☐ |
| ១៣ | ខ្ញុំបានជំរុញសិស្សឱ្យចែករំលែកបទពិសោធន៍ឬចំណេះដឹងមានស្រាប់ដល់មិត្តភក្ដិផងដែរ។ | ☐ |
| ១៤ | នៅក្នុងការបង្រៀនរបស់ខ្ញុំ ខ្ញុំមានបញ្ចូលការងារជាក្រុម ការពិភាក្សា ការឡើងធ្វើបទបង្ហាញ ការវិភាគករណីសិក្សា ការសម្ដែងតួ និងការធ្វើគម្រោងជាដើម ។ | ☐ |
| គ.ការលើកទឹកចិត្តសិស្ស | | |
| ១៥ | ខ្ញុំតែងតែសរសើរដល់សិស្សដែលបានចូលរួមមតិយោបល់ឬធ្វើបទបង្ហាញ។ | ☐ |
| ១៦ | ពេលសិស្សឡើងពន្យល់ ឬបញ្ចេញគំនិត យោបល់មិនត្រឹមត្រូវ ខ្ញុំមិនបន្ទោសទេ តែខ្ញុំលើកទឹកចិត្ត ឬពោលសរសើរសេចក្ដីក្លាហានរបស់សិស្សនោះ។ | ☐ |
| ១៧ | ខ្ញុំតែងតែស្ដាប់ចម្លើយរបស់សិស្សដោយការយកចិត្តទុកដាក់។ | ☐ |
| ១៨ | ខ្ញុំលើកទឹកចិត្តសិស្សឱ្យសួរសំណួរនៅពេលពួកគេមិនយល់ ។ | ☐ |
| ១៩ | ខ្ញុំតែងតែលើកទឹកចិត្តសិស្សកុំឱ្យខ្លាចគ្រូបង្រៀន ព្រោះគ្រូគឺជាអ្នកចាំជួយឱ្យពួកគេរៀនសូត្រចេះដឹង។ | ☐ |
| ឃ.ការចែករំលែកវិធីបង្រៀនដល់សមាជិកក្រុមបច្ចេកទេស | | |
| ២០ | ខ្ញុំតែងតែចំណាយពេលប្រជុំជាទៀងទាត់ជាមួយគ្រូផ្សេងៗ ដើម្បីចែករំលែកវិធីបង្រៀនដល់សមាជិកក្រុមបច្ចេកទេស។ | ☐ |
| ២១ | ខ្ញុំតែងតែទទួលយកមតិយោបល់ពីគ្រូដទៃៗទៀត។ | ☐ |
| ២២ | ដើម្បីកែលម្អការបង្រៀនរបស់ខ្ញុំឱ្យកាន់តែល្អ ខ្ញុំបានស្នើសុំឱ្យគ្រូដទៃចូលមកសង្កេតនៅក្នុងថ្នាក់បង្រៀនរបស់ខ្ញុំ ដើម្បីវាយតម្លៃពីការបង្រៀនរបស់ខ្ញុំ។ | ☐ |

**ខ. ការវាយតម្លៃការសិក្សារបស់សិស្ស**

ការវាយតម្លៃការសិក្សារបស់សិស្សអាចធ្វើតាមវិធីច្រើនបែបដូចជា ការធ្វើតេស្ត ការសង្កេតការចូលរួមសកម្មភាពក្នុងថ្នាក់ (ការចែករំលែកចំណេះដឹង ការពិភាក្សា ការសួរ

សំណួរជាដើម) ការសរសេរតែងសេចក្តី ការសម្តែងតួ ការប្រឡង ការធ្វើបទបង្ហាញ និងការអនុវត្តធ្វើគម្រោងអ្វីមួយជាដើម។ មុនពេលធ្វើកិច្ចតែងការបង្រៀន គ្រូគួរគិតថា តើគួរវាយតម្លៃការសិក្សារបស់សិស្សដោយវិធីណា និងតើសកម្មភាពរៀនសូត្រណាគួរបានពិន្ទុប៉ុន្មាន។ ដូចនៅក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្សក្នុងឯកសារនេះ គ្រូអាចវាយតម្លៃទៅលើវត្តមានរបស់សិស្ស សកម្មភាពនៅក្នុងថ្នាក់ ការសរសេរ ការឡើងធ្វើបទបង្ហាញ ការធ្វើលំហាត់ ការឆ្លើយសំណួរ ការប្រឡងប្រចាំខែ ការប្រឡងឆមាសលើកទី១ និងការប្រឡងឆមាសលើកទី២។

| ល.រ | ការវាយតម្លៃការសិក្សារបស់សិស្ស | ពិន្ទុនិងភាគរយ |
|---|---|---|
| ១ | វត្តមាន | |
| ២ | សកម្មភាពនៅក្នុងថ្នាក់(ការពិភាក្សា ការជជែកវែកញែក ការងារដៃគូ ការងារជាក្រុមជាដើម) | |
| ៣ | ការសរសេរ(តែងសេចក្តី វិភាគករណីសិក្សា ឬការស្រាវជ្រាវ) | |
| ៤ | ការឡើងធ្វើបទបង្ហាញ | |
| ៥ | សំណួរ (ការឆ្លើយសំណួរ ឬកិច្ចការផ្ទះ) | |
| ៦ | ការប្រឡងប្រចាំខែ | |
| ៧ | ការប្រឡងឆមាស | |
| | | ពិន្ទុសរុប =..............= 100% |

ទោះបីយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពជាក់ស្តែង ការវាយតម្លៃដូចតារាងខាងលើអាចជាបន្ទុកធ្ងន់ដល់គ្រូបង្រៀន ជាពិសេសនៅពេលគ្រូត្រូវបង្រៀនច្រើនថ្នាក់ ហើយសិស្សមានចំនួនពី៤០ទៅ៥០នាក់ក្នុងមួយថ្នាក់។ ដើម្បីកាត់បន្ថយបន្ទុក គ្រូគួរដាក់ពិន្ទុតែលើវត្តមាន លំហាត់ និងការប្រឡងប្រចាំខែ និងប្រឡងឆមាស ។ ក្នុងការដាក់ពិន្ទុនេះទៀតសោត គ្រូគួរគិតថា តើពិន្ទុប៉ុន្មានគួរជាពិន្ទុដែលបង្ហាញថាសិស្សមានសមត្ថភាពខ្ពស់ មិនបាច់ចាំបង្រៀនឡើងវិញ ឬតាមដានញឹកញាប់ តើពិន្ទុប៉ុន្មានគួរជាពិន្ទុត្រូវតាមដានញឹកញាប់ និងពិន្ទុប៉ុន្មានត្រូវហៅសិស្សមកបង្រៀនឡើងវិញ។ឧទាហរណ៍ ពិន្ទុលើសពី៨៥បានន័យថាសិស្សនោះមានសមត្ថភាពខ្ពស់។ សិស្សដែលបានពិន្ទុចន្លោះ៦៥ទៅ៨៥ត្រូវការតាមដានបន្ថែម ចំណែកឯសិស្សដែលបានពិន្ទុទាបជាង៦៥ ត្រូវហៅមករៀនសាឡើងវិញ។

ចំពោះសកម្មភាពសិស្សនៅក្នុងថ្នាក់ គ្រូគួរតាមដាននិងផ្តល់យោបល់ត្រឡប់ទៅសិស្សវិញដើម្បីកែលម្អបណ្តើរៗតាំងពីការចាប់ផ្តើមរៀននៅថ្ងៃដំបូង រហូតដល់ថ្ងៃរៀនចុងក្រោយ។ការតាមដាននិងការវាយតម្លៃសកម្មភាពសិស្សក្នុងថ្នាក់ ការស្រាវជ្រាវ ការសរសេរមេរៀនសង្ខេប និងការធ្វើបទបង្ហាញមានដូចតារាងគំរូខាងក្រោម ៖

| **សកម្មភាពចូលរួមរបស់សិស្សនៅក្នុងថ្នាក់ (១=មិនដែលចូលរួម ២=ចូលរួមតិចតួច ៣=ចូលរួមខ្លះៗ ៤=ចូលរួមច្រើនគួរសម្ប ៥=ចូលរួមយ៉ាងសកម្ម)** | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ល.រ | ឈ្មោះសិស្ស | មេរៀនទី១ | | | | | មេរៀនទី២ | | | | | មេរៀនទី៣ | | | | |
| | | ១ | ២ | ៣ | ៤ | ៥ | ១ | ២ | ៣ | ៤ | ៥ | ១ | ២ | ៣ | ៤ | ៥ |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

| **ការវាយតម្លៃលើសមត្ថភាពរបស់សិស្សក្នុងការសរសេរកិច្ចការស្រាវជ្រាវ (១=ខ្សោយ ត្រូវរៀនសរសេរឡើងវិញ ២=មធ្យម នៅមានកំហុសច្រើនដែលត្រូវកែប្រែ ៣=បង្គួរ មានកំហុសខ្លះៗតែអាចទទួលយកបាន ៤=ល្អបង្គួរ មានកំហុសបន្តិចបន្តួច ៥=ល្អណាស់)** | | | | | |
|---|---|---|---|---|---|
| លក្ខខណ្ឌវាយតម្លៃ | ១ | ២ | ៣ | ៤ | ៥ |
| **១. សេចក្តីផ្តើម** | | | | | |
| តើសិស្សបានសរសេរលំនាំបញ្ហាមុននឹងរៀបរាប់អំពីគោលបំណងនៃការសរសេរដែរឬទេ(អាចជាបញ្ហាឬព្រឹត្តិការណ៍សំខាន់អ្វីមួយដែលនាំឱ្យសិស្សចង់សរសេររៀបរាប់ឬបកស្រាយ)? | | | | | |
| តើសិស្សបានពន្យល់អំពីគោលបំណងច្បាស់លាស់ដែរឬទេ? | | | | | |
| តើគោលបំណងនោះឆ្លុះបញ្ចាំងនូវអ្វីដែលគ្រូបានដាក់ឱ្យសិស្សធ្វើដែរឬទេ? | | | | | |

| | | | | | |
|---|---|---|---|---|---|
| តើសិស្សបានពន្យល់អំពីវិធីសាស្ត្រដែលបានប្រមូលព័ត៌មានទាក់ទងនឹងប្រធានបទនោះដែរឬទេ? | | | | | |
| **២. តួសេចក្តី** | | | | | |
| តើព័ត៌មានដែលបានយកមកប្រើនោះមានទាក់ទងនឹងប្រធានបទដែរឬទេ? | | | | | |
| តើមានការផ្តល់ឧទាហរណ៍ឬភស្តុតាងអ្វីជាអំណះអំណាងដែរឬទេ? | | | | | |
| តើការសរសេរនោះមានរៀបចំតាមលំដាប់លំដោយប្រទាក់ក្រឡាគ្នាដែរឬទេ? | | | | | |
| តើបានប្រើឃ្លាភ្ជាប់សេចក្តី (ចំណុចទីមួយ.........ចំណុចទីពីរ......... ឬជាដំបូង.........បន្ទាប់មកទៀត.........)ដែរឬទេ? | | | | | |
| **៣. សេចក្តីសន្និដ្ឋាន** | | | | | |
| តើសិស្សបានសរសេរសង្ខេបឡើងវិញនៅក្នុងសេចក្តីសន្និដ្ឋានដែរឬទេ? | | | | | |
| ប្រសិនបើបានសរសេរសង្ខេប តើការសរសេរសង្ខេបនោះបានឆ្លុះបញ្ចាំងពីគោលបំណងនៃការសរសេរនោះដែរឬទេ? | | | | | |
| **៤. ការប្រើប្រាស់ឯកសារយោង** | | | | | |
| តើមានបញ្ជីឯកសារយោងដែរឬទេ? | | | | | |
| តើសិស្សប្រើឯកសារយោងទាំងនោះបានត្រឹមត្រូវដែរឬទេ? | | | | | |
| តើឯកសារយោងនោះទាក់ទងនឹងប្រធានបទដែរឬទេ? | | | | | |
| តើឯកសារយោងនោះជាឯកសារថ្មីដែរឬទេ? | | | | | |

**៥. យោបល់ក្នុងការកែលម្អរបស់គ្រូ**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

.. .......................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................។

| ការវាយតម្លៃលើសមត្ថភាពរបស់សិស្សក្នុងការសង្ខេបមេរៀនឬអត្ថបទ<br>(១=ខ្សោយ ត្រូវរៀនសរសេរឡើងវិញ ២=មធ្យម នៅមានកំហុសច្រើនដែលត្រូវកែប្រែ ៣=បង្គួរ មានកំហុសខ្លះៗតែអាចទទួលយកបាន ៤=ល្អបង្គួរ មានកំហុសបន្តិចបន្តួច ៥=ល្អណាស់) | | | | | |
|---|---|---|---|---|---|
| **លក្ខខណ្ឌវាយតម្លៃ** | ១ | ២ | ៣ | ៤ | ៥ |
| **១.គំនិតឬចំណុចសំខាន់ៗក្នុងការរៀបចំរចនាសម្ព័ន្ធ** | | | | | |
| តើការសង្ខេបនោះបានសរសេរបញ្ចូលគំនិតឬចំណុចសំខាន់ទាំងអស់ដែលមាននៅក្នុងមេរៀនឬអត្ថបទដែរឬទេ? | | | | | |
| តើមានការបញ្ចូលឧទាហរណ៍ឬភស្តុតាងជាអំណះអំណាងនៅក្នុងមេរៀនឬអត្ថបទដើមដែរឬទេ? | | | | | |
| តើការសង្ខេបនោះបានរៀបចំគំនិតឬចំណុចសំខាន់ៗតាមលំដាប់លំដោយដែរឬទេ? | | | | | |
| តើមានការប្រើឃ្លាភ្ជាប់សេចក្តី (ចំណុចទីមួយ.........ចំណុចទីពីរ.........ឬជាដំបូង......... បន្ទាប់មកទៀត.........)ដែរឬទេ? | | | | | |
| តើការសង្ខេបនោះមានថែមថយគំនិតឬចំណុចដែលមិនមាននៅក្នុងមេរៀនឬអត្ថបទដើមដែរឬទេ? | | | | | |
| តើអត្ថន័យនៃការសង្ខេបនោះ ដូចគ្នាទៅនឹងមេរៀន ឬអត្ថបទដើមដែរឬទេ? | | | | | |
| តើសិស្សបានប្រើពាក្យពេចន៍ខ្លួនឯងមកសរសេរសង្ខេប( មិនលួចចម្លងពីក្នុងមេរៀនឬអត្ថបទដើម)ដែរឬទេ? | | | | | |

**២.យោបល់របស់គ្រូក្នុងការកែលម្អ**

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

...................................................................................................................................................

....................................................................................................................................................

.. ..................................................................................................................................................។

| ការវាយតម្លៃលើសមត្ថភាពសិស្សក្នុងការសរសេរអត្ថបទឆ្លុះបញ្ចាំង<br>(១=ខ្សោយ ត្រូវរៀនសរសេរឡើងវិញ ២=មធ្យម នៅមានកំហុសច្រើនដែលត្រូវកែប្រែ ៣=បង្គួរ មានកំហុសខ្លះៗតែអាចទទួលយកបាន ៤=ល្អបង្គួរ មានកំហុសបន្តិចបន្តួច ៥=ល្អណាស់) | | | | | |
|---|---|---|---|---|---|
| **លក្ខខណ្ឌវាយតម្លៃ** | ១ | ២ | ៣ | ៤ | ៥ |
| **១. ការយល់ដឹងមេរៀន ឬអត្ថបទ** | | | | | |
| តើការសរសេរនោះបានឆ្លុះបញ្ចាំងឱ្យឃើញការយល់ដឹងរបស់សិស្សទៅលើមេរៀនឬអត្ថបទដែលសិស្សបានអានដែរឬទេ? | | | | | |
| តើការសរសេរនោះបានរៀបរាប់ពីបញ្ញត្តិសំខាន់ៗនៅក្នុងមេរៀនឬអត្ថបទដែរឬទេ? | | | | | |
| **២. ទំនាក់ទំនងមេរៀន ឬអត្ថបទទៅនឹងចំណេះដឹង ឬបទពិសោធន៍របស់សិស្ស** | | | | | |
| តើការសរសេរនោះបានរៀបរាប់ពីគំនិត/បញ្ញត្តិសំខាន់ៗនៅក្នុងមេរៀនឬអត្ថបទ បានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអានដែរឬទេ? | | | | | |
| តើការសរសេរនោះ បានរៀបរាប់ពីទំនាក់ទំនងឬភាពផ្ទុយគ្នារវាងគំនិត/បញ្ញត្តិសំខាន់ៗ នៅក្នុងមេរៀនឬអត្ថបទទៅនឹងចំណេះដឹងឬបទពិសោធន៍របស់សិស្សដែរឬទេ? | | | | | |
| តើការសរសេរនោះបានបង្ហាញពីការឆ្លុះបញ្ចាំងរបស់សិស្សថាហេតុអ្វីបានជាគំនិត/បញ្ញត្តិសំខាន់ទាំងនោះទាក់ទាញចំណាប់អារម្មណ៍របស់ខ្លួនដែរឬទេ? | | | | | |
| តើការសរសេរនោះ បានពន្យល់ថាគំនិត/បញ្ញត្តិសំខាន់ៗទាំងនោះបានជួយសិស្សឱ្យយល់ថាចំណេះដឹងឬបទពិសោធន៍ដែលខ្លួនមានពីមុនមកត្រឹមត្រូវដែរឬទេ? | | | | | |
| តើការសរសេរនោះ បានពន្យល់ថាគំនិត/បញ្ញត្តិសំខាន់ៗជាចំណេះដឹង ឬបទពិសោធន៍ថ្មីបានជួយសិស្សឱ្យផ្លាស់ប្តូរការគិត/ ចំណេះដឹង/បទពិសោធន៍ដែលមានពីមុនដែរឬទេ? | | | | | |
| តើការសរសេរនោះ បានរៀបរាប់ថាសិស្សយល់ស្រប ឬមិនយល់ស្របទៅនឹងគំនិត/បញ្ញត្តិសំខាន់ទាំងនោះ និងពន្យល់ប្រាប់អំពីមូលហេតុយល់ស្របឬមិនយល់ស្របដែរឬទេ? | | | | | |

| |
|---|
| **៣. យោបល់របស់គ្រូក្នុងការកែលម្អ** |
| ........................................................................................................................................ |
| ........................................................................................................................................ |
| ........................................................................................................................................ |
| ....................................................................................................................................។ |

| **ការវាយតម្លៃលើសមត្ថភាពរបស់សិស្សក្នុងការធ្វើបទបង្ហាញ** (១=ខ្សោយ ត្រូវរៀនធ្វើឡើងវិញ ២=មធ្យម នៅមានកំហុសច្រើនដែលត្រូវកែប្រែ ៣=បង្គួរ មានកំហុសខ្លះៗតែអាចទទួលយកបាន ៤=ល្អបង្គួរ មានកំហុសបន្តិចបន្តួច ៥=ល្អណាស់) | | | | | |
|---|---|---|---|---|---|
| **លក្ខខណ្ឌវាយតម្លៃ** | ១ | ២ | ៣ | ៤ | ៥ |
| **១. សេចក្តីផ្តើម** | | | | | |
| តើសិស្សបានប្រើវិធីសាស្រ្តទាក់ទាញចំណាប់អារម្មណ៍អ្នកស្តាប់ដែរឬទេ(សួរសំណួរ និទានរឿង ពណ៌នាអំពីព្រឹត្តិការណ៍ដ៏គួរឱ្យចាប់អារម្មណ៍)? | | | | | |
| តើបានពន្យល់អំពីវត្ថុបំណងនៃបទបង្ហាញបានច្បាស់លាស់ដែរឬទេ? | | | | | |
| តើបានរៀបរាប់ប្រាប់អំពីចំណុចអ្វីខ្លះដែលត្រូវនិយាយនៅក្នុងការធ្វើបទបង្ហាញនោះដែរឬទេ? | | | | | |
| **២. តួសេចក្តី** | | | | | |
| តើព័ត៌មានដែលបានយកមកប្រើទាក់ទងនឹងប្រធានបទដែរឬទេ? | | | | | |
| តើមានការផ្តល់ឧទាហរណ៍ឬភស្តុតាងអ្វីជាអំណះអំណាងដែរឬទេ? | | | | | |
| តើការធ្វើបទបង្ហាញនោះ មានរៀបចំតាមលំដាប់លំដោយប្រទាក់ក្រឡាគ្នាដែរឬទេ? | | | | | |
| តើការធ្វើបទបង្ហាញនោះងាយស្រួលចាប់បានដែរឬទេ? | | | | | |
| **៣. សេចក្តីបញ្ចប់** | | | | | |
| តើមានការសង្ខេបឡើងវិញមុននឹងបញ្ចប់ការធ្វើបទបង្ហាញនោះដែរឬទេ? | | | | | |
| ប្រសិនបើមានការសង្ខេប តើការសង្ខេបនោះបានឆ្លុះបញ្ចាំងថាការធ្វើបទបង្ហាញនោះ បានបង្ហាញដូចអ្វីដែលមាននៅក្នុងវត្ថុបំណងនៃការ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ធ្វើបទបង្ហាញដែរឬទេ? | | | | | |
| **៤. បំណិនក្នុងការធ្វើបទបង្ហាញ** | | | | | |
| **ក.ភាពច្បាស់លាស់** | | | | | |
| តើការធ្វើបទបង្ហាញនោះ បានពន្យល់ពាក្យបច្ចេកទេសដែរឬទេ? | | | | | |
| តើការធ្វើបទបង្ហាញនោះបានចៀសវាងប្រើពាក្យសម្ដីមិនជាក់លាក់ ឬមានលក្ខណៈអរូបីដែរឬទេ | | | | | |
| **ខ.ការប្រើឧទាហរណ៍** | | | | | |
| តើបទបង្ហាញនោះបានប្រើឧទាហរណ៍គ្រប់គ្រាន់យកមកជាអំណះអំណាងដែរឬទេ? | | | | | |
| តើឧទាហរណ៍ដែលបានប្រើមានជាប់ពាក់ព័ន្ធនឹងវត្ថុបំណងនៃការធ្វើបទបង្ហាញដែរឬទេ? | | | | | |
| **គ.ការសង្កត់ធ្ងន់លើកន្លែងឬន័យសំខាន់ៗ** | | | | | |
| តើការធ្វើបទបង្ហាញនោះបានប្រើវិធីសាស្ត្រក្នុងការទាញចំណាប់អារម្មណ៍អ្នកស្ដាប់ឱ្យចាប់អារម្មណ៍លើចំណុចសំខាន់ៗដែរឬទេ? | | | | | |
| ប្រសិនបើប្រើ តើប្រើវិធីសាស្ត្រអ្វី?<br>• ការប្រើប្រាស់លេខរៀង(ចំណុចទី១គឺ...ចំណុចទី២គឺ....)<br>• ការប្រើពាក្យសង្កត់ន័យ (ចំណុចសំខាន់គឺ...)<br>• ការនិយាយសាឡើងវិញ ដើម្បីសង្កត់ន័យថាវាមានសារៈសំខាន់<br>• ការសង្ខេប<br>• ការប្រើឧបករណ៍ជំនួយមានរូបភាព ការធ្វើសកម្មភាពបង្ហាញជាដើម<br>• ការប្រើប្រាស់កាយវិការ។ | | | | | |
| **ឃ.ការពិនិត្យមើលថាអ្នកស្ដាប់យល់ឬមិនយល់** | | | | | |
| តើការធ្វើបទបង្ហាញនោះមានការសួរបញ្ជាក់ដើម្បីឱ្យប្រាកដថាអ្នកស្ដាប់យល់ឬតាមទាន់ការធ្វើបទបង្ហាញនោះដែរឬទេ? | | | | | |
| តើអ្នកធ្វើបទបង្ហាញ មានសង្កេតមើលកាយវិការរបស់អ្នកស្ដាប់ថាតើគេយល់ឬមិនយល់ដែរឬទេ? | | | | | |

| ង.ការឆ្លើយសំណួរ | | | | | |
|---|---|---|---|---|---|
| តើការធ្វើបទបង្ហាញនេះបានជំរុញឱ្យអ្នកស្តាប់សួរសំណួរដែរឬទេ? | | | | | |
| តើមានពេលគ្រប់គ្រាន់ក្នុងការឆ្លើយសំណួរដែរឬទេ? | | | | | |
| តើចម្លើយនោះបានឆ្លើយតបទៅនឹងសំណួរដែលអ្នកស្តាប់បានសួរដែរឬទេ? | | | | | |
| តើចម្លើយនោះច្បាស់លាស់និងឆ្លើយត្រង់ៗទៅកាន់អ្នកស្តាប់ដែរឬទេ? | | | | | |
| **៥. កាយវិការក្នុងពេលធ្វើបទបង្ហាញ** | | | | | |
| តើអ្នកធ្វើបទបង្ហាញយល់ច្បាស់អំពីប្រធានបទដែលខ្លួនបង្ហាញដែរឬទេ? | | | | | |
| តើអ្នកធ្វើបទបង្ហាញមានទំនុកចិត្តលើខ្លួនឯងដែរឬទេ? | | | | | |
| តើអ្នកធ្វើបទបង្ហាញនិយាយច្បាស់ដែរឬទេ? | | | | | |
| តើអ្នកធ្វើបទបង្ហាញបានសម្លឹងមើលអ្នកស្តាប់នៅគ្រប់ជ្រុងដែរឬទេ? | | | | | |
| តើការធ្វើបទបង្ហាញនោះមានល្បឿនសមរម្យ(មិនលឿនពេក មិនយឺតពេក)ដែរឬទេ? | | | | | |
| តើការធ្វើបទបង្ហាញនោះចប់ទៅតាមពេលវេលាដែលបានកំណត់ដែរឬទេ? | | | | | |

**៦. យោបល់របស់គ្រូក្នុងការកែលម្អ**

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................។

## ២.៥ វិធីបង្រៀន

### ១.វិធីបង្រៀន ៣-២-១

**លំនាំណែនាំ**

វិធីបង្រៀន ៣-២-១ ជាវិធីមួយដែលជួយដល់សិស្សឱ្យចេះស្វែងរកព័ត៌មានសំខាន់ៗនៅក្នុងអត្ថបទ មេរៀនក៏ដូចជាការបង្កើតសំណួរទាក់ទងទៅនឹងអ្វីដែលពួកគេមិនយល់ ឬក៏ត្រូវការបកស្រាយឬផ្តល់ឧទាហរណ៍បន្ថែមទៀត។ នៅក្នុងវិធីបង្រៀននេះសិស្សត្រូវព្យាយាមរកចំណុចសំខាន់ៗចំនួន៣ទាក់ទងទៅនឹងមេរៀនដែលពួកគេបានអាន។ បន្ទាប់មកបង្កើតសំណួរចំនួន២ទាក់ទងនឹងមេរៀនដែលគេនៅមានភាពស្រពេចស្រពិលនិងចង់ឱ្យមានការពន្យល់បន្ថែម។ ជាចុងក្រោយ សិស្សត្រូវពិនិត្យរកមើលចំណុចមួយដែលពួកគេចាប់អារម្មណ៍ឬគិតថាមានប្រយោជន៍ទាក់ទងទៅនឹងការអានមេរៀននោះ។

**វត្ថុបំណង**

- ជួយសិស្សឱ្យមានការផ្តោតទៅលើចំណុចឬព័ត៌មានសំខាន់ៗនៅក្នុងអត្ថបទមេរៀនជាជាងគ្រាន់តែអានឱ្យយល់
- ផ្តល់ឱកាសឱ្យសិស្សបង្កើតសំណួរនិងហ៊ានសួរសំណួរពេលពួកគេមិនយល់
- បណ្តុះសិស្សឱ្យចេះមានចំណាប់អារម្មណ៍និងដឹងពីអត្ថប្រយោជន៍ដែលពួកគេទទួលបានបន្ទាប់ពីអានអត្ថបទមេរៀន។
- បង្កើតបរិយាកាសសិក្សាបែបសហការរវាងសិស្សនិងសិស្ស សិស្សនិងគ្រូ។

**សម្ភារៈ**

តារាង ៣-២-១

**រយៈពេល**

២០នាទីទៅ៣០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូឱ្យសិស្សអានអត្ថបទមេរៀនដោយតម្រូវឱ្យសិស្សរកគំនិតសំខាន់ៗចំនួន៣ បង្កើតសំណួរទាក់ទងនឹងអ្វីដែលគេមិនយល់ឬចង់ឱ្យគ្រូពន្យល់បន្ថែមចំនួន២ និងចំណុចចំនួន១ដែលពួកគេចាប់អារម្មណ៍ក្នុងអត្ថបទមេរៀន។

**ជំហានទី២**

គ្រូចែកក្រដាសតារាង៣-២-១ទៅឱ្យសិស្សទាំងអស់នៅក្នុងថ្នាក់ឬគ្រូគូសចម្លងតារាងនោះដាក់លើក្ដារខៀន ដើម្បីឱ្យសិស្សចម្លងតាម រួចផ្ដល់ពេលឱ្យសិស្សអានអត្ថបទមេរៀន និងបំពេញព័ត៌មានចូលទៅក្នុងតារាង៣-២-១។

**តារាង៣-២-១**

| | |
|---|---|
| ចំណុចសំខាន់ៗ៣ | ១. |
| | ២. |
| | ៣. |
| សំណួរ២ | ១. |
| | ២. |
| ចំណុចចាប់អារម្មណ៍ ១ | ១. |

**ជំហានទី៣**

បន្ទាប់ពីសិស្សបានបំពេញកិច្ចការរួចហើយ គ្រូឱ្យសិស្សមួយចំនួនចែករំលែកព័ត៌មានដែលពួកគេបានសរសេរបំពេញនៅលើតារាង៣-២-១របស់ពួកគេទៅមិត្តភក្ដិ។

**ជំហានទី៤**

គ្រូឆ្លើយសំណួរដែលសិស្សមានក៏បានឬគ្រូស្នើឱ្យសិស្សនៅក្នុងថ្នាក់ស្ម័គ្រចិត្តឆ្លើយក៏បាន។

## ២.វិធីបង្រៀន ឱ្យមួយ បានមួយ (Give one Get one)

**លំណែនាំ**

វិធីបង្រៀនឱ្យមួយ បានមួយ មិនត្រឹមតែជួយសិស្សឱ្យមានសកម្មភាពនៅក្នុងថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យពួកគេចេះនឹកគិតដល់អ្វីដែលគេបានរៀនឬចេះពីមុនមកថែមទៀត។ នៅក្នុងការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល ការឱ្យតម្លៃទៅលើចំណេះដឹងឬបទពិសោធន៍ដែលសិស្សមានពីមុនៗមក មានសារៈសំខាន់ណាស់ក្នុងការលើកទឹកចិត្តសិស្សឱ្យយល់ថាខ្លួនក៏មានចំណេះដឹងខ្លះៗ និងខំប្រឹងប្រែងរៀនសូត្របន្តទៀត។វិធីនេះមិនត្រឹមតែបង្កើតបរិយាកាសស្និទ្ធស្នាលរវាងសិស្សនិងសិស្សទេប៉ុន្តែវិធីនេះបានឱ្យពួកគេចេះជួយគ្នាបង្កើតនិងចែកចាយគំនិតបានលឿនថែមទៀតផង។

**វត្ថុបំណង**

- បង្កើតបរិយាកាសរៀនផង សប្បាយផង
- ជួយពង្រឹងទំនាក់ទំនងនិងការចែករំលែកគំនិតរវាងសិស្សនិងសិស្ស
- ជួយសិស្សឱ្យយល់ដឹងអំពីតម្លៃនៃចំណេះដឹងឬបទពិសោធន៍ដែលខ្លួនមានពីមុនៗមក។

**សម្ភារៈ**

តារាងឱ្យមួយ បានមួយ( Give one get one)។

**រយៈពេល**

១៥នាទីទៅ២០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូដាក់សំណួរមួយឱ្យសិស្សរកចម្លើយឱ្យបានច្រើនតាមដែលពួកគេអាចធ្វើបាន។

**ជំហានទី២**

- គ្រូឱ្យសិស្សរកចម្លើយឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន និងបំពេញចូលក្នុងខ្ទង់(កូឡោន)«បញ្ជីចម្លើយរបស់ខ្លួន»រួចបង់លេខតាមលំដាប់លំដោយ។
- គ្រូចែកក្រដាសតារាង «ឱ្យមួយបានមួយ»ឬសរសេរចម្លងដាក់លើក្ដារខៀនរួចឱ្យសិស្សចម្លងដាក់ក្នុងសៀវភៅរៀងៗខ្លួន។

| **បញ្ជីចម្លើយរបស់ខ្លួន** | **បញ្ជីចម្លើយបានមកពីដៃគូ** | **ឈ្មោះដៃគូដែលបានឱ្យចម្លើយថ្មី** |
|---|---|---|
| ១. | | |
| ២. | | |
| ៣. | | |
| ៤. | | |
| ៥. | | |

**ជំហានទី៣**

គ្រូឱ្យសិស្សទាំងអស់ចេញពីកន្លែងអង្គុយរបស់ខ្លួននិងជ្រើសរើសដៃគូដើម្បីបំពេញចម្លើយក្នុងតារាង។

**ជំហានទី៤**

គ្រូណែនាំសិស្សម្នាក់ឱ្យអានចម្លើយទី១ នៅក្នុងក្រដាសបញ្ជីចម្លើយរបស់ខ្លួនប្រសិនបើដៃគូមានចម្លើយដូចគ្នា សិស្សនោះត្រូវអានចម្លើយទី២ឬទី៣រហូតទាល់តែ

សិស្សជាដៃគូនោះបានទទួលចម្លើយដែលមិនមាននៅក្នុងក្រដាសបញ្ជីរបស់ខ្លួន។ ពេលបានទទួលចម្លើយពីដៃគូ សិស្សនោះត្រូវសរសេរចម្លើយនោះទៅក្នុងខ្ទង់(កូឡោន) «បញ្ជីចម្លើយបានមកពីដៃគូនានា»រួចដាក់ឈ្មោះដៃគូដែលផ្តល់ចម្លើយឱ្យ បន្ទាប់មកសិស្សដៃគូម្ខាងទៀតត្រូវធ្វើដូចគ្នាវិញដែរ ដោយអានចម្លើយទី១ឬទី២ឬទី៣ រហូតទាល់តែដៃគូរបស់ខ្លួនបានទទួលចម្លើយមួយដែលមិនមាននៅក្នុងបញ្ជីរបស់ខ្លួន។ បន្ទាប់ពីបានចម្លើយម្នាក់មួយៗហើយ សិស្សត្រូវបំបែកគ្នាទៅរកដៃគូថ្មីទៀតនិងធ្វើដូចលើកមុនដែរ។ ប៉ុន្តែប្រសិនបើអ្នកទាំងពីរមានចម្លើយដូចគ្នាទាំងអស់ នោះពួកគេត្រូវបំបែកគ្នាទៅរកដៃគូផ្សេងទៀតដើម្បីរកចម្លើយថ្មី។

**ជំហានទី៥**

គ្រូហៅសិស្សណាម្នាក់អានបញ្ជីចម្លើយរបស់ខ្លួន រួចហើយកត់ត្រានៅលើក្តារខៀន និងឱ្យសិស្សដទៃទៀតជួយអានចម្លើយដែលពុំមាន។ បន្ទាប់មកគ្រូប្រមូលក្រដាសទាំងអស់មកទុកដើម្បីដាក់ពិន្ទុ។

**ជម្រើសវិធីបង្រៀនផ្សេងទៀត** (Variation)

គ្រូអាចដាក់សំណួរមួយ រួចឱ្យសិស្សរកចម្លើយពីរ បន្ទាប់មកគ្រូឱ្យពួកគេស្វែងរកដៃគូ និងសុំឱ្យដៃគូប្រាប់ចម្លើយមួយដល់ខ្លួន។ពួកគេចម្លងចម្លើយដែលទទួលបានចូលក្នុងបញ្ជីរៀងៗខ្លួន ប៉ុន្តែប្រសិនបើគេមានចម្លើយដូចគ្នា គេត្រូវនាំគ្នារកមើលចម្លើយមួយថ្មីទៀត។ បន្ទាប់មកគ្រូឱ្យពួកគេបង្កើតជាក្រុមមួយទៀត ដែលមានសមាជិក៥ទៅ៦នាក់ រួចហើយចែករំលែកចម្លើយគ្នាទៅវិញទៅមកនៅក្នុងក្រុមនោះ។ សមាជិកក្រុមម្នាក់ៗត្រូវកត់ចម្លើយចូលទៅក្នុងបញ្ជីចម្លើយរបស់ខ្លួននិងប្រគល់ជូនគ្រូ។

## ៣.វិធីបង្រៀន ខ្ញុំស្រាវជ្រាវ (I Search)

**លំណែនាំ**

នៅក្នុងការសិក្សា សិស្សមិនមែនត្រឹមតែហាត់រៀននៅក្នុងថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែសិស្សត្រូវរៀនសូត្រពីចំណេះដឹងផ្សេងៗនៅខាងក្រៅសាលារៀនទៀតផង ដើម្បីពង្រីកការយល់ដឹងរបស់ពួកគេ ក៏ដូចជាយកទ្រឹស្តីដែលពួកគេបានរៀនទៅអនុវត្តផងដែរ។ វិធីខ្ញុំស្រាវជ្រាវទាក់ទងនឹងការស្វែងរកព័ត៌មានផ្សេងៗទៀតក្រៅពីព័ត៌មានដែលបានមកពីសៀវភៅសិក្សាគោល។ វិធីនេះផ្តោតសំខាន់លើការសម្ភាសបុគ្គលដែលមានចំណេះដឹងឬព័ត៌មានដែលទាក់ទងនឹងការឆ្លល់របស់សិស្ស ។

**វត្ថុបំណង**

- បង្រៀនសិស្សឱ្យដឹងអំពីវិធីនិងដំណើរការនៃការប្រមូលព័ត៌មានឬសម្ភាសន៍
- ធ្វើការវិភាគថាតើអ្វីដែលពួកគេរៀនសូត្រនៅក្នុងថ្នាក់និងនៅខាងក្រៅថ្នាក់ខុសគ្នាដូចម្តេច
- ជួយសិស្សឱ្យហាត់រៀនសរសេររបាយការណ៍ស្រាវជ្រាវនិងធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ពួកគេ។

**សម្ភារៈ**

ក្រដាសសៀវភៅឬក្រដាសA4ដែលសិស្សអាចយកមកសរសេរសំណួរឬព័ត៌មានបាន។

**រយៈពេល**

៣០នាទីទៅ៤០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

ជាដំបូង គ្រូអាចរៀបរាប់ដោយសង្ខេបពីប្រធានបទឬបញ្ហាណាមួយឱ្យសិស្សស្តាប់ ហើយសាកសួរទៅសិស្សថាតើពួកគេចង់ដឹងពីប្រធានបទឬបញ្ហានោះជាក់លាក់ជាងនេះដែរឬទេ។ នៅក្នុងដំណាក់កាលនេះ គ្រូឱ្យសិស្សប្រាប់ពីអ្វីដែលគេចាប់អារម្មណ៍ចង់ដឹងបន្ថែមទៀត រួចហើយគ្រូសរសេរបញ្ហានោះនៅលើក្តារខៀន។ ឧទាហរណ៍ គ្រូនិយាយអំពីតម្លាភាពនៅក្នុងឃុំ។ សិស្សអាចចាប់អារម្មណ៍ចង់ដឹងបន្ថែមទៀតថា តើគេធ្វើដូចម្តេចទើបដឹងថាឃុំមានតម្លាភាព? តើមានច្បាប់អនុញ្ញាតឱ្យប្រជាជនទទួលព័ត៌មានអំពីតម្លាភាពដែរឬទេ? ហើយថា តើមានច្បាប់អ្វីដែលដាក់ទោសដល់ការកេងបន្លំថវិកាទ្រព្យសម្បត្តិនៅក្នុងឃុំជាដើម។

**ជំហានទី២**

គ្រូឱ្យសិស្សចាប់ដៃគូគ្នាពិភាក្សារកតែសំណួរណាទាក់ទងនឹងអ្វីដែលគេចាប់អារម្មណ៍ហើយឡើងអានសំណួរទាំងនោះ។ ប្រសិនបើសិស្សផ្សេងទៀតបានចោទសួរសំណួរទាំងនោះរួចហើយ សិស្សក្រុមដទៃទៀតមិនចាំបាច់ចោទសួរឡើងវិញទៀតទេ។ បន្ទាប់មក គ្រូសរសេរសំណួរទាំងនោះលើក្តារខៀន និងប្រាប់សិស្សថាអាចជ្រើសរើសហើយបង្កើតបញ្ជីសំណួរទាក់ទងទៅនឹងអ្វីដែលគេចាប់អារម្មណ៍។

**ជំហានទី៣**

បន្ទាប់ពីសិស្សមានបញ្ជីសំណួររួចហើយ គ្រូត្រូវសួរទៅសិស្សថាតើប្អូនចង់សួរអ្នកណាខ្លះ។

**ជំហានទី៤**

បន្ទាប់ពីបានដឹងច្បាស់ថាតើអ្នកណាខ្លះដែលសិស្សចង់សាកសួរ នៅទីកន្លែងណាខ្លះដែលពួកគេអាចទៅរកព័ត៌មានបាន គ្រូប្រាប់សិស្សឱ្យរៀបចំផែនការក្នុងការចុះប្រមូលព័ត៌មាន។ ផែនការទាំងនោះត្រូវមានពេលវេលា ទីកន្លែង បុគ្គលដែលត្រូវសម្ភាសអ្នកទទួលការសម្ភាសនិងសួរសំណួរជាដើម។

**ជំហានទី៥**

បន្ទាប់ពីបានសម្ភាស និងទទួលព័ត៌មានគ្រប់គ្រាន់ហើយ គ្រូឱ្យសិស្សសរសេររបាយការណ៍មួយដែលរួមបញ្ចូលទាំងវត្ថុបំណង ហេតុអ្វីបានគេចង់ដឹងរឿងឬបញ្ហានោះ តើពួកគេមានសំណួរអ្វីខ្លះសម្រាប់ចុះទៅសួរយកព័ត៌មាន តើគេចុះយកព័ត៌មានដោយរបៀបណា តើគេបានរៀនសូត្រអ្វីខ្លះ តើគេយល់យ៉ាងដូចម្តេចអំពីការចុះប្រមូលព័ត៌មាននោះនិងកត់ត្រាឯកសារយោង។

**ជម្រើសវិធីបង្រៀនផ្សេងទៀត**(Variation)

នៅក្នុងលក្ខខណ្ឌខ្លះ សិស្សមិនអាចរកអ្នកសម្ភាសបាន ដូច្នេះគ្រូគួរតែបង្វែរឱ្យសិស្សស្វែងរកចម្លើយនៅក្នុងបណ្ណាល័យ ឬតាមគេហទំព័រវិញ។ ប៉ុន្តែគ្រូគួរតែបង្រៀនសិស្សឱ្យចេះស្រាវជ្រាវនិងកត់ត្រាព័ត៌មាន ជាពិសេសកត់ត្រានៅលើប័ណ្ណតូចៗ ។

## ៤. វិធីបង្រៀន ជីក ស (Jigsaw)

**លំណែនាំ**

វិធីជីកស ជាវិធីមួយបង្កើតឱ្យមានការរៀនសូត្ររបស់សិស្សពីគ្នាទៅវិញទៅមក។ វិធីនេះបែងចែកសិស្សជាក្រុម ពោលគឺ ក្រុមដើមឬក្រុមគ្រួសារ និងក្រុមជំនាញ។ សមាជិកនៅក្នុងក្រុមមិនមែនត្រឹមតែធ្វើទំនាក់ទំនងជាមួយនឹងក្រុមរបស់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែត្រូវទៅចូលរួមជាមួយសមាជិកមកពីក្រុមផ្សេងទៀត ដើម្បីបង្កើតក្រុមជំនាញដែលសិក្សាស្វែងយល់ពីបញ្ហា រិះរកសំណួរនិងចម្លើយដើម្បីត្រឡប់យកមកជជីកសួរសមាជិកក្រុមដើមរបស់ខ្លួនដើម្បីរកចម្លើយវិញ។

**វត្ថុបំណង**

- ជួយសិស្សឱ្យរៀនពីការធ្វើទំនាក់ទំនងនិងសហការគ្នាជាមួយសមាជិកក្រុមផ្សេងទៀត
- បណ្តុះគំនិតចែករំលែកអ្វីដែលគេមានទៅដល់ក្រុមដើម នៅពេលដែលគេបានរៀនអ្វីថ្មីពីកន្លែងផ្សេងឬក្រុមផ្សេងទៀត
- ជួយសិស្សឱ្យចេះបង្កើតសំណួរ ចេះសួរ និងចេះធ្វើបទបង្ហាញ ។

**សម្ភារៈ**

ក្រដាសរ៉ាម(A4)ឬក្រដាសសៀវភៅសរសេរដែលសិស្សត្រូវសរសេរចម្លើយឆ្លើយទៅសំណួរដែលខ្លួនទទួលខុសត្រូវនិងសំណួរសម្រាប់ជជីកសួរដល់សមាជិកនៅក្នុងក្រុមដើម។

**រយៈពេល** : ៥០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូត្រូវមានសំណួរត្រៀមចំនួន៤ឬ៥ទាក់ទងនឹងមេរៀន។

**ជំហានទី២**

គ្រូបែងចែកសិស្សជា៤ ឬ៥ក្រុមទៅតាមសំណួរនោះ។ ក្រុមបង្កើតថ្មីនេះអាចដាក់ឈ្មោះអ្វីក៏បាន។ គ្រូឱ្យពួកគេដាក់លេខសម្គាល់ទៅសមាជិកម្នាក់ៗនៃក្រុមពី១ដល់៤(ឬ៥ទៅតាមសំណួរ)។

**ជំហានទី៣**

គ្រូឱ្យសមាជិកដែលមានលេខដូចគ្នានៅតាមក្រុមនីមួយៗមកបង្កើតក្រុមថ្មីមួយទៀត ដោយដាក់ឈ្មោះថាក្រុមជំនាញទី១ ទី២ ទី៣ ទី៤ ទៅតាមលេខសំណួរ។ គ្រូត្រូវចាត់ឱ្យក្រុមជំនាញនីមួយៗទទួលខុសត្រូវរកចម្លើយចំពោះសំណួរណាមួយនៃសំណួរទាំង៤ឬ៥ដែលគ្រូបានត្រៀមពីមុនមកហើយ។ ប៉ុន្តែពួកគេមិនអនុញ្ញាតឱ្យប្រាប់ចម្លើយទៅកាន់សមាជិកក្រុមដើមរបស់ពួកគេទេ ពួកគេត្រូវបង្កើតសំណួរប្រដេញមួយចំនួនដើម្បីសួរជជីកដល់សមាជិកក្រុមដើម។ ក្រុមនីមួយៗមានពេលពី១០ទៅ១៥នាទីក្នុងការពិភាក្សាគ្នារកចម្លើយនិងបង្កើតសំណួរ។

**ជំហានទី៤**

បន្ទាប់ពីពិភាក្សាហើយ ពួកគេម្នាក់ៗត្រូវត្រឡប់មកក្រុមដើមរៀងៗខ្លួនវិញ រួចមាន

ពេលពី៥ទៅ ១០នាទី ម្នាក់ក្នុងការសួរ ស្តាប់ចម្លើយ និងសួរដេញដោលរហូតសមាជិកទាំងអស់រកបានចម្លើយ ។

**ជំហានទី៥**

គ្រូឱ្យសិស្សជាសមាជិកក្រុមឡើងផ្តល់ចម្លើយនៅក្នុងថ្នាក់។ សមាជិកលេខ៤ ឆ្លើយសំណួរលេខ១ សមាជិកលេខ៣ ឆ្លើយសំណួរលេខ២ សមាជិកលេខ២ ឆ្លើយសំណួរលេខ៣ និងសមាជិកលេខ១ ឆ្លើយសំណួរលេខ៤។

## ៥.វិធីបង្រៀន ខ្ញុំដឹងអ្វី /ខ្ញុំចង់ដឹងអ្វី /ខ្ញុំបានរៀនអ្វី

( What I Know/What I Want to Know/What I Learned (KWL)

**លំណែនាំ**

ខ្ញុំដឹងអ្វី/ ខ្ញុំចង់ដឹងអ្វី/ ខ្ញុំបានរៀនអ្វី គឺជាវិធីបង្រៀនដែលជួយសិស្សឱ្យចេះចែករំលែកចំណេះដឹងដែលខ្លួនមាននិងចេះបង្កើតសំណួរមុននឹងរៀនមេរៀនថ្មី។ វិធីនេះក៏បានជួយសិស្សឱ្យសំយោគចំណេះដឹងដែលខ្លួនមាន និងចំណេះដឹងថ្មីដែលខ្លួនទើបបានរៀន ឬក៏បដិសេធចោលចំណេះដឹងមិនត្រឹមត្រូវដែលខ្លួនមានទាំងស្រុង។

**វត្ថុបំណង**

- លើកទឹកចិត្តសិស្សឱ្យរៀនតាមរយៈការចែករំលែកចំណេះដឹងដែលខ្លួនមានពីមុនមក
- ជួយសិស្សឱ្យមានគោលដៅច្បាស់លាស់ក្នុងការអានអត្ថបទឬមេរៀនថ្មី តាមរយៈការបង្កើតសំណួរដែលពួកគេចង់ដឹងមុនពេលអានអត្ថបទឬមេរៀនថ្មី
- ជួយពួកគេឱ្យចេះធ្វើសំយោគឬក៏បដិសេធចំណេះដឹងណាមិនត្រឹមត្រូវ។

**សម្ភារៈ**

- សម្រាប់គ្រូ ជាធម្មតាគ្រូប្រើដីសឬហ្វឺតសម្រាប់គូសនៅលើក្តារខៀន ប៉ុន្តែករណីដែលក្តារខៀនតូចមិនអាចបែងចែកជាបីខ្ទង់(កូឡោន)បាន គ្រូអាចប្រើក្រដាសផ្ទាំងធំចំនួនបីផ្ទាំងបាន។
- សម្រាប់សិស្ស ត្រូវមានសៀវភៅសិក្សាគោល និងសៀវភៅកត់ត្រាដើម្បីមើល និងកត់ត្រាក្នុងពេលពិភាក្សាជាមួយដៃគូ ក៏ដូចជាចម្លងព័ត៌មានដែលមានដាក់នៅក្នុងខ្ទង់(កូឡោន)ទាំងបីទុក ។

**រយៈពេល**

៤០នាទីទៅ៥០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូគូសបែងចែកក្តារខៀនជាបីផ្នែកហើយសរសេរ «តើយើងបានដឹងអ្វីអំពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ?»នៅក្នុងខ្ទង់(កូឡោន)ទី១ «តើយើងចង់ដឹងឬមានការឆ្ងល់អ្វីទៀតទាក់ទងនឹងមេរៀននេះ?» នៅក្នុងខ្ទង់(កូឡោន)ទី២ «តើយើងបានរៀនចេះអ្វីខ្លះបន្ទាប់ពីបានអានមេរៀននេះ?» នៅក្នុងខ្ទង់(កូឡោន)ទី៣។

| តើយើងបានដឹងអ្វីអំពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ? | តើយើងចង់ដឹងឬមានការឆ្ងល់អ្វីទៀតទាក់ទងនឹងមេរៀននេះ? | តើយើងបានរៀនចេះអ្វីខ្លះបន្ទាប់ពីបានអានមេរៀននេះ? |
|---|---|---|
| ................................................<br>............. ................ ....................<br>................................................<br>................................................<br>................................................<br>................................................ | ................................................<br>................................................<br>................................................<br>................................................<br>................................................<br>................................................ | ................................................<br>................................................<br>................................................<br>................................................<br>................................................<br>................................................ |

**ជំហានទី២**

គ្រូប្រាប់សិស្សអំពីចំណងជើងមេរៀនដែលសិស្សត្រូវអានរួចឱ្យសិស្សពិភាក្សាគ្នាជាដៃគូថាតើពួកគេបានដឹងអ្វីខ្លះទាក់ទងនឹងមេរៀននោះ។

**ជំហានទី៣**

គ្រូសួរទៅដៃគូពិភាក្សានោះឱ្យឆ្លើយហើយសរសេរចម្លើយចូលទៅក្នុងខ្ទង់(កូឡោន)ទី១ «តើយើងបានដឹងអ្វីអំពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ?»

**ជំហានទី៤**

បន្ទាប់មក គ្រូចាប់ផ្តើមសួរទៅសិស្សបន្តទៀតថាតើពួកគេមានអ្វីដែលមិនទាន់ដឹងឬមិនសូវប្រាកដ ឬក៏ពួកគេចង់ដឹងអ្វីបន្ថែមទៀតទាក់ទងនឹងមេរៀនដែលគេនឹងចាប់ផ្តើមរៀននោះ។គ្រូអាចយកការឆ្ងល់ទាំងនោះធ្វើជាសំណួររួចបំពេញនៅក្នុងខ្ទង់(កូឡោន)ទី២ « តើយើងចង់ដឹងឬមានការឆ្ងល់អ្វីទៀតទាក់ទងនឹងមេរៀននេះ?»។

**ជំហានទី៥**

គ្រូឱ្យសិស្សទាំងអស់ចាប់ដៃគូរួចអានមេរៀនដោយផ្តោតទៅសំណួរដែលមាននៅក្នុងខ្ទង់(កូឡោន)ទី២«តើយើងចង់ដឹងឬមានការឆ្ងល់អ្វីទៀតទាក់ទងនឹងមេរៀន

នេះ?» ហើយព្យាយាមឆ្លើយសំណួរទាំងនោះ។ បន្ទាប់ពីសិស្សបញ្ចប់ការអាន និងរកចម្លើយឃើញហើយ គ្រូសួរទៅសិស្សឱ្យឆ្លើយសំណួរម្តងមួយៗនៅក្នុងខ្ទង់(កូឡោន)ទី២ និងបំពេញចម្លើយទៅក្នុងខ្ទង់(កូឡោន)ទី៣«តើយើងបានរៀនចេះអ្វីខ្លះបន្ទាប់ពីបានអានមេរៀននេះ?»។

## ៦.វិធីបង្រៀន បន្ទាត់តម្លៃ ( Value Line)

**លំនាំ**

ការសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាមានសារៈសំខាន់ណាស់ក្នុងការបណ្តុះតម្លៃនៃការទទួលខុសត្រូវ ការបំពេញកាតព្វកិច្ច ការគោរពសិទ្ធិ ការគោរពច្បាប់។ល។ ដើម្បីបណ្តុះតម្លៃនេះ វិធីបង្រៀនបន្ទាត់តម្លៃ ត្រូវបានយកមកប្រើប្រាស់ដើម្បីឱ្យសិស្សចេះរិះគិត និងទទួលយកតម្លៃប្រកបដោយការពិចារណាចៀសវាងការទទួលយកអ្វីមួយទៅតាមឥទ្ធិពលបុគ្គលឬក៏ក្រុមណាមួយដោយគ្មានការពិចារណាច្បាស់លាស់ដែលអាចនាំឱ្យកើតបញ្ហាទៅថ្ងៃក្រោយ។

**វត្ថុបំណង**

- ឱ្យសិស្សចេះស្វែងយល់ពិចារណាពីតម្លៃអ្វីមួយមុននឹងទទួលយកតម្លៃនោះមកប្រើក្នុងការរស់នៅ
- ឱ្យសិស្សយល់អំពីដំណើរការក្នុងការជ្រើសរើសយកតម្លៃអ្វីមួយដោយសេរីដោយមិនទទួលការគាបសង្កត់ឬលួងលោមពីនរណាម្នាក់
- រៀនសម្រេចចិត្តដោយការស្តាប់មើលហេតុផលជាជាងការជឿឬការប្រកាន់យកតម្លៃអ្វីមួយដោយងាយៗ គ្មានគិតពិចារណា។

**សម្ភារៈ**

ក្រដាសវ៉ាម (A4) ឬសៀវភៅសរសេរសម្រាប់សិស្សសរសេរ

**រយៈពេល**

១០នាទីទៅ២០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូត្រូវចាប់ផ្តើមលើកឡើងនូវសំណួរខ្លះៗទាក់ទងនឹងតម្លៃសីលធម៌នៅក្នុងមេរៀនដែលសិស្សទើបរៀនចប់ឬគ្រូឱ្យសិស្សសួរសំណួរដោយខ្លួនឯងទាក់ទងនឹងតម្លៃ

នៃសីលធម៌នៅក្នុងមេរៀននោះ។ឧទាហរណ៍ គ្រូឬសិស្សអាចសួរថា តើតុលាការគួរប្រកាន់ភាពឯករាជ្យដែរឬទេ ប្រសិនបើការកាត់ក្តីនោះអាចនាំឱ្យខ្លួននិងក្រុមគ្រួសាររបស់ខ្លួនអាចមានបញ្ហា?

**ជំហានទី២**

គ្រូឱ្យសិស្សយកក្រដាសមួយសន្លឹក និងទុកពេលឱ្យសិស្សពី៥ទៅ៨នាទីដើម្បីសរសេរចម្លើយដោយផ្តល់ហេតុផល ហេតុអ្វីបានជាពួកគេយល់ស្របឬមិនយល់ស្រប។

**ជំហានទី៣**

គ្រូពន្យល់សិស្សថាមានគំនិតពីរដែលផ្ទុយគ្នា មួយគឺយល់ស្របនូវតម្លៃសីលធម៌នោះ និងមួយទៀតមិនយល់ស្របនូវតម្លៃនោះ។ បន្ទាប់មក គ្រូជ្រើសរើសសិស្សម្នាក់ឱ្យឆ្លើយយល់ស្របនិងសិស្សម្នាក់ទៀតឆ្លើយមិនយល់ស្រប។

**ជំហានទី៤**

សិស្សត្រូវជ្រើសរើសតម្លៃនោះតាមរយៈការបោះឆ្នោតក៏បានឬឱ្យសិស្សដទៃទៅឈរជិតសិស្សម្នាក់ដែលឆ្លើយយល់ស្រប ប្រសិនបើគេមានគំនិតយល់ស្របដែរ និងទៅឈរក្បែរសិស្សម្នាក់ទៀត ប្រសិនបើគេមិនយល់ស្របតម្លៃនោះដូចគ្នា(គ្រូក៏អាចជ្រើសរើសទៅឈរនៅក្នុងក្រុមណាមួយផងដែរ)។

**ជំហានទី៥**

បន្ទាប់មកគ្រូឱ្យសិស្សទាំងនោះជជែកគ្នាម្តងទៀត ថាតើពួកគេនៅតែមានគំនិតដូចដើម ឬក៏ពួកគេចង់ផ្លាស់ប្តូរគំនិត។ ក្រុមនីមួយៗត្រូវជ្រើសរើសសមាជិកម្នាក់ឱ្យធ្វើជាអ្នកនាំពាក្យ រួចហើយជួយអ្នកនាំពាក្យនោះឱ្យបង្កើតសេចក្តីថ្លែងការណ៍មួយ និងឡើងនិយាយសេចក្តីថ្លែងការណ៍នោះ។ ពេលក្រុមនីមួយៗធ្វើសេចក្តីថ្លែងការណ៍ គ្រូត្រូវសួរទៅសិស្សថា តើមានសិស្សណាចូលចិត្តហើយចង់ប្តូរកន្លែងឬប្តូរក្រុមដែរឬទេ។ គ្រូក៏អាចសម្រេចចិត្តជ្រើសរើសឬប្តូរទីតាំងទៅក្រុមណាមួយផងដែរ។

## ៧. វិធីបង្រៀន អត្ថបទចំពោះអត្ថបទ អត្ថបទចំពោះខ្លួន អត្ថបទចំពោះពិភពលោក

Text to text, text to self, text to world (TTT,TTS,TTW)

**លំណែនាំ**

វិធីបង្រៀនអត្ថបទចំពោះអត្ថបទ អត្ថបទចំពោះខ្លួន អត្ថបទចំពោះពិភពលោក (TTT,TTS,TTW) មិនត្រឹមតែជួយសិស្សឱ្យយល់អំពីគំនិតឬចំណេះដឹងដែលអ្នកនិពន្ធ

ចង់ឱ្យអ្នកអានយល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យសិស្សចេះឆ្លុះបញ្ចាំង ថាតើចំណេះដឹងនោះមានទំនាក់ទំនងអ្វីឬក៏ខុសគ្នាពីចំណេះដឹងនៅក្នុងមេរៀនដទៃដែរឬទេ។ វិធីនេះបានជួយឱ្យអ្នកអានចេះផ្សារភ្ជាប់ចំណេះដឹងនៅក្នុងមេរៀនទៅនឹងបទពិសោធន៍ និងទស្សនៈរបស់អ្នកអាន ហើយជួយឱ្យអ្នកអានចេះប្រើព័ត៌មាននៅក្នុងមេរៀនវិភាគឬប៉ាន់ស្មានថាតើថ្ងៃអនាគតអាចមានរឿងអ្វីកើតឡើងផងដែរ។

**វត្ថុបំណង**

- ជួយសិស្សឱ្យចេះប្រៀបធៀបមេរៀនដែលខ្លួនត្រូវរៀនទៅនឹងមេរៀនមុនៗ
- ជំរុញសិស្សឱ្យចេះយកអ្វីដែលរៀនមកផ្សារភ្ជាប់នឹងបទពិសោធន៍ដែលខ្លួនមាន
- ជួយសិស្សឱ្យចេះយកអ្វីដែលរៀនមកវិភាគនិងផ្សារភ្ជាប់ទៅនឹងព្រឹត្តិការណ៍នានាដែលកើតមានតាំងពីអតីតកាល បច្ចុប្បន្នកាលនិងអនាគតកាល។

**សម្ភារៈ**

តារាង TTT,TTS,TTW និងក្រដាសវ៉ាម (A4) ឬសៀវភៅសរសេរ។

**រយៈពេល**

៥០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូផ្តល់តារាង TTT,TTS,TTW ទៅឱ្យសិស្ស រួចពន្យល់សិស្សពីសកម្មភាពដែលសិស្សត្រូវបំពេញនៅក្នុងតារាង។

| | |
|---|---|
| ទំនាក់ទំនងមេរៀនចាស់ទៅមេរៀនថ្មី(តើគោលគំនិតនៅក្នុងមេរៀននេះបានរំឭកឱ្យប្អូននឹកឃើញមេរៀនដទៃទៀតយ៉ាងដូចម្តេច?) | -អ្វីដែលយើងបានអាន បានរំឭកដល់យើងនូវ.........ដោយសារ.................................................... |
| | -គំនិតនៅក្នុងមេរៀននេះ មានភាពស្រដៀងគ្នានៅក្នុងមេរៀន..........ពីព្រោះ.......................... |
| | -គំនិតនៅក្នុងមេរៀននេះមានលក្ខណៈខុសគ្នាពីមេរៀន.............ពីព្រោះ................................. |
| ទំនាក់ទំនងមេរៀនមកខ្លួនយើង(តើគោលគំនិតនៅក្នុងអត្ថបទនេះមានទំនាក់ទំនងជាមួយនឹងជីវិត ទស្សនៈ | -នៅពេលយើងអានមេរៀននេះ វាបានធ្វើឱ្យយើងនឹកឃើញនៅពេលដែលយើង................. ..................................................................................... |
| | -យើងយល់ស្របជាមួយមេរៀននេះដោយសារនៅក្នុងជីវិតយើង........................................... |

| | |
|---|---|
| និងបទពិសោធន៍របស់ប្អូនយ៉ាងដូចម្តេច?) | -យើងមិនយល់ស្របជាមួយនឹងមេរៀនដែលយើងបានអាននេះទេពីព្រោះនៅក្នុងជីវិតយើង ......................................................................... |
| ទំនាក់ទំនងមេរៀនទៅកាន់សហគមន៍ជាតិ និងពិភពលោក (តើគោលគំនិតនៅក្នុងមេរៀននេះមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយនឹងព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងសហគមន៍ជាតិនិងពិភពលោក នៅក្នុងអតីតកាល បច្ចុប្បន្នកាលនិងអនាគតកាលយ៉ាងដូចម្តេច?) | -មេរៀនដែលយើងបានអាននេះធ្វើឱ្យយើងគិតដល់.......... (ព្រឹត្តិការណ៍នៅក្នុងអតីតកាលដែលទាក់ទងនឹងសហគមន៍ ជាតិ ឬពិភពលោក)ដោយសារ................................................. |
| | -មេរៀនដែលយើងបានអាននេះធ្វើឱ្យយើងគិតដល់..... (ព្រឹត្តិការណ៍ថ្មីៗដែលទាក់ទងនឹងសហគមន៍ ជាតិ ឬពិភពលោក)ដោយសារ .................................................................................. |
| | -មេរៀនដែលយើងអាន បានធ្វើឱ្យយើងគិតដល់រឿងដែលអាចកើតមាននៅថ្ងៃអនាគត (ព្រឹត្តិការណ៍ដែលទាក់ទងនឹងសហគមន៍ជាតិឬពិភពលោក)ដោយសារ......................... .................................................................................. |

**ជំហានទី២**

គ្រូឱ្យសិស្សចាប់ដៃគូគ្នារួចអានមេរៀន (គ្រូអាចសម្រេចចិត្តឱ្យសិស្សបំពេញតារាងនេះជាក្រុមក៏បានឬជាបុគ្គលក៏បានអាស្រ័យលើពេលវេលានិងចំនួនសិស្សនៅក្នុងថ្នាក់រៀននីមួយៗ ប៉ុន្តែនៅក្នុងសៀវភៅនេះ អ្នកនិពន្ធជ្រើសរើសយកការងារជាក្រុមព្រោះសិស្សនៅក្នុងថ្នាក់អាចមានចន្លោះពី៤០ទៅ៥០នាក់ដែលជាចំនួនច្រើនធ្វើឱ្យមានភាពលំបាកសម្រាប់គ្រូក្នុងការពន្យល់សិស្សម្នាក់ៗបន្ថែមទៀតផង និងពិបាកត្រួតពិនិត្យកិច្ចការសិស្សផង)។

**ជំហានទី៣**

បន្ទាប់មកសិស្សត្រូវពិភាក្សាគ្នាថា តើមេរៀននោះមានលក្ខណៈស្រដៀងគ្នាឬខុសគ្នាពីមេរៀនដែលខ្លួនធ្លាប់បានរៀនពីមុនមកឬទេ រួចបំពេញនៅក្នុងខ្ទង់(កូឡោន)ទី១។

**ជំហានទី៤**

បន្ទាប់មកទៀតសិស្សត្រូវពិភាក្សាគ្នាបន្តទៀតថា តើមេរៀនកំពុងអាននោះមានទំនាក់ទំនងអ្វីចំពោះជីវិត ទស្សនៈ និងបទពិសោធន៍ដែលខ្លួនធ្លាប់មានឬធ្លាប់ដឹងឮដែរឬទេ រួចបំពេញចូលទៅក្នុងខ្ទង់(កូឡោន)ទី២។

**ជំហានទី៥**

នៅពេលសិស្សបំពេញខ្ទង់(កូឡោន)ទី២ចប់ គ្រូឱ្យសិស្សពិភាក្សាគ្នាថាតើមេរៀននោះមានទាក់ទងអ្វីទៅនឹងព្រឹត្តិការណ៍នៅក្នុងអតីតកាលនិងបច្ចុប្បន្នកាល។ ដោយយោងតាមព័ត៌មានដែលមាននៅក្នុងមេរៀននោះ សិស្សក៏ត្រូវពិភាក្សានិងវិភាគមើលថាតើអាចមានរឿងអ្វីកើតឡើង នៅក្នុងថ្ងៃអនាគតដែរឬទេ ។ បន្ទាប់មកសិស្សបំពេញព័ត៌មានទាំងអស់ចូលក្នុងខ្ទង់(កូឡោន)ទី៣និងប្រគល់កិច្ចការជូនគ្រូ។

## ៨.វិធីបង្រៀន ការវិភាគបញ្ហា( COPE)

**លំនែណាំ**

វិធីបង្រៀនការវិភាគបញ្ហា ប្រើប្រាស់ដើម្បីជួយសិស្សស្វែងរកព័ត៌មានជាក់លាក់នៅពេលពួកគេអានអត្ថបទជាជាងអានដោយគ្មានគោលដៅច្បាស់លាស់។ វិធីនេះជួយសិស្សឱ្យចេះយកព័ត៌មានទាំងនោះមកធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទឬតាមន័យនិងចេះពន្យល់បន្ទាប់ពីយល់ព័ត៌មាននោះច្បាស់លាស់រួចរាល់ហើយ។

**វត្ថុបំណង**

- បង្ហាត់សិស្សឱ្យចេះដោះស្រាយបញ្ហាឬការឆ្លើយតាមរយៈការប្រមូលព័ត៌មាន រៀបចំព័ត៌មាន វិភាគព័ត៌មាន និងពន្យល់
- ឱ្យសិស្សចេះពន្យល់នូវអ្វីដែលខ្លួនបានសិក្សា បានវិភាគ
- បណ្តុះសិស្សឱ្យចេះដោះស្រាយបញ្ហាតាមការស្រាវជ្រាវ និងការវិភាគ។

**សម្ភារៈ**

ក្រដាសរ៉ាម(A4) សៀវភៅសរសេរសម្រាប់កត់ត្រាព័ត៌មាន

**រយៈពេល**

២០នាទីទៅ៣០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូជ្រើសរើសចំណុចឬផ្នែកណាមួយនៅក្នុងមេរៀនដែលត្រូវបង្រៀនរួចបង្កើតជាសំណួរទាក់ទងនឹងចំណុចឬផ្នែកនោះ។ ឧទាហរណ៍នៅក្នុងជំពូក៣ មេរៀនទី១៣ គ្រូដាក់សំណួរទាក់ទងនឹងភាពខុសគ្នារវាង ឯកបក្ស ទ្វេបក្ស និងពហុបក្ស។

**ជំហានទី២**

គ្រូពន្យល់ប្រាប់ទៅសិស្សអំពីវិធីសាស្ត្រ COPE ដែលជាអក្សរកាត់នៃពាក្យអង់គ្លេសថា Collection (ប្រមូលព័ត៌មានដែលទាក់ទង), Organize (រៀបចំព័ត៌មាននោះឱ្យមានលំដាប់លំដោយ ឬទៅតាមប្រភេទ និងន័យ) Process (ធ្វើការវិភាគព័ត៌មានទាំងនោះដើម្បីឱ្យយល់) និងExplain (ធ្វើការពន្យល់)។

**ជំហានទី៣**

គ្រូពិភាក្សាជាមួយសិស្ស៖

- តើព័ត៌មានអ្វីខ្លះដែលត្រូវប្រមូល ឧទាហរណ៍ទាក់ទងនឹងភាពខុសគ្នារវាង ឯកបក្ស ទ្វេបក្ស និងពហុបក្ស។ សិស្សអាចរកព័ត៌មានទាក់ទងនឹងចំនួនគណបក្ស លទ្ធិដែលប្រកាន់យកតាមបក្សនីមួយៗ អ្នកអាចឈរឈ្មោះបានវត្តមានរបស់គណបក្សជំទាស់ ផលវិបាកដែលប្រកាន់យកប្រភេទគណបក្សនីមួយៗជាដើម។
- តើត្រូវរៀបចំព័ត៌មាននោះឱ្យមានសណ្តាប់ធ្នាប់ឬទៅតាមប្រភេទឬន័យយ៉ាងដូចម្តេច? ឧទាហរណ៍សិស្សអាចធ្វើតារាង ដែលគេអាចសរសេរបញ្ចូលទៅតាមប្រភេទព័ត៌មានទាក់ទងនឹងចំនួនគណបក្ស លទ្ធិដែលគេប្រកាន់យក អ្នកអាចឈរឈ្មោះឱ្យគេបោះឆ្នោត។ល។
- តើគេត្រូវវិភាគយ៉ាងដូចម្តេច? ឧទាហរណ៍ គេអាចធ្វើការវិភាគទាក់ទងនឹងប្រព័ន្ធគណបក្សនយោបាយនីមួយៗថា តើមានចំណុចវិជ្ជមានឬអវិជ្ជមានអ្វីខ្លះដែរឬទេ? តើក្នុងចំណោមប្រព័ន្ធបក្សទាំងបី តើប្រព័ន្ធមួយណាល្អជាងគេសម្រាប់ប្រជាពលរដ្ឋ?
- តើគេប្រើវិធីសាស្ត្រអ្វី ដើម្បីធ្វើការពន្យល់អ្នកដទៃឱ្យងាយយល់?

**ជំហានទី៤**

គ្រូកំណត់ពេលវេលាឱ្យសិស្សធ្វើការនោះជាក្រុមឬជាបុគ្គល។

**ជំហានទី៥**

គ្រូឱ្យតំណាងក្រុមឬបុគ្គលឡើងធ្វើបទបង្ហាញ។

## ៩.វិធីបង្រៀន ការអានជាដៃគូ/ការសង្ខេបជាដៃគូ

(Paired Reading/ Paired Summarizing)

**លំណែនាំ**

នៅក្នុងការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល សិស្សគឺជាតួអង្គយ៉ាងសំខាន់។ ពួកគេមិនត្រឹមតែទៅសាលារៀនដើម្បីទទួលការណែនាំពីគ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ជាអ្នកចូលរួមចំណែកយ៉ាងសកម្មក្នុងការត្រិះរិះពិចារណា និងសំយោគអ្វីដែលគេទទួលបានពីសាលារៀនមក។ នៅក្នុងវិធីការអានជាដៃគូឬការសង្ខេបជាដៃគូ សិស្សមិនត្រឹមតែអានអត្ថបទដើម្បីយល់ន័យឬសេចក្ដីនៅក្នុងអត្ថបទទេ ប៉ុន្តែថែមទាំងចេះបង្កើតសំណួរ ឆ្កឹះរកមើលន័យសំខាន់ៗ រួចសង្ខេបមេរៀននោះ យកមកប្រើប្រាស់ក្នុងការត្រិះរិះពិចារណា និងសំយោគចំណេះដឹងដែលខ្លួនមានជាមួយនឹងអ្វីដែលបានមកពីមេរៀនដែលខ្លួនបានសិក្សា ។

**វត្ថុបំណង**

- ជួយសិស្សឱ្យចេះអាន និងរកមើលចំណុចសំខាន់ៗនៃមេរៀន
- បណ្ដុះគំនិតសិស្សឱ្យចេះសរសេរសង្ខេបចំណុចសំខាន់នៃមេរៀនដើម្បីប្រើប្រាស់ក្នុងការត្រិះរិះពិចារណា និងសំយោគនៅពេលក្រោយ។

**សម្ភារៈ**

ក្រដាសរ៉ាម(A4) ឬសៀវភៅសរសេរ

**រយៈពេល**

៣០នាទីទៅ៤០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូប្រាប់មេរៀនដែលសិស្សត្រូវរៀន រួចសួរសំណួរទៅសិស្ស ថាតើពួកគេចង់រៀនឬចង់ដឹងឬចង់បានព័ត៌មានបន្ថែមទៀតលើសពីអ្វីដែលគេបានដឹងឬដើម្បីបំបាត់ភាព

ស្រពេចស្រពិលទាក់ទងទៅនឹងមេរៀនថ្មីនោះដែរឬទេ។ ពេលសិស្សសួរសំណួរ គ្រូត្រូវចម្លងសំណួរនោះដាក់លើក្ដារខៀន។

**ជំហានទី២**

គ្រូចាប់ផ្ដើមពន្យល់សិស្សថា ពួកគេនឹងអានអត្ថបទ/មេរៀនដើម្បីដឹងឱ្យបានកាន់តែច្បាស់និងឆ្លើយសំណួរដែលពួកគេបានលើកឡើងមកនោះ។ គ្រូត្រូវអានសំណួរទាំងនោះខ្លាំងៗម្ដងទៀត ហើយពន្យល់សិស្សឱ្យចាប់អារម្មណ៍ទៅលើសំណួរទាំងនោះ និងស្វែងរកព័ត៌មានទាក់ទងនឹងសំណួរនៅពេលគេអាន(ដោយសារវិធីនេះថ្មី គ្រូអាចអានបង្ហាញដល់សិស្ស រួចហើយសង្ខេបឱ្យសិស្សមើល)។

**ជំហានទី៣**

គ្រូឱ្យសិស្សចាប់ដៃគូគ្នា ហើយសិស្សម្នាក់អានវគ្គទីមួយនិងសង្ខេប ហើយសិស្សម្នាក់ទៀតជាដៃគូជាអ្នកបង្កើតសំណួរពីរឬបី សួរទៅកាន់សិស្សជាដៃគូទាក់ទងការសង្ខេបនៃវគ្គនោះ។ សិស្សទាំងពីរនាក់ត្រូវព្យាយាមឆ្លើយរាល់សំណួរដែលបានសួរនោះ។ គ្រូកំណត់រយៈពេលឱ្យសិស្សឈប់ ហើយសួរទៅកាន់សិស្សនៅក្នុងថ្នាក់ថា តើវគ្គនោះបានពន្យល់អ្វីខ្លះ? សិស្សម្នាក់ឆ្លើយហើយគ្រូអាចសួរដេញដោលឱ្យសិស្សផ្សេងទៀតចូលរួមបញ្ចេញគំនិតដែលបានសង្ខេបផ្សេងខុសពីនេះ។

**ជំហានទី៤**

បន្ទាប់មកគ្រូឱ្យសិស្សចាប់ផ្ដើមអានវគ្គទីពីរ តែម្ដងនេះអ្នកដែលបានអាន និងសង្ខេបនៅវគ្គទី១ ត្រូវដើរតួនាទីជាអ្នកសួរសំណួរវិញម្ដង ឯអ្នកសួរត្រូវអាននិងសង្ខេបវិញ។ គ្រូត្រូវឱ្យសិស្សធ្វើរបៀបនេះជាបន្តបន្ទាប់រហូតដល់ចប់មេរៀន(គ្រូត្រូវចេះសង្កេតមើលថា តើមានសិស្សណាម្នាក់ត្រូវការជំនួយក្នុងការសង្ខេបឬសួរសំណួរដែរឬទេ។ បើមានត្រូវផ្ដល់ជំនួយដល់សិស្សម្នាក់នោះភ្លាម។ ប៉ុន្តែប្រសិនបើគ្រូឃើញថា មានសិស្សច្រើនត្រូវការជំនួយ គ្រូគួរតែពន្យល់សិស្សនៅក្នុងថ្នាក់ទាំងមូលតែម្ដង)។

## ១០.វិធីបង្រៀន ការអានផ្ទាល់

Directed Reading Activity (DRA)

**លំនាំ**

នៅក្នុងពេលខ្លះ សិស្សមិនបានអានអត្ថបទឬមេរៀនពីផ្ទះមកទេ។ ប្រការនេះអាចលំបាកចំពោះការប្រើវិធីបង្រៀនមួយចំនួន ដូច្នេះហើយទើបទាមទារឱ្យគ្រូត្រូវឱ្យសិស្សអាននៅក្នុងថ្នាក់រៀន។ ប៉ុន្តែការអានដោយពុំមានគោលដៅច្បាស់លាស់អាច

ចំណាយពេលវេលាច្រើន និងមិនអាចជួយសិស្សឱ្យទទួលបានអ្វីដែលពួកគេគួរទទួលបានទេ។ វិធីនេះ គឺជាវិធីបង្រៀនមួយជួយសិស្សឱ្យអានអត្ថបទឬមេរៀនដោយជាក់លាក់ និងស្វែងរកចម្លើយឬចំណុចសំខាន់ៗនៅក្នុងមេរៀនដោយខ្លួនឯង ក្រោមការសម្របសម្រួលពីគ្រូបង្រៀន។

**វត្ថុបំណង**

- បង្កើតបរិយាកាសដែលធ្វើឱ្យសិស្សមានការឆ្ងល់ ចង់ដឹង ចង់ស្វែងរកចម្លើយនៅពេលគេអាន ហើយចង់អានបន្តទៀត
- ជួយសិស្សឱ្យមានគោលបំណងជាក់លាក់នៅពេលអានអត្ថបទឬមេរៀន
- ជំរុញសិស្សឱ្យចូលរួមរកចម្លើយនិងចែករំលែកចម្លើយទៅសិស្សដទៃទៀត។

**សម្ភារៈ**

- អត្ថបទឬមេរៀននៅក្នុងសៀវភៅសិក្សាគោល
- សំណួរសម្រាប់សួរសិស្ស។

**រយៈពេល**

៤០នាទីទៅ៥០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូត្រូវបែងចែកអត្ថបទឬមេរៀនទាំងមូលជា៤ឬ៥វគ្គ រួចបង្កើតសំណួរសម្រាប់វគ្គនីមួយៗដើម្បីសួរសិស្សមុនពេលពួកគេអានវគ្គទាំងនោះដើម្បីស្វែងរកចម្លើយ។ សំណួរទាំងនោះអាចទាក់ទងនឹងន័យ ព្រឹត្តិការណ៍ និងបុគ្គលសំខាន់ៗក្នុងអត្ថបទ ។

**ជំហានទី២**

មុនចាប់ផ្តើមវគ្គនីមួយៗ គ្រូចោទសំណួរដែលបានត្រៀមរួចហើយទៅសិស្ស។ បន្ទាប់មកឱ្យសិស្សអានអត្ថបទ ឬមេរៀននិងស្វែងរកចម្លើយ។

**ជំហានទី៣**

បន្ទាប់ពីសិស្សរកឃើញចម្លើយហើយ គ្រូហៅសិស្ស២ឬ៣នាក់ឆ្លើយចម្លើយ ។

**ជំហានទី៤**

គ្រូធ្វើបន្តរហូតដល់សិស្សអានអត្ថបទឬមេរៀនចប់ រួចហើយគ្រូសង្ខេបនូវអ្វីដែលសិស្សបានអាននិងឆ្លើយសំណួរទាំងនោះ។

## ១១.វិធីបង្រៀន ការពិភាក្សាជាសំបុកពីងពាង/ បណ្ដាញពិភាក្សា

(Discussion Web)

**លំនៃណនាំ**

ចំណេះដឹងបានមកពីប្រភពផ្សេងៗគ្នាជាច្រើន។ ចំណេះដឹងខ្លះចេញមកពីសង្គម ពីគ្រួសារ ឬក្រុមដែលបុគ្គលម្នាក់ៗមានទំនាក់ទំនងជាមួយ។ ចំណេះដឹងទាំងនោះ ពេលខ្លះក៏មិនត្រូវបានត្រិះរិះពិចារណា រកមើលហេតុផលថាតើសមស្របឬត្រឹមត្រូវនោះទេ។ ដូច្នេះហើយ វិធីពិភាក្សាជាសំបុកពីងពាង/បណ្ដាញពិភាក្សា ត្រូវបង្កើតឡើងដើម្បីជួយដល់សិស្សឱ្យចេះរកមូលហេតុនិងពិភាក្សាផ្លាស់ប្ដូរយោបល់គ្នារកមើលថា តើអ្វីដែលពួកគេបានដឹងពីមុនមកមានហេតុផលសមស្របនិងអាចទទួលយកបានដែរឬទេ។

**វត្ថុបំណង**

- ជំរុញសិស្សឱ្យរៀនសូត្រពីគ្នាទៅវិញទៅមកតាមរយៈការពិភាក្សាផ្លាស់ប្ដូរយោបល់គ្នា
- ជួយសិស្សឱ្យចេះរិះរកហេតុផលដើម្បីការពារគំនិតដែលខ្លួនមានឬប្រកាន់យក
- បណ្ដុះគំនិតជជែកវែកញែកគ្នាដោយសន្តិវិធីចៀសវាងការប្រើអំពើហិង្សា។

**សម្ភារៈ**

តារាងពិភាក្សាជាសំបុកពីងពាង/បណ្ដាញពិភាក្សា (Discussion Web)

**រយៈពេល**

២០នាទីទៅ៣០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូត្រូវបង្កើតសំណួរមួយដែលមានលក្ខណៈប្រឈមគ្នាដូចជា តើប្ដីអាចស្ដីបន្ទោសប្រពន្ធបានដែរឬទេ ប្រសិនបើប្រពន្ធនោះលេងល្បែង ឬតើយើងគួរឱ្យស្ត្រីនៅតែក្នុងផ្ទះចាប់ពីម៉ោង៧យប់ ដើម្បីសុវត្ថិភាពជាដើម។

**ជំហានទី២**

គ្រូដាក់សំណួរឱ្យសិស្សចូលរួមឆ្លើយ ។ ពេលសិស្សឆ្លើយ គ្រូត្រូវសរសេរឈ្មោះសិស្ស បន្ទាប់មកសរសេរចម្លើយដាក់ពីខាងក្រោមឈ្មោះនោះ។ នៅពេលបានចម្លើយហើយ គ្រូអាចមើលចម្លើយនោះ ហើយបង្កើតប្រយោគមួយដូចជា ប្ដីអាចស្ដីបន្ទោសប្រពន្ធបានដើម្បីកុំឱ្យប្រព្រឹត្តខុសឬស្ត្រីមិនត្រូវចេញទៅក្រៅនៅពេលយប់ទេ ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួន។

**ជំហានទី៣**

គ្រូឱ្យសិស្សយកក្រដាសសៀវភៅ រួចគូសតារាងដូចខាងក្រោម។ មួយផ្នែកសម្រាប់សរសេរចម្លើយយល់ស្របនិងមួយផ្នែកទៀតសម្រាប់សរសេរចម្លើយមិនយល់ស្រប ហើយគ្រូឱ្យសិស្សចាប់ដៃគូគ្នាពិភាក្សារកមូលហេតុថា ហេតុអ្វីសិស្សយល់ស្រប និងមិនយល់ស្រប រួចសរសេរដាក់នៅក្នុងក្រដាសសៀវភៅរបស់ខ្លួន។

ការពិភាក្សា

| ខ្ញុំយល់ស្រប | ខ្ញុំមិនយល់ស្រប |
|---|---|
| ........................................................................<br>........................................................................<br>........................................................................ | ........................................................................<br>........................................................................<br>........................................................................ |

**ជំហានទី៤**

បន្ទាប់មក គ្រូឱ្យសិស្សចាប់ក្រុមដែលមានសមាជិក៥នាក់ ហើយចែករំលែកនិងសរសេរមូលហេតុបន្ថែមចូលទៅក្នុងតារាងយល់ស្របនិងមិនយល់ស្រប។ ពួកគេត្រូវធ្វើការតស៊ូមតិគ្នា(Debate)ដើម្បីជ្រើសរើសយកគោលជំហរតែមួយប៉ុណ្ណោះ ថាតើពួកគេយល់ស្របឬមិនយល់ស្របរួចសង្ខេបជំហរនោះដាក់នៅក្នុងតារាងដូចខាងក្រោម។ បន្ទាប់ពីសិស្សធ្វើកិច្ចការនេះចប់ គ្រូហៅតំណាងក្រុមឡើងឆ្លើយសំណួរ។

ការពិភាក្សា

| ក្រុមរបស់ខ្ញុំយល់ស្រប | ក្រុមរបស់ខ្ញុំមិនយល់ស្រប |
|---|---|
| ........................................................................<br>........................................................................<br>........................................................................<br>........................................................................ | ........................................................................<br>........................................................................<br>........................................................................<br>........................................................................ |

| យោបល់: |
|---|
| ..................................................................................................................................................<br>..................................................................................................................................................<br>..................................................................................................................................................<br>..................................................................................................................................................<br>..................................................................................................................................................។ |

## ១២. វិធីបង្រៀន ការរួមគ្នាគិតជាដៃគូ (Think Pair Share)

**លំនាំ**

វិធីបង្រៀនរួមគ្នាគិតជាដៃគូ ជាវិធីមួយជួយសិស្សឱ្យចេះរួមគ្នារៀនអ្វីមួយ។ សិស្សម្នាក់ៗត្រូវរៀនរិះរកចម្លើយដោយខ្លួនឯងជាមុនសិន រួចចែករំលែកដល់សិស្សជាដៃគូម្នាក់ទៀត។ នៅក្នុងវិធីសាស្ត្រចាស់ៗភាគច្រើនគឺសិស្សត្រូវឈប់ត្រឹមចំណុចនេះ ប៉ុន្តែតាមការសង្កេត សិស្សខ្លះជ្រើសរើសតែដៃគូដែលខ្លួនស្គាល់ប៉ុណ្ណោះ ជាហេតុធ្វើឱ្យការពិភាក្សាមិនសូវស៊ីជម្រៅហើយក៏មិនអាចជួយបង្កើតភាពជឿជាក់ដល់ខ្លួននៅពេលចែករំលែកមតិគំនិត យោបល់របស់ខ្លួនក្នុងចំណោមមនុស្សច្រើននោះដែរ។ ដូច្នេះវិធីបង្រៀននេះមិនត្រឹមតែជួយសិស្សរៀនសូត្ររួមគ្នាទេ ប៉ុន្តែបង្កើតជំនឿចិត្តនៅពេលចែករំលែកដល់ក្រុមធំ។

**វត្ថុបំណង**

- ជួយសិស្សឱ្យរៀនជាក្រុម
- ពង្រឹងជំនាញទំនាក់ទំនងនិងការនិយាយនៅក្នុងក្រុមធំឬសាធារណៈ។

**សម្ភារៈ**

ក្រដាសវ៉ាម(A4) ឬសៀវភៅសរសេរសម្រាប់ឱ្យសិស្សសរសេរចម្លើយ។

**រយៈពេល**

៣០នាទីទៅ៤០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូដាក់សំណួរមួយឱ្យសិស្សគិតរិះរកចម្លើយ។សិស្សម្នាក់ៗត្រូវកត់ត្រាចម្លើយដែលខ្លួនបានរិះរកឃើញ។

**ជំហានទី២**

បន្ទាប់មក គ្រូឱ្យសិស្សចាប់ដៃគូ ហើយចែករំលែក និងពិភាក្សាចម្លើយដែលខ្លួនមាន។សិស្សដែលចាប់ដៃគូត្រូវកត់ត្រាចម្លើយដែលបានសំយោគបញ្ចូលគ្នា។

**ជំហានទី៣**

គ្រូឱ្យសិស្សដៃគូនោះចាប់ដៃគូមួយគូទៀត(សរុប៤នាក់)រួចហើយចែករំលែកអ្វីដែលខ្លួនមានឱ្យគ្នាទៅវិញទៅមក និងត្រូវកត់ត្រាចម្លើយដែលបានសំយោគបញ្ចូលគ្នា។

**ជំហានទី៤**

គ្រូប្រមូលក្រដាសកិច្ចការដែលសិស្សបានធ្វើទៅពិនិត្យ។

## ១៣.វិធីបង្រៀន ដើមឈើបញ្ហា (Problem Tree)

**លំណែនាំ**

ជាគោលការណ៍នៅក្នុងការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល សិស្សត្រូវបង្រៀនឱ្យចេះរកវិធីដោះស្រាយបញ្ហាដោយខ្លួនឯង។ គ្រូគ្រាន់តែមានមុខនាទីជាអ្នកកំណត់បញ្ហាឱ្យសិស្ស ប៉ុន្តែមិនអាចប្រាប់ពីវិធីក្នុងការដោះស្រាយនោះទេ។ប៉ុន្តែដើម្បីដោះស្រាយបញ្ហានោះបាន ទាមទារឱ្យសិស្សយល់ដឹងថាតើវិធីដើមឈើបញ្ហា ត្រូវបានគេបង្ហាញថា បញ្ហានោះកើតមកពីអ្វី តើបញ្ហានោះបង្កឱ្យមានផលប៉ះពាល់អ្វី ទើបសិស្សអាចកំណត់រកវិធីដោះស្រាយបាន។ ដូច្នេះវិធីបង្រៀនដើមឈើបញ្ហាត្រូវបានគេយកមកប្រើប្រាស់សម្រាប់បង្រៀនសិស្សឱ្យចេះកំណត់ឫសគល់ដែលនាំឱ្យមានបញ្ហានោះ និងផលវិបាកដែលបញ្ហានោះបានបង្កើតឡើង។

**វត្ថុបំណង**

- ជួយសិស្សឱ្យចេះកំណត់ឫសគល់នៃបញ្ហានិងរកផលអវិជ្ជមានដែលកើតមកពីបញ្ហានោះ
- បង្រៀនសិស្សឱ្យចេះទាញរកដំណោះស្រាយដើម្បីលុបបំបាត់ឫសគល់នៃបញ្ហា
- បណ្តុះគំនិតសិស្សឱ្យយល់ពីតម្លៃនៃការធ្វើការងារជាក្រុមដើម្បីដោះស្រាយបញ្ហាអ្វីមួយ។

**សម្ភារៈ**

ក្រដាសដែលមានរូបដើមឈើបញ្ហា(Problem tree )

**រយៈពេល**

១០នាទីទៅ២០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូអាចបែងចែកសិស្សជាក្រុមតូចៗរួចឱ្យក្រដាសដែលមានរូបដើមឈើមួយដើមដែលមានទាំងដើម ទាំងឫស ទាំងមែកដល់សិស្ស (សូមមើលរូបភាព)។ បន្ទាប់មកគ្រូពន្យល់ប្រាប់សិស្សថា ដើមតំណាងឱ្យបញ្ហា ឫសតំណាងឫសគល់នៃបញ្ហា និងមែកតំណាងឱ្យផលវិបាកដែលកើតឡើងមកពីបញ្ហានោះ។ គ្រូអាចសរសេរបញ្ហាណាមួយនៅលើដើមរួចឱ្យសិស្សព្យាយាមពិភាក្សាគ្នាដើម្បីរកឫសគល់នៃបញ្ហានោះ។

ឧទាហរណ៍ គ្រូសរសេរ«អំពើពុករលួយ»នៅលើដើម រួចឱ្យសិស្សពិភាក្សាគ្នារកមើលឫសគល់នៃអំពើពុករលួយ។




**ជំហានទី២**

គ្រូឱ្យសិស្សពិភាក្សាគ្នារកមើលឫសគល់នៃអំពើពុករលួយតាមតែអាចធ្វើទៅបាន ឧទាហរណ៍ ឫសគល់នៃអំពើពុករលួយមានដូចជា ការអនុវត្តច្បាប់នៅធូររលុង តុលាការមិនឯករាជ្យ និងមិនយុត្តិធម៌ មិនមានតម្លាភាព រដ្ឋបាលសាធារណៈដំណើរការយឺតយ៉ាវជាដើម។ នៅពេលសិស្សកំណត់បានឫសគល់នៃបញ្ហាហើយ គ្រូអាចសរសេរបញ្ហាទាំងនោះនៅលើឫសនៃដើមឈើនោះ។គ្រូឱ្យសិស្សមើលទៅលើឫសនីមួយៗ ហើយពិភាក្សាគ្នាថា តើឫសនោះអាចបង្កផលអវិជ្ជមានអ្វីខ្លះ។

**ជំហានទី៣**

គ្រូឱ្យសិស្សពិភាក្សារកមើលផលអវិជ្ជមានឬផលប៉ះពាល់ដែលកើតចេញពីឫស។ ឧទាហរណ៍ តុលាការមិនឯករាជ្យអាចបង្កើតឱ្យមានវប្បធម៌និទណ្ឌភាព ពោលគឺមនុស្សដែលប្រព្រឹត្តអំពើពុករលួយមិនត្រូវបានចាប់ខ្លួន និងដាក់ទោសទេ។ តុលាការមិនឯករាជ្យក៏អាចបង្កើតឱ្យមានអសន្តិសុខក្នុងសង្គម និងការរំលោភបំពានសិទ្ធិមនុស្សផងដែរ។ នៅពេលសិស្សរកឃើញផលអវិជ្ជមានឬផលប៉ះពាល់ហើយ គ្រូឱ្យសិស្សពិភាក្សាគ្នាបន្តទៀតថាតើគេត្រូវធ្វើដូចម្ដេច ទើបអាចលុបបំបាត់អំពើពុករលួយដែលបង្កឱ្យមានបញ្ហាជាច្រើនដល់ប្រជាជននិងសង្គមជាតិនោះ។

**ជំហានទី៤**

ដើម្បីរកដំណោះស្រាយបាន សិស្សអាចមើលឫសគល់នៃបញ្ហានីមួយៗនៅលើឫសឈើរួចពិភាក្សាគ្នាថា តើគេត្រូវធ្វើដូចម្តេច ទើបលុបបំបាត់ឫសគល់នៃបញ្ហានីមួយៗបាន។ ឧទាហរណ៍ ដើម្បីលុបបំបាត់តុលាការមិនឯករាជ្យ ត្រូវជំរុញឱ្យស្ថាប័នតុលាការមានតម្លាភាព ពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពតាមរយៈការដំឡើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ ជាពិសេសនៅតាមស្ថាប័នតុលាការ ស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នអប់រំឱ្យបានសមរម្យ បណ្តុះបណ្តាលនៅតាមសាលារៀននិងនៅតាមទីសាធារណៈឱ្យប្រជាជនយល់ដឹងអំពីច្បាប់ អំពីសិទ្ធិ ព្រោះកាលណាពួកគាត់យល់ដឹងពីច្បាប់និងសិទ្ធិពួកគាត់នឹងធ្វើអ្វីៗស្របទៅតាមច្បាប់និងសិទ្ធិ ហើយអាចការពារសិទ្ធិសេរីភាពរបស់ខ្លួនពេលមានការរំលោភបំពានទៀតផង។

## ១៤. វិធីបង្រៀន ការកត់ត្រាពាក្យគន្លឹះនិងខ្លឹមសារសំខាន់ៗ (Frayer)

**លំនាំ**

ការកត់ត្រាមានសារៈសំខាន់ណាស់ក្នុងការជួយសិស្សឱ្យអាចយកកំណត់ត្រាមករំឭកមុនពេលប្រឡងបាន។ប៉ុន្តែការកត់ត្រានៅក្នុងសៀវភៅកំណត់ត្រាខ្លះស្មុគស្មាញពិបាករកឃើញភ្លាមៗណាស់។ ដូច្នេះវិធីកត់ត្រាពាក្យគន្លឹះនិងខ្លឹមសារសំខាន់ៗ ត្រូវបានកែច្នៃឡើងដើម្បីជួយជំរុញសិស្សឱ្យចេះកត់ត្រាពាក្យគន្លឹះសំខាន់ៗផង អាចងាយស្រួលរកយកមករំឭកមុនពេលប្រឡងផង និងអាចឱ្យសិស្សចេះរកឧទាហរណ៍មកពន្យល់ និងចេះរកលក្ខណៈសម្គាល់ និងលក្ខណៈផ្ទុយនៃពាក្យគន្លឹះនោះផង។

**វត្ថុបំណង**

- ជួយសិស្សឱ្យចេះកត់ត្រាពាក្យគន្លឹះសំខាន់ៗ
- ជួយសិស្សឱ្យចេះពាក្យគន្លឹះច្បាស់លាស់តាមរយៈការរកឧទាហរណ៍មកពន្យល់ រកលក្ខណៈសម្គាល់ និងលក្ខណៈផ្ទុយនៃពាក្យនោះផង
- បង្កលក្ខណៈងាយស្រួលដល់សិស្សក្នុងការរកកំណត់ត្រាមករំឭកមុនពេលប្រឡង។

**សម្ភារៈ**

ប័ណ្ណកត់ត្រាពាក្យគន្លឹះនិងខ្លឹមសារសំខាន់ៗ

**ពេលវេលា**

៥នាទីទៅ១០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូអាចផ្តល់ប័ណ្ណកត់ត្រាពាក្យគន្លឹះនិងខ្លឹមសារសំខាន់ៗទៅឱ្យសិស្សរួចពន្យល់សិស្សថា ប័ណ្ណនេះមានសារៈសំខាន់ណាស់ក្នុងការជួយឱ្យពួកគេរៀនចេះពាក្យគន្លឹះថ្មីដោយងាយ។នៅក្នុងប័ណ្ណនេះរង្វង់កណ្តាលគឺសម្រាប់សរសេរពាក្យគន្លឹះមួយ ។ ចំណែកឯប្រអប់បួននៅជុំវិញរង្វង់នោះគឺសម្រាប់សរសេរនិយមន័យ ឧទាហរណ៍ លក្ខណៈសម្គាល់និងលក្ខណៈផ្ទុយ។ ដើម្បីឱ្យសិស្សងាយយល់ គ្រូអាចជ្រើសរើសពាក្យគន្លឹះមួយយកមកបង្ហាញ ឧទាហរណ៍ ពាក្យ " តម្លាភាព "។

**ជំហានទី២**

គ្រូឱ្យសិស្សអានមេរៀន រួចស្រង់យកពាក្យគន្លឹះមួយ ហើយសរសេរចូលទៅក្នុងរង្វង់កណ្តាល (សិស្សអាចធ្វើការងារនេះជាក្រុមក៏បាន)។ បន្ទាប់មកព្យាយាមរកមើលនិយមន័យនៃពាក្យនោះនៅក្នុងសៀវភៅ(ឬនៅក្នុងប្រភពផ្សេងទៀត)។ ពេលរកបានហើយគ្រូឱ្យសិស្សកត់ចូលក្នុងប្រអប់ដែលមានសរសេរថា «និយមន័យ»។

**ជំហានទី៣**

គ្រូឱ្យសិស្សអាននិយមន័យនោះឱ្យយល់ រួចហើយព្យាយាមស្វែងរកឧទាហរណ៍ពីរឬបីទាក់ទងនឹងនិយមន័យនៃពាក្យគន្លឹះនោះ(សិស្សអាចធ្វើការងារនេះជាក្រុមបាន)។ បន្ទាប់ពីរកបានឧទាហរណ៍ហើយ គ្រូឱ្យសិស្សកត់ចូលទៅក្នុងប្រអប់ដែលមានសរសេរថា «ឧទាហរណ៍»។

ជំហានទី៤

គ្រូឱ្យសិស្សពិនិត្យមើលថា តើមានអ្វីសម្គាល់ទង្វើនេះឬទង្វើនោះ តម្លាភាព ឬមិនតម្លាភាព(សិស្សអាចធ្វើការងារនេះជាក្រុមក៏បាន)។ពេលរកឃើញលក្ខណៈសម្គាល់ដែលចាត់ទុកជាតម្លាភាពសិស្សត្រូវសរសេរចូលទៅប្រអប់ដែលសរសេរថា«លក្ខណៈសម្គាល់» ចំណែកឯទង្វើដែលមិនមែនតម្លាភាព សិស្សត្រូវសរសេរចូលទៅក្នុងប្រអប់ដែលសរសេរថា«លក្ខណៈផ្ទុយ» (សូមមើលឧទាហរណ៍ដែលមានភ្ជាប់)។

**តម្លាភាព**

| និយមន័យ | លក្ខណៈសម្គាល់ |
| --- | --- |
| តម្លាភាពគឺជាការបើកចំហ ការស្មោះត្រង់ គ្មានការលាក់លៀម ដោយបង្កលក្ខណៈឱ្យមានការចូលរួមដ៏សុទ្ធចិត្ត និងរីករាយក្នុងគ្រប់ទិដ្ឋភាពសង្គម នយោបាយ សេដ្ឋកិច្ចនិងវប្បធម៌។ | ❖ បើកចំហ<br>❖ គ្មានការលាក់លៀម<br>❖ ស្មោះត្រង់<br>❖ អនុញ្ញាតឱ្យមានការចូលរួមពីភាគីផ្សេងៗឬសាធារណជន |
| **ឧទាហរណ៍** | **លក្ខណៈផ្ទុយ** |
| ❖ នៅតាមឃុំនីមួយៗមានការបិទផ្សាយអំពីចំណូលចំណាយ និងតម្លៃសេវាកម្មនៅមុខសាលាឃុំ។<br>❖ អង្គការនានាតែងតែបញ្ចេញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យសាធារណជនដឹងឮជារៀងរាល់ឆ្នាំ។ | ❖ លាក់លៀមឬបិទបាំងមិនឱ្យនរណាចូលរួមដឹងឮ<br>❖ មិនផ្សព្វផ្សាយចេញជាសាធារណៈ<br>❖ បង្កឱ្យមានការរារាំងនៅពេលមាននរណាចង់សុំព័ត៌មាន។ |

## ១៥.វិធីបង្រៀន ការធ្វើប័ណ្ណស្រង់ព័ត៌មាន

### លំណែនាំ

តាមការពិនិត្យអំពីការសិក្សារបស់សិស្សនៅវិទ្យាល័យ សិស្សភាគច្រើនទន្ទេញមេរៀនចាំមាត់។ ការទន្ទេញមិនមានអ្វីខុសទេប៉ុន្តែអាចភ្លេចទៅវិញនៅក្នុងអំឡុងពេលណាមួយ។ ម្យ៉ាងទៀតសិស្សក៏ប្រហែលជាលំបាកក្នុងការទន្ទេញមេរៀនទាំងអស់ឡើងវិញមុនពេលប្រឡងឆមាសផងដែរ។ ដូច្នេះវិធីដែលងាយជាងការទន្ទេញមេរៀនឱ្យចាំនោះ គឺការចេះសរសេរស្រង់យកព័ត៌មានសំខាន់ៗមកទុក។ ពេលណាគ្រូដាក់កិច្ចការឱ្យធ្វើនៅផ្ទះឬសិស្សត្រូវរំឭកមេរៀនមុនពេលប្រឡង សិស្សមិនចាំបាច់មើលសៀវភៅឡើងវិញទេ គឺគ្រាន់តែប្រមូលប័ណ្ណព័ត៌មានមកមើលជាការស្រេច។

**វត្ថុបំណង**

- បណ្តុះសិស្សឱ្យតម្លៃនិងធ្វើការស្រង់ព័ត៌មានសំខាន់ៗពេលអានអត្ថបទមេរៀនឬឯកសារ
- បង្ហាត់សិស្សឱ្យចេះស្រង់ព័ត៌មានសំខាន់ៗដើម្បីងាយចាំអាចយកមកប្រើប្រាស់នៅពេលក្រោយ។

**សម្ភារៈ**

ប័ណ្ណស្រង់ព័ត៌មាន។

**រយៈពេល**

២០នាទីទៅ៣០នាទី។

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូឱ្យសិស្សកាត់ក្រដាសរាងចតុកោណកែងតូចល្មម(ដើម្បីឱ្យសិស្សយល់ដឹងកាន់តែច្បាស់ជាពិសេសទំហំក្រដាស គ្រូគួរតែកាត់ឱ្យសិស្សមើលជាមុន)។

**ជំហានទី២**

គ្រូពន្យល់សិស្សថា ប័ណ្ណស្រង់ព័ត៌មានអាចយកទៅកត់ត្រាពាក្យ គំនិតឬព្រឹត្តិការណ៍សំខាន់ៗពេលសិស្សអានសៀវភៅឬឯកសារដើម្បីសិក្សាស្រាវជ្រាវ។ បន្ទាប់មក គ្រូបែងចែកសិស្សជាក្រុមតូចៗប្រហែល៣ទៅ៥នាក់ក្នុង១ក្រុម រួចហើយហុចប័ណ្ណស្រង់ព័ត៌មានមួយសន្លឹកទៅឱ្យក្រុមនីមួយៗ។ គ្រូឱ្យសិស្សពិនិត្យមើលនិងពិភាក្សាគ្នាថាតើមានព័ត៌មានអ្វីខ្លះនៅក្នុងប័ណ្ណស្រង់ព័ត៌មាននោះ។

**ជំហានទី៣**

បន្ទាប់ពីសិស្សផ្តល់ចម្លើយហើយ គ្រូបង្រៀនសិស្សពីវិធីស្រង់ព័ត៌មានដាក់ចូលក្នុងប័ណ្ណព័ត៌មាន។ គ្រូអាចពន្យល់ថានៅក្នុងប័ណ្ណព័ត៌មាន មានព័ត៌មានដូចជាឈ្មោះអ្នកនិពន្ធ ឆ្នាំបោះពុម្ព ចំណងជើងសៀវភៅ ឬឯកសារ ទំព័រ និងពាក្យគន្លឹះ/គំនិត/ព្រឹត្តិការណ៍សំខាន់ណាមួយ។

នៅពេលសិស្សអាននឹងប្រទះឃើញពាក្យគន្លឹះ/គំនិត/ព្រឹត្តិការណ៍សំខាន់ណាមួយ សិស្សអាចកត់ត្រាឈ្មោះអ្នកនិពន្ធ ឆ្នាំ ចំណងជើងអត្ថបទ ឬឯកសារ និងលេខទំព័រដាក់នៅខាងលើផ្នែកខាងស្តាំក៏បាន ឬដាក់នៅម្ខាងទៀតនៃប័ណ្ណស្រង់ព័ត៌មានក៏បាន បន្ទាប់មកទើបកត់ពាក្យគន្លឹះ/គំនិត/ព្រឹត្តិការណ៍សំខាន់ណាមួយ(តែមួយប៉ុណ្ណោះ) ចូលទៅផ្នែកកណ្តាលនៃផ្ទៃប័ណ្ណឬទៅផ្នែកម្ខាងទៀតនៃប័ណ្ណដែលមិនទាន់សរសេរអ្វី។

ទម្រង់ទី១

ហេងមណីចិន្តា.(១៩៩៧).មគ្គុទេសក៍ជីវិត ទំព័រទី៥៨

ក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានចាប់ផ្តើមពិនិត្យផ្ទៀងផ្ទាត់និង ប្រែព្រះត្រៃបិដកពីបាលីមកជាភាសាខ្មែរនៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៣០ ក្រោមព្រះរាជូបត្ថម្ភពីព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស។

ទម្រង់ទី២

ឥន្ទ ឱមសាម៉េង.(២០០៥).ប្រវត្តិទស្សន:សាសនា សីលធម៌ នយោបាយ ទំព័រទី១០២ ខន្តី

ការមានសេចក្តីអត់ធនគឺទ្រាំនឹងសេចក្តីលំបាក និងការមើលងាយពីអ្នកដទៃ។

គ្រូឱ្យសិស្សរកសៀវភៅសិក្សាគោលអាននិងហាត់ស្រង់ព័ត៌មានដាក់ចូលក្នុងប័ណ្ណស្រង់ព័ត៌មាន។

## ១៦. វិធីបង្រៀន ការការពារគំនិត (Debate)

### លំនាំ

ភាគច្រើន បុគ្គលម្នាក់ៗតែងតែព្យាយាមទន្ទេញឱ្យចាំអ្វីដែលគេបានអាន ដោយមិនសូវបានត្រិះរិះពិចារណា ថាតើអ្វីដែលគេបានអាននោះមានអំណះអំណាងសមហេតុផលដែរឬទេ។ ដូចលោក**មេហ្ស៊ីរ៉ូវ** (Mezirow) បានពន្យល់ថា កាលណាបុគ្គលណាម្នាក់ប្រកាន់យកអ្វីមួយហើយ ពួកគេនឹងមិនងាយផ្លាស់ប្តូរទេ លុះត្រាតែមានហេតុភេទណាមួយកើតឡើងដែលធ្វើឱ្យបុគ្គលនោះដឹងថាការប្រកាន់នោះខុស មិនសមហេតុផល មិនអាចយកមកប្រើការកើត ទើបបុគ្គលនោះធ្វើការផ្លាស់ប្តូរ។ ដូច្នេះវិធីការការពារមតិ (Debate)មានសារៈសំខាន់ណាស់ក្នុងការជួយឱ្យបុគ្គលម្នាក់ៗ ត្រូវចេះរកអំណះអំណាងមកគាំទ្រអ្វីដែលខ្លួនប្រកាន់យក។ ប៉ុន្តែមនុស្សជាច្រើនយល់ច្រឡំថា ការធ្វើការការពារមតិ គឺដើម្បីរកអ្នកចាញ់និងអ្នកឈ្នះ ព្រោះគេឃើញមានក្រុមបានពិន្ទុខ្ពស់ជាង បានការសរសើរច្រើនជាងជាដើម។តាមការពិតទៅ បើទោះបីជាមានការប្រកាសថាក្រុមនេះបាន

ពិន្ទុច្រើនជាងក្រុមនោះក្តី ក្រុមទាំងអស់ជាអ្នកបានទទួលលទ្ធផលដូចគ្នា គឺចំណេះដឹងនិងបទពិសោធន៍ថ្មីៗដែលក្រុមទាំងអស់បានបង្កើតឡើងរួមគ្នា។

**វត្ថុបំណង**

- ជួយសិស្សឱ្យរៀនចេះធ្វើការជាក្រុម
- ជំរុញសិស្សឱ្យចេះស្វែងរកអំណះអំណាងទៅលើគំនិតយោបល់អ្វីមួយដែលពួកគេប្រកាន់យក
- ដើម្បីឱ្យសិស្សយល់ដឹងនិងមានសមត្ថភាពអាចឈរឈ្មោះបោះឆ្នោតនាថ្ងៃអនាគតតាមរយៈការបង្កើតបរិយាកាសមួយស្រដៀងនឹងការឡើងធ្វើការការពារមតិក្នុងការរកសំឡេងឆ្នោតរបស់បេក្ខជនឈរឈ្មោះឱ្យគេបោះឆ្នោត។

**សម្ភារៈ**

ប្រអប់ដាក់ក្រដាសឆ្នោត

**រយៈពេល**

៥០នាទី

**ដំណើរការបង្រៀន**

**ជំហានទី១**

គ្រូជ្រើសរើសប្រធានបទណាមួយដែលមានលក្ខណៈប្រឈមគ្នា។ ឧទាហរណ៍នៅក្នុងជំពូកទី៣ មេរៀនទី៧ អំពីលទ្ធិប្រជាធិបតេយ្យ គ្រូអាចជ្រើសរើសប្រធានបទថា«នៅក្នុងរដ្ឋដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ អ្នកមិនចេះអក្សរមិនគួរអនុញ្ញាតឱ្យបោះឆ្នោតទេ ព្រោះគាត់មិនចេះគិតពិចារណាជ្រើសរើសមេដឹកនាំល្អបានឡើយ»។

**ជំហានទី២**

គ្រូអាចជ្រើសរើសសិស្សស្ម័គ្រចិត្ត១០នាក់ ដោយចែកចេញជាក្រុមស្របនិងក្រុមជំទាស់។ ចំណែកឯសិស្សដែលមិនបានជ្រើសរើសត្រូវដើរតួនាទីធ្វើជាអ្នកវាយតម្លៃតាមរយៈការបោះឆ្នោតនៅពេលចប់ការការពារមតិ(Debate)។

**ជំហានទី៣**

សិស្សទាំងពីរក្រុមមានពេលតែ១០ទៅ១៥នាទី ដើម្បីពិភាក្សារកអំណះអំណាងការពារក្រុមខ្លួន។

**ជំហានទី៤**

បន្ទាប់ពីសិស្សពិភាក្សាគ្នារួចហើយ គ្រូត្រូវប្រាប់ពីលក្ខន្តិកៈនិងរយៈពេលដែលសមាជិកក្រុមនីមួយៗអាចឡើងនិយាយបាន។

**ជំហានទី៥**

បន្ទាប់ពីយល់លក្ខន្តិកៈ និងពេលវេលាដែលសមាជិកម្នាក់ៗមានហើយ គ្រូឱ្យសមាជិកស្របឡើងនិយាយមុន បន្ទាប់មកសមាជិករបស់ក្រុមជំទាស់ឡើងម្តងវិញ។ សមាជិកក្រុមនីមួយៗឡើងការពារគំនិតក្រុមរបស់ខ្លួនម្នាក់ម្តងៗ។សមាជិកទីប្រាំដែលជាសមាជិកចុងក្រោយនៃក្រុមទាំងពីរត្រូវឡើងមកនិយាយសរុបគាំទ្រឬជំទាស់របស់ក្រុមខ្លួន និងសុំឱ្យអ្នកវាយតម្លៃបោះឆ្នោតជូនពួកគេ។

បន្ទាប់ពីបោះឆ្នោតហើយ គ្រូប្រកាសក្រុមដែលបានសំឡេងឆ្នោតច្រើនជាងគេ ហើយគ្រូអាចពន្យល់អំពីមតិយោបល់ដែលខ្លួនមានចំពោះប្រធានបទ ការការពារមតិនោះផងដែរ។

## ១៧.វិធីបង្រៀន ការបង្កើតសំណួរចម្លើយ (Jeopardy)

**លំនាំ**

នៅក្នុងការសិក្សា សិស្សភាគច្រើនទន្ទេញមេរៀនឬចាំទទួលសំណួរពីគ្រូដើម្បីឱ្យដឹងថាខ្លួនត្រូវមើលកន្លែងណានៅក្នុងមេរៀនមុនពេលប្រឡង។ការធ្វើបែបនេះ ពេលខ្លះក៏យឺតពេលសម្រាប់សិស្សក្នុងការទន្ទេញមេរៀនឱ្យចាំទាំងអស់ឬក៏រកចម្លើយចំពោះសំណួរជាច្រើនដែលគ្រូដាក់ឱ្យដែរ។ ដូច្នេះ វិធីបង្រៀនការបង្កើតសំណួរចម្លើយ ត្រូវបានយកមកបង្រៀនសិស្សឱ្យចេះបង្កើតសំណួរ។ ពេលសិស្សចេះបង្កើតសំណួរហើយសិស្សអាចយកវិធីនេះទៅបង្កើតសំណួរនៅក្នុងមេរៀននីមួយៗដោយខ្លួនឯង និងរៀបចំចម្លើយត្រៀមទុកនៅពេលប្រឡងឬធ្វើតេស្តសាកល្បង ។

**វត្ថុបំណង**

- បង្វឹកសិស្សឱ្យចេះបង្កើតសំណួរនៅពេលអានមេរៀនឬដើម្បីត្រៀមខ្លួនប្រឡង
- បង្កើតបរិយាកាសសប្បាយរីករាយនៅក្នុងថ្នាក់រៀនផងដែរ។

**សម្ភារៈ**

បញ្ជីសំណួរចម្លើយ តារាងពិន្ទុ គ្រាប់ឡុកឡាក់

**រយៈពេល**

៤០នាទីទៅ៥០នាទី

## ដំណើរការបង្រៀន

### ជំហានទី១

គ្រូមើលមេរៀន និងបង្កើតបញ្ជីសំណួរចម្លើយដោយបែងចែកជាបួនប្រភេទ (ឬច្រើនជាងនេះប្រសិនបើមេរៀនវែង)។ គ្រូអាចបែងចែកប្រភេទទៅតាមចំណងជើងរងនៅក្នុងមេរៀនបាន។ ដូចនៅក្នុងមេរៀនទី១០ សំណួរចម្លើយត្រូវបែងចែកជាប្រភេទទៅតាមចំណងជើងរងនៅក្នុងសៀវភៅពោលគឺប្រភេទទី១:ការហ្វឹកហ្វឺនកូនជាង ប្រភេទទី២:កិច្ចសន្យាការងារ ប្រភេទទី៣:លក្ខខណ្ឌនៃការចូលបម្រើការងារ និងប្រភេទទី៤: គ្រោះថ្នាក់ការងារ។ នៅក្នុងប្រភេទនីមួយៗ គ្រូអាចមានអត្ថបទខ្លីៗចំនួន៥ ដើម្បីអានឱ្យសិស្សស្តាប់ និងបង្កើតសំណួរដែលត្រូវនឹងអត្ថបទខ្លីៗនោះ។ សិស្សដែលត្រូវបែងចែកជាក្រុមទៅតាមប្រភេទសំណួរ អាចជ្រើសរើសអត្ថបទតាមចិត្ត ពោលគឺអាចជ្រើសរើសនៅក្នុងប្រភេទតែមួយក៏បានឬឆ្លងទៅប្រភេទផ្សេងក៏បាន។ អត្ថបទដែលក្រុមសិស្សណាមួយជ្រើសរើសហើយ ក្រុមសិស្សផ្សេងទៀតមិនអាចជ្រើសរើសបានទេ ប៉ុន្តែបើក្រុមដែលរើសមុន ផ្តល់ចម្លើយមិនត្រូវ នោះក្រុមបន្ទាប់អាចផ្តល់ចម្លើយជំនួសបាន។ ក្នុងអត្ថបទខ្លីៗទាំងនោះមានពិន្ទុ៥ ១០ ១៥ ២០ និង២៥។ ឧទាហរណ៍ បើក្រុមណាជ្រើសរើស និងឆ្លើយត្រូវ អត្ថបទដែលបានពិន្ទុ១០ និងបានទទួល១០ពិន្ទុ ប៉ុន្តែបើឆ្លើយខុសនឹងត្រូវបាត់បង់១០ពិន្ទុវិញ។ ចំណែកឯក្រុមដែលអាចរកចម្លើយជំនួសឱ្យក្រុមមុន នឹងត្រូវបូកពិន្ទុពីក្រុមបាត់បង់ជាមួយនឹងពិន្ទុដែលឆ្លើយសំណួរត្រូវផងដែរ (ដូចក្នុងឧទាហរណ៍ខាងលើនេះដែរក្រុមដែលអាចឆ្លើយជំនួសត្រូវនឹងបានពិន្ទុ២០)។

| តារាងពិន្ទុ | | | |
|---|---|---|---|
| **ប្រភេទទី១** | **ប្រភេទទី២** | **ប្រភេទទី៣** | **ប្រភេទទី៤** |
| ៥ | ៥ | ៥ | ៥ |
| ១០ | ១០ | ១០ | ១០ |
| ១៥ | ១៥ | ១៥ | ១៥ |
| ២០ | ២០ | ២០ | ២០ |
| ២៥ | ២៥ | ២៥ | ២៥ |

### ជំហានទី២

គ្រូបែងចែកសិស្សជាបួនក្រុមទៅតាមប្រភេទសំណួរ រួចពន្យល់សិស្សពីលក្ខន្តិកៈ និងពិន្ទុ។

**ជំហានទី៣**

គ្រូឱ្យប្រធានក្រុមទាំងបួនក្រុមឡើងមកបោះគ្រាប់ឡុកឡាក់។ ក្រុមណាបានលេខច្រើនជាងគេអាចចាប់ផ្ដើមមុន។ ចំណែកក្រុមដែលមានលេខរៀងបន្ទាប់នឹងចាប់ផ្ដើមបន្ទាប់ពីក្រុមមុនផ្ដល់ចម្លើយរួច។ នៅពេលចាប់ផ្ដើម គ្រូឱ្យក្រុមរើសសមាជិកម្នាក់ដើម្បីឆ្លើយសំណួររួចឱ្យសមាជិកនោះរើសប្រភេទសំណួរ និងពិន្ទុដែលគេចង់បាន (ពិន្ទុមាន៥ ១០ ១៥ ២០ និង២៥)។ បន្ទាប់មកគ្រូអានអត្ថបទទៅតាមប្រភេទសំណួរ និងពិន្ទុនោះ ឯសិស្សដែលជាសមាជិកត្រូវបង្កើតសំណួរតបទៅអត្ថបទនោះ។ ប្រសិនបើឆ្លើយត្រូវនឹងបានពិន្ទុទៅតាមនោះ ប៉ុន្តែបើខុសនឹងត្រូវកាត់ទៅឱ្យក្រុមបន្ទាប់ដែលបានឆ្លើយត្រូវ។ ប្រសិនបើឆ្លើយមិនត្រូវទាំងអស់គ្នា គឺកាត់ពិន្ទុទាំងអស់គ្នា។

**ជំហានទី៤**

គ្រូឱ្យសិស្សទាំងអស់បង្កើតសំណួរដើម្បីឆ្លើយតបទៅនឹងអត្ថបទមេរៀនទាំង២០ រួចហើយសរុបពិន្ទុដោយប្រកាសថាក្រុមណាបានពិន្ទុច្រើនជាងគេ។ ជាចុងបញ្ចប់គ្រូអាចពន្យល់សិស្សពីសារៈសំខាន់នៃការបង្កើតសំណួរនៅពេលអានអត្ថបទ ដើម្បីត្រៀមខ្លួនប្រឡងជាបណ្ដើរៗ។

# ៣. វិធីសាស្ត្របង្រៀន
# ពលរដ្ឋវិជ្ជា
# ថ្នាក់ទី១០ ទី១១



# ថ្នាក់ទី១០

<table>
<tr><td>ជំពូក៣</td><td colspan="2">ការចូលរួមអភិវឌ្ឍសហគមន៍</td></tr>
<tr><td>មេរៀនទី</td><td colspan="2">៤</td></tr>
<tr><td>ចំណងជើងមេរៀន</td><td colspan="2">សិទ្ធិនិងករណីយកិច្ច</td></tr>
<tr><td>ពណ៌នាអំពីមេរៀនដោយសង្ខេប</td><td colspan="2">សិទ្ធិមនុស្សគឺអ្វីៗទាំងអស់ដែលមនុស្សត្រូវការជាចាំបាច់សម្រាប់ឱ្យមនុស្សរស់នៅបានក្នុងសេចក្ដីថ្លៃថ្នូរជាមនុស្ស។ មនុស្សគ្រប់រូបមានសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិវប្បធម៌ សិទ្ធិសង្គមកិច្ច សិទ្ធិពលរដ្ឋ។ ករណីយកិច្ចជាកិច្ចដែលប្រជាពលរដ្ឋត្រូវបំពេញ។ ប្រជាពលរដ្ឋម្នាក់ៗត្រូវបំពេញករណីយកិច្ចតាមច្បាប់របស់រដ្ឋដែលបានកំណត់។ប្រជាពលរដ្ឋមានសិទ្ធិ និងករណីយកិច្ចចូលរួមអភិវឌ្ឍប្រទេសជាតិតាមសមត្ថភាពរៀងៗខ្លួន មិនបង្កភាពអសកម្មដល់សង្គម និងចូលរួមគោរពច្បាប់សង្គម។</td></tr>
<tr><td rowspan="3">វត្ថុបំណង</td><td>១</td><td>• រៀបរាប់ពីនិយមន័យសិទ្ធិ ករណីយកិច្ចពលរដ្ឋ<br>• ពណ៌នាពីសិទ្ធិផ្សេងៗរបស់ពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ។</td></tr>
<tr><td>២</td><td>• ប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងនាមជាពលរដ្ឋដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរ<br>• ប្រើប្រាស់និងគោរពសិទ្ធិជនជាតិភាគតិចផ្សេង។</td></tr>
<tr><td>៣</td><td>• ប្រកាន់ខ្ជាប់ភាពជាពលរដ្ឋល្អដែលចេះប្រើប្រាស់សិទ្ធិតាមគោលការណ៍ច្បាប់។</td></tr>
<tr><td rowspan="3">សម្ភារៈ</td><td colspan="2">សៀវភៅសិស្ស</td></tr>
<tr><td colspan="2">ផ្ទាំងរូបភាព</td></tr>
<tr><td colspan="2">តារាងបីខ្ទង់(៣កូឡោន)(ខ្ញុំដឹងអ្វី/ខ្ញុំចង់ដឹងអ្វី/ខ្ញុំរៀនអ្វី)</td></tr>
<tr><td>រយៈពេល</td><td colspan="2">៣ម៉ោង</td></tr>
</table>

## ដំណើរការបង្រៀន

### ការចាប់ផ្ដើមមេរៀន

គ្រូៈ សួស្តីប្អូនៗ តើប្អូនៗសុខសប្បាយជាទេថ្ងៃនេះ?ថ្ងៃនេះយើងនឹងសិក្សាមេរៀនអំពីសិទ្ធិនិងករណីយកិច្ច។ នៅក្នុងប្រទេសនានានៅលើពិភពលោក ការទទួលស្គាល់ និងការជំរុញឱ្យមានការការពារសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋបានប្រព្រឹត្តទៅយ៉ាងទូលំទូលាយ។ តើប្អូនៗដឹងទេថា អ្វីជាសិទ្ធិនិងអ្វីជាករណីយកិច្ច ?

### មេរៀនថ្មី

គ្រូប្រើវិធីបង្រៀន ខ្ញុំដឹងអ្វី / ខ្ញុំចង់ដឹងអ្វី/ ខ្ញុំរៀនអ្វី(K/W/L)

គ្រូៈ ដើម្បីដឹងថា ប្អូនៗមានចំណេះដឹងអ្វីខ្លះទាក់ទងនឹងសិទ្ធិនិងករណីយកិច្ច ថ្ងៃនេះប្អូនត្រូវឆ្លើយសំណួរក្នុងតារាងខាងក្រោម(គ្រូចែកក្រដាសឬចម្លងតារាងខាងក្រោមដាក់លើក្ដារខៀន)។ យើងជួយរកចម្លើយនិងចែករំលែកចំណេះដឹងពីគ្នាទៅវិញទៅមក។

| តើប្អូនបានដឹងអ្វីអំពីសិទ្ធិ? និងអ្វីជាករណីយកិច្ច? | តើប្អូនចង់ដឹងអំពីអ្វីទៀត? | តើប្អូនបានរៀនចេះអ្វីខ្លះ? |
|---|---|---|
| ................................................<br>................................................<br>................................................<br>................................................ | ................................................<br>............................................<br>................................................<br>................................................ | ................................................<br>................................................<br>................................................<br>................................................ |

គ្រូៈ ឥឡូវប្អូនណាស្ម័គ្រចិត្តជួយចែករំលែកចំណេះដឹងទាក់ទងនឹងនិយមន័យសិទ្ធិនិងករណីយកិច្ច សូមប្អូនលើកដៃនិងឡើងឆ្លើយ។ គ្រូនឹងសរសេរចម្លើយរបស់ប្អូននៅក្នុងខ្ទង់(កូឡោន)ទី១ (គ្រូលើកទឹកចិត្ត និងជំរុញសិស្សឱ្យឆ្លើយបានច្រើននាក់) ។

**ចម្លើយរំពឹងទុកៈ**

តើសិទ្ធិជាអ្វី? តើករណីយកិច្ចជាអ្វី?

-សិទ្ធិគឺជាអ្វីដែលមនុស្សម្នាក់ៗមានតាំងពីកំណើតមក។សិទ្ធិគឺអ្វីៗដែលមនុស្សត្រូវការជាចាំបាច់ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរជាមនុស្ស។ មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីធ្វើសកម្មភាពឬសម្រេចចិត្តធ្វើអ្វីមួយដោយសេរីតែមិនឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍អ្នកដទៃឡើយ។

-ករណីយកិច្ច ជាកិច្ចដែលត្រូវធ្វើ ត្រូវបំពេញ ឬជាកិច្ចការដែលពលរដ្ឋម្នាក់ៗត្រូវចូលរួមបំពេញដើម្បីជាប្រយោជន៍សាធារណៈ។

គ្រូៈ ឥឡូវយើងបានចម្លើយជាច្រើន។ នេះបញ្ជាក់ឱ្យឃើញថាប្អូនបានយល់ដឹងយ៉ាងច្រើនពីនិយមន័យសិទ្ធិនិងករណីយកិច្ច។ ឥឡូវគ្រូចង់ដឹងថា តើប្អូនមានសំណួរ ឬចង់

| |
|---|
| ដឹងអំពីអ្វីបន្ថែមទៀតទាក់ទងនឹងសិទ្ធិ និងករណីយកិច្ចដែរឬទេ(គ្រូជំរុញសិស្សឱ្យសួរសំណួរទាក់ទងទៅនឹងវត្ថុបំណងនៃមេរៀន)នៅពេលសិស្សសួរសំណួរ គ្រូសរសេរសំណួរទាំងនោះដាក់នៅក្នុងខ្ទង់(កូឡោន)ទី២ ហើយប្រាប់ទៅសិស្សថាប្អូននឹងស្វែងរកចម្លើយនៅក្នុងសៀវភៅសិក្សាគោល។<br>**ចម្លើយរំពឹងទុក៖**<br>តើប្អូនចង់ដឹងអំពីអ្វីទៀត?<br>• តើហេតុអ្វីបានជាមនុស្សយើងចាំបាច់ត្រូវមានសិទ្ធិ?<br>• តើករណីយកិច្ចរបស់ប្រជាពលរដ្ឋមានអ្វីខ្លះ?<br>• ប្រសិនបើមានគេរំលោភសិទ្ធិរបស់យើង តើយើងត្រូវធ្វើដូចម្ដេច?<br>• តើករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការជួយអភិវឌ្ឍសហគមន៍មានអ្វីខ្លះ?<br>• ហេតុអ្វីបានជាយើងត្រូវគោរពសិទ្ធិរបស់អ្នកដទៃ? |
| គ្រូ: ឥឡូវគ្រូឱ្យប្អូនៗចាប់ដៃគូគ្នាជាមួយអ្នកអង្គុយនៅក្បែរប្អូន រួចរកមើលចម្លើយនៃសំណួរទាំងអស់ និងកត់ត្រាដាក់ក្នុងសៀវភៅសរសេររបស់ប្អូន។ |
| នៅពេលសិស្សរកចម្លើយឃើញហើយ គ្រូជ្រើសរើសឱ្យក្រុមដៃគូនីមួយៗឡើងឆ្លើយសំណួរខាងលើ និងសរសេរចម្លើយទាំងនោះនៅក្នុងខ្ទង់(កូឡោន)ទី៣។<br>**ចម្លើយរំពឹងទុក៖**<br>តើយើងបានរៀនចេះអ្វីខ្លះ?<br>- សិទ្ធិមនុស្សគឺអ្វីៗទាំងអស់ដែលមនុស្សត្រូវការជាចាំបាច់សម្រាប់ឱ្យមនុស្សរស់ក្នុងសេចក្ដីថ្លៃថ្នូរជាមនុស្ស។<br>- ករណីយកិច្ច ជាកិច្ចដែលត្រូវធ្វើ ជាកិច្ចដែលប្រជាពលរដ្ឋត្រូវបំពេញតាមច្បាប់រដ្ឋបានចែងសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។<br>- ករណីយកិច្ចរបស់ប្រជាពលរដ្ឋមានដូចជា ការគោរពច្បាប់ កិច្ចការពារសិទ្ធិរបស់ខ្លួន ការគោរពសិទ្ធិអ្នកដទៃ ការចូលរួមអភិវឌ្ឍសង្គម។<br>- ប្រសិនបើមានគេរំលោភសិទ្ធិ យើងអាចប្ដឹងទៅតុលាការ។ តុលាការអាចរកយុត្តិធម៌ និងអាចសម្រេចឱ្យអ្នកប្រព្រឹត្តិខុសចេញជាសំណង ឬដាក់ទោសជាប់ពន្ធនាគារ។<br>- ករណីយកិច្ចរបស់ប្រជាពលរដ្ឋគឺ រួមចំណែកក្នុងការអភិវឌ្ឍសង្គម ដូចជាធ្វើជាមនុស្សល្អ មិនបង្កភាពអសកម្មដល់សង្គម ពង្រីកជំនាញ ទទួលខុសត្រូវចំពោះសេដ្ឋកិច្ចគ្រួសារ គោរពច្បាប់ពន្ធដារ មិនគេចវេះការបង់ពន្ធ រត់ពន្ធខុសច្បាប់ ។<br>- មូលហេតុដែលយើងត្រូវគោរពសិទ្ធិអ្នកដទៃដោយសារទាក់ទងនឹងច្បាប់ដែលយើង |

| |
|---|
| ត្រូវគោរព។ បុគ្គលទាំងអស់ត្រូវមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់ តាមមាត្រា២៩ នៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សបានចែងថា មនុស្សគ្រប់រូបសុទ្ធតែមានកាតព្វកិច្ចក្នុងការគោរពសិទ្ធិអ្នកដទៃ។ ចំណែកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានទទួលស្គាល់សិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗផងដែរ។ កាលណាយើងរំលោភសិទ្ធិអ្នកដទៃ នោះយើងនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ |
| **ការពង្រឹងពុទ្ធិ**<br>បន្ទាប់ពីសិស្សបានឡើងឆ្លើយសំណួរដែលពួកគេបានឆ្លល់រួចហើយគ្រូឱ្យសិស្សអានចម្លើយទាំងនោះម្តងទៀតជាការសង្ខេប ឬពន្យល់នូវអ្វីដែលពួកគេបានរៀនក្នុងមេរៀននោះ។ បន្ទាប់មកទៀតគ្រូឱ្យសិស្សទាំងអស់កត់ត្រាចម្លើយពីក្នុងខ្ទង់(កូឡោន) ទាំង៣ដាក់ចូលក្នុងសៀវភៅសរសេររបស់ពួកគេរៀងៗខ្លួន។ |
| **កិច្ចការផ្ទះ**<br>ចូរអានសំណួរហើយរកចម្លើយក្នុងករណីសិក្សាខាងក្រោម៖<br>១.តើប្តីបងមុំបានរំលោភសិទ្ធិអ្វីខ្លះមកលើបងមុំ និងកូនៗ?<br>២.តើហេតុអ្វីបានជាបងមុំមិនព្រមប្តឹងប្តីរបស់គាត់?តើការគិតបែបនោះត្រឹមត្រូវដែរឬទេ?<br>៣.ប្រសិនបើប្អូនជាអ្នកជិតខាងរបស់បងមុំ តើប្អូននឹងធ្វើអ្វីដើម្បីជួយបងមុំ?<br><u>ករណីសិក្សា : អំពើហិង្សានៅក្នុងគ្រួសារបងមុំ</u><br>បងមុំមានស្វាមីនិងកូនបីនាក់។ ប្តីបងមុំជាអ្នកដើរលក់ទំនិញឱ្យក្រុមហ៊ុនមួយ។ ប្តីបងមុំចូលចិត្តជួបជុំមិត្តភក្តិនិងផឹកសុរាណាស់។ ពេលមកផ្ទះម្តងៗ ប្តីបងមុំតែងរករឿងវាយធ្វើបាបប្រពន្ធកូនមិនសូវដែលខានឡើយ។ បងមុំមិនចង់ប្តឹងប្តីរបស់គាត់ទៅតុលាការទេ ព្រោះខ្លាចគ្មាននរណារកស៊ីចិញ្ចឹមកូនៗរបស់គាត់។ ថ្ងៃមួយបងមុំ និងប្តីរបស់គាត់បានឈ្លោះគ្នាយ៉ាងខ្លាំង ដោយសារប្តីរបស់គាត់ចង់ឱ្យកូនស្រីឈប់រៀនហើយទៅបម្រើនៅផ្ទះថៅកែរបស់គាត់នៅក្រុងភ្នំពេញ។ តែបងមុំមិនយល់ស្របតាមធ្វើឱ្យប្តីគាត់ខឹងយ៉ាងខ្លាំងរួចស្តីបន្ទោស និងរុញបងមុំឱ្យដួលបែកក្បាល។ អ្នកជិតខាងបានជួយបញ្ជូនបងមុំទៅមណ្ឌលសុខភាព។ ពេលបងមុំមានស្ថានភាពសុខភាពល្អឡើងវិញ អ្នកជិតខាងបានប្រាប់គាត់ឱ្យប្តឹងប្តីគាត់ទៅតុលាការ ព្រោះពួកគាត់បារម្ភថាប្តីរបស់គាត់អាចប្រើអំពើហិង្សាធ្ងន់ធ្ងរជាងនេះនៅថ្ងៃក្រោយទៀត។ ប៉ុន្តែបងមុំបានត្រឹមតែយំ ពុំព្រមប្តឹងប្តីរបស់គាត់ទេ។ |

<table>
<tr><td>ជំពូក៣</td><td colspan="2">ការចូលរួមអភិវឌ្ឍសហគមន៍</td></tr>
<tr><td>មេរៀនទី</td><td colspan="2">៥</td></tr>
<tr><td>ចំណងជើងមេរៀន</td><td colspan="2">ការសម្តែងមតិ</td></tr>
<tr><td>ពណ៌នាអំពីមេរៀនដោយសង្ខេប</td><td colspan="2">ក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការសម្តែងមតិ តវ៉ាចំពោះអ្វីដែលខ្លួនពុំពេញចិត្តឬគិតថាបាត់បង់ផលប្រយោជន៍របស់ខ្លួន ប៉ុន្តែសេរីភាពនៃការបញ្ចេញមតិត្រូវមានការទទួលខុសត្រូវ ហើយត្រូវប្រើប្រាស់ឱ្យស្របតាមច្បាប់។<br>ការសម្តែងមតិជាការបញ្ចេញសំឡេង ជាមធ្យោបាយប្រាប់អ្វីដែលកើតឡើង និងត្រូវរកវិធីដោះស្រាយ មានការទទួលខុសត្រូវ ត្រូវមានក្រមសីលធម៌មិនត្រូវប៉ះពាល់ដល់សិទ្ធិបុគ្គល កិត្តិយស សេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះអ្នកដទៃ។ ការសម្តែងមតិអាចធ្វើឡើងតាមរយៈសារព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ បណ្តាញទំនាក់ទំនងសង្គម ហើយត្រូវមានក្រមសីលធម៌ គោរពសច្ចធម៌ សុចរិតភាព សាមគ្គីភាព ប្រើរូបភាពថ្លៃថ្នូរ ។ល។</td></tr>
<tr><td rowspan="3">វត្ថុបំណង</td><td>១</td><td>ប្រាប់បានពីសិទ្ធិក្នុងការបញ្ចេញមតិនិងគោលការណ៍នៃការសម្តែងមតិតាមរយៈសារព័ត៌មាន។</td></tr>
<tr><td>២</td><td>កំណត់បានពីសារៈសំខាន់នៃសេរីភាពក្នុងការបញ្ចេញមតិនិងការទទួលខុសត្រូវ។</td></tr>
<tr><td>៣</td><td>មានស្មារតីទទួលខុសត្រូវក្នុងការបញ្ចេញមតិ។</td></tr>
<tr><td rowspan="4">សម្ភារៈ</td><td colspan="2">សៀវភៅសិស្ស</td></tr>
<tr><td colspan="2">រូបភាពការបំពុលបរិស្ថាន</td></tr>
<tr><td colspan="2">រូបភាពការសម្តែងមតិ</td></tr>
<tr><td colspan="2">សំបុកពីងពាង/ បណ្តាញពិភាក្សា (Discussion Web)</td></tr>
<tr><td>រយៈពេល</td><td colspan="2">២ម៉ោង</td></tr>
</table>

| ដំណើរការបង្រៀន |
| --- |
| **ការចាប់ផ្ដើមមេរៀន**<br>គ្រូនិយាយសួស្ដីទៅកាន់សិស្ស រួចហើយប្រាប់សិស្សអំពីមេរៀនដែលពួកគេត្រូវរៀន និងអំពីវត្ថុបំណងនៃមេរៀន។ បន្ទាប់មកគ្រូលើកបង្ហាញរូបភាពបីទាក់ទងនឹងការសម្ដែងមតិ រួចបិទនៅលើក្ដារខៀន (គួរមានរូបយុវជនចូលរួមផងដែរ) រួចសួរទៅសិស្សថា តើពួកគេកំពុងធ្វើអ្វី និងហេតុអ្វីបានជាពួកគេធ្វើដូចនេះនៅក្នុងរូបភាពនីមួយៗ?ពេលសិស្សឆ្លើយសំណួរ គ្រូសរសេរចម្លើយដាក់នៅក្រោមរូបភាពនីមួយៗ។ |
| **ចម្លើយរំពឹងទុកៈ**<br>រូបភាពទី១ កម្មករកំពុងធ្វើបាតុកម្មទាមទារការគោរពសិទ្ធិ។<br>រូបភាពទី២ សិស្សកំពុងតែបញ្ចេញមតិទាក់ទងនឹងការបំពុលបរិស្ថាន។<br>រូបភាពទី៣ ស្ត្រីកំពុងតវ៉ាទាមទារឱ្យបញ្ឈប់អំពើហិង្សា។ |
| គ្រូៈ ល្អណាស់ ចម្លើយរបស់ប្អូនសុទ្ធតែត្រឹមត្រូវ។ ប៉ុន្តែតើប្អូនដឹងទេថា តើពេលណាទើបគេអាចសម្ដែងមតិបាន? ហេតុអ្វីបានជាគេអាចសម្ដែងមតិបាន? តើការសម្ដែងមតិនោះអាចធ្វើតាមវិធីណាខ្លះ និងត្រូវធ្វើដូចម្ដេចទើបការសម្ដែងមតិនោះប្រកបដោយទំនួលខុសត្រូវ និងស្របទៅតាមច្បាប់? តើការសម្ដែងមតិមានសារៈសំខាន់ដែរឬទេ? |
| **មេរៀនថ្មី**<br>គ្រូៈ ដើម្បីរកចម្លើយនៃសំណួរទាំងបីនេះ ចូរប្អូនៗស្ដាប់គ្រូអានខ្លឹមសារសំខាន់ៗនៃមេរៀនហើយកត់ត្រាចម្លើយដែលឆ្លើយតបទៅនឹងសំណួរទាំងបី រួចគ្រូនឹងហៅប្អូនមួយចំនួនឱ្យឡើងឆ្លើយ។<br>គ្រូៈ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ តវ៉ាចំពោះអ្វីដែលខ្លួនមិនពេញចិត្ត ឬគិតថាបាត់បង់ផលប្រយោជន៍របស់ខ្លួន។ ដូចក្នុងរូបភាពរបស់យើងយុវជនអាចបញ្ចេញមតិតវ៉ានៅពេលដែលមានការបំពុលបរិស្ថានពីរោងចក្រ ការចោលសំរាមទៅក្នុងទឹក ឬនៅទីសាធារណៈ។ កម្មករអាចតវ៉ារឿងការបញ្ឈប់ពីការងារដោយមិនសមហេតុផល ការបង្ខំឱ្យធ្វើការបន្ថែមម៉ោងឬការសម្ដែងមតិទាក់ទងនឹងការប្រើប្រាស់អំពើហិង្សានៅក្នុងគ្រួសារឬការរើសអើងដល់ជនពិការជាដើម។<br>គ្រូៈ ឥឡូវតើប្អូនណាអាចឆ្លើយបានថា តើក្នុងករណីណាទើបគេធ្វើការសម្ដែងមតិ? |
| **ចម្លើយរំពឹងទុកៈ**<br>• គេអាចសម្ដែងមតិក្នុងករណីដែលមានការរំលោភបំពានសិទ្ធិនិងផលប្រយោជន៍របស់ខ្លួន |

- គេអាចសម្តែងមតិក្នុងករណីមានក្រុមហ៊ុនឬបុគ្គលណាម្នាក់ព្យាយាមធ្វើឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គលណាម្នាក់។

គ្រូ: ល្អណាស់។ ឥឡូវគ្រូអានបន្តទៀត។ តាមសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សត្រង់មាត្រា១៩បានចែងថា មនុស្សគ្រប់រូបមានសិទ្ធិ សេរីភាពក្នុងការប្រកាន់គំនិត និងការសម្តែងមតិ។ សិទ្ធិនេះរួមមានសេរីភាពក្នុងការប្រកាន់ និងបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក គ្មានការបារម្ភភិតភ័យដោយសារមតិរបស់ខ្លួន និងសេរីភាពក្នុងការស្វែងរកនិងផ្សព្វផ្សាយព័ត៌មានព្រមទាំងគំនិតរបស់ខ្លួនស្របទៅតាមច្បាប់ដែលបានកំណត់។ ប្រទេសកម្ពុជាយើងក៏បានគាំទ្រសេចក្តីថ្លែងការណ៍នេះផងដែរ។
គ្រូ: តើប្អូនណាអាចឆ្លើយបានថា ហេតុអ្វីបានជាយើងមានសិទ្ធិបញ្ចេញមតិនិងតវ៉ា?

**ចម្លើយរំពឹងទុកៈ**

- ច្បាប់
- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស
- រាល់ប្រទេសទាំងអស់ជាសមាជិកដែលបានទទួលស្គាល់សេចក្តីថ្លែងការណ៍ជាសកលត្រូវធានាឱ្យបានការគោរពសិទ្ធិបញ្ចេញមតិ។ ប្រទេសកម្ពុជាក៏ជារដ្ឋសមាជិកដែលបានទទួលស្គាល់សេចក្តីថ្លែងការណ៍នោះ ដូចនេះហើយប្រជាជនកម្ពុជាទាំងអស់មានសិទ្ធិក្នុងការសម្តែងមតិដែលច្បាប់បានកំណត់។

គ្រូ: ពិតជាល្អមែនប្អូនៗ។
គ្រូអានបន្តៈ ប្រទេសកម្ពុជាបានផ្តល់សិទ្ធិសេរីភាពក្នុងការសម្តែងមតិដោយសេរីចំពោះបុគ្គលសាធារណៈ ឬប្រឆាំងតវ៉ាចំពោះនិយោជក ប្រសិនបើពួកគេរងការគាបសង្កត់ដោយមធ្យោបាយណាមួយឬសកម្មភាពដែលខុសច្បាប់បញ្ញត្តិបានចែង។ ប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានបើកទូលាយដូចជាសារព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ដែលជាឧបករណ៍ដើម្បីសម្តែងមតិជាសាធារណៈ។ ប្រជាពលរដ្ឋមានសិទ្ធិតវ៉ាគ្រប់យ៉ាងតាម រយៈការសុំច្បាប់ធ្វើកូដកម្ម បាតុកម្ម ឬតវ៉ារាល់អ្វីដែលខ្លួនគិតថាជាការរំលោភសិទ្ធិរបស់ខ្លួន។ ប៉ុន្តែការសម្តែតមតិ ការធ្វើបាតុកម្មឬការសម្តែងមតិដោយមធ្យោបាយផ្សេងៗក្តី ពុំត្រូវធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់ ទ្រព្យសម្បត្តិសាធារណៈ ឬបុគ្គលនិងរំលោភបំពានដល់សិទ្ធិសេរីភាពរបស់អ្នកដទៃឡើយ។

គ្រូសួរៈ តើប្អូនណាអាចឆ្លើយសំណួរបានទេថា តើការសម្តែងមតិនោះអាចធ្វើតាមវិធីណាខ្លះ និងត្រូវធ្វើយ៉ាងណាទើបការសម្តែងមតិនោះប្រកបដោយទំនួលខុសត្រូវ និងស្របទៅតាមច្បាប់?

**ចម្លើយរំពឹងទុកៈ**

- ការសម្តែងមតិអាចធ្វើតាមរយៈការសរសេរនៅក្នុងទស្សនាវដ្តី សារព័ត៌មានប៉ុន្តែការសម្តែងមតិនេះមិនត្រូវប៉ះពាល់ដល់កិត្តិយស សិទ្ធិសេរីភាពរបស់អ្នកដទៃឡើយ
- គេក៏អាចសម្តែងមតិតាមវិទ្យុ ឬទូរទស្សន៍ដែរ ប៉ុន្តែការសម្តែងមតិនោះត្រូវតែជាការពិតជាក់ស្តែងមិនមែនធ្វើឡើងដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួននិងដើម្បីញុះញង់បង្កឱ្យមានភាពចលាចល ឬហិង្សាទេ។
- គេអាចសម្តែងមតិតាមរយៈការធ្វើបាតុកម្ម ឬកូដកម្ម ប៉ុន្តែគេត្រូវធ្វើយ៉ាងណាសុំច្បាប់អនុញ្ញាត ហើយមិនត្រូវបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ ទ្រព្យសម្បត្តិ និងសិទ្ធិសេរីភាពរបស់អ្នកដទៃឡើយ។

**ការពង្រឹងពុទ្ធិ**( Discussion Web)

គ្រូ: ឥឡូវយើងយល់ដឹងអំពីអ្វីជាការសម្តែងមតិ ពីសិទ្ធិក្នុងការសម្តែងមតិ និងមធ្យោបាយនានាក្នុងការសម្តែងមតិ។ គ្រូចង់ឱ្យប្អូនៗពិភាក្សាគ្នាថា តើការសម្តែងមតិគួរប្រើហិង្សាដែរឬទេ? ប្អូនៗត្រូវចាប់ដៃគូគ្នាពីរនាក់ រួចរកមូលហេតុ៣ ឬ៤ ដែលគាំទ្រថាមិនគួរប្រើហិង្សា និងមូលហេតុ៣ ឬ៤ដែលគាំទ្រឱ្យប្រើហិង្សា។ បន្ទាប់មកពិភាក្សាគ្នាថា តើប្អូនជ្រើសរើសយកមួយណា។(គ្រូចែកក្រដាស Discussion Web ក៏បានឬគូសលើក្តារខៀន ហើយឱ្យសិស្សចម្លងដាក់ក្នុងក្រដាស ឬសៀវភៅសរសេរក៏បាន។

តារាងការពិភាក្សា

| ខ្ញុំយល់ស្រប | មូលហេតុ | ខ្ញុំមិនយល់ស្រប | មូលហេតុ |
|---|---|---|---|
| ....................................<br>....................................<br>....................................<br>.................................... | ....................................<br>....................................<br>....................................<br>.................................... | ....................................<br>....................................<br>....................................<br>.................................... | ....................................<br>....................................<br>....................................<br>.................................... |

យោបល់សរុប:

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................។

**កិច្ចការផ្ទះ**

គ្រូដាក់កិច្ចការឱ្យសិស្សៈចូរសរសេរសំបុត្រចំហជំរុញឪពុកម្តាយ អាណាព្យាបាលសិស្សឱ្យបំពេញកាតព្វកិច្ចបញ្ជូនកូនទៅសាលារៀន។

សេចក្តីព្រាង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សំបុត្រចំហ**

**ជូនចំពោះឪពុកម្តាយ អាណាព្យាបាលសិស្ស**

កម្មវត្ថុ: សំណើសុំបញ្ជូនកូនដែលគ្រប់អាយុនិងកុមារមានអាយុច្រើនមិនបានទៅចូលរៀនឱ្យទៅសាលារៀន

សូមគោរពជូនលោកឪពុកអ្នកម្តាយ អាណាព្យាបាលដែលមានកូនគ្រប់អាយុ និងកុមារដែលមានអាយុច្រើនហើយមិនបានទៅចូលរៀន សូមបញ្ជូនកូន និងកុមារឱ្យបានចូលរៀនគ្រប់ៗគ្នា។

- រៀបរាប់អំពីផលប្រយោជន៍នៃការអប់រំ
- រៀបរាប់អំពីសិទ្ធិសំខាន់ៗរបស់កុមារ ច្បាប់អប់រំ
- សរុបសេចក្តីដោយពន្យល់តម្លៃនៃការអប់រំ
- សេចក្តីថ្លែងអំណរគុណ។

ថ្ងៃ..................... ខែ.................... ឆ្នាំ........ព.ស.២៥៦២

ថ្ងៃទី...... ខែ..... ឆ្នាំ ២០...

ហត្ថលេខាននិងឈ្មោះអ្នកស្នើសុំ

| | | |
|---|---|---|
| **ជំពូក៣** | **ការចូលរួមអភិវឌ្ឍសហគមន៍** | |
| **មេរៀនទី** | ៦ | |
| **ចំណងជើងមេរៀន** | **កិច្ចការពារសិទ្ធិរបស់ខ្លួន** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | មនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់។ ច្បាប់រ៉ាប់រងការពារអាយុជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សម្នាក់ៗមិនឱ្យមានការរំលោភបំពានលើរូបរាងកាយមនុស្សណាម្នាក់ឡើយ។ ការចោទប្រកាន់ ការចាប់ឬឃាត់ខ្លួនឬឃុំខ្លួនមនុស្សណាម្នាក់ត្រូវឱ្យជនជាប់ចោទ ឬជនសង្ស័យមានវិធីការពារខ្លួនដើម្បីចៀសវាងការរំលោភសិទ្ធិ។ ជនសង្ស័យមានសិទ្ធិរកសាក្សីឬមេធាវី សួររកដីកាកោះហៅ និងមានសិទ្ធិប្តឹងសុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួន។ | |
| **វត្ថុបំណង** | ១ | - ពណ៌នាពីទង្វើផ្សេងៗដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស<br>- ពណ៌នាពីតួនាទី និងសិទ្ធិរបស់មេធាវី។ |
| | ២ | - បង្ហាញពីនីតិវិធីនិងកិច្ចការពារខ្លួនកុំឱ្យមានការរំលោភសិទ្ធិមនុស្ស<br>- អនុវត្តកិច្ចការពារសិទ្ធិរបស់ខ្លួននិងជួយទាមទារសិទ្ធិឱ្យបុគ្គលណាម្នាក់ដែលត្រូវគេរំលោភសិទ្ធិ។ |
| | ៣ | - បណ្តុះស្មារតីគោរពសិទ្ធិនិងទប់ស្កាត់ការរំលោភសិទ្ធិអ្នកដទៃ។ |
| **សម្ភារៈ** | សៀវភៅសិក្សាគោល | |
| | រូបភាពដើមឈើ(Problem Tree) | |
| | តារាងពន្យល់ពាក្យគន្លឹះ | |
| **រយៈពេល** | **៣ម៉ោង** | |

## ដំណើរការបង្រៀន

### ការចាប់ផ្ដើមមេរៀន

យើងបានសិក្សាមេរៀនមុនៗរួចមកហើយអំពីសិទ្ធិ។វាមានសារៈសំខាន់ណាស់សម្រាប់យើង គ្រួសារយើង សហគមន៍យើង និងប្រទេសជាតិរបស់យើង។ នៅពេលដែលមានការរំលោភសិទ្ធិ នោះយើង ក្រុមគ្រួសាររបស់យើង ប្រទេសជាតិរបស់យើងពិតជាទទួលការធ្វើទុក្ខបុកម្នេញជាក់ជាពុំខានទេ។ ដូចនៅក្នុងសម័យខ្មែរក្រហមអញ្ចឹងប្រជាជនខ្មែរយើងបានទទួលរងនូវការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ។តើប្អូនៗបានដឹងឮពីឪពុកម្ដាយ សាច់ញាតិ ឬពីអ្នកដទៃ ថាតើហេតុអ្វីបានជាមានការរំលោភសិទ្ធិមនុស្សនៅក្នុងសម័យខ្មែរក្រហម?

### មេរៀនថ្មី




គ្រូគូររូបដើមឈើរួចសរសេរពាក្យថា " ការរំលោភសិទ្ធិមនុស្សនៅសម័យខ្មែរក្រហម " នៅលើដើមឈើ បន្ទាប់មកគ្រូលើកទឹកចិត្តសិស្សឱ្យផ្ដល់ចម្លើយ ដោយមានហេតុផលដែលនាំឱ្យមានការរំលោភសិទ្ធិមនុស្សនៅសម័យនោះ។ សិស្សរក និងសរសេរចម្លើយទាំងនោះនៅឫសឈើ។

| |
|---|
| **ចម្លើយរំពឹងទុក៖**<br>ការរំលោភសិទ្ធិមនុស្សនៅសម័យនោះកើតមានឡើងដោយសារ៖<br>• គ្មានច្បាប់ការពារសិទ្ធិសេរីភាពរបស់ប្រជាជន<br>• គ្មានតុលាការឯករាជ្យ យុត្តិធម៌ដែលប្រជាជនអាចសុំឱ្យស្វែងរកយុត្តិធម៌ដល់ខ្លួនបាន ទាំងរដ្ឋាភិបាល ទាំងមន្ត្រីពង្រឹងច្បាប់ គឺជាអ្នករំលោភសិទ្ធិសេរីភាពរបស់ប្រជាជន<br>• គ្មានយន្តការប្ដឹងផ្ដល់ត្រឹមត្រូវនៅតាមមូលដ្ឋានទេ<br>• សមាជិកសភាដែលជាតំណាងប្រជាជន គ្មានសិទ្ធិអំណាចការពារសិទ្ធិ សេរីភាព និងផលប្រយោជន៍របស់ប្រជាជនទេ។ |
| គ្រូ: អរគុណណាស់ដែលប្អូនៗបានផ្ដល់ចម្លើយយ៉ាងត្រឹមត្រូវ។តើប្អូនៗធ្លាប់ឮ ឬដឹងថា ការរំលោភសិទ្ធិមនុស្សនៅសម័យនោះនាំឱ្យប្រជាជនកម្ពុជារងទុក្ខអ្វីខ្លះដែរឬទេ?<br>**ចម្លើយរំពឹងទុក៖**<br>• នៅសម័យខ្មែរក្រហមមានការបង្ខំប្រជាជនឱ្យធ្វើការធ្ងន់ធ្ងរ<br>• ការសម្លាប់មនុស្សដោយមិនបានកាត់ក្ដីត្រឹមត្រូវពីតុលាការនិងគ្មានការការពារពីមេធាវីទេ<br>• ការហាមឃាត់មិនឱ្យកុមារ និងយុវជនទទួលបានការអប់រំត្រឹមត្រូវ<br>• ការមិនផ្ដល់សេវាព្យាបាលជំងឺត្រឹមត្រូវនៅពេលប្រជាជនឈឺ<br>• ការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយពុំមានការព្រមព្រៀងពីសាមីខ្លួន<br>• ការធ្វើទារុណកម្ម ការរំលោភបំពានផ្លូវភេទ ។ |
| គ្រូ: អរគុណណាស់ដែលប្អូនមានសេចក្ដីក្លាហាន ចូលរួមផ្ដល់ចម្លើយយ៉ាងផុសផុល។ ជាការពិតណាស់ កាលណាគ្មានការគោរពសិទ្ធិមនុស្ស ពុំមានការគោរពច្បាប់ នោះការរំលោភបំពាននឹងកើតមាន មិនថានៅក្នុងអតីតកាល ឬបច្ចុប្បន្ននោះទេ។គ្រូជឿជាក់ថាប្អូនៗក៏ធ្លាប់ឮអំពីបញ្ហាជនខិលខូចបង្ខំឱ្យកុមារធ្វើការងារធ្ងន់ ឱ្យសុំទាន ការជួញដូរស្ត្រី និងកុមារ ការប្រើប្រាស់អំពើហិង្សា ការរំលោភបំពានផ្លូវភេទជាដើម។<br>គ្រូ: ប្អូនៗបានបង្ហាញសកម្មភាពនៃការរំលោភសិទ្ធិជាច្រើន ដែលប្អូនបានសរសេរនៅលើក្ដារខៀន។គ្រូបែងចែកប្អូនៗជា៥ក្រុម ក្រុមនីមួយៗត្រូវរកចម្លើយនៅក្នុងសៀវភៅសិក្សាគោលថា តើមាននីតិវិធីអ្វីខ្លះដែលអាចជួយការពារយើងនៅពេលមានការរំលោភបំពានសិទ្ធិរបស់យើង។ ប្អូនៗមានរយៈពេល៥នាទី ដើម្បីជួយរកចម្លើយគ្នា។<br>បន្ទាប់ពីសិស្សរកបានចម្លើយហើយ គ្រូហៅក្រុមនីមួយៗឱ្យឡើងឆ្លើយ ។ |

| |
|---|
| **ចម្លើយរំពឹងទុក៖**<br>• ដោយសារយើងមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ប្រសិនបើមាននរណាម្នាក់រំលោភលើសិទ្ធិរបស់យើង យើងអាចរកមេធាវីការពារក្តីឱ្យយើងបាន។<br>• ប្រសិនបើគេចង់ចោទប្រកាន់ ចាប់ ឬឃាត់ខ្លួន ឃុំខ្លួន យើងមានសិទ្ធិសួររកដីកាកោះហៅ ឬដីកាចាប់ខ្លួនដែលចេញដោយតុលាការ។ ប្រសិនបើគេមានដីកា យើងត្រូវពិនិត្យមើលថាតើដីកានោះពិតជាកោះហៅឈ្មោះរបស់យើងមែនឬទេ។ ប្រសិនបើគេពុំមានដីកាទេ គេមិនអាចចោទប្រកាន់ ចាប់ខ្លួន ឬឃុំខ្លួនយើងបានឡើយ ព្រោះច្បាប់មិនបានអនុញ្ញាត លើកលែងតែករណីនោះជាបទល្មើសជាក់ស្តែង។<br>• ក្នុងករណីមានការដកហូត គាបសង្កត់ទារប្រាក់ ទ្រព្យសម្បត្តិ ឬក៏មានការសម្លុតដោយប្រើកម្លាំងបាយ យើងត្រូវរាយការណ៍ទៅមេធាវីភ្លាម ឬសុំឱ្យនគរបាលចេញលិខិតកត់ត្រាវត្ថុតាងទាំងនេះ។ក្នុងករណីដែលមន្ត្រីនគរបាលឃាត់ខ្លួន ការឃាត់ខ្លួននោះមិនអាចធ្វើលើសពី៤៨ម៉ោងបានទេ។ ប្រសិនបើករណីនេះកើតឡើង យើងត្រូវរាយការណ៍ដល់មេធាវី ដើម្បីទាមទារឱ្យមន្ត្រីនគរបាលគោរពទៅតាមច្បាប់។<br>• ប្រសិនបើយើងយល់ថា ការកាត់ក្តីរបស់តុលាការរាជធានី/ខេត្ត មិនផ្តល់យុត្តិធម៌ឱ្យខ្លួន យើងអាចប្តឹងទៅសាលាឧទ្ធរណ៍ ឬតុលាការកំពូលបាន។<br>• កាលណាមានការរំលោភសិទ្ធិដូចជាការប៉ះពាល់ដល់ទ្រព្យសម្បត្តិ កិត្តិយស សេចក្តីថ្លៃថ្នូរ រំលោភបំពានឬបង្កហិង្សាដល់រូបរាងកាយ យើងអាចប្តឹងសុំឱ្យតុលាការរកយុត្តិធម៌ ដោយដាក់ទោសលើបុគ្គលនោះ និងឱ្យសងជំងឺចិត្តចំពោះការខូចខាតដែលបុគ្គលនោះបានបង្កឡើង។ |
| គ្រូ៖ ល្អណាស់ប្អូនៗពិតជារកបានចម្លើយយ៉ាងត្រឹមត្រូវមែន ប៉ុន្តែគ្រូឮប្អូនៗនិយាយពីរឿងដីកា។ ឥឡូវគ្រូចង់ដឹងថាតើអ្វីជាដីកា ហើយដីកាមានប៉ុន្មានប្រភេទ តើប្អូនណាអាចជួយឆ្លើយបាន? |
| **ចម្លើយរំពឹងទុក៖**<br>ដីកាជាសេចក្តីសម្រេចដែលចេញដោយចៅក្រមម្នាក់ឯង ឬព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងក្នុងការឃុំខ្លួន លើកលែងការចោទប្រកាន់ ឬដោះលែងបណ្តោះអាសន្ន។ ដីកាមានបីប្រភេទគឺដីកាចោទប្រកាន់ ដីកាដោះលែងបណ្តោះអាសន្ន និងដីកាឃុំខ្លួន។ |

គ្រូគូររូបដូចខាងក្រោមនៅលើក្តារខៀន  រួចឱ្យក្រុមនីមួយៗរកសិទ្ធ និងករណីយកិច្ចរបស់មេធាវីម្នាក់មួយ។ គ្រូហៅសិស្សស្ម័គ្រចិត្តឱ្យសរសេរនៅក្នុងរង្វង់ខាងក្រោម ។



**ចម្លើយរំពឹងទុក៖**

- ត្រូវរៀបចំធ្វើពាក្យបណ្តឹងទៅតុលាការនៅពេលមានគេមកពឹងពាក់រកជំនួយ
- ជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី
- ត្រូវចុះទៅជាមួយចៅក្រម នៅពេលមានការឆែកឆេរផ្ទះជនជាប់ចោទ
- អាចទាក់ទងកូនក្តីរបស់ខ្លួនដោយសេរីគ្រប់ពេលតែមិនអាចប្រគល់ឯកសារឬវត្ថុតាងអ្វីមួយដល់កូនក្តីរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបអង្កេតឡើយ
- មានសិទ្ធិអានសំណុំរឿងឬថតចម្លងឯកសារនោះបានបើយល់ថាជាការចាំបាច់។

| ការពង្រឹងពុទ្ធិ |
|---|
| គ្រូ: ឥឡូវប្អូនៗបានដឹងអំពីការការពារសិទ្ធិរបស់ខ្លួន និងជួយអ្នកដទៃក៏ដូចជាដឹងអំពីសិទ្ធិនិងករណីយកិច្ចរបស់មេធាវី។ដូច្នេះគ្រូចង់ឱ្យប្អូនៗសរសេរសង្ខេបពីអ្វីដែលប្អូនបានរៀននៅថ្ងៃនេះ។ |
| **កិច្ចការផ្ទះ** |
| ១.គ្រូឱ្យសិស្សរៀបរាប់ពីសកម្មភាពដែលគេត្រូវធ្វើនៅពេលមាននរណាម្នាក់ត្រូវគេរំលោភបំពាន។<br>២.គ្រូឱ្យសិស្សរកពាក្យគន្លឹះប្រាំក្នុងមេរៀនបន្ទាប់។សិស្សត្រូវសរសេរលេខទំព័រ និងវគ្គដែលពួកគេបានជួបពាក្យគន្លឹះទាំងនោះមុនគេ រួចហើយព្យាយាមរកនិយមន័យនៃពាក្យគន្លឹះទាំងនោះនៅក្នុងសៀវភៅសិក្សាគោល ឬឯកសារផ្សេងបាន។ |

| ល.រ | ពាក្យគន្លឹះ | ទំព័រ | វគ្គ | និយមន័យ(អាចមាននៅក្នុងសៀវភៅសិក្សាគោល ឬរកពីឯកសារផ្សេងៗ) |
|---|---|---|---|---|
| ១ | សេរីភាព | | | |
| ២ | អំណាចផ្ដាច់ការ | | | |
| ៣ | សមាគម | | | |
| ៤ | អនាធិបតេយ្យ | | | |
| ៥ | អយុត្តិធម៌ | | | |

# ថ្នាក់ទី១១

<table>
<tr><td>ជំពូក១</td><td colspan="2">តម្លៃមនុស្ស</td></tr>
<tr><td>មេរៀនទី</td><td colspan="2">៥</td></tr>
<tr><td>ចំណងជើងមេរៀន</td><td colspan="2">សេរីភាព</td></tr>
<tr><td>ពណ៌នាអំពីមេរៀនដោយសង្ខេប</td><td colspan="2">មនុស្សគ្រប់រូបតែងតែត្រូវការសិទ្ធិនិងសេរីភាពដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរជាមនុស្ស។ សេរីភាពជាអំណាចនៃការធ្វើអ្វីៗបានតាមការប៉ងប្រាថ្នាក្នុងសកម្មភាពគ្រប់បែបយ៉ាងដោយគ្មានការបង្ខិតបង្ខំ តែត្រូវស្ថិតក្នុងក្របខ័ណ្ឌច្បាប់។ទស្សនវិទូជាច្រើនបានកំណត់ន័យនៃបញ្ញត្តិសេរីភាពខុសៗគ្នាប៉ុន្តែមានគំនិតជារួមគឺមនុស្សធ្វើអ្វីៗត្រូវគោរពសិទ្ធិអ្នកដទៃ និងគោរពច្បាប់។សង្គមមានសេរីភាព មានយុត្តិធម៌ សង្គមនោះពិតជាសង្គមមានសន្តិភាព ការអភិវឌ្ឍ និងមានស្ថិរភាពយូរអង្វែង។</td></tr>
<tr><td rowspan="3">វត្ថុបំណង</td><td>១</td><td>- កំណត់បាននិយមន័យនិងអត្ថន័យនៃពាក្យសេរីភាព<br>- រៀបរាប់ពីសារប្រយោជន៍នៃការមានសេរីភាពនិងផលនៃការមានសេរីភាព។</td></tr>
<tr><td>២</td><td>វិភាគទស្សនៈរបស់ទស្សនវិទូមួយចំនួនស្ដីពីសេរីភាព។</td></tr>
<tr><td>៣</td><td>អនុវត្តឱ្យបានខ្ជាប់ខ្ជួនសិទ្ធិសេរីភាពរបស់ខ្លួននិងគោរពសិទ្ធិអ្នកដទៃ។</td></tr>
<tr><td rowspan="2">សម្ភារៈ</td><td colspan="2">សៀវភៅសិស្ស</td></tr>
<tr><td colspan="2">ដ្យាក្រាមពន្យល់និយមន័យ</td></tr>
<tr><td>រយៈពេល</td><td colspan="2">៣ម៉ោង</td></tr>
</table>

**ដំណើរការបង្រៀន**

**ការចាប់ផ្តើមមេរៀន**

គ្រូ: មនុស្សម្នាក់ៗអាចរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ សិក្សារៀនសូត្រ ក្រេបយកចំណេះវិជ្ជាមកបំពេញការងារឬប្រកបរបររកស៊ីឱ្យមានការរីកចម្រើនទៅបាន លុះត្រាតែបុគ្គលនោះមានសេរីភាព។

១. តើសេរីភាពមាននិយមន័យដូចម្តេច?
២. តើមានទស្សនវិទូល្បីៗណាខ្លះដែលបានផ្តល់ទស្សនៈទាក់ទងនឹងសេរីភាព?
៣. តើយើងម្នាក់ៗទទួលសេរីភាពអ្វីខ្លះ?
៤. តើសេរីភាពមានប៉ុន្មានប្រភេទ? គឺអ្វីខ្លះ?
៥. តើការមានសេរីភាពទទួលបានផលអ្វីខ្លះ?

**មេរៀនថ្មី**

គ្រូ:សរសេរសំណួរទាំងនេះដាក់លើក្តារខៀន រួចពន្យល់សិស្សថាពួកគេនឹងរកចម្លើយសម្រាប់សំណួរខាងលើ។ គ្រូបែងចែកសិស្សជា៥ក្រុមទៅតាមសំណួរ។ក្រុមបង្កើតនេះអាចដាក់ឈ្មោះអ្វីក៏បានដូចជាគោព្រៃ ខ្លារខិន នាគរាជ នគរភ្នំ សំពៅមាស។ គ្រូឱ្យពួកគេដាក់លេខសម្គាល់ទៅសមាជិកនៃក្រុមនីមួយៗពីលេខ១ដល់លេខ៥(ទៅតាមចំនួនសំណួរ) ។




បន្ទាប់មក គ្រូឱ្យសមាជិកដែលមានលេខដូចគ្នាបង្កើតជាក្រុមថ្មីផ្សេងទៀតទៅតាមលេខនីមួយៗ ដោយដាក់ឈ្មោះថាក្រុមជំនាញទី១ ទី២ ទី៣ ទី៤ និងទី៥ (តាមចំនួនសំណួរ)។ គ្រូត្រូវចាត់ឱ្យក្រុមជំនាញនីមួយៗទទួលខុសត្រូវរកចម្លើយសម្រាប់សំណួរដែលមានលេខដូចគ្នាទៅនឹងលេខក្រុមជំនាញរបស់ពួកគេ ។

ក្រុមជំនាញទី១ រកចម្លើយសម្រាប់សំណួរទី១: តើសេរីភាពមាននិយមន័យដូចម្តេច?

ក្រុមជំនាញទី២រកចម្លើយសម្រាប់សំណួរទី២: តើមានទស្សនវិទូល្បីៗណាខ្លះដែលបានផ្តល់ទស្សនៈទាក់ទងនឹងសេរីភាព?

ក្រុមជំនាញទី៣ រកចម្លើយសម្រាប់សំណួរទី៣: តើយើងម្នាក់ៗទទួលបានសេរីភាពអ្វីខ្លះ?

ក្រុមជំនាញទី៤ រកចម្លើយសំណួរទី៤: តើសេរីភាពមានប៉ុន្មានប្រភេទ? គឺអ្វីខ្លះ?

ក្រុមជំនាញទី៥ រកចម្លើយសំណួរទី៥: តើការមានសេរីភាពទទួលបានផលអ្វីខ្លះ?

ក្រុមនីមួយៗមានរយៈពេល១៥នាទីក្នុងការរកចម្លើយ រួចបង្កើតសំណួរដើម្បីយកទៅសួរសមាជិកក្រុមដើម។ បន្ទាប់ពីរកចម្លើយនិងបង្កើតសំណួរចប់សព្វគ្រប់ហើយ ពួកគេម្នាក់ៗត្រូវត្រឡប់មកក្រុមដើមរៀងៗខ្លួនវិញ ម្នាក់ៗមានរយៈពេល៥នាទី ក្នុងការសួរដេញដោលរហូតសមាជិកទាំងអស់អាចរកចម្លើយនៃសំណួរដែលខ្លួនទទួលខុសត្រូវ ។

**ក្រុមគោព្រៃ**

សមាជិកក្រុមជំនាញទី១ត្រឡប់មកក្រុមដើមវិញ សួរនិងស្ដាប់ចម្លើយ: យើងឃើញថាសេរីភាពមកពីពាក្យសេរី+ភាព តើនរណាអាចពន្យល់បាន សេរីមានន័យថាដូចម្ដេច?

សមាជិកដទៃឆ្លើយ: សេរីបានន័យថា យើងធ្វើអ្វីក៏បានដែរ។

សមាជិកក្រុមជំនាញទី១: អញ្ចឹងធ្វើខុសច្បាប់ក៏បានដែរ មែនទេ?

សមាជិកដទៃឆ្លើយ: យើងធ្វើអ្វីក៏បាន ប៉ុន្តែមិនត្រូវប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់អ្នកដទៃឡើយ។

សមាជិកក្រុមជំនាញទី១: តើយើងត្រូវធ្វើដូចម្ដេច ដើម្បីកុំឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់អ្នកដទៃ?

សមាជិកដទៃ: បាទ/ចាស គឺយើងត្រូវគោរពច្បាប់ ព្រោះច្បាប់បានកំណត់យ៉ាងច្បាស់ថាយើងអាចធ្វើអ្វីបាន ឬមិនបាន ដើម្បីធានាឱ្យយើងមានសិទ្ធិសេរីភាពស្មើៗគ្នា ដោយមិនប៉ះពាល់ ឬរំលោភលើសិទ្ធិអ្នកដទៃឡើយ ។

សមាជិកក្រុមជំនាញទី១: ត្រឹមត្រូវហើយ ដូច្នេះយើងមើលឃើញថាសេរីភាពជាសកម្មភាពដែលយើងអាចធ្វើបាន ប៉ុន្តែត្រូវអនុលោមទៅតាមច្បាប់ដែលបានកំណត់ចៀសវាងការរំលោភលើសិទ្ធិសេរីភាពរបស់អ្នកដទៃ។

**ក្រុមខ្លារខិន**

សមាជិកក្រុមជំនាញទី២: តើនរណាដឹងទេថា **លោកហ្សង់ ហ្សាក់រូសូ** និយាយយ៉ាងដូចម្ដេច អំពីភាពខុសគ្នារវាងមនុស្ស និងសត្វ នៅពេលគាត់ពន្យល់ពីសេរីភាព?

សមាជិកដទៃ: បាទ/ចាស គាត់ចង់សំដៅថា មនុស្សខុសពីសត្វ ត្រង់មនុស្សមានបញ្ញាមានសមត្ថភាពក្នុងការជ្រើសរើសយកសកម្មភាពទាំងឡាយណាដែលគេអាចធ្វើបានមកអនុវត្ត ។

សមាជិកក្រុមជំនាញទី២: តើអ្នកអាចឱ្យឧទាហរណ៍មួយបានដែរឬទេ?
សមាជិកដទៃ: បាទ/ចាស មនុស្សអាចបោះឆ្នោតជ្រើសរើសមេដឹកនាំដែលខ្លួនពេញចិត្ត។ មនុស្សអាចប្តឹងតវ៉ាឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនបាន ប្រសិនបើមាននរណារំលោភបំពានលើសិទ្ធរបស់ខ្លួន ប៉ុន្តែសត្វមិនអាចធ្វើកិច្ចការទាំងនេះបានទេ។
សមាជិកក្រុមជំនាញទី២: ល្អណាស់។ ចុះលោក**ដេកាត** ថាទាល់តែទទួលស្គាល់ការពិតបានហៅថាជនមានសេរីភាព តើគាត់ចង់សំដៅលើអ្វីដែរ?
សមាជិកដទៃ: ចាស/ចាស គាត់ចង់ពន្យល់ថា មានតែបុគ្គលដែលអាចឃើញខុសថាខុស ឃើញត្រូវថាត្រូវទេ ទើបអាចបញ្ជាក់បានថា គាត់មានសេរីភាព គ្មានការគាបសង្កត់ពីនរណាម្នាក់ឡើយ។
សមាជិកជំនាញទី២: ត្រឹមត្រូវណាស់។ ដូចលោក**ប៉ូលសាត្រ**និយាយដែរថា សេរីភាពជាភាពធ្វើអ្វីមួយដោយគ្មានលក្ខខណ្ឌទេ។ មនុស្សទាំងអស់មានសេរីភាពស្មើគ្នា មិនរងគំនាបដោយសារវណ្ណៈ មុខងារ ឬឋានៈធំតូច ក្រឬមានឡើយ។ឯលោក**អាល់ប៊ែកាមុស** យល់ឃើញថា សេរីភាពជាការភ្ញាក់ខ្លួន។ គាត់គិតថាមនុស្សយើង បើចង់ឱ្យជីវិតមានន័យលុះត្រាតែភ្ញាក់ខ្លួន ខំប្រឹងធ្វើខ្លួន ដើម្បីរកន័យពិតឱ្យជីវិត។ តើនរណាមានយោបល់អ្វីទៀតទេ?
សមាជិកដទៃ: ចាស/បាទ គាត់ចង់ពន្យល់ថា មនុស្សយើងបានទទួលគំនាបខ្លះពីសង្គមដែលធ្វើឱ្យយើងមិនមានសេរីភាពទេ ។ ដូចជាស្ត្រីខ្មែរយើងអញ្ចឹង ពីមុនមកគេមិនឱ្យរៀនសូត្រទេ ព្រោះគេខ្លាចចេះសរសេរសំបុត្រស្នេហា។ ប៉ុន្តែការមិនបានរៀនសូត្រ ធ្វើឱ្យគាត់មិនអាចមានឱកាសទទួលបានការងារល្អមកចិញ្ចឹមជីវិតរបស់គាត់ទេ។ គាត់ត្រូវពឹងពាក់លើប្តីរបស់គាត់ដើម្បីរស់។ គាត់មិនអាចសម្រេចចិត្តអ្វីបានទេ លុះត្រាតែមានការយល់ព្រមពីប្តីរបស់គាត់ជាមុន។ សូម្បីតែប្តីរបស់គាត់ប្រើអំពើហិង្សា ក៏គាត់មិនចង់ប្តឹង ឬលែងលះដែរព្រោះកាលណានគរបាលចាប់ប្តីរបស់គាត់ នោះគាត់និងកូនៗគ្មាននរណាចិញ្ចឹមទេ។ ដូច្នេះគាត់ត្រូវភ្ញាក់ខ្លួន ខំអត់ធ្មត់ស្វះស្វែងរកការសិក្សាឱ្យមានចំណេះដឹង មានការងារធ្វើ មានសិទ្ធិសេរីភាពក្នុងការសម្រេចចិត្តធ្វើអ្វីមួយ នោះទើបជីវិតមានន័យ។
អ្នកជំនាញទី២: ត្រឹមត្រូវហើយ អ្នកទាំងអស់គ្នាពិតជាយល់ពីសេរីភាពបានយ៉ាងច្បាស់។ ប៉ុន្តែដូចលោក **បូស៊ុយអេ** និយាយអញ្ចឹង សេរីភាព ជាសិទ្ធិធ្វើអ្វីៗបានទាំងអស់ ប៉ុន្តែត្រូវនៅក្រោមដែនកំណត់នៃច្បាប់ព្រោះមានតែច្បាប់ទេទើបធានាថាយើងទាំងអស់គ្នាមានសិទ្ធិសេរីភាពស្មើៗគ្នា។

**ក្រុមនគរភ្នំ**

សមាជិកក្រុមជំនាញទី៣: គេថាដើម្បីឱ្យសង្គមមួយមានយុត្តិធម៌ទៅបានលុះត្រាតែមនុស្សយើងម្នាក់ៗមានសេរីភាព។ ប៉ុន្តែ តើយើងម្នាក់ៗគួរទទួលបានសេរីភាពអ្វីខ្លះ? តើនរណាអាចប្រាប់ពីការទទួលបានសេរីភាពណាមួយដែរឬទេ?

សមាជិកដទៃ: ចាស/បាទ គឺសេរីភាពនៃការបញ្ចេញមតិ។

សមាជិកក្រុមជំនាញទី៣: តើសេរីភាពនេះសំដៅលើអ្វីទៅ?

សមាជិកដទៃ: ចាស/បាទ សេរីភាពក្នុងការចូលរួមបញ្ចេញមតិ មិនថាតាមពាក្យសម្តី តាមការសរសេរ ឬតាមការផ្សាយព័ត៌មានទេ នៅពេលបុគ្គលនោះមើលឃើញអ្វីមួយខុស ឬអ្វីមួយត្រូវ។ ម្យ៉ាងទៀត បុគ្គលម្នាក់ៗមានសេរីភាពក្នុងការទទួលបានព័ត៌មាន ជជែកពិភាក្សា និងធ្វើការសម្រេចចិត្ត ដើម្បីឱ្យមានការឯកភាពគ្នា សាមគ្គីគ្នា និងចូលរួមក្នុងការអភិវឌ្ឍសង្គមជាតិ។

សមាជិកក្រុមជំនាញទី៣: បាទ/ចាស ល្អណាស់។ តើមានសេរីភាពអ្វីខ្លះទៀតឬទេ?

សមាជិកដទៃ: បាទ/ចាស គឺសេរីភាពនៃការជួបជុំគ្នា។ ព្រោះការជួបជុំគ្នា គឺជាសេរីភាពមួយដែលជួយមនុស្សឱ្យអាចរៀនសូត្រពីគ្នា ផ្លាស់ប្តូរឬចែករំលែកយោបល់គ្នា ឬព័ត៌មានឱ្យគ្នាទៅវិញទៅមក។ សេរីភាពនៃការជួបជុំគ្នានេះធ្វើឱ្យប្រជាជនអាចរួមគ្នាពិភាក្សា និងសម្រេចចិត្តក្នុងការដោះស្រាយបញ្ហារួមផងដែរ។

សមាជិកក្រុមជំនាញទី៣: ពិតជាល្អមែន ដូចយើងទាំងអស់គ្នាកំពុងតែពិភាក្សារកចម្លើយដើម្បីឆ្លើយសំណួរអញ្ចឹង។ តើមានសេរីភាពអ្វីផ្សេងទៀតដែរឬទេ?

សមាជិកដទៃ: ចាស/បាទ គឺសេរីភាពនៃការបង្កើតសមាគម។

សមាជិកក្រុមជំនាញទី៣:តើគេចាំបាច់មានសេរីភាពក្នុងការបង្កើតសមាគមដែរឬទេ?

សមាជិកដទៃ: ចាស/បាទ ពិតជាចាំបាច់ណាស់។កាលណាមនុស្សមានជំនាញ មានបទពិសោធន៍ផ្សេងៗ សម្រេចចិត្តបង្កើតជាក្រុម នោះធ្វើឱ្យកម្លាំងក៏កាន់តែខ្លាំងក្លា ព្រោះគេមានបទពិសោធន៍ មានចំណេះវិជ្ជា មានការគាំទ្រ។ ម្យ៉ាងទៀត ការបង្កើតសមាគមនឹងការពារដល់សមាជិកណាដែលរងគ្រោះដោយការរំលោភសិទ្ធិ ឬកេងប្រវ័ញ្ចន៍យកប្រយោជន៍។ ដោយមើលឃើញពីសារៈសំខាន់នេះហើយ ទើបមានការបង្កើតច្បាប់ឡើងដើម្បីអនុញ្ញាតនិងធានាសិទ្ធិមូលដ្ឋានសម្រាប់បង្កើតសមាគមរបស់ប្រជាពលរដ្ឋទូទៅ។ សមាជិកក្រុមជំនាញទី៣: ពិតជាល្អមែន។ អ្នកទាំងអស់គ្នាមានការយល់ដឹងច្រើនទាក់ទងនឹងរូបភាពនៃការមានសេរីភាព។ អញ្ចឹងការទទួលបានសេរីភាពគឺមានសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំគ្នា ការបង្កើតសមាគមជាដើម។

**ក្រុមនាគរាជ**

សមាជិកក្រុមជំនាញទី៤: យើងដឹងហើយថា សេរីភាពមានច្រើនប្រភេទណាស់។ តើនរណាដឹងថាសេរីភាពមានប្រភេទអ្វីខ្លះ?

សមាជិកដទៃ: បាទ/ចាស គឺសេរីភាពធម្មជាតិ។

សមាជិកក្រុមជំនាញទី៤: តើសេរីភាពក្នុងការដើរកំសាន្តនៅក្នុងព្រៃមែនទេ?

សមាជិកដទៃ: មិនមែនអញ្ចឹងទេ។ សេរីភាពធម្មជាតិនៅទីនេះ គឺសំដៅលើសេរីភាពដែលមនុស្សម្នាក់ៗមានតាំងពីកំណើតមកម្លេះ។ មនុស្សយើងម្នាក់ៗមានសេរីភាពដោយគ្មានការគំរាមកំហែង និងការបង្ខិតបង្ខំពីអ្នកដទៃឡើយ។មនុស្សយើងម្នាក់ៗអាចធ្វើអ្វីបានទៅតាមឆន្ទៈរបស់ខ្លួនដោយគ្មាននរណា ឬវត្ថុអ្វីមករារាំងមនសិការរបស់បុគ្គលម្នាក់ៗបានឡើយ ប្រសិនបើបុគ្គលនោះមិនយល់ព្រមលះបង់សេរីភាព។

សមាជិកក្រុមជំនាញទី៤: បាទ/ចាស សូមអរគុណដែលបានបកស្រាយជួយឱ្យខ្ញុំយល់ច្រឡំ។ ចុះតើយើងមានសេរីភាពប្រភេទផ្សេងទៀតដែរឬទេ?

សមាជិកដទៃ:ចាស/បាទ គឺសេរីភាពពលរដ្ឋ ពោលគឺប្រជាពលរដ្ឋម្នាក់ៗមានសេរីភាពធ្វើអ្វីៗបានគ្រប់យ៉ាងតាមចិត្តប្រាថ្នារបស់ខ្លួន តែមិនត្រូវបំពានលើច្បាប់ទេ។ ពលរដ្ឋម្នាក់ៗក៏មានសេរីភាពទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់និងក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យផងដែរ។

សមាជិកក្រុមជំនាញទី៤: ចាស/បាទ សូមអរគុណ។ ចុះសេរីភាពខាងនយោបាយតើយើងមានដែរឬទេ? ហើយតើវាមានសារៈសំខាន់អ្វីខ្លះក្នុងការមានសេរីភាពនេះ?

សមាជិកដទៃទៀត: បាទ/ចាស គឺបុគ្គលគ្រប់រូបមានសេរីភាពធ្វើនយោបាយទៅតាមច្បាប់កំណត់។ សេរីភាពនេះមានសារៈសំខាន់ណាស់ ព្រោះសេរីភាពនេះបានអនុញ្ញាតឱ្យប្រជាពលរដ្ឋជួបជុំគ្នា អាចបង្កើតសមាគម មានសិទ្ធិបញ្ចេញមតិយោបល់សិទ្ធិសរសេរអត្ថបទ សិទ្ធិជ្រើសរើសអ្នកតំណាង ឬឈរឈ្មោះជាអ្នកតំណាងតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌។

សមាជិកក្រុមជំនាញទី៤: ចាស/បាទ ពិតជាល្អមែន សង្ឃឹមថាសមាជិកក្នុងក្រុមយើងនឹងឈរឈ្មោះជាមេឃុំនាពេលអនាគត។ ចុះយើងមានសេរីភាពប្រភេទផ្សេងទៀតដែរឬទេ?

សមាជិកម្នាក់ទៀត:បាទ/ចាស គឺសេរីភាពផ្នែកសេដ្ឋកិច្ច។ ពលរដ្ឋម្នាក់ៗមានសេរីភាពក្នុងការប្រកបរបរវិជ្ជាជីវៈទៅតាមចំណង់ចំណូលចិត្តរបស់ខ្លួន លើកលែងតែវិជ្ជាជីវៈណាដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ និងត្រូវបានច្បាប់ហាមឃាត់តែប៉ុណ្ណោះ។ បុគ្គល

| |
|---|
| ណាប្រកបរបរខុសច្បាប់មានឈ្មោះថារំលោភច្បាប់និងប៉ះពាល់ដល់សិទ្ធិ សេរីភាពរបស់អ្នកដទៃ និងត្រូវច្បាប់ដាក់ទោស។<br>សមាជិកក្រុមជំនាញទី៤: ពិតជាល្អណាស់។ ក្រុមយើងរកបានចម្លើយល្អៗជាច្រើន។ ដូច្នេះ យើងឃើញថា សេរីភាពមានច្រើនប្រភេទ ក្នុងនោះមានសេរីភាពធម្មជាតិ សេរីភាពពលរដ្ឋ សេរីភាពនយោបាយ សេរីភាពសេដ្ឋកិច្ច។ |
| **ក្រុមគោព្រៃ**<br>សមាជិកក្រុមជំនាញទី៥: ជាការពិតណាស់ យើងម្នាក់ៗតែងតែទាមទារចង់បានសេរីភាព ប៉ុន្តែតើសេរីភាពមានផលអ្វីខ្លះបានជាយើងម្នាក់ៗចង់បានម្លេះ? តើនរណាអាចជួយផ្តល់យោបល់ទាក់ទងនឹងផលនៃការមានសេរីភាពបានដែរឬទេ?<br>សមាជិកដទៃ: បាទ/ចាស ដូចលោក យ៉ន ស្ទុយអាមីល អះអាងអញ្ចឹង សេរីភាពមានសារៈសំខាន់ណាស់ក្នុងការជួយឱ្យសង្គមមានយុត្តិធម៌ និងអភិវឌ្ឍន៍។<br>សមាជិកក្រុមជំនាញទី៥: តើអាចពន្យល់បានទេថា ហេតុអ្វីសេរីភាពអាចជួយសង្គមឱ្យមានយុត្តិធម៌?<br>សមាជិកដទៃ: បាទ/ចាស កាលណាមនុស្សអាចបញ្ចេញមតិយោបល់ អាចផ្សព្វផ្សាយតាមសារព័ត៌មានជាដើម នោះអាចជួយឱ្យមានការដឹងឮ និងថ្កោលទោសចំពោះការរំលោភសិទ្ធិប្រជាជនពីសំណាក់អ្នកមានប្រាក់អំណាច មានអំណាច។<br>សមាជិកក្រុមជំនាញទី៥: បាទ/ចាស សូមអរគុណសម្រាប់ការផ្តល់ចម្លើយនេះ។ តើហេតុអ្វីសេរីភាពអាចជួយឱ្យមានការអភិវឌ្ឍទៅបាន?<br>សមាជិកដទៃ: បាទ/ចាស សង្គមណាក៏ដោយ កាលណាមនុស្សគ្មានសេរីភាពក្នុងការបញ្ចេញមតិទិតៀន សង្គមនោះច្បាស់ជាមានការគាបសង្កត់ កេងប្រវ័ញ្ច អយុត្តិធម៌ អំពើពុករលួយ បក្ខពួកនិយមនិងអំណាចផ្តាច់ការមិនខាន។ប៉ុន្តែផ្ទុយទៅវិញ កាលណាមនុស្សមានសេរីភាព ប្រជាជនអាចបញ្ចេញមតិទិតៀនធ្វើឱ្យមនុស្សខិលខូចលែងហ៊ានគាបសង្កត់ កេងប្រវ័ញ្ច បង្កភាពអយុត្តិធម៌និងប្រព្រឹត្តអំពើពុករលួយ បក្ខពួកនិយម និងអំណាចផ្តាច់ការតទៅទៀតហើយ។ដូច្នេះ បើមនុស្សម្នាក់ៗមានសេរីភាពនៅក្នុងសង្គមនោះភាពយុត្តិធម៌នឹងកើតមាន ហើយសន្តិភាពនិងស្ថេរភាពក៏មានភាពស្ថិតស្ថេរដែរ។<br>សមាជិកក្រុមជំនាញទី៥: ពិតជាអស្ចារ្យមែន។ ដោយសារការពន្យល់របស់អ្នកទាំងអស់គ្នា ខ្ញុំបានរៀនសូត្រ និងដឹងច្រើនពីផលរបស់សេរីភាព។ ខ្ញុំនឹងព្យាយាមការពារសេរីភាពរបស់ខ្ញុំដែលច្បាប់បានធានាមិនឱ្យនរណារំលោភបំពានឬរារាំងបានឡើយ។ |

**ការពង្រឹងពុទ្ធិ**

បន្ទាប់ពីសិស្សបញ្ចប់ការពិភាក្សា គ្រូឱ្យសិស្សជាសមាជិកក្រុមឡើងសង្ខេបចម្លើយ។ សមាជិកលេខ៤ ឆ្លើយសំណួរលេខ១ សមាជិកលេខ៣ឆ្លើយសំណួរលេខ២ សមាជិកលេខ២ ឆ្លើយសំណួរលេខ៣ និងសមាជិកលេខ១ ឆ្លើយសំណួរលេខ៤។

**កិច្ចការផ្ទះ**

គ្រូឱ្យសិស្សរកនិយមន័យនៃពាក្យឯករាជភាព ភយាគតិ ឆន្ទាគតិ មោហាគតិ ទោសាគតិ ព្រមទាំងលក្ខណៈសម្គាល់ លក្ខណៈផ្ទុយ និងឧទាហរណ៍នៃពាក្យនីមួយៗ នៅក្នុងមេរៀនបន្ទាប់។







និយមន័យ
លក្ខណៈសម្គាល់
ឆន្ទាគតិ
ឧទាហរណ៍
លក្ខណៈផ្ទុយ


និយមន័យ
លក្ខណៈសម្គាល់
មោហាគតិ
ឧទាហរណ៍
លក្ខណៈផ្ទុយ


និយមន័យ
លក្ខណៈសម្គាល់
ទោសាគតិ
ឧទាហរណ៍
លក្ខណៈផ្ទុយ

| | | |
|---|---|---|
| **ជំពូក១** | **តម្លៃមនុស្ស** | |
| **មេរៀនទី** | **៦** | |
| **ចំណងជើងមេរៀន** | **ឯករាជភាព** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | មនុស្សម្នាក់ៗក៏ដូចជាប្រទេសនីមួយៗដែរតែងតែចង់បានឯករាជ្យ ព្រោះគេមានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើអ្វីៗបាន និងរស់នៅក្នុងសេចក្តីថ្លៃថ្នូរ ធ្វើអ្វីៗដោយខ្លួនឯង មិនស្ថិតក្រោមការចាត់ចែងរបស់អ្នកដទៃ និងរស់នៅដោយស្ងប់ចិត្ត។ ទស្សនវិទូជាច្រើនបានលើកឡើងពីចំណុចរួមមួយគឺឯករាជ្យមិនមែនបានមកដោយងាយស្រួលនោះទេ គឺត្រូវតែមានការទាមទារ។ | |
| **វត្ថុបំណង** | ១ | - កំណត់បាននិយមន័យឯករាជភាពនិងពណ៌នារូបភាពនៃការមានឯករាជភាព<br>- រៀបរាប់ពីផលនៃការទទួលបានដោយការមានឯករាជភាព។ |
| | ២ | បង្ហាញទស្សនៈផ្សេងៗដែលទាក់ទងទៅនឹងឯករាជភាព។ |
| | ៣ | ប្រកាន់ខ្ជាប់ស្មារតីទទួលខុសត្រូវដោយឯករាជ្យ។ |
| **សម្ភារៈ** | សៀវភៅសិស្ស | |
| | រូបភាព (Character map) | |
| | Video clip គំនូរជីវចលរឿងក្រពើនិងថៅក្រមទាំងប្រាំ ឬ រឿងមហាឫសីប្រស់ខ្លា | |
| **រយៈពេល** | ៣ម៉ោង | |

## ដំណើរការបង្រៀន

### ការចាប់ផ្ដើមមេរៀន

ថ្ងៃនេះ តើប្អូនៗសុខសប្បាយជាទេ? យើងនឹងចាប់ផ្ដើមរៀនមេរៀនដោយមើលគំនូរជីវចលដែលមានចំណងជើងថាក្រពើនិងចៅក្រមទាំងប្រាំ ឬស្ដាប់ ឬអានរឿងមួយដែលមានចំណងជើងថាមហាឫសីប្រស់ខ្លា(ក្នុងករណីគ្មានគំនូរជីវចល សិស្សអានរឿង)។

នៅពេលមើលឬស្ដាប់ឬអានរឿង គ្រូចង់ឱ្យប្អូនៗស្វែងរកចម្លើយនៃសំណួរដូចខាងក្រោម៖

១. តើតួអង្គណាខ្លះតំណាងឱ្យឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ និងឯករាជភាព?

២.តើតួអង្គទាំងនោះធ្វើអ្វីខ្លះទើបគេចាត់ទុកថា ជាតួអង្គតំណាងឱ្យ ឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ និងឯករាជភាព?

---

បន្ទាប់ពីសិស្សបានទស្សនាគំនូរជីវចលឬស្ដាប់ឬអានរឿងរួចហើយ គ្រូចែកសិស្សជាក្រុមដែលមានសមាជិកប្រាំនាក់។ បន្ទាប់មកគ្រូប្រគល់ក្រដាស៥សន្លឹកទៅឱ្យក្រុមសិស្សដើម្បីពិភាក្សា និងជួយគ្នាបំពេញទៅតាមតួអង្គនីមួយៗ។




---

បន្ទាប់មកគ្រូឱ្យក្រុមទី១ពន្យល់ពីតួអង្គទី១ និងគតិដែលតួអង្គមាន ក្រុមទី២ពន្យល់តួអង្គទី២ ក្រុមទី៣ ពន្យល់ពីតួអង្គទី៣ ក្រុមទី៤ពន្យល់ពីតួអង្គទី៤ ក្រុមទី៥ពន្យល់ពីតួអង្គទី៥ និងគតិដែលតួអង្គមាន។

**មេរៀនថ្មី**

បន្ទាប់ពីសិស្សពន្យល់ហើយ គ្រូពន្យល់បន្ថែមពីពាក្យ ឯករាជភាព:ឯករាជភាព គឺសំដៅទៅលើការមិនស្ថិតក្រោមចំណុះអ្នកដទៃ ហើយមានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើអ្វីៗដែលចង់ធ្វើ ឱ្យតែទង្វើនោះមិនប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ហើយស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់។ ទាំងបុគ្គល ទាំងស្ថាប័ន ទាំងរដ្ឋត្រូវការជាចាំបាច់នូវឯករាជភាពដើម្បីធានាឱ្យបានយុត្តិធម៌ និងស្មើភាពគ្នា។




គ្រូពន្យល់សិស្សនៅតាមរង្វង់នីមួយៗដោយមានភ្ជាប់ឧទាហរណ៍មកជាមួយផង។ គ្រូ: បុគ្គលមានឯករាជភាព គឺមានសេរីភាពក្នុងការជ្រើសរើសអ្វីមួយទៅតាមបំណងប្រាថ្នារបស់ខ្លួន។ ដូចជាកសិករក្ដី ពាណិជ្ជករក្ដី អាចជ្រើសរើសការដាំអ្វី ឬប្រកបរបរអ្វីទៅតាមការចង់បានរបស់ខ្លួន លើកលែងតែដំណាំ ឬរបរណាដែលប៉ះពាល់ដល់អ្នកដទៃនិងមានការហាមឃាត់ដោយច្បាប់។ ស្ថាប័នក៏ដូចគ្នាដែរ ត្រូវមានឯករាជភាព។ ដូចជាស្ថាប័នតុលាការ ចៅក្រមត្រូវមានឯករាជភាពមិនចំណុះក្រោមការគាបសង្កត់ពីស្ថាប័នណា បុគ្គលណា ឬគណបក្សនយោបាយណាឡើយ។ សូម្បីតែសាច់ញាតិរបស់ខ្លួនក៏ដោយ ឱ្យតែប្រព្រឹត្តខុសច្បាប់ ត្រូវមានទោសទាំងអស់។ ការកាត់ក្ដីត្រូវផ្អែកលើអង្គហេតុដែលបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងអង្គច្បាប់ដែលត្រូវយកមកអនុវត្តធ្វើយ៉ាងណាចៀសវាងអគតិទាំងបួន ពោលគឺមិនលម្អៀងព្រោះស្រលាញ់(ឆន្ទាគតិ) មិនលម្អៀងព្រោះស្អប់(ទោសាគតិ) មិនលម្អៀងព្រោះវង្វេង(មោហាគតិ) មិនលម្អៀងព្រោះភ័យខ្លាច(ភយាគតិ) ។ ទាក់ទងនឹងរដ្ឋឯករាជ្យ នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសយើង

តើប្អូនណាដឹងថាយើងធ្លាប់ទទួលរងការដាក់អាណានិគមពីប្រទេសណាដែរឬទេ?

សិស្ស: ចាស/បាទ ពីប្រទេសបារាំង ។

គ្រូ:តើប្រទេសយើងស្ថិតក្នុងស្ថានភាពយ៉ាងដូចម្ដេចពេលស្ថិតនៅក្រោមអាណានិគមនិយមបារាំង?

សិស្ស: ប្រទេសយើងគ្មានសិទ្ធិសម្រេចអ្វីទាំងអស់ បារាំងបានធ្វើការគាបសង្កត់ និងបង្ខំឱ្យប្រជាជនបង់ពន្ធយ៉ាងធ្ងន់ធ្ងរទាំងដីធ្លី ផ្ទះសម្បែង ទូក រទេះ និងសត្វចិញ្ចឹមថែមទៀតផង។ នៅក្នុងសម័យនោះ យើងមិនឃើញមានការរីកចម្រើនទេ ព្រោះបារាំងរកផលប្រយោជន៍សម្រាប់តែប្រទេស និងប្រជាជនរបស់គេតែប៉ុណ្ណោះ។

គ្រូ: ពិតមែនហើយ កាលណារដ្ឋណាមួយបាត់បង់ឯករាជភាព រដ្ឋនោះមិនអាចធ្វើអ្វីដើម្បីបម្រើប្រយោជន៍ប្រជាពលរដ្ឋ និងប្រទេសខ្លួនបានទេ។ ដូច្នេះហើយ ទើបប្រជាពលរដ្ឋខ្មែរបានក្រោកឡើងប្រឆាំងនឹងបារាំង។ ជាពិសេសក្រោមព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យជាតិរបស់សម្ដេចព្រះបាទនរោត្តមសីហនុ ទើបប្រទេសកម្ពុជាបានទទួលឯករាជ្យពេញលេញពីបារាំងចាប់ពីថ្ងៃទី៩ ខែវិច្ឆកា ឆ្នាំ១៩៥៣មក។

គ្រូបិទក្រដាសផ្ទាំងធំបីនៅតាមជញ្ជាំងនីមួយៗនៃបន្ទប់រៀន រួចហើយបិទរូប និង សរសេរឈ្មោះ លោកថូម៉ាសផេន លោកហ្សង់ហ្សាក់រូស្សូ និងមហាត្មះគន្ធី ហើយបែងចែកសិស្សជាបីក្រុមដើម្បីរកចម្លើយបំពេញ១)ប្រវត្តិសង្ខេប ២)ស្នាដៃឬគំនិតទាក់ទងនឹងឯករាជភាព។ក្រុមនីមួយៗត្រូវចាត់ឱ្យមានអ្នកចាំពន្យល់ពេលក្រុមពីរទៀតបានដើរមកដល់កន្លែងពួកគេ ហើយត្រូវធ្វើដំណើរទៅស្ដាប់ក្រុមគេពន្យល់វិញម្ដងពេលក្រុមខ្លួនពន្យល់ចប់។

**ការពង្រឹងពុទ្ធិ**

គ្រូ: ឥឡូវយើងបានរៀនចប់មេរៀនឯករាជភាពហើយ។ គ្រូចង់ដឹងថា តើប្អូនៗបានយល់ និងចងចាំនូវអ្វីដែលយើងទើបបានរៀនដែរឬទេ។ ដូច្នេះ គ្រូចង់ឱ្យប្អូនៗបង្កើតជាក្រុមរួចជួយបំពេញក្នុងតារាងប្រៀបធៀបដូចដែលគ្រូគូសនៅលើក្ដារខៀនរវាងឯករាជ្យ និងមិនឯករាជ្យរបស់បុគ្គល ស្ថាប័ន និងប្រទេស។

| | ឯករាជ្យ | មិនឯករាជ្យ |
|---|---|---|
| បុគ្គល | | |
| ស្ថាប័ន | | |
| ប្រទេស | | |

| |
|---|
| បន្ទាប់ពីសិស្សបានធ្វើចប់ គ្រូហៅសិស្សទាំង៣ក្រុមឡើងពន្យល់។ដើម្បីបញ្ចប់មេរៀនគ្រូសង្ខេបៈយើងឃើញថា ឯករាជភាពឬភាពដែលមិនស្ថិតក្រោមចំណុះនរណាម្នាក់ ស្ថាប័នណាមួយក្នុងការគិតធ្វើអ្វីមួយដោយមិនរងការគាបសង្កត់ បំភិតបំភ័យនោះមានសារៈសំខាន់ណាស់។ កាលណាមានឯករាជភាព យើងអាចៈ<br>• រស់នៅមានសេរីភាពពេញលេញទាំងក្នុងការគិត ទាំងក្នុងការប្រកបមុខរបរ<br>• ជាមនុស្សមានកិត្តិយស មានភាពថ្លៃថ្នូរ និងគ្មានការគាបសង្កត់ពីអ្នកដទៃ<br>• មានសេរីភាពក្នុងការកសាងសុភមង្គលដោយខ្លួនឯង មិនពឹងពាក់អ្នកដទៃ រស់នៅដោយស្ងប់ចិត្ត<br>• មិនខ្វាយខ្វល់ មិនខ្លាចឥទ្ធិពលពីខាងក្រៅ<br>• មានទំនួលខុសត្រូវចំពោះអ្វីដែលខ្លួនបានធ្វើ ព្រោះការងារនោះមិនបានស្ថិតក្រោមគំនាប ឬការភ័យខ្លាចពីអ្នកដទៃ<br>• ប្រទេសមានការអភិវឌ្ឍ ព្រោះអ្នកដឹកនាំមានអំណាចពេញលេញ មានសេរីភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រទេសជាតិតាមបំណងប្រាថ្នាដោយមិនរណប ឬស្តាប់តាមបញ្ជាប្រទេសដទៃ ពោលគឺធ្វើអ្វីដើម្បីប្រយោជន៍របស់ប្រជាពលរដ្ឋ និងប្រទេសជាតិខ្លួន។ |
| **កិច្ចការផ្ទះ**<br>គ្រូដាក់កិច្ចការឱ្យសិស្សរកព័ត៌មានទាក់ទងនឹងបុគ្គលឯករាជ្យ។សិស្សអាចពិនិត្យមើលមិត្តរួមថ្នាក់ សមាជិកក្នុងក្រុមគ្រួសាររបស់ខ្លួន អ្នកជិតខាង ឬបុគ្គលណាម្នាក់នៅក្នុងភូមិ នៅក្នុងប្រទេស ក្រៅប្រទេស ឬនៅទីកន្លែងណាមួយក៏បាន។ សិស្សត្រូវសរសេររៀបរាប់ពីបុគ្គលនោះដូចខាងក្រោមៈ<br>១. តើបុគ្គលនោះជានរណា?<br>២. តើចំណុច ឬលក្ខណៈអ្វីបានជាប្អូនចាត់ទុកថាគាត់ជាបុគ្គលឯករាជ្យ?<br>៣. តើប្អូនចង់ក្លាយខ្លួនជាបុគ្គលឯករាជ្យដូចគាត់ដែរឬទេ?<br>៤. តើប្អូនត្រូវធ្វើដូចម្តេច ដើម្បីក្លាយជាបុគ្គលឯករាជ្យបាន? |

<table>
<tr><td>ជំពូក១</td><td colspan="2">តម្លៃមនុស្ស</td></tr>
<tr><td>មេរៀនទី</td><td colspan="2">១០</td></tr>
<tr><td>ចំណងជើងមេរៀន</td><td colspan="2">តម្លាភាព</td></tr>
<tr><td>ពណ៌នាអំពីមេរៀនដោយសង្ខេប</td><td colspan="2">តម្លាភាពជាការបើកចំហរ គ្មានការលាក់លៀមដោយបង្កឱ្យមានការចូលរួមដ៏សុទ្ធចិត្ត ការស្មោះត្រង់មានការនិយាយពិត និយាយត្រង់ ការមិនរើសអើង មិននិយមបក្ខពួក ។ ក្នុងគ្រប់ទិដ្ឋភាពសង្គមទាំងអស់ ការកសាងតម្លាភាពជាការសំខាន់ ដើម្បីការរួមរស់នៅជាមួយគ្នាដោយក្ដីស្មោះត្រង់ ការជឿទុកចិត្តគ្នាមានសន្តិភាព និងការរីកចម្រើន។<br>ការកសាងតម្លាភាព ទាមទារឱ្យមនុស្សម្នាក់ៗមានឆន្ទៈមោះមុតក្នុងការប្ដេជ្ញាចិត្ត កសាងទំនុកចិត្ត ឱ្យមានភាពស្មោះត្រង់ មិនលាក់លៀម មិនស៊ីសំណូកក្នុងការរស់នៅប្រចាំថ្ងៃ។ តម្លាភាពជាមូលដ្ឋាននៃការធ្វើឱ្យមានការជឿទុកចិត្តពីមនុស្សគ្រប់រូប ប្រជាពលរដ្ឋគ្រប់ជនជាតិ គ្រប់ស្រទាប់វណ្ណៈ ព្រមទាំងអង្គការជាតិ អង្គការអន្តរជាតិ និងបណ្ដាអ្នកវិនិយោគទុន។</td></tr>
<tr><td rowspan="3">វត្ថុបំណង</td><td>១</td><td>ប្រាប់បានពីនិយមន័យតម្លាភាព និងរៀបរាប់ពីសារប្រយោជន៍នៃការប្រតិបត្តិការងារប្រកបដោយតម្លាភាព។</td></tr>
<tr><td>២</td><td>បង្ហាញទស្សនៈផ្សេងៗដែលទាក់ទងនឹងតម្លាភាព។</td></tr>
<tr><td>៣</td><td>ប្រកាន់ខ្ជាប់សេចក្ដីក្លាហានក្នុងការបង្ហាញការពិតដោយមិនលាក់លៀម។</td></tr>
<tr><td rowspan="3">សម្ភារៈ</td><td colspan="2">សៀវភៅសិស្ស</td></tr>
<tr><td colspan="2">ចង់ពណ៌ខ្មៅចំនួនពីរ</td></tr>
<tr><td colspan="2">ក្រដាសផ្ទាំងធំ រូបដ្យាក្រាមបំពេញទស្សនៈផ្សេងៗ</td></tr>
<tr><td>រយៈពេល</td><td colspan="2">៣ម៉ោង</td></tr>
</table>

| ដំណើរការបង្រៀន |
| --- |
| **ការចាប់ផ្តើមមេរៀន**<br>• គ្រូយកថង់ពីរមកបង្ហាញសិស្ស។ថង់មួយមើលធ្លុះពីម្ខាងទៅម្ខាង ឯថង់មួយទៀតពណ៌ខ្មៅមើលមិនឃើញពីម្ខាងទៅម្ខាងទេ។ គ្រូយករបស់របរដាក់ចូលទៅក្នុងថង់ទាំងពីរដោយមិនឱ្យសិស្សដឹង រួចសួរទៅសិស្សថាតើថង់មួយណាដែលពួកគេអាចមើលឃើញវត្ថុនៅខាងក្នុងបាន។<br>• គ្រូបន្តសួរសិស្សថា ប្រសិនបើថង់ទាំងពីរនេះតំណាងឱ្យសង្គម ឬស្ថាប័នណាមួយតើសិស្សគិតថាអំពើទុច្ចរិតអាចកើតឡើងនៅក្នុងសង្គម ឬស្ថាប័នមួយណា? |
| **ចម្លើយរំពឹងទុក**:<br>ចាស/បាទ លោក/អ្នកគ្រូ អំពើទុច្ចរិតអាចកើតឡើងនៅក្នុងសង្គម ឬ ស្ថាប័នដែលបិទបាំងមិនឱ្យសាធារណជនដឹង ឬទទួលព័ត៌មានថាមានអ្វីកើតឡើងនៅក្នុងនោះ។ |
| គ្រូ: ល្អណាស់ប្អូន។ |
| **មេរៀនថ្មី**<br>គ្រូឱ្យសិស្សពន្យល់អំពីនិយមន័យនៃតម្លាភាព:<br>**ចម្លើយរំពឹងទុក**:<br>• តម្លាភាពតាមន័យត្រង់ គឺមកពីពាក្យថាថ្លា មើលឃើញធ្លុះពីម្ខាងទៅម្ខាង ប៉ុន្តែតាមន័យបច្ចេកទេស គឺសំដៅលើការបើកចំហ ភាពស្មោះត្រង់ គ្មានការលាក់លៀម ដោយបង្កលក្ខណៈឱ្យមានការចូលរួមដោយសុទ្ធចិត្ត និងរីករាយក្នុងគ្រប់ទិដ្ឋភាពសង្គម នយោបាយ សេដ្ឋកិច្ច និងវប្បធម៌។<br>• តម្លាភាពបានបង្ហាញឱ្យឃើញពីការនិយាយពិត និយាយត្រង់ ការគោរពសិទ្ធិ ការមិនរើសអើង មិននិយមបក្ខពួក មិនបោកបញ្ឆោត មិនប្រើល្បិចកល មិនមួលបង្កាច់ មិនលាក់លៀម មិនច្រណែនឈ្នានីស មិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួន និងការទទួលស្គាល់ការពិតនៅក្នុងគ្រប់សកម្មភាពទាំងអស់ ជាពិសេសការស្គាល់ខ្លួនឯងយ៉ាងច្បាស់លាស់ពីអ្វីដែលខ្លួនមាន អ្វីដែលជាចំណុចខ្លាំង និងចំណុចខ្សោយ។ |
| គ្រូ: តើប្អូនណាដឹងថា តម្លាភាពអាចរីកលូតលាស់បាននៅក្នុងសង្គមដូចម្តេច?<br>**ចម្លើយរំពឹងទុក**: បាទ/ចាស លោក/អ្នកគ្រូ គឺតាមការតាមដានរាល់សកម្មភាពរបស់ឃុំ/សង្កាត់ ហើយការតាមដានសកម្មភាពទាំងនោះ អាចធ្វើទៅបានតាមរយៈការចុះទៅពិនិត្យមើល ស្ថានភាពរកព័ត៌មានដែលសាលាឃុំ/សង្កាត់តែងបិទផ្សាយអំពី |

| |
|---|
| សកម្មភាពនានា ចំណូលចំណាយរបស់ឃុំ/សង្កាត់ ជាពិសេស រៀងរាល់ឆ្នាំ ឃុំ/សង្កាត់ នឹងបិទផ្ទាំងព័ត៌មានគណនេយ្យភាពសង្គមដែលរៀបរាប់អំពីសកម្មភាព និងចំណូលចំណាយរបស់ឃុំ/សង្កាត់ទាំងមូល។ |
| គ្រូ: អរគុណណាស់ដែលប្អូនៗបានជួយចែករំលែកចំណេះដឹងនេះដល់មិត្តរួមថ្នាក់ និងខ្ញុំជាគ្រូ។ តើប្អូនណាដឹងថាដើម្បីកសាងតម្លាភាពបាន តើយើងត្រូវធ្វើដូចម្ដេចខ្លះ? |
| **ចម្លើយរំពឹងទុកៈ**<br>• បាទ/ចាស លោក/អ្នកគ្រូ យើងត្រូវការបណ្ដុះស្មារតីស្អាតស្អំ សុចរិត ស្មោះត្រង់ បង្ហាញការពិតគ្មានការលាក់លៀម គោរពនិងអនុវត្តច្បាប់បានគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ<br>• បាទ/ចាស លោក/អ្នកគ្រូ ជាធម្មតាដើម្បីកសាងអ្វីមួយទៅបានដោយជោគជ័យ យើងត្រូវចាប់ផ្ដើមពីខ្លួនយើងជាមុនសិន ដូច្នេះមនុស្សរាល់គ្នាទាំងរូបខ្ញុំ ទាំងអ្នកដទៃ ត្រូវមានតម្លាភាពជាមុនសិន ពោលគឺធ្វើយ៉ាងណាឱ្យយើងមានឆន្ទៈក្នុងការធ្វើអ្វីមួយដោយតម្លាភាព ដើម្បីជាប្រយោជន៍រួមរបស់សហគមន៍ និងសង្គមជាតិ ទោះបីមានឧបសគ្គយ៉ាងណាក៏យើងត្រូវមានការប្ដេជ្ញាចិត្តខ្ពស់ និងសេចក្ដីព្យាយាមធ្វើយ៉ាងណាឱ្យយើងមានតម្លាភាពដោយគ្មានលម្អៀង និងត្រូវខំប្រឹងប្រែងបណ្ដុះបញ្ញាឱ្យខ្លួនឯងដឹងថាអ្វីជាទង្វើប្រកបដោយតម្លាភាពដែលបង្កើតឱ្យមានប្រយោជន៍រួម និងអ្វីជាទង្វើដែលនាំឱ្យកើតអំពើទុច្ចរិតមិនមានតម្លាភាព។<br>• បាទ/ចាស លោក/អ្នកគ្រូ ដើម្បីកសាងតម្លាភាព យើងទាំងអស់គ្នាត្រូវបំពេញការងារដោយតម្លាភាព ពោលគឺមិនបែងចែកក្រុម បក្ខពួកទេ យើងត្រូវប្រកាន់យកជំហរអព្យាក្រឹត មិនលម្អៀងទៅរកបុគ្គលណាម្នាក់ មិនប្រព្រឹត្តអំពើគំរាមកំហែង ការបំភិតបំភ័យជាដើម។ម្យ៉ាងទៀត ក្នុងការរៀបចំច្បាប់ឬគម្រោងការងារអ្វីមួយគេត្រូវគិតពីប្រយោជន៍រួម ប្រយោជន៍ប្រជាជន មិនតម្រូវសម្រាប់ជនមួយក្រុម ឬប្រយោជន៍នរណាម្នាក់ឡើយ ដោយផ្ដល់ឱកាសឱ្យប្រជាជនបានបញ្ចេញសំឡេង បានយល់ដឹងជាសាធារណៈ ហើយត្រូវទទួលយកមតិយោបល់ចូលរួមពីសាធារណជនទៅពិចារណា ដើម្បីកែលម្អការងារទាំងនោះ។<br>• ចាស/បាទ លោក/អ្នកគ្រូ នៅក្នុងសាលាជំនុំជម្រះក្ដី ការកាត់ក្ដីត្រូវគោរពតាមគោលការណ៍ច្បាប់ដែលបានកំណត់ប្រកបដោយយុត្តិធម៌និងសុក្រឹតបំផុត។ ប្រសិនបើធ្វើបានដូច្នេះ នោះយើងពិតជាអាចកសាងតម្លាភាពបានយ៉ាងជោគជ័យ។ |

| |
|---|
| គ្រូ:អរគុណប្អូនៗបានចូលរួមចំណែកក្នុងការបញ្ចេញមតិ/យោបល់ទាក់ទងនឹងការកសាងតម្លាភាព។ ការហ៊ានបញ្ចេញមតិ យោបល់ក៏មានន័យថាប្អូនក៏កំពុងតែជួយកសាងតម្លាភាពដែរ។ឥឡូវយើងនឹងសិក្សាអំពីផលនៃការប្រតិបត្តិការងារដោយតម្លាភាព។ លោក/អ្នកគ្រូឱ្យក្រដាសប្អូនម្នាក់មួយសន្លឹក។ប្អូនត្រូវរកនឹកមើលថាតើផលបានមកពីការប្រតិបត្តិការងារដោយតម្លាភាពមានអ្វីខ្លះ រួចសរសេរបង់លេខ១ ២ ឬ៣ ទៅតាមចំនួនដែលប្អូនរកបាន។ ឥឡូវចាប់ផ្តើមសរសេរចុះ។ |
| គ្រូ: ឥឡូវប្អូនកាន់ក្រដាសរបស់ប្អូនទៅរកមិត្តរួមថ្នាក់ណាម្នាក់ ហើយប្រាប់ចម្លើយមួយដល់គេ។ប្រសិនបើចម្លើយមាននៅក្នុងបញ្ជីរបស់គេហើយ ប្អូនត្រូវបន្តប្រាប់រហូតដល់គេបានចម្លើយដែលគ្មាននៅក្នុងបញ្ជីរបស់គេ។ ប្រសិនបើប្អូនប្រាប់ចម្លើយអស់ហើយ ប៉ុន្តែគេក៏មានដែរនោះ អញ្ចឹងប្អូនត្រូវសុំឱ្យគេប្រាប់ប្អូនមួយចំណុចវិញ ប្រសិនបើចំណុចនោះមានដូចនៅក្នុងបញ្ជីរបស់ប្អូន ប្អូនត្រូវប្រាប់ទៅមិត្តរួមថ្នាក់នោះថា ប្អូនមានរួចហើយ ដូចនេះមិត្តនោះត្រូវបន្តប្រាប់ទៀតលុះត្រាតែប្អូនបានចម្លើយដែលមិនទាន់មាននៅក្នុងបញ្ជីរបស់ប្អូន ប៉ុន្តែប្រសិនបើមិត្តរួមថ្នាក់ពុំមានចម្លើយផ្តល់ឱ្យបន្តទៀត ប្អូនត្រូវទៅរកមិត្តរួមថ្នាក់ផ្សេងម្នាក់ទៀត។<br>បន្ទាប់ពីបញ្ចប់សកម្មភាពគ្រូឱ្យសិស្សផ្តល់ចម្លើយម្នាក់មួយៗ ហើយគ្រូសរសេរចម្លើយដាក់លើក្តារខៀន។ |
| **ចម្លើយរំពឹងទុក**: មានការជឿទុកចិត្តគ្នា មានទំនាក់ទំនងល្អ ការគោរពសិទ្ធិគ្នា មានការសហការគ្នាបានល្អ មានស្មារតីសាមគ្គីភាព មានសេចក្តីក្លាហានក្នុងការទទួលខុសត្រូវ មានការចេះគ្រប់គ្រងខ្លួនឯង គ្មានចិត្តលោភលន់ មានការយកចិត្តទុកដាក់ចំពោះអ្នកដទៃក៏ដូចជាចំពោះខ្លួនឯង មានមនសិការជាតិ ហ៊ានលាតត្រដាងការពិត មានការអភិវឌ្ឍឆាប់រហ័ស និងមានចិត្តសន្តិភាព មិនមានបក្ខពួកនិយម ឬញាតិនិយម មិនបំពានលើសិទ្ធិនិងទ្រព្យសម្បត្តិអ្នកដទៃ មិនមានគំនិតលាក់លៀម។ |
| បន្ទាប់មក គ្រូក៏និយាយទៅកាន់សិស្សថា មានទស្សនៈអ្នកប្រាជ្ញផ្សេងៗដូចជា ព្រះពុទ្ធអង្គ លោកដេម៉ូគ្រីត និងលោកមហាម័ត ទាក់ទងនឹងតម្លាភាពដែលប្អូនគួរដឹង និងយកមកពិចារណា ។ គ្រូបែងចែកសិស្សជាបីក្រុម និងឱ្យក្រដាសផ្ទាំងធំទៅឱ្យក្រុមនីមួយៗ យកទៅបិទនៅតាមជញ្ជាំងបន្ទប់រៀន ហើយឱ្យសិស្សស្វែងរកទ្រឹស្តីរបស់អ្នកប្រាជ្ញទាំងបីរូបទាក់ទងនឹងតម្លាភាព។ បន្ទាប់មក គ្រូឱ្យសិស្សក្នុងក្រុមនីមួយៗធ្វើបទបង្ហាញទៅដល់ក្រុមផ្សេងៗទៀត។ |




**សម្គាល់:**

ក្រុមទី១៖ យកទស្សនៈរបស់ព្រះពុទ្ធ

ក្រុមទី២៖ យកទស្សនៈរបស់លោកដេម៉ូគ្រីត

ក្រុមទី៣៖ យកទស្សនៈរបស់លោកមហាម៉ែត ។

**ការពង្រឹងពុទ្ធិ**

បន្ទាប់ពីសិស្សបង្ហាញទ្រឹស្តីអ្នកប្រាជ្ញផ្សេងៗទាក់ទងនឹងតម្លាភាពហើយ គ្រូឱ្យសិស្សសង្ខេបមេរៀន និងឱ្យសិស្សម្នាក់ៗសរសេរតែងសេចក្តីខ្លីមួយដើម្បីពន្យល់ពីមតិដែលលើកឡើងថា«សង្គមដែលគ្មានតម្លាភាព នឹងធ្វើឱ្យសង្គមមិនអាចឈានទៅរកការអភិវឌ្ឍបានឡើយ»។

**កិច្ចការផ្ទះ**

គ្រូឱ្យសិស្សអានមេរៀនស្តីពីលទ្ធិប្រជាធិបតេយ្យនិងបំពេញព័ត៌មានចូលទៅក្នុងតារាង(គ្រូពន្យល់សិស្សឱ្យបានច្បាស់លាស់ មុននឹងឱ្យសិស្សធ្វើកិច្ចការនេះ)។

| | |
|---|---|
| ទំនាក់ទំនងមេរៀនទៅមេរៀន (តើគោលគំនិតនៅក្នុងមេរៀននេះបានរំលឹកសិស្សឱ្យនឹកឃើញមេរៀនដទៃទៀតយ៉ាង | -អ្វីដែលយើងបានអាន បានរំលឹកដល់យើងនូវ............................ដោយសារ....................................... ...................................................................................... |
| | -គំនិតនៅក្នុងមេរៀននេះ មានភាពស្រដៀងគ្នាទៅនឹងមេរៀន........................ពីព្រោះ................................ |

| | |
|---|---|
| ដូចម្តេច?) | -គំនិតនៅក្នុងមេរៀននេះមានលក្ខណៈខុសគ្នាពីមេរៀន..........................ពីព្រោះ..................................<br>............................................................................................ |
| ទំនាក់ទំនងមេរៀនមកខ្លួនឯង (តើគោលគំនិតនៅក្នុងអត្ថបទនេះមានទំនាក់ទំនងអ្វីជាមួយនឹងជីវិតទស្សនៈនិងបទពិសោធន៍របស់ខ្លួន?) | -នៅពេលយើងអានមេរៀននេះ វាបានធ្វើឱ្យយើងនឹកឃើញនៅពេលដែលយើង..................................................<br>-យើងយល់ស្របជាមួយមេរៀននេះដោយសារនៅក្នុងជីវិតយើង យើង.................................................<br>-យើងមិនយល់ស្របជាមួយនឹងមេរៀនដែលយើងបានអាននេះទេពីព្រោះនៅក្នុងជីវិតយើង<br>...........................................................................................<br>............................................................................................ |
| ទំនាក់ទំនងមេរៀនទៅកាន់សហគមន៍ជាតិនិងពិភពលោក (តើគោលគំនិតនៅក្នុងមេរៀននេះមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងសហគមន៍ ជាតិ និងពិភពលោកនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល?) | -មេរៀនដែលយើងបានអាននេះធ្វើឱ្យយើងគិតដល់..........<br>.............(ព្រឹត្តិការណ៍នៅក្នុងអតីតកាលដែលទាក់ទងនឹងសហគមន៍ជាតិឬពិភពលោក)ដោយសារ.................<br>...........................................................................................<br>...........................................................................................<br>-មេរៀនដែលយើងបានអាននេះធ្វើឱ្យយើងគិតដល់..................<br>(ព្រឹត្តិការណ៍ថ្មីៗដែលទាក់ទងនឹងសហគមន៍ប្រទេសជាតិ ពិភពលោក)ដោយសារ.......................<br>...........................................................................................<br>-មេរៀនដែលយើងបានអានធ្វើឱ្យយើងគិតដល់រឿងដែលអាចកើតមាននៅថ្ងៃអនាគត(ព្រឹត្តិការណ៍ដែលទាក់ទងនឹងសហគមន៍ ប្រទេសជាតិ ឬពិភពលោក) ដោយសារ........................................................<br>............................................................................................................................<br>............................................................................................ |

| | | |
|---|---|---|
| **ជំពូក៣** | **ការចូលរួមអភិវឌ្ឍសហគមន៍** | |
| **មេរៀនទី** | **១** | |
| **ចំណងជើងមេរៀន** | **លទ្ធិប្រជាធិបតេយ្យ** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | នៅក្នុងទស្សវត្សរ៍ចុងក្រោយនេះ ប្រជាពលរដ្ឋនៃបណ្ដាប្រទេសមួយចំនួនបានទាមទារសិទ្ធិសេរីភាព ការគោរពសិទ្ធិមនុស្ស ការអនុវត្តលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋតាមបែបលទ្ធិប្រជាធិបតេយ្យមានគោលការណ៍សំខាន់ៗដូចជាការផ្ដល់សិទ្ធិសេរីភាព ការមានសេរីភាពសារព័ត៌មាននិងការបញ្ចេញមតិ ការបង្កើតសមាគម ការបង្កើតគណបក្សនយោបាយ ប្រព័ន្ធពហុបក្ស ការបោះឆ្នោតដោយសេរីត្រឹមត្រូវ ការបែងចែកអំណាចដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ | |
| **វត្ថុបំណង** | ១ | • កំណត់និយមន័យលទ្ធិប្រជាធិបតេយ្យ<br>• រៀបរាប់លក្ខណៈសំខាន់ៗនៅក្នុងគោលការណ៍លទ្ធិប្រជាធិបតេយ្យ។ |
| | ២ | បង្ហាញពីសារៈសំខាន់និងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ។ |
| | ៣ | បណ្ដុះស្មារតីអនុវត្តលទ្ធិប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន និងសង្គម។ |
| **សម្ភារៈ** | សៀវភៅសិស្ស | |
| | រូបភាពក្នុងសៀវភៅសិស្ស | |
| **រយៈពេល** | ៣ម៉ោង | |

| ដំណើរការបង្រៀន |
|---|
| **ការចាប់ផ្តើមមេរៀន**<br>គ្រូៈ សួស្តីប្អូនៗទាំងអស់គ្នា។ យើងបានសិក្សារៀនសូត្រពីគ្នាទៅវិញទៅមកជាច្រើនសប្តាហ៍មកហើយ។យើងបានសិក្សាអំពីសិទ្ធិសេរីភាព ឯករាជភាព តម្លាភាពជាដើម។ ថ្ងៃនេះ យើងនឹងសិក្សាអំពីលទ្ធិប្រជាធិបតេយ្យវិញម្តង។ថ្ងៃមុន លោក/អ្នកគ្រូបានដាក់កិច្ចការឱ្យអ្នកទាំងអស់គ្នាធ្វើ ដើម្បីជួយឱ្យប្អូនៗអាន និងឆ្លុះបញ្ចាំងពីមេរៀនប្រជាធិបតេយ្យទៅនឹងមេរៀនផ្សេងៗ ទាក់ទងនឹងបទពិសោធន៍ដែលខ្លួនមានទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតមាននៅក្នុងសហគមន៍ ឬនៅក្រៅសហគមន៍របស់ប្អូន។ មុននឹងប្រមូលកិច្ចការនេះ លោក/អ្នកគ្រូចង់ឱ្យប្អូនខ្លះឡើងធ្វើបទបង្ហាញពីកិច្ចការដែលលោក/អ្នកគ្រូដាក់ឱ្យធ្វើ។ |
| **ចម្លើយរំពឹងទុកៈ** |

| | |
|---|---|
| ទំនាក់ទំនងមេរៀនចាស់ទៅមេរៀនថ្មី(តើគោលគំនិតនៅក្នុងមេរៀននេះ បានរំឭកឱ្យប្អូននឹកឃើញមេរៀនដទៃទៀតយ៉ាងដូចម្តេច? ) | - អ្វីដែលយើងបានអាន បានរំឭកដល់មេរៀនស្តីអំពីសេរីភាពដោយសារកាលណាយើងពុំមានសេរីភាពក្នុងការបញ្ចេញមតិ ក្នុងការទទួលបានព័ត៌មានការបោះឆ្នោតជ្រើសតាំងអ្នកតំណាងទេ យើងក៏មិនអាចមានប្រជាធិបតេយ្យពិតប្រាកដដែរ។ |
| | -គំនិតនៅក្នុងមេរៀននេះ មានភាពស្រដៀងគ្នាទៅនឹងមេរៀនសេរីភាពពីព្រោះមេរៀននេះក៏ពន្យល់ពីសេរីភាពដែលបុគ្គលម្នាក់ៗមានដូចជាការបញ្ចេញមតិ ការធ្វើនយោបាយ ការប្រកបរបរចិញ្ចឹមជីវិត និងការប្រកាន់យកជំនឿដែលខ្លួនពេញចិត្តផងដែរ។ |
| | -គំនិតនៅក្នុងមេរៀននេះ មានលក្ខណៈខុសគ្នាពីមេរៀនដែលពណ៌នាអំពីគុណវិបត្តិនៃសុរា និងបារី។ នៅក្នុងមេរៀននេះនិយាយពីសិទ្ធិសេរីភាពដែលបុគ្គលម្នាក់ៗមាននិងស្របទៅតាមច្បាប់។ ប៉ុន្តែមេរៀនស្តីពីវិបត្តិនៃសុរា និងបារី ទោះបីជាយើងមានសិទ្ធិសេរីភាព |

| | |
|---|---|
| | ប្រើប្រាស់ស្របច្បាប់ក៏ដោយក៏យើងមិនគួរប្រើប្រាស់ ឬគាំទ្រឱ្យប្រើដែរ ព្រោះផលលំបាកនៃការប្រើប្រាស់សុរានិងបារី ធ្វើឱ្យប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើប្រាស់។ |
| ទំនាក់ទំនងមេរៀនមកខ្លួនយើង(តើគោលគំនិតនៅក្នុងមេរៀននេះ មានទំនាក់ទំនងអ្វីជាមួយនឹងជីវិត ទស្សនៈ និងបទពិសោធន៍របស់ប្អូន ?) | -នៅពេលយើងអានមេរៀននេះ វាធ្វើឱ្យយើងនឹកឃើញនៅពេលដែលយើងចូលរួមបោះឆ្នោតជ្រើសរើសប្រធានថ្នាក់តាមបែបប្រជាធិបតេយ្យដោយពុំមានការចាត់តាំងពីនរណាម្នាក់ ឬពីសាលារៀនឡើយ...។ |
| | -យើងយល់ស្របជាមួយអត្ថបទ ដោយសារជីវិតយើងមានតែការប្រកាន់យកលទ្ធិប្រជាធិបតេយ្យទេទើបចៀសផុតពីមានសង្គ្រាម។ ការប្រកាន់យកលទ្ធិប្រជាធិបតេយ្យនឹងនាំមកការរីកចម្រើន និងសុខសន្តិភាពដល់ប្រទេសជាតិ និងប្រជាពលរដ្ឋ...។ |
| | -យើងមិនយល់ស្របជាមួយនឹងអត្ថបទដែលយើងបានអាននេះទេពីព្រោះយើងធ្លាប់ឃើញមានការតវ៉ាឬចោទប្រកាន់ថាតុលាការមួយចំនួននៅក្នុងប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យមានភាពពុករលួយ ។ |
| ទំនាក់ទំនងមេរៀនទៅកាន់ពិភពលោក (តើគោលគំនិតនៅក្នុងមេរៀននេះ មានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងពិភពលោកនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគត ?) | -មេរៀនដែលយើងបានអាននេះ ធ្វើឱ្យយើងគិតដល់ការបោះឆ្នោតឃុំ/សង្កាត់នៅឆ្នាំ ២០១៧(ព្រឹត្តិការណ៍នៅក្នុងអតីតកាល) ដោយសារនៅក្នុងមេរៀននេះបាននិយាយពីការប្រើប្រាស់សិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការជ្រើសរើសអ្នកតំណាងឱ្យជួយដោះស្រាយបញ្ហាដែលខ្លួនមាន។ |
| | -អត្ថបទដែលយើងបានអាននេះ ធ្វើឱ្យយើង |

| | |
|---|---|
| | គិតដល់ការធ្វើរដ្ឋប្រហាររបស់ពួកយោធាថៃ ដើម្បីបណ្តេញរដ្ឋាភិបាលស្របច្បាប់។ ប្រការនេះជាការរំលោភបំពានការប្រកាន់លទ្ធិប្រជាធិបតេយ្យដែលលើកឡើងថាការដឹកនាំរដ្ឋាភិបាល គឺត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋដោយសេរី និងយុត្តិធម៌។ |
| | -អត្ថបទដែលយើងបានអាន ធ្វើឱ្យយើងគិតដល់ការគោរពសិទ្ធិសេរីភាពរបស់កម្មករមកពីប្រទេសដទៃនៅក្នុងសហគមន៍អាស៊ាន ដោយសារប្រទេសយើងជាសមាជិកនៃសហគមន៍អាស៊ាន ដូចជាប្រទេសភូមា/មីយ៉ាន់ម៉ា និងប្រទេសសមាជិកផ្សេងទៀតមួយចំនួន ទទួលយកលទ្ធិប្រជាធិបតេយ្យ និងជំរុញឱ្យមានការការពារសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ។ |

**មេរៀនថ្មី**

គ្រូៈ អរគុណដែលប្អូនៗបានចូលរួមចែករំលែកចំណេះដឹងទាក់ទងនឹងលទ្ធិប្រជាធិបតេយ្យ។ គ្រូចង់សួរទៅប្អូនៗថា តើលទ្ធិប្រជាធិបតេយ្យមានដើមកំណើតនៅប្រទេសណាដំបូងគេ ហើយមានន័យដូចម្តេច?

**ចម្លើយរំពឹងទុកៈ**

តាមអ្នកប្រវត្តិសាស្ត្រ ប្រទេសក្រិចជាប្រទេសដែលផ្តល់កំណើតដំបូងគេ ដល់លទ្ធិប្រជាធិបតេយ្យ។ ពាក្យថា ប្រជាធិបតេយ្យ គឺមានដើមកំណើតមកពីពាក្យក្រិចថា Demokratia។ Demos មានន័យថាប្រជាឬប្រជាជន រីឯKratros មានន័យថាអធិបតេយ្យ ដែលសំដៅលើអំណាចជាធំ។ ដូច្នេះ លទ្ធិប្រជាធិបតេយ្យមានន័យថាជាទម្រង់នៃការដឹកនាំប្រទេសដែលផ្តល់អំណាចទាំងអស់ឱ្យទៅប្រជាជន។ ប្រជាជនមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសអ្នកតំណាងរបស់ខ្លួន ឱ្យបង្កើតរដ្ឋាភិបាលដែលមានតួនាទីសំខាន់ក្នុងការចាត់ចែងការងារប្រទេសជាតិស្របទៅតាមឆន្ទៈនិងផលប្រយោជន៍របស់ប្រជាជន។

| |
|---|
| គ្រូ: ឥឡូវយើងនឹងពិនិត្យទៅលើលក្ខណៈសំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យវិញម្ដង។ លក្ខណៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យមានដូចជាសិទ្ធិសេរីភាព សេរីភាពសារព័ត៌មាន និងការបញ្ចេញមតិ ការបង្កើតគណបក្សនយោបាយ ការបោះឆ្នោត ប្រព័ន្ធពហុបក្ស និងការបែងចែកអំណាច។ គ្រូនឹងដាក់សំណួរ រួចហើយយើងអានអត្ថបទទាំងអស់គ្នា បន្ទាប់មកយើងនឹងជួយឆ្លើយទាំងអស់គ្នា។<br>គ្រូ:ឥឡូវយើងមើលលើផ្នែកសិទ្ធិសេរីភាពមុនគេ។ សំណួរគឺតើសិទ្ធិមានន័យដូចម្ដេច? សេរីភាពមានន័យដូចម្ដេច? តើហេតុអ្វីបានយើងត្រូវមានទាំងសិទ្ធិ ទាំងសេរីភាពផង? គ្រូឱ្យសិស្សអានអត្ថបទមេរៀនដោយស្ងៀមស្ងាត់ បន្ទាប់មកគ្រូឱ្យសិស្សឡើងឆ្លើយសំណួរ។ |
| **ចម្លើយរំពឹងទុកៈ**<br>• សិទ្ធិគឺ សំដៅលើការទាមទារអ្វីដែលមនុស្សត្រូវតែមានជាចាំបាច់ដើម្បីឱ្យការរស់នៅរបស់ខ្លួនមានភាពសមរម្យថ្លៃថ្នូរជាមនុស្ស។<br>• សេរីភាពគឺ សំដៅលើអ្វីៗគ្រប់យ៉ាងដែលមនុស្សចង់បាន និងចង់ធ្វើអ្វីៗដោយគ្មានការគាបសង្កត់ និងបង្ខិតបង្ខំពីនរណាម្នាក់ ឬក្រុមណាមួយឡើយ។ ឧទាហរណ៍ មនុស្សម្នាក់ៗមានសេរីភាពក្នុងការគិត និងការប្រើគំនិតសេរីភាពខាងជំនឿសាសនា សេរីភាពក្នុងការជ្រើសរើសគូស្រករ សេរីភាពក្នុងការដើរលេងកំសាន្ត និងសេរីភាពក្នុងការបញ្ចេញមតិ។<br>• ហេតុដែលយើងត្រូវមានទាំងសិទ្ធិផង ទាំងសេរីភាពផង គឺដោយសារតែសិទ្ធិ និងសេរីភាពមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត។បុគ្គលជាទូទៅមានសិទ្ធិតាំងពីកំណើតមកម្លេះ ប៉ុន្តែត្រូវប្រើសិទ្ធិនិងសេរីភាពកុំឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពអ្នកដទៃ។ឧទាហរណ៍ យើងមានសិទ្ធិ សេរីភាពក្នុងការធ្វើបុណ្យសព តែកុំឱ្យមានផលប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកជិតខាងដែលកំពុងមានពិធីរៀបអាពាហ៍ពិពាហ៍។ ដូច្នេះហើយ ដើម្បីឱ្យជីវិតខ្លួនរស់នៅមានន័យនិងប្រកបដោយសុខសន្តិភាព សុភមង្គល មនុស្សយើងគ្រប់រូបត្រូវតែមានសិទ្ធិ និងសេរីភាពរបស់ខ្លួន អាចអនុវត្តសិទ្ធិសេរីភាពទាំងនោះបាន អនុលោមទៅតាមច្បាប់ និងក្រមសីលធម៌ដែលបានចែង នោះយើងនឹងមិនត្រូវបានគេរើសអើង និងមើលងាយមើលថោកឡើយ។ |
| គ្រូ: ឥឡូវយើងអានវគ្គសេរីភាពសារព័ត៌មាន និងការបញ្ចេញមតិម្ដង។ សំណួរសម្រាប់ផ្នែកនេះគឺ តើសេរីភាពនៃសារព័ត៌មាន និងការបញ្ចេញមតិមានន័យដូចម្ដេច? |

| |
|---|
| តើយើងអាចបញ្ចេញមតិតាមវិធីណាបាន? តើការបញ្ចេញមតិតាមវិធីទាំងនោះបានជួយអ្វីខ្លះដល់ប្រជាពលរដ្ឋ? |
| **ចម្លើយរំពឹងទុក៖**<br>• សេរីភាពសារព័ត៌មាន និងការបញ្ចេញមតិ គឺសំដៅដល់ការផ្សព្វផ្សាយព័ត៌មាន និងមតិដោយគ្មានការជ្រៀតជ្រែក គ្មានការព្រួយបារម្ភភិតភ័យ ការមានសេរីភាពក្នុងការស្វែងរក និងទទួលព័ត៌មានទូទៅដោយគ្មាន ការរាំងស្របទៅតាមច្បាប់ និងមិនប៉ះពាល់ដល់សិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់អ្នកដទៃ។<br>• យើងអាចបញ្ចេញមតិតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ វិទ្យុ អ៊ីនធើណេត សារព័ត៌មាន ទស្សនាវដ្ដី ឬនៅក្នុងការប្រជុំ វេទិការសម្ដែងមតិសាធារណៈជាដើម ស្របទៅតាមច្បាប់ និងមិនប៉ះពាល់ទៅដល់សិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់អ្នកដទៃ។<br>• ការបញ្ចេញមតិតាមវិធីទាំងនេះបានជួយដល់ប្រជាពលរដ្ឋដូចជា៖<br>១. ជួយផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នានាក្នុង និងក្រៅប្រទេសដល់ប្រជាពលរដ្ឋឱ្យបានដឹងពីសភាពការណ៍ដែលកើតមាន និងជួយផ្សព្វផ្សាយចំណេះដឹងនិងគំនិតថ្មីៗបន្ថែមទៀត<br>២.ជួយដល់ការអភិវឌ្ឍទាំងផ្នែកនយោបាយ ទាំងផ្នែកវិទ្យាសាស្ត្រ ទាំងផ្នែកបច្ចេកទេសដល់ប្រជាពលរដ្ឋ<br>៣. ផ្ដល់ព័ត៌មាន និងបទពិសោធន៍ដល់ថ្នាក់ដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ<br>៤. ផ្សព្វផ្សាយគំនិតថ្មីៗលើគ្រប់វិស័យ ពិសេសបញ្ហាជាតិនានា។ល។ |
| គ្រូ: ល្អណាស់ប្អូនៗ។ឥឡូវយើងអានទៅផ្នែកបន្ទាប់ទៀតគឺគណបក្សនយោបាយនិងការបោះឆ្នោត។ សំណួរនៅក្នុងផ្នែកនេះ តើយើងម្នាក់ៗមានសិទ្ធិអ្វីខ្លះទាក់ទងនឹងគណបក្សនយោបាយ? តើយើងមានសិទ្ធិអ្វីខ្លះទាក់ទងនឹងការបោះឆ្នោត? |
| **ចម្លើយរំពឹងទុក៖**<br>• ចំពោះសិទ្ធិទាក់ទងនឹងគណបក្សនយោបាយគឺពលរដ្ឋគ្រប់រូបមានសិទ្ធិបង្កើតគណបក្សនយោបាយ ប្រកួតប្រជែងដោយសេរី យុត្តិធម៌ ដើម្បីបម្រើផលប្រយោជន៍ប្រជាជន និងផ្សព្វផ្សាយពីគោលនយោបាយរបស់ខ្លួន។ ពួកគេក៏មានសិទ្ធិបញ្ជូនមតិយោបល់របស់ប្រជាជនទៅឱ្យតំណាងរាស្ត្រ ឬរដ្ឋាភិបាលបានដឹងពីបំណងរបស់ខ្លួន ដើម្បីជួយដោះស្រាយរាល់ការលំបាករបស់ប្រជាជន។ |

| |
|---|
| • ចំពោះសិទ្ធិបោះឆ្នោត ប្រជាពលរដ្ឋទាំងអស់ត្រូវមានសិទ្ធិជ្រើសរើសអ្នកតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរី យុត្តិធម៌ សម្ងាត់ ស្មើភាព សុចរិត និងដោយទៀងទាត់តាមពេលកំណត់។ |
| គ្រូ: ទាក់ទងនឹងការបោះឆ្នោត ព្រះរាជាណាចក្រកម្ពុជាយើង បានជ្រើសរើសយកប្រព័ន្ធពហុបក្ស។ ចូរប្អូនទាំងអស់គ្នាអានអត្ថបទបន្ទាប់រួចហើយជួយពន្យល់ប្រាប់មិត្តរួមថ្នាក់ថា តើហេតុអ្វីបានជាប្រទេសយើងជ្រើសរើសយកប្រព័ន្ធនេះ។ |
| **ចម្លើយរំពឹងទុក:**<br>ដោយសារបុគ្គលយើងម្នាក់ៗក៏អាចមានគំនិត មតិយោបល់ខុសៗគ្នា ដូច្នេះហើយ ការជ្រើសរើសយកប្រព័ន្ធពហុបក្ស គឺដើម្បីផ្តល់នូវជម្រើសផ្សេងៗឱ្យប្រជាពលរដ្ឋម្នាក់ៗមានជម្រើសច្រើនក្នុងការជ្រើសរើស ទៅតាមការពេញចិត្តរបស់ខ្លួន។ ម្យ៉ាងវិញទៀត ការជ្រើសរើសប្រព័ន្ធនេះ ក៏បានឆ្លុះបញ្ចាំងការចេះស្តាប់ ចេះស្វែងយល់ ចេះគោរពគំនិតអ្នកដទៃ ព្រមទាំងចេះទទួលយកគំនិតមតិភាគច្រើន ក៏ដូចជាការគោរព ការការពារទស្សនៈនៃមតិភាគតិច និងចេះធានាសិទ្ធិសេរីភាព មតិរបស់ប្រជាពលរដ្ឋភាគតិចផងដែរ។ |
| គ្រូ: ឥឡូវយើងមកដល់វគ្គចុងក្រោយហើយ។ វគ្គនេះទាក់ទងនឹងការបែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ យើងនឹងបន្តអានវគ្គនេះទាំងអស់គ្នាបន្តទៀត។សំណួរសម្រាប់វគ្គនេះគឺ តើហេតុអ្វីបានជាគេត្រូវបែងចែកអំណាចនេះឱ្យដាច់ពីគ្នា? តើអំណាចនីមួយៗមានកាតព្វកិច្ចអ្វីខ្លះ? |
| **ចម្លើយរំពឹងទុកៈ**<br>• ការបែងចែកអំណាចទាំងបីនេះគឺដោយសារចង់ធានាឱ្យមានតុល្យភាពអំណាចក្នុងការទប់ស្កាត់កុំឱ្យមានការរំលោភបំពានគ្នាទៅវិញទៅមក និងធានាថាគ្មានអំណាចណាមួយបំពានសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋឬបង្កភាពអយុត្តិធម៌ដែលផ្ទុយពីរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលឡើយ។<br>• អំណាចនីតិប្បញ្ញត្តិដែលកើតឡើងដោយការបោះឆ្នោតមានកាតព្វកិច្ចពីរត្រូវបំពេញ ពោលគឺកាតព្វកិច្ចធ្វើច្បាប់ និងតាមដានប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ដើម្បីការពារនិងធានានូវការគោរពសិទ្ធិសេរីភាព ផលប្រយោជន៍ប្រជាជន សណ្តាប់ធ្នាប់សង្គមជាតិ និងយុត្តិធម៌សង្គម។<br>• អំណាចនីតិប្រតិបត្តិ ជាអំណាចមួយដែលមានកាតព្វកិច្ចដឹកនាំប្រតិបត្តិ |

នយោបាយក្នុងនិងក្រៅប្រទេសទៅតាមច្បាប់និងកម្មវិធីនយោបាយដែល រដ្ឋសភាបានផ្ដល់សេចក្ដីទុកចិត្តរួចហើយ ។

- អំណាចតុលាការ ជាអំណាចមួយដែលមានភាពឯករាជ្យ មិនលម្អៀងទៅលើ ភាគី ស្ថាប័ន បុគ្គល ឬគណបក្សនយោបាយណាមួយឡើយ។អំណាចនេះ មានកាតព្វកិច្ចការពារ និងធានានូវយុត្តិធម៌សង្គម ការពារផលប្រយោជន៍ ប្រជាពលរដ្ឋ និងគោរពសិទ្ធិមនុស្សដោយធ្វើការកាត់សេចក្ដី ឬវិនិច្ឆ័យ ជំនុំជម្រះដោយផ្អែកទៅលើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិនានា។

**ការពង្រឹងពុទ្ធិ**

គ្រូៈឥឡូវមុននឹងបញ្ចប់មេរៀន គ្រូឱ្យប្អូន១០នាក់ស្ម័គ្រចិត្តចូលរួមធ្វើការតស៊ូមតិ (Debate)។ក្រុមគាំទ្រមានសមាជិក៥នាក់ និងក្រុមជំទាស់មានសមាជិក៥នាក់ដែរ។ យើងតស៊ូមតិ(Debate) ទាក់ទងនឹងប្រធានបទដែលថា «នៅក្នុងរដ្ឋដែលប្រកាន់យក លទ្ធិប្រជាធិបតេយ្យ អ្នកមិនចេះអក្សរមិនគួរអនុញ្ញាតឱ្យបោះឆ្នោតទេព្រោះគាត់មិន ចេះគិតពិចារណាជ្រើសរើសមេដឹកនាំល្អបានឡើយ»។ អ្នកដែលនៅសល់ពីនេះគឺត្រូវ ដើរតួនាទីជាអ្នកបោះឆ្នោតវាយតម្លៃថាក្រុមណាលើកហេតុផលបានល្អជាង។

**ចម្លើយរំពឹងទុកៈ** ការតស៊ូមតិ(Debate)

**សមាជិកទី១ក្រុមជំទាស់**

នៅក្នុងសង្គមប្រកាន់លទ្ធិប្រជាធិបតេយ្យ មនុស្សគឺមានសិទ្ធិសេរីភាពស្មើៗគ្នាដោយពុំ មានការរើសអើងអ្វីឡើយ សូម្បីតែអ្នករៀនសូត្រ ឬមិនបានរៀនសូត្រក៏មានសិទ្ធិស្មើ គ្នាដែរ។ ការដែលឱ្យមានសិទ្ធិស្មើគ្នានេះព្រោះថាបុគ្គលម្នាក់ៗមានសិទ្ធិសម្រេចលើ អាយុជីវិតរបស់ខ្លួន គ្មានបុគ្គលណាម្នាក់អាចមកដណ្ដើមយកសិទ្ធិនេះទៅសម្រេច ជំនួសយើងបានឡើយ។កាលណាបុគ្គលណាម្នាក់មកសម្រេចជំនួសយើង ការសម្រេច នោះអាចខុស ហើយប៉ះពាល់ដល់ជីវិតយើងយ៉ាងធ្ងន់ធ្ងរ ហើយក៏ពិបាករកមនុស្សមក ទទួលខុសត្រូវចំពោះការសម្រេចចិត្តខុសនេះណាស់។ ដូច្នេះហើយក្រុមរបស់ខ្ញុំគាំទ្រ ថាមិនថាអ្នកចេះអក្សរឬមិនចេះអក្សរទេ ត្រូវតែមានសិទ្ធិក្នុងការបោះឆ្នោតទៅតាមឆន្ទៈ រៀងៗខ្លួន។

**សមាជិកទី១ ក្រុមស្រប**

ក្រុមរបស់ខ្ញុំសុំជំទាស់ទៅនឹងគំនិតដែលថ្លែងថា មនុស្សទាំងអស់មិនថាអ្នកចេះអក្សរ ឬ មិនចេះអក្សរត្រូវតែមានសិទ្ធិបោះឆ្នោត។ ក្រុមខ្ញុំមិនគាំទ្រ ការផ្ដល់សិទ្ធិបោះឆ្នោត ឱ្យទៅអ្នកមិនចេះអក្សរឡើយ ព្រោះពួកគាត់ពុំមានសមត្ថភាពក្នុងការស្វែងរក និង

| |
|---|
| ជ្រើសរើសមេដឹកនាំល្អបានឡើយ។ ការជ្រើសរើសមេដឹកនាំល្អមួយបានទាមទារឱ្យមានការស្វះស្វែងរកព័ត៌មានដែលគេសរសេរពីបុគ្គលឈរឈ្មោះនោះ ចុះបើពួកគាត់មិនចេះអក្សរផង តើគាត់អាចទទួលបានព័ត៌មានទាំងនោះដោយរបៀបណា? ដូច្នេះពួកគាត់គ្មានសមត្ថភាពក្នុងការសម្រេចចិត្តប្រកបដោយការពិចារណាត្រឹមត្រូវពីការជ្រើសរើសមេដឹកនាំបានទេ។ ក្រុមខ្ញុំនៅតែបដិសេធសិទ្ធិបោះឆ្នោតរបស់ពួកអ្នកមិនចេះអក្សរ។ |
| **<u>សមាជិកទី២ ក្រុមជំទាស់</u>**<br>ការលើកឡើងថា អ្នកមិនចេះអក្សរមិនអាចរកព័ត៌មានទាក់ទងនឹងបេក្ខជនឈរឈ្មោះនោះមិនត្រឹមត្រូវទេ។ជាការពិត ទោះបីគាត់មិនអាចអានអក្សរបាន ក៏មិនមានន័យថាគាត់មិនអាចទទួលព័ត៌មានបានដែរ។ ប្រភពព័ត៌មាន មានច្រើនបែបច្រើនយ៉ាង ក្នុងនោះក៏មានជារូបភាព និងសំឡេងផងដែរ។ ដូចដែលយើងធ្លាប់បានឃើញហើយថា ជារៀងរាល់ពេលមានការឃោសនាបោះឆ្នោត យើងតែងតែឃើញសមាជិកគណបក្សផ្សព្វផ្សាយពីគោលនយោបាយរបស់បក្សខ្លួនជាសំឡេង ឬជាវីដេអូទៀតផង។ ដូច្នេះទាំងអ្នកចេះអក្សរ និងមិនចេះអក្សរ នៅតែអាចទទួលបានព័ត៌មាន ដើម្បីជួយឱ្យពួកគាត់សម្រេចចិត្តបោះឆ្នោតបានយ៉ាងត្រឹមត្រូវ។ ក្រុមខ្ញុំនៅតែគាំទ្រឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសិទ្ធិបោះឆ្នោតស្មើៗគ្នា មិនថាជាអ្នកចេះអក្សរ ឬមិនចេះអក្សរ។ |
| **<u>សមាជិកទី២ក្រុមស្រប</u>**<br>ជាការពិតហើយដែលថា មានប្រភពព័ត៌មានច្រើន មានទាំងរូបភាព និងសំឡេង ប៉ុន្តែអ្នកមិនចេះអក្សរច្រើនតែជាអ្នកក្រីក្រ និងធ្វើការដោយកម្លាំងបាយ ដូច្នេះពួកគាត់គ្មានលទ្ធភាពទិញទូរទស្សន៍ ឬវិទ្យុទេ។ ទោះបីជាគាត់មានលទ្ធភាពក៏ពួកគាត់គ្មានពេលមើលឬស្ដាប់ដែរ ព្រោះត្រូវធ្វើការមួយថ្ងៃពេញ ដូច្នេះហើយពួកគាត់មិនគួរទទួលបានសិទ្ធិបោះឆ្នោតទេ។ |
| **<u>សមាជិកទី៣ក្រុមជំទាស់</u>**<br>ការឃោសនាបោះឆ្នោតមិនមែនធ្វើត្រឹមតែតាមទូរទស្សន៍ វិទ្យុនោះទេ។ គ្រប់គណបក្សទាំងអស់តែងតែចុះមកជួបប្រជាជនដោយផ្ទាល់ ដើម្បីពន្យល់ណែនាំអំពីគោលនយោបាយ និងសមិទ្ធផលរបស់បក្សគេ។ ម្យ៉ាងទៀតក៏មានការដង្ហែ និងចាក់សំឡេងរួមទាំងបញ្ចាំងទូរទស្សន៍នៅតាមទីសាធារណៈតាំងពីព្រឹករហូតដល់ម៉ោង៨យប់ជារៀងរាល់ថ្ងៃ ជាពិសេសគឺថ្ងៃឈប់សម្រាក។ដូចនេះប្រជាជន នៅតែអាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងអាចសម្រេចចិត្តបោះឆ្នោតបានយ៉ាងត្រឹមត្រូវ។ |

| |
|---|
| **<u>សមាជិកទី៣ក្រុមស្រប</u>**<br>ដូចសមាជិកក្រុមរបស់ខ្ញុំបានពន្យល់អញ្ចឹង។ ពួកអ្នកមិនចេះអក្សរ ត្រូវធ្វើការយ៉ាងលំបាកតាំងពីព្រឹករហូតដល់ល្ងាច ពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ឬក៏ត្រូវថែមម៉ោងនៅយប់ ឬថ្ងៃសម្រាកផង ដូច្នេះហើយគាត់ពុំមានពេលវេលាគ្រប់គ្រាន់មកចូលរួម ឬស្តាប់ការឃោសនានោះទេ។ម្យ៉ាងទៀតពួកគាត់មិនបានរៀនសូត្រ ពួកគាត់ពុំដឹងថាត្រូវវិភាគ ឬពិចារណាយ៉ាងណា ដើម្បីជ្រើសរើសមេដឹកនាំល្អបានទេ។ ដូចនេះពួកគាត់គួរទុកសិទ្ធិនេះឱ្យអ្នកចេះអក្សរជាអ្នកសម្រេចវិញ។ |
| **<u>សមាជិកទី៤ក្រុមជំទាស់</u>**<br>ជាការពិតណាស់ការរៀនសូត្រជួយឱ្យយើងយល់ដឹង និងចេះត្រិះរិះពិចារណាបានស៊ីជម្រៅ ប៉ុន្តែការរៀនសូត្រមិនមែនធ្វើឡើងតែនៅក្នុងសាលារៀនទេ។ ពួកអ្នកមិនចេះអក្សរក៏បានរៀនសូត្រពីការរស់នៅប្រចាំថ្ងៃ ពីការងារ ពីការជជែកពិភាក្សា និងការទទួលបានព័ត៌មានពីប្រភពផ្សេងៗផងដែរ ដូច្នេះពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចចិត្តជ្រើសរើសមេដឹកនាំណាដែលអាចជួយដោះស្រាយបញ្ហារបស់គាត់បាន។ |
| **<u>សមាជិកទី៤ក្រុមស្រប</u>**<br>ទោះបីយ៉ាងណាក្តី អ្នកធ្លាប់ចូលសាលារៀន ធ្លាប់ទទួលការបណ្តុះបណ្តាលឱ្យចេះពិចារណា វិភាគថាបុគ្គលណាសមជាមេដឹកនាំ ទើបអាចមានសមត្ថភាពច្រើនជាង ល្អជាង។ ដូចយើងឃើញហើយនៅស្ថាប័នរដ្ឋក្តី ឯកជនក្តី គេតែងតែយកអ្នករៀនសូត្រចេះអក្សរទៅធ្វើការមានឋានៈតួនាទី ទាក់ទងនឹងការសម្រេចចិត្តពីព្រោះពួកគេមានសមត្ថភាពច្រើនជាងអ្នកមិនចេះអក្សរ។ |
| **<u>សមាជិកទី៥ក្រុមជំទាស់ (ឡើងសរុប)</u>**<br>ក្រុមរបស់ខ្ញុំនៅតែយល់ស្របថាបុគ្គលទាំងអស់មិនថារៀនបានកម្រិតណា ឬមិនបានរៀន ត្រូវតែមានសិទ្ធិក្នុងការបោះឆ្នោត ព្រោះលទ្ធផលនៃការបោះឆ្នោត មានជាប់ពាក់ព័ន្ធនឹងជីវិតរបស់បុគ្គលរៀងៗខ្លួនមិនអាចឱ្យនរណាមកសម្រេចជំនួសបានឡើយ។<br>ម្យ៉ាងទៀត បើទោះបីជាពួកគាត់មិនចេះអក្សរក៏ពួកគាត់អាចទទួលព័ត៌មានពីប្រភពនានាបានដែរ ជាពិសេសគឺផ្នែកសំឡេង និងរូបភាព។ ការទម្លាក់កំហុសទៅអ្នកមិនចេះអក្សរ គឺជាអ្នកនាំជ្រើសរើសឱ្យមានមេដឹកនាំអាក្រក់នោះមិនត្រឹមត្រូវទេ។ មេដឹកនាំអាក្រក់អាចកើតឡើងបានដោយសារស្ថាប័ននានា រួមទាំងរដ្ឋសភា និងតុលាការមិនឯករាជ្យ មិនតម្លាភាព បរាជ័យក្នុងការត្រួតពិនិត្យរារាំងនិងដាក់ទោសចំពោះមេដឹកនាំ |

| |
|---|
| ដែលប្រព្រឹត្តិខុស។ដូច្នេះ ក្រុមខ្ញុំនៅតែជំទាស់ថាទាំងអ្នកចេះ ទាំងអ្នកមិនចេះអក្សរត្រូវតែមានសិទ្ធិបោះឆ្នោត។ |
| <u>**សមាជិកទី៥ក្រុមស្រប(ឡើងសរុប)**</u><br>ចំណែកក្រុមរបស់ខ្ញុំ នៅតែគាំទ្រថាដោយសារអ្នកមិនចេះអក្សរ មិនចេះតាមដានវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ ទើបធ្វើឱ្យពួកបេក្ខជនអាក្រក់ៗអាចមកភូតភរបោកប្រាស់បាន។ អ្នកមិនចេះអក្សរខ្លះចាញ់ការគំរាមកំហែង ឬក៏លក់សន្លឹកឆ្នោតរបស់ខ្លួនជាថ្នូរនឹងប្រាក់កាស ឬអំណោយបន្តិចបន្តួច។ ដូច្នេះក្រុមរបស់ខ្ញុំនៅតែប្រកាន់ជំហរថាពួកអ្នកមិនចេះអក្សរមិនគួរទទួលបានសិទ្ធិបោះឆ្នោតទេ។ |
| បន្ទាប់ពីការតស៊ូមតិ(Debate)ចប់ គ្រូឱ្យសិស្សបោះឆ្នោត។ |
| **កិច្ចការផ្ទះ**<br>គ្រូៈ គ្រូដាក់កិច្ចការផ្ទះឱ្យប្អូនៗ។ ប្អូនៗត្រូវឆ្លើយសំណួរថា តើលទ្ធិប្រជាធិបតេយ្យមានសារៈសំខាន់អ្វីខ្លះដល់សង្គមជាតិ?សប្តាហ៍ក្រោយ គ្រូនឹងប្រមូលយកចម្លើយពីប្អូនៗ។ |
| **ចម្លើយរំពឹងទុកៈ**<br>លទ្ធិប្រជាធិបតេយ្យមានសារៈសំខាន់ណាស់ក្នុងការការពារ និងធានាឱ្យមានការគោរពសិទ្ធិសេរីភាពក្នុងការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត ការគោរពជំនឿសាសនា។លទ្ធិប្រជាធិបតេយ្យបានធានានូវសិទ្ធិ ក្នុងការប្តឹងតវ៉ាឱ្យអនុវត្តច្បាប់ស្មើភាពគ្នានិងមិនលម្អៀងប្រសិនបើអ្នកមានអំណាច ឬទ្រព្យធនរំលោភបំពានលើប្រជាជនសាមញ្ញ ប្រជាជនត្រូវប្រឆាំងតវ៉ាលើការរំលោភបំពាន ឬភាពអយុត្តិធម៌តាមរយៈការធ្វើបាតុកម្ម ស្របទៅតាមច្បាប់កំណត់។ ប្រជាជនដែលរស់នៅក្នុងរបបប្រជាធិបតេយ្យក៏បានទទួល និងការការពារសិទ្ធិក្នុងការទទួលព័ត៌មាន ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ សិទ្ធិក្នុងការជួបប្រជុំ ឬសិទ្ធិក្នុងការបង្កើតសមាគម សហជីពដើម្បីការពារផលប្រយោជន៍ប្រជាជន កម្មករ និយោជិត និងនិយោជក។ ប្រជាជនមិនត្រឹមតែមានសិទ្ធិបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែអាចឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតជ្រើសរើសជាមេដឹកនាំ ដើម្បីចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ ធ្វើឱ្យមានយុត្តិធម៌ ការគោរពសិទ្ធិ និងកសាងប្រយោជន៍ដល់ប្រជាជន សង្គមជាតិមាតុភូមិផងដែរ។ដោយសារការប្រកាន់យកលទ្ធិប្រជាធិបតេយ្យនេះហើយទើបធ្វើឱ្យសង្គមជាតិមានសុខសន្តិភាព ស្ថេរភាព និងការរីកចម្រើន។ |

| | | |
|---|---|---|
| **ជំពូក៣** | **ការចូលរួមអភិវឌ្ឍសហគមន៍** | |
| **មេរៀនទី** | **២** | |
| **ចំណងជើងមេរៀន** | **សិទ្ធិពលរដ្ឋ** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | ពលរដ្ឋជាប្រជាជនទាំងប្រុស ទាំងស្រីដែលទុកជាកម្លាំងស្នូលសម្រាប់ប្រទេសជាតិ។ ពលរដ្ឋត្រូវមានការទទួលខុសត្រូវ គោរពតួនាទីនិងករណីយកិច្ចរបស់ខ្លួនចំពោះគ្រួសារ សង្គម និងចូលរួមជួយកសាងសង្គម។ពលរដ្ឋគ្រប់រូបទទួលបានសិទ្ធិគ្រប់បែបយ៉ាងដូចជាសិទ្ធិផ្ទាល់ខ្លួន សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច សិទ្ធិវប្បធម៌ និងសិទ្ធិសំខាន់ៗផ្សេងទៀត។ | |
| **វត្ថុបំណង** | ១ | ប្រាប់និយមន័យពលរដ្ឋ សិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ សិទ្ធិសង្គមកិច្ច សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិវប្បធម៌។ |
| | ២ | ពន្យល់ពីសិទ្ធិផ្សេងៗដែលមនុស្សត្រូវមានដូចជាសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិវប្បធម៌។ |
| | ៣ | គោរពខ្ជាប់ខ្ជួនគោលការណ៍ច្បាប់ និងគោរពសិទ្ធិអ្នកដទៃ។ |
| **សម្ភារៈ** | សៀវភៅសិស្ស | |
| | រូបភាពក្នុងសៀវភៅសិស្ស | |
| | រូបមនុស្សដែលមានបញ្ជាក់ពីសិទ្ធិ | |
| | ផ្ទាំងក្រដាសធំរូបដ្យាក្រាម(Character map) | |
| **រយៈពេល** | ៣ម៉ោង | |

| ដំណើរការបង្រៀន |
|---|
| **ការចាប់ផ្ដើមមេរៀន**<br>គ្រូ: យើងបានសិក្សាជាច្រើនដងមកហើយអំពីសិទ្ធិកាលនៅថ្នាក់ទី១០ ក៏ដូចជាមេរៀនមុនៗនៅថ្នាក់ទី១១នេះផងដែរ។ ថ្ងៃនេះយើងនឹងសិក្សាឱ្យស៊ីជម្រៅបន្ថែមទៀតទៅលើសិទ្ធិពលរដ្ឋ ប៉ុន្តែមុននឹងចាប់ផ្ដើមលោក/អ្នកគ្រូចង់ដឹងថាតើប្អូនៗបានអានអត្ថបទមេរៀន និងមានចំណាប់អារម្មណ៍លើអត្ថបទនេះយ៉ាងដូចម្ដេចខ្លះ។ ប្អូនៗត្រូវអានអត្ថបទនេះម្ដងទៀត រួចរកមើលគំនិតសំខាន់ៗចំនួន៣ បង្កើតសំណួរចំនួន២ទាក់ទងមេរៀនដែលប្អូនគិតថានៅមិនទាន់យល់ច្បាស់ និងរក១ចំណុចដែលប្អូនចូលចិត្តនិងចាប់អារម្មណ៍ ។ |
| **ចម្លើយរំពឹងទុកៈ**<br>ក. គំនិតសំខាន់៣៖<br>១.ពលរដ្ឋទាំងអស់មិនថាអាក្រក់ ល្អ ស ខ្មៅ ក្រ មាន ប្រកាន់សាសនាអ្វី ជាតិសាសន៍អ្វី ឬក៏ពិការទេ គឺមានសិទ្ធិស្មើៗគ្នាទាំងអស់។<br>២.មនុស្សម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការរស់នៅ និងការពារខ្លួនស្របតាមច្បាប់ ស្របតាមវប្បធម៌ ទំនៀមទម្លាប់របស់ជាតិ។<br>៣.ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិចូលរួមការបោះឆ្នោត សិទ្ធិក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការបង្កើតគណបក្សនយោបាយ និងសិទ្ធិចូលរួមក្នុងឆាកនយោបាយ ក្នុងការបង្កើតសមាគម សហជីព សិទ្ធិធ្វើកូដកម្ម សិទ្ធិចូលរួមប្រជុំដោយសេរី។<br>ខ. សំណួរ២៖<br>១. តើសិទ្ធិទទួលចំណីអាហារគ្រប់គ្រាន់មានន័យដូចម្ដេច?<br>២. តើពលរដ្ឋត្រូវមានលក្ខណៈអ្វីខ្លះ ដើម្បីចូលរួមក្នុងការបោះឆ្នោតបាន?<br>គ. ចំណុចចូលចិត្ត១៖<br>សិទ្ធិរបស់ពលរដ្ឋទាំងអស់មានការទទួលស្គាល់ និងការពារស្មើៗគ្នា។ សិទ្ធិរបស់ពលរដ្ឋមិនអាចលក់ ទិញ ដូរ ឬដកហូតបានឡើយ។ |
| គ្រូឱ្យសិស្សពីរឬបីនាក់ឡើងអានកិច្ចការរបស់ពួកគេ ហើយឆ្លើយសំណួរដែលពួកគេបានសួរ។ |
| **មេរៀនថ្មី**<br>គ្រូ: សិទ្ធិពលរដ្ឋបានមកពីការផ្គុំចូលគ្នារវាងសិទ្ធិ និងពលរដ្ឋ។ តើប្អូនណាអាចជួយពន្យល់មិត្តរួមថ្នាក់ និងលោក/អ្នកគ្រូបានទេ? |

**ចម្លើយរំពឹងទុក៖**

- សិទ្ធិ គឺជាអ្វីៗដែលមនុស្សត្រូវមានជាចាំបាច់សម្រាប់រស់នៅឱ្យបានសមរម្យ និងមានសេចក្តីថ្លៃថ្នូរជាមនុស្ស។សិទ្ធិជាអំណាចពិសេសរបស់មនុស្សដែលមានតាំងពីកំណើតសម្រាប់ឱ្យមនុស្សការពារខ្លួនពីការរំលោភបំពានរបស់អ្នកដទៃ និងអាចឱ្យមនុស្សធ្វើអ្វីៗបានដូចមានចែងក្នុងច្បាប់។
- ពលរដ្ឋគឺសំដៅលើប្រជាជនទាំងប្រុសទាំងស្រីដែលទុកជាកម្លាំងស្នូលសម្រាប់ប្រទេសជាតិ។ ពលរដ្ឋមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ពលរដ្ឋត្រូវមានការទទួលខុសត្រូវចំពោះមុខច្បាប់ មានករណីយកិច្ចចំពោះសង្គម។ ពលរដ្ឋជាមនុស្សដែលមានកម្លាំងកាយ ប្រាជ្ញា ស្មារតីគ្រប់គ្រាន់សម្រាប់ធ្វើសកម្មភាពដោយសេរីតាមគោលបំណង និងចំណង់ចំណូលចិត្តរបស់ខ្លួនដោយស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ ដើម្បីចូលរួមការពារអភិវឌ្ឍសង្គម។

គ្រូ: ល្អណាស់ប្អូនៗ។ ឥឡូវយើងពិនិត្យមើលថា តើមនុស្សមានសិទ្ធិអ្វីខ្លះ។ នៅលើក្តារខៀន គ្រូមានរូបមនុស្សម្នាក់ គ្រូចង់ឱ្យប្អូនៗទាំងអស់គ្នាជួយសរសេរនៅជុំវិញរូបនោះពីសិទ្ធិពលរដ្ឋទាំងអស់។




បន្ទាប់ពីសិស្សបានបំពេញនៅលើរូបមនុស្សរួចហើយ គ្រូពន្យល់អំពីសិទ្ធិពលរដ្ឋនីមួយៗ។

បន្ទាប់ពីពន្យល់ចប់ហើយ គ្រូសួរសិស្សថាតើប្អូនៗមិនយល់ត្រង់កន្លែងណាខ្លះ?

បន្ទាប់មកទៀតដើម្បីឱ្យសិស្សកាន់តែយល់ស៊ីជម្រៅ គ្រូបែងចែកសិស្សជាបួនក្រុម ទៅតាមសិទ្ធិនីមួយៗ គឺសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច សិទ្ធិវប្បធម៌។ ក្រុមនីមួយៗទទួលខុសត្រូវ រកមើលថាតើសិទ្ធិដែលក្រុមខ្លួនទទួលខុសត្រូវនោះសំដៅលើអ្វី ឬមានចំណុចសំខាន់អ្វីខ្លះ រួចហើយពន្យល់ដល់មិត្តរួមថ្នាក់។ គ្រូបិទក្រដាសធំបួនផ្ទាំងនៅតាមជញ្ជាំងនីមួយៗនៅក្នុងបន្ទប់រៀន និងឱ្យសិស្សគូសជារូបប្រអប់ចតុកោណកែងហើយសរសេរសិទ្ធិដែលក្រុមខ្លួនទទួលខុសត្រូវ រួចគូសខ្សែងភ្ជាប់ទៅនឹងរង្វង់ និងសរសេរចំណុចសំខាន់ ឬនិយមន័យយ៉ាងសង្ខេបនៅក្នុងនោះ។




**កំណត់សម្គាល់**

សិស្សក្រុមទី១ គឺរៀបរាប់សិទ្ធិនយោបាយ

សិស្សក្រុមទី២ គឺរៀបរាប់សិទ្ធិសេដ្ឋកិច្ច

សិស្សក្រុមទី៣ គឺរៀបរាប់សិទ្ធិសង្គមកិច្ច

សិស្សក្រុមទី៤ គឺរៀបរាប់សិទ្ធិវប្បធម៌។

**ចម្លើយរំពឹងទុក**

| សិទ្ធិនយោបាយ | សិទ្ធិសេដ្ឋកិច្ច | សិទ្ធិសង្គមកិច្ច | សិទ្ធិវប្បធម៌ |
|---|---|---|---|
| - សិទ្ធិចូលរួមបោះឆ្នោត<br>- សិទ្ធិក្នុងការបញ្ចេញមតិ<br>- សិទ្ធិបង្កើតគណបក្សនយោបាយ<br>- សិទ្ធិក្នុងការបង្កើតសមាគម សហជីព | - សិទ្ធិទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ<br>- សិទ្ធិក្នុងការជ្រើសរើសមុខរបរ<br>- សិទ្ធិមានទ្រព្យសម្បត្តិកម្មសិទ្ធិ<br>- សិទ្ធិប្តឹងតវ៉ាទាមទារសងថ្លៃ | - សិទ្ធិមានសន្តិសុខសង្គម<br>- សិទ្ធិសម្រាកកំសាន្ត<br>- សិទ្ធិស្មើគ្នាក្នុងការរៀបចំអាពាហ៍ពិពាហ៍<br>- សិទ្ធិទទួលការការពារសុខភាព | - សិទ្ធិទទួលការអប់រំ<br>- សិទ្ធិប្រកាន់ទំនៀមទម្លាប់<br>- សិទ្ធិប្រកាន់ជំនឿសាសនា<br>- សិទ្ធិមានជំនឿដោយ |

| | | | |
|---|---|---|---|
| - សិទ្ធិចូលរួមប្រជុំដោយសេរី | ការខូចខាត<br>- សិទ្ធិមានអាហារគ្រប់គ្រាន់<br>- សិទ្ធិមានជីវភាពរស់នៅសមរម្យ | - សិទ្ធិសម្រាកលំហែនិងកំសាន្ត | សេរី |

**ការពង្រឹងពុទ្ធិ**

គ្រូ ៖ ដើម្បីត្រួតពិនិត្យក៏ដូចជាជួយប្អូនៗឱ្យចងចាំ គ្រូឱ្យប្អូនៗឆ្លើយសំណួរខាងក្រោម៖

១.ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ចំពោះចម្លើយណាដែលប្អូនយល់ថាត្រឹមត្រូវ។

ក.សិទ្ធិនយោបាយ

☐ ស្នាក់នៅក្រៅប្រទេស ☐ស្ម័គ្រចិត្តចូលបម្រើកងទ័ព ☐ ចូលជាសមាជិកសមាគម

ខ.សិទ្ធិសេដ្ឋកិច្ច

☐ ការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ចំពោះក្រុមហ៊ុនមួយដែលរំលោភយកដី

☐ ទិញសម្ភារៈ មករៀបចំពិធីបុណ្យចូលឆ្នាំខ្មែរ

☐ ចេញទៅកំសាន្តនៅឯបរទេស។

គ. សិទ្ធិវប្បធម៌

☐ ការសុំសំបុត្រកំណើត ☐ការសុំចូលបម្រើការងារ ☐ ការឆ្លាក់រូបបដិមា

ឃ.សិទ្ធិសង្គមកិច្ច

☐ ការសាងសង់សាលារៀន

☐ ម្តាយខ្ញុំចែកដីស្រែទៅឱ្យប្អូនខ្ញុំ

☐ ជនមិនទាន់គ្រប់អាយុមិនទាន់មានសិទ្ធិចូលរួមបោះឆ្នោតទេ?។

២. ដូចម្តេចហៅថាសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិវប្បធម៌?

៣. តើការធ្វើកូដកម្ម និងបាតុកម្មអហិង្សាជាសិទ្ធិអ្វី? ហេតុអ្វីចាំបាច់ត្រូវមានច្បាប់អនុញ្ញាតក្នុងការធ្វើបាតុកម្មអហិង្សា?

៤.តើប្រជាពលរដ្ឋម្នាក់ៗមានសិទ្ធិអ្វីខ្លះ?

៥.ចូររៀបរាប់សិទ្ធិពលរដ្ឋដែលកំពុងអនុវត្តសព្វថ្ងៃ។

៦.តើសិស្សមានសិទ្ធិដូចគ្នានឹងមនុស្សចាស់ដែរឬទេ?

**កិច្ចការផ្ទះ**

ចូរអានរឿងខាងក្រោម រួចរៀបរាប់សិទ្ធិដែលបងស្រីសុជាតាទទួលបាន និងត្រូវបានគេគោរព។

បងស្រីសុជាតា ត្រូវបានក្រុមហ៊ុនមួយអនុញ្ញាតឱ្យទៅធ្វើការនៅក្រៅប្រទេស។ នៅទីនោះគាត់មានការងារធ្វើ និងទទួលបានប្រាក់កម្រៃយ៉ាងសមរម្យ។ ពីរឆ្នាំក្រោយមក គាត់បានវិលត្រលប់មកស្រុកកំណើតវិញ ដោយសារមានបញ្ហានៅក្នុងគ្រួសារ ហើយបញ្ហានោះមិនអាចដោះស្រាយបានឡើយ ទីបំផុតគាត់និងប្តីរបស់គាត់ត្រូវបែកបាក់គ្នា។ គាត់រស់នៅក្នុងភាពជាស្ត្រីមេម៉ាយ ពេលនោះមានមនុស្សមួយចំនួនបានមាក់ងាយគាត់។ ថ្ងៃមួយបងស្រី សុជាតាបានស្ម័គ្រចិត្តចូលជាសមាជិកនៅក្នុងសហគមន៍។ បងស្រីយកចិត្តទុកដាក់ ខំព្យាយាមធ្វើការងារ មិនយូរប៉ុន្មានគាត់ក៏បានក្លាយជាអ្នកដឹកនាំម្នាក់នៅក្នុងសហគមន៍នោះ។

| | | |
|---|---|---|
| **ជំពូក៣** | **ការចូលរួមអភិវឌ្ឍសហគមន៍** | |
| **មេរៀនទី** | ៣ | |
| **ចំណងជើងមេរៀន** | **សិទ្ធិនិងការទទួលខុសត្រូវ** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | ព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស។មនុស្សម្នាក់ៗត្រូវតែយល់ដឹងអ្វីជាសិទ្ធិ អ្វីជាការទទួលខុសត្រូវដើម្បីចៀសវាងការរំលោភសិទ្ធិ និងធ្វើអ្វីៗដោយគ្មានការទទួលខុសត្រូវ។ សិទ្ធិគឺអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាច់សម្រាប់រស់នៅឱ្យបានសមរម្យនិងមានសេចក្តីថ្លៃថ្នូរជាមនុស្ស។ មនុស្សគ្រប់រូបត្រូវមានការទទួលខុសត្រូវលើខ្លួនឯង ការទទួលខុសត្រូវចំពោះសង្គម និងការប្រើសិទ្ធិសេរីភាពរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ។ | |
| **វត្ថុបំណង** | ១ | • កំណត់បាននិយមន័យសិទ្ធិ និងការទទួលខុសត្រូវ<br>• ពណ៌នាទំនាក់ទំនងរវាងសិទ្ធិ និងការទទួលខុសត្រូវ។ |
| | ២ | បង្ហាញការទទួលខុសត្រូវចំពោះខ្លួនឯង និងការទទួលខុសត្រូវចំពោះសង្គម។ |
| | ៣ | មានស្មារតីចេះទទួលខុសត្រូវចំពោះអំពើឬ សកម្មភាពដែលខ្លួនបានធ្វើ។ |
| **សម្ភារៈ** | សៀវភៅសិស្ស | |
| | រូបភាពក្នុងសៀវភៅសិស្ស | |
| | បញ្ជីគម្រោង | |
| **រយៈពេល** | ៣ម៉ោង | |

<table>
<tr><th>ដំណើរការបង្រៀន</th></tr>
<tr><td>ការចាប់ផ្ដើមមេរៀន<br>គ្រូ: សួស្ដីប្អូនៗ តើសុខសប្បាយទេថ្ងៃនេះ?<br>សិស្ស:ខ្ញុំសុខសប្បាយទេ លោក/អ្នកគ្រូ។</td></tr>
<tr><td>គ្រូ:ថ្ងៃនេះយើងរៀនមេរៀនថ្មី ស្ដីពីសិទ្ធិនិងការទទួលខុសត្រូវ។ យើងបានរៀនអំពីសិទ្ធិជាច្រើនលើកច្រើនសាមកហើយ តើប្អូនណានៅចាំថាសិទ្ធិមានន័យថាដូចម្ដេច? តើយើងមានសិទ្ធិតាំងពីពេលណាមក? តើយើងមានសិទ្ធិអ្វីខ្លះជាចម្បង?</td></tr>
<tr><td>ចម្លើយរំពឹងទុកៈ<br>សិទ្ធិ ជាអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាច់សម្រាប់រស់នៅឱ្យសមរម្យ និងមានសេចក្ដីថ្លៃថ្នូរជាមនុស្ស។ មនុស្សយើងម្នាក់ៗមានសិទ្ធិតាំងពីកំណើតសម្រាប់ការពារខ្លួនពីការរំលោភបំពានរបស់អ្នកដទៃ និងអាចធ្វើអ្វីៗបានក្នុងក្របខ័ណ្ឌច្បាប់។យើងមានសិទ្ធិចម្បងជាច្រើន ដូចជាសិទ្ធិបញ្ចេញមតិ សិទ្ធិមានទ្រព្យសម្បត្តិ កម្មសិទ្ធិ សិទ្ធិមានការងារធ្វើ សិទ្ធិមានជំនឿសាសនា សិទ្ធិទទួលបានការអប់រំ សិទ្ធិធ្វើដំណើរដោយសេរី សិទ្ធិទទួលព័ត៌មាន សិទ្ធិចូលរួមសមាគម សិទ្ធិចូលរួមសកម្មភាពនយោបាយជាដើម។</td></tr>
<tr><td>គ្រូ: ល្អណាស់ដែលប្អូនៗនៅចាំ។ គ្រូពិតជាសប្បាយចិត្តមែនថ្ងៃនេះ។</td></tr>
<tr><td>មេរៀនថ្មី<br>គ្រូ: យើងដឹងអំពីសិទ្ធិគ្រប់គ្នាហើយ ចុះតើអ្វីទៅជាការទទួលខុសត្រូវ? គ្រូគូសរង្វង់រួចសរសេរពាក្យការទទួលខុសត្រូវចូលក្នុងនោះរួចឱ្យសិស្សផ្ដល់ចម្លើយ។<br>ចម្លើយរំពឹងទុកៈ<br>
</td></tr>
</table>

គ្រូៈ អរគុណណាស់ប្អូនៗដែលបានជួយផ្តល់ចម្លើយដ៏ត្រឹមត្រូវ។ សរុបមក ការទទួលខុសត្រូវ គឺសំដៅលើកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ដែលត្រូវធានារ៉ាប់រងអំពើរបស់ខ្លួន ហ៊ានទទួលសារភាពថា ខ្លួនជាអ្នកប្រព្រឹត្តិ និងទទួលវិបាកនៃអំពើទាំងនោះ។ តើប្អូនៗណាខ្លះអាចផ្តល់ឧទាហរណ៍ទាក់ទងនឹងការទទួលខុសត្រូវបានដែរឬទេ?

**ចម្លើយរំពឹងទុកៈ**

ប្រសិនបើប្តីប្រើអំពើហិង្សាចំពោះប្រពន្ធ នោះបុរសជាប្តីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាពិសេសគឺការជាប់ពន្ធនាគារ។សិស្សត្រូវទទួលខុសត្រូវក្នុងការរៀនសូត្រ និងធ្វើលំហាត់ដែលគ្រូដាក់ឱ្យធ្វើ បើមិនដូច្នេះទេសិស្សនឹងទទួលបានលទ្ធផលការសិក្សាមិនល្អ។ រដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះសុខុមាលភាពរបស់ប្រជាជន។

គ្រូៈ អរគុណណាស់ដែលប្អូនៗជួយផ្តល់ឧទាហរណ៍។ ឥឡូវនេះយើងជួយគ្នារកមើលចម្លើយទាក់ទងនឹងការទទួលខុសត្រូវលើខ្លួនឯង និងការទទួលខុសត្រូវលើសង្គម។គ្រូបែងចែកប្អូនជាពីរក្រុម។ក្រុមទី១ទទួលខុសត្រូវរកចម្លើយចំពោះការទទួលខុសត្រូវលើខ្លួនឯង និងក្រុមទី២ទទួលខុសត្រូវរកចម្លើយ ចំពោះការទទួលខុសត្រូវលើសង្គម។ ពេលប្អូនៗរកចម្លើយបាន ប្អូនត្រូវសរសេរលើក្រដាសតូចៗ រួចយកទៅបិទនៅលើក្រដាសផ្ទាំងធំដែលគ្រូបិទជាប់លើជញ្ជាំងបន្ទប់ទាំងសងខាង។







**ចម្លើយរំពឹងទុក**

ការទទួលខុសត្រូវលើខ្លួនឯងៈ

- ការទទួលខុសត្រូវរបស់មាតាបិតាក្នុងការចិញ្ចឹមបីបាច់អប់រំកូនឱ្យក្លាយជាពលរដ្ឋល្អ
- ការទទួលខុសត្រូវក្នុងនាមជាស្វាមី ភរិយា កូន ឬបងប្អូន និងញាតិសន្តាន ពោលគឺស្គាល់ និងបំពេញតួនាទីរបស់ខ្លួនមិនឱ្យគ្រួសារ ជួបការលំបាកក្នុងការរស់នៅជាមួយគ្នា

- ការទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន ពោលគឺគោរពសីលធម៌រស់នៅជាពលរដ្ឋល្អ គោរពច្បាប់ គោរពសិទ្ធិនិងផលប្រយោជន៍អ្នកដទៃ
- ការហ៊ានទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តដោយចេតនាក្តីឬអចេតនាក្តី និងចេះកែប្រែខ្លួនឈប់ប្រព្រឹត្តកំហុសតទៅទៀត
- ការទទួលខុសត្រូវចំពោះការសិក្សា ឬការងាររបស់ខ្លួន
- ការគោរពពាក្យសម្តី និងកិច្ចសន្យាដែលខ្លួនបានធ្វើ
- ការប្រកាន់ខ្ជាប់នូវឯករាជភាព សមភាព តម្លាភាព សច្ចធម៌ និងយុត្តិធម៌។

ការទទួលខុសត្រូវលើសង្គម ៖

- ការគោរពនិងអនុវត្តតាមច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗទៀត
- ការចូលរួមថែរក្សា ការពារផលប្រយោជន៍សាធារណៈ
- ការចុះឈ្មោះបោះឆ្នោត ទៅបោះឆ្នោតជ្រើសរើសអ្នកដឹកនាំតាមឆន្ទៈរបស់ខ្លួន
- ការចូលរួមថែរក្សាទំនៀមទម្លាប់ប្រពៃណីនិងថែរក្សាការពារសម្បត្តិវប្បធម៌ជាតិ
- ការបង់ពន្ធដារសម្រាប់រួមចំណែកក្នុងដំណើរការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ
- ការប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យស្របទៅតាមសីលធម៌ ច្បាប់សង្គមដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃនិងត្រូវគោរពសិទ្ធិអ្នកដទៃ
- ការសម្អាតនិងថែរក្សាបរិស្ថានគ្រប់ទីកន្លែង
- ការគោរពសិទ្ធិដល់ការរស់នៅរបស់ជនជាតិផ្សេងៗដោយរួមមានជំនឿ ទំនៀមទម្លាប់ប្រពៃណី សាសនារបស់ជនជាតិនោះ។ល។

គ្រូៈ អរគុណដែលប្អូនៗបានបំពេញពាក្យលើក្រដាសផ្ទាំងធំទាំងពីរបានយ៉ាងល្អ និងត្រឹមត្រូវ។ យើងគួរបិទក្រដាសនេះនៅជញ្ជាំងខាងក្រោយ ដើម្បីឱ្យយើងចងចាំពីការទទួលខុសត្រូវលើខ្លួនឯងនិងសង្គម។ ឥឡូវយើងបន្តមេរៀនរបស់យើងតទៅទៀត។ យើងបានយល់ដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវហើយ ប៉ុន្តែយើងអាចឆ្ងល់ថាតើសិទ្ធិនិងការទទួលខុសត្រូវមានអ្វីជាប់ទាក់ទងគ្នាដែរឬទេ។ ចូរប្អូនសង្កេតមើលរូបភាពតុល្យភាពរវាងសិទ្ធិនិងការទទួលខុសត្រូវនេះ តើប្អូនយល់យ៉ាងណាដែរ?



តុល្យភាពសិទ្ធិនិងការទទួលខុសត្រូវ

**ចម្លើយរំពឹងទុកៈ**

រូបភាពនោះចង់ពន្យល់ថា បុគ្គលម្នាក់ៗមានសិទ្ធិអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនធ្វើអ្វីក៏បានប៉ុន្តែការប្រើប្រាស់សិទ្ធិនោះត្រូវទទួលខុសត្រូវចំពោះរឿងហេតុដែលកើតឡើងពីការប្រើប្រាស់សិទ្ធិផងដែរ។

គ្រូៈ អរគុណណាស់ប្អូនដែលបានជួយផ្តល់ចម្លើយ។ ប្អូនៗបានស្តាប់មិត្តរួមថ្នាក់របស់ប្អូនពន្យល់ហើយថា ទោះបីជាយើងមានសិទ្ធិសេរីភាពចង់ធ្វើអ្វីក៏បាន យើងត្រូវតែមានការទទួលខុសត្រូវដែរ ប្រសិនបើការប្រើប្រាស់សិទ្ធិនោះ ធ្វើឱ្យប៉ះពាល់ឬខូចខាតដល់បុគ្គល ឬទ្រព្យសម្បត្តិអ្នកដទៃ។ ឧទាហរណ៍ យើងមានសិទ្ធិនិយាយស្តីឬសម្តែងមតិ ប៉ុន្តែប្រសិនបើការនិយាយស្តីឬសម្តែងមតិនោះមិនពិត នាំឱ្យខូចខាតឬប៉ះពាល់ដល់កិត្តិយសអ្នកដទៃ នោះយើងត្រូវតែទទួលទោស។ យើងមានសិទ្ធិប្រកបរបរចិញ្ចឹមជិវិត ប៉ុន្តែប្រសិនបើផលិតផលឬទំនិញយើងលក់នោះពុំមានគុណភាព ឬប៉ះពាល់ដល់សុខភាពនិងអាយុជីវិតរបស់អ្នកប្រើប្រាស់ នោះយើងក៏ត្រូវមានទោសដែរ។ ដូច្នេះ ហើយរាល់ពេលដែលយើងម្នាក់ៗប្រើប្រាស់សិទ្ធិរបស់យើង យើងក៏ត្រូវតែមានការទទួលខុសត្រូវចំពោះវិបាកដែលកើតចេញពីការប្រើប្រាស់សិទ្ធិនោះគ្រប់ពេលដែរ។

**ការពង្រឹងពុទ្ធិ**

គ្រូៈ ឥឡូវយើងជិតបញ្ចប់មេរៀនរបស់យើងហើយ។ ដើម្បីដឹងច្បាស់ថា ប្អូនៗយល់អំពីសិទ្ធិនិងការទទួលខុសត្រូវនេះ គ្រូបែងចែកប្អូនៗជាប្រាំក្រុម ដើម្បីពិភាក្សាគ្នាថា តើក្នុងនាមជាសិស្ស តើប្អូនគិតថាប្អូនគួរមានការទទួលខុសត្រូវអ្វីចំពោះសាលារៀនរបស់ប្អូន?

**ចម្លើយរំពឹងទុកៈ**

- ថែរក្សាបរិស្ថានសាលារៀនតាមរយៈការបង្កើតសួនច្បារនិងដាំដើមឈើ
- ថែរក្សាសម្ភារឧបទេសនិងបរិក្ខារ
- សម្អាតអនាម័យ
- ខំប្រឹងប្រែងរៀនសូត្រដើម្បីឱ្យគេដឹងថាសាលារៀននេះជាថ្នាលបណ្តុះបណ្តាលសិស្សពូកែៗ
- ជួយផ្សព្វផ្សាយកិត្តិនាមសាលារៀនតាមរយៈការធ្វើគម្រោងចុះជួយសហគមន៍ អ្នកទុរគត ជនពិការ កុមារកំព្រាជាដើម
- ធ្វើជាសិស្សល្អ មិត្តល្អ កូនល្អ ប្រជាពលរដ្ឋល្អតាមរយៈការរស់នៅប្រកបដោយសីលធម៌ សុជីវធម៌ គោរពច្បាប់ គោរពសិទ្ធិនិងប្រយោជន៍អ្នក

ដទៃ គោរពដឹងគុណដល់ឪពុកម្ដាយ និងលោកគ្រូ អ្នកគ្រូ

- ជួយបង្ហាត់បង្រៀនមិត្តភក្តិ។

**កិច្ចការផ្ទះ**

គ្រូៈ ឥឡូវនេះប្អូនៗនៅក្នុងក្រុមនីមួយៗបានដឹងអំពីការទទួលខុសត្រូវរបស់ខ្លួនហើយ។ មុននឹងបញ្ចប់មេរៀននេះ គ្រូចង់ដាក់ការងារឱ្យប្អូនៗធ្វើនៅផ្ទះ។ ប្អូនៗត្រូវសរសេរគម្រោងទាក់ទងការទទួលខុសត្រូវរបស់ប្អូនចំពោះសាលារៀន។ នៅប្រទេសមួយចំនួន ប្អូនៗជាសិស្សសាលារៀនរៀបចំគម្រោងសម្អាតបន្ទប់ទឹកនិងបន្ទប់រៀនទាំងអស់របស់ពួកគេ។ ចំណែកប្អូនខ្លះទៀត រៀបគម្រោងដាំដើមឈើឬដើមផ្កា រៀបចំពាក្យស្លោក ឬក៏រើសសំរាមនៅទីសាធារណៈជាដើម។ប្អូនអាចជ្រើសរើសគម្រោងអ្វីក៏បានតាមដែលប្អូនៗចង់បាន។ គម្រោងរបស់ក្រុមណាល្អជាងគេ យើងនឹងសម្រេចជ្រើសរើសគម្រោងនោះយកមកអនុវត្ត។ (គ្រូចែកក្រដាសបញ្ជីសមាសភាគសំខាន់ៗនៅក្នុងគម្រោងឱ្យក្រុមនីមួយៗយកទៅបំពេញនៅផ្ទះ)។

| ល.រ | **បញ្ជីសមាសភាគសំខាន់ៗនៅក្នុងគម្រោង** | **ព័ត៌មានលម្អិត** |
|---|---|---|
| ១ | ឈ្មោះគម្រោងៈ | ........................................................................ |
| ២ | គោលបំណងៈ | ........................................................................ |
| ៣ | ទីកន្លែងអនុវត្តគម្រោងៈ | ........................................................................ |
| ៤ | កាលបរិច្ឆេទៈ | ........................................................................ |
| ៥ | មធ្យោបាយដឹកជញ្ជូនៈ | ........................................................................ |
| ៦ | ធនធានត្រូវការជាសម្ភារៈ | ........................................................................ |
| ៧ | ធនធានត្រូវការជាមនុស្សៈ | ........................................................................ |
| ៨ | ប្រភពធនធានៈ | ........................................................................ |
| ៩ | សកម្មភាពៈ | ........................................................................ |
| ១០ | អ្នកទទួលខុសត្រូវសំខាន់ៗ | ឈ្មោះ..............................តួនាទី.........................<br>ទូរស័ព្ទៈ |
| | | ឈ្មោះ..............................តួនាទី.........................<br>ទូរស័ព្ទៈ |
| | | ឈ្មោះ..............................តួនាទី.........................<br>ទូរស័ព្ទៈ |

| ជំពូក៣ | ការចូលរួមអភិវឌ្ឍសហគមន៍ | |
|---|---|---|
| មេរៀនទី | ៥ | |
| ចំណងជើងមេរៀន | ច្បាប់ការងារ | |
| ពណ៌នាអំពីមេរៀនដោយសង្ខេប | ច្បាប់ការងារ ជាច្បាប់សម្រាប់គ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងនិយោជិត។ ច្បាប់នេះអនុវត្តទៅលើបុគ្គលិកទាំងអស់ លើកលែងតែបុគ្គលិកដែលគ្រប់គ្រងដោយសហលក្ខន្តិកៈអ្នករាជការ ឬលក្ខន្តិកៈទូត ចៅក្រម នគរបាល កងទ័ព កងតម្រួត បុគ្គលិកធ្វើការតាមផ្លូវអាកាស នាវាសមុទ្រ ព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈ។ ច្បាប់ការងារត្រូវបានអនុវត្តចំពោះសហគ្រាសឬគ្រឹះស្ថានឧស្សាហកម្មរ៉ែ ពាណិជ្ជកម្ម សេវាកម្ម កសិកម្ម ដឹកជញ្ជូន។និយោជិតចាំបាច់ស្វែងយល់អំពីចំណេះដឹងច្បាប់ការងារទាក់ទងនឹងការហ្វឹកហ្វឺនកូនជាង កិច្ចសន្យាការងារ លក្ខខណ្ឌនៃការចូលបម្រើការងារ និងគ្រោះថ្នាក់ការងារ។ | |
| វត្ថុបំណង | ១ | ឱ្យនិយមន័យ និងពណ៌នាលក្ខខណ្ឌទូទៅនៃច្បាប់ការងារ ព្រមទាំងរៀបរាប់របៀបហ្វឹកហ្វឺនការងារដល់កូនជាង និងការធ្វើកិច្ចសន្យាការងារ។ |
| | ២ | បង្ហាញលក្ខខណ្ឌការងារសម្រាប់កុមារ និងការងារសម្រាប់ស្ត្រី។ |
| | ៣ | មានស្មារតីប្រុងប្រយ័ត្ននៅពេលធ្វើការងារដើម្បីចៀសផុតពីគ្រោះថ្នាក់ផ្សេងៗ។ |
| សម្ភារៈ | សៀវភៅសិស្ស | |
| | ករណីសិក្សា" បងស្រីចន្ទី " | |
| | តារាងអត្ថបទខ្លីៗ | |
| | ច្បាប់ការងារ | |
| រយៈពេល | ៣ម៉ោង | |

| ដំណើរការបង្រៀន |
| --- |
| **ការចាប់ផ្ដើមមេរៀន**<br>គ្រូ: មនុស្សយើងម្នាក់ៗអាចមានតម្លៃ និងដំណើរជីវិតទៅបានដោយសារការមានការងារចិញ្ចឹមជីវិតរបស់ខ្លួន។ ការងារទាំងអស់ដែលស្របច្បាប់សុទ្ធតែជាការងារដែលមានតម្លៃ មិនថាជាគ្រូបង្រៀន ជាកសិករ ជាកម្មករ ជាមន្ត្រីរាជការ ជាបុគ្គលិកក្រុមហ៊ុន ជាមេដឹកនាំរដ្ឋាភិបាលឬជាអ្នកប្រមូលសំរាម មនុស្សម្នាក់ៗសុទ្ធតែបានបំពេញកាតព្វកិច្ចចិញ្ចឹមជីវិតខ្លួន ក្រុមគ្រួសារ ក៏ដូចជាការចូលរួមអភិវឌ្ឍជាតិផងដែរ។ ដោយសារតម្លៃនិងសេចក្ដីថ្លៃថ្នូរនេះហើយ ទើបបានជាអ្នកធ្វើការងារទាំងអស់ត្រូវបានគោរព និងទទួលបានការការពារពីច្បាប់ដែលមានឈ្មោះថាច្បាប់ការងារ។ដើម្បីយល់ដឹងកាន់តែច្បាស់ថា តើច្បាប់ការងារមានន័យដូចម្ដេច បានជួយការពារយើងអ្វីខ្លះ នោះគ្រូមានករណីសិក្សាមួយឱ្យប្អូនៗអាន។ បន្ទាប់ពីអានហើយយើងចូលរួមគិតជាដៃគូ ពោលគឺប្អូនត្រូវគិតពិចារណាខ្លួនឯងសិនថាតើបងស្រីចន្ទីគាត់បានទទួលការរំលោភបំពានដោយរបៀបណា ហើយប្អូនគិតថា ប្រសិនបើមានច្បាប់ការងារ តើគាត់នឹងបានទទួលកិច្ចការពារអ្វីខ្លះ។ បន្ទាប់មកពិភាក្សាជាមួយមិត្តរួមថ្នាក់ដែលនៅជិតប្អូនអំពីគំនិតយល់ឃើញរបស់ប្អូន។ គ្រូនឹងហៅប្អូនឱ្យចែករំលែកចំណេះដឹងគ្នាទៅវិញទៅមកបន្ទាប់ពីពិភាក្សាគ្នាចប់។ |
| **ករណីសិក្សារបស់បងស្រីចន្ទី**<br>ប្អូនស្រីខ្ញុំ និងខ្ញុំបានមកធ្វើការនៅស្រុកថៃតាមមេខ្យល់។ មេខ្យល់បានប្រាប់ខ្ញុំថា មានគេរកអ្នកធ្វើការនៅហាងលក់បាយ។ គេឱ្យប្រាក់ខែ៤០០០បាតក្នុងមួយខែ (ប្រហែល១៣០ដុល្លា)ហើយមានកន្លែងស្នាក់នៅ។កាលនោះគេមិនបានប្រាប់ពីឈ្មោះឬទីកន្លែងហាងនោះនៅទីណាទេ។ យើងមានទូរស័ព្ទមួយគ្រឿងសម្រាប់ទាក់ទងជាមួយថៅកែដើម្បីឱ្យគាត់មកទទួលពួកខ្ញុំ។ ពួកខ្ញុំត្រូវបានថៅកែនាំទៅហាងលក់បាយរបស់គាត់ដើម្បីធ្វើការ។ ខ្ញុំទៅធ្វើការនៅក្នុងហាងនោះពីព្រលឹមដល់យប់។ នៅថ្ងៃឈប់សម្រាក ខ្ញុំត្រូវធ្វើការងាផ្ទះរបស់ខ្ញុំ និងមិនដែលចេញពីផ្ទះថៅកែនិងហាងទេ ដោយសារខ្ញុំមិនសូវស្គាល់និងមិនចេះនិយាយភាសាថៃ។<br>ថៅកែខ្ញុំក៏មិនចង់ឱ្យខ្ញុំចេញទៅណាដែរ។បន្ទាប់ពីធ្វើការបានរយៈពេល២ខែមកខ្ញុំបានសុំបើកប្រាក់ខែ ប៉ុន្តែថៅកែរបស់ខ្ញុំបានប្រាប់ថា ខ្ញុំនៅជាប់បំណុលគាត់។ គាត់បានបង្ហាញពីការចំណាយថ្លៃធ្វើដំណើរ អាហារ បន្ទប់ សម្លៀកបំពាក់ និងការចំណាយលើរឿងផ្សេងៗទៀត។ ថៅកែបានបង្ហាញបញ្ជីចំណាយដែលគាត់បានកត់ |

| |
|---|
| ត្រារាល់ថ្ងៃ ហើយប្រាប់ពួកខ្ញុំថាពួកខ្ញុំបានជំពាក់គាត់៦០០០០បាត (១៨០០ដុល្លា)។ គាត់ប្រាប់ពួកខ្ញុំថា ខ្ញុំត្រូវធ្វើការកាត់លុយបំណុលនោះសិនទើបពួកខ្ញុំអាចទទួលបានប្រាក់ខែ។ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបំណុលដ៏សន្ធឹកសន្ធាប់នេះ។ ខ្ញុំភ័យខ្លាចថា ខ្ញុំត្រូវធ្វើការឱ្យថៅកែនេះរហូតដល់មិនអាចត្រលប់ទៅផ្ទះបាន។ ដូច្នេះខ្ញុំសម្រេចចិត្តទូរស័ព្ទមកម្ដាយខ្ញុំនៅស្រុកខ្មែរ និងរៀបរាប់ប្រាប់គាត់ពីអ្វីដែលកើតមានចំពោះពួកខ្ញុំ។ ម្ដាយខ្ញុំបាននិយាយថា គាត់នឹងរកគេឱ្យជួយខ្ញុំ។ពីរថ្ងៃក្រោយមកនគរបាលជាតិថៃម្នាក់បានទូរស័ព្ទមករកពួកខ្ញុំសួរនាំកន្លែងដែលពួកខ្ញុំស្នាក់នៅ។ គាត់បានយកពួកខ្ញុំចេញពីហាងលក់បាយនោះទើបខ្ញុំនិងប្អូនខ្ញុំអាចត្រលប់មកផ្ទះវិញបាន។ |
| **ចម្លើយរំពឹងទុក** : បងស្រីចន្ទីត្រូវបានគេបោកប្រាស់ដោយសារតែដំបូងឡើយគេបានប្រាប់គាត់ថា គាត់មិនបាច់ចំណាយលើអ្វីទេ គាត់អាចទៅធ្វើការនៅស្រុកថៃបាន និងទទួលបានប្រាក់ខែ៤០០០បាតក្នុងមួយខែ។ ប៉ុន្តែរឿងនេះមិនពិតទេ។គាត់ក៏មិនបានអនុញ្ញាតឱ្យធ្វើដំណើរទៅណាមកណាដោយសេរីដែរ។ ជាគោលការណ៍ បុគ្គលម្នាក់ៗត្រូវធ្វើការយ៉ាងច្រើនណាស់៨ម៉ោងក្នុងមួយថ្ងៃ ប្រសិនបើថៅកែចង់ឱ្យគាត់ធ្វើការលើសម៉ោង ថៅកែនោះត្រូវទទួលបានការយល់ព្រមពីគាត់ជាមុនសិន និងត្រូវផ្ដល់កម្រៃបន្ថែមយ៉ាងសមរម្យដល់គាត់។<br>ប្រសិនបើមានច្បាប់ការងារ គាត់នឹងត្រូវផ្ដល់ប្រាក់ខែត្រឹមត្រូវតាមកិច្ចសន្យា គាត់ត្រូវធ្វើការទៅតាមចំនួនម៉ោងដែលច្បាប់បានកំណត់។ គាត់នឹងទទួលបានប្រាក់បន្ថែមម៉ោង ប្រសិនបើគាត់ធ្វើការលើសពី៨ម៉ោង គាត់នឹងត្រូវគេអនុញ្ញាតឱ្យធ្វើដំណើរដោយសេរី រួមទាំងឈប់ធ្វើការងារដែលគាត់មិនពេញចិត្តផងដែរ ដោយគ្រាន់តែជូនដំណឹងគេជាមុន។ប្រសិនបើគាត់មានគ្រោះថ្នាក់នៅពេលធ្វើការ គាត់ក៏ទទួលបានការព្យាបាល ឬប្រាក់សំណងផងដែរ។ |
| **មេរៀនថ្មី**<br>បន្ទាប់ពីចែករំលែកការយល់ឃើញរបស់សិស្សរួចហើយ គ្រូសួរទៅសិស្សថាតើពួកគេធ្លាប់ឮរឿងស្រដៀងគ្នានេះដែរឬទេ រួចឱ្យគេជួយនិទានប្រាប់។ បន្ទាប់ពីសិស្សនិទានប្រាប់ហើយ គ្រូចាប់ផ្ដើមមេរៀនថ្មី។<br>គ្រូ: ដូចប្អូនៗយល់បានខ្លះៗមកហើយ ច្បាប់ការងារជាច្បាប់សម្រាប់គ្រប់គ្រងរាល់ទំនាក់ទំនង ដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក(ថៅកែ) និងកម្មករនិយោជិត(អ្នកធ្វើការ) ដើម្បីយកមកអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទោះបីជាកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ភាគីទាំងសងខាងមានសញ្ជាតិអ្វី |

| |
|---|
| ហើយទោះបីជាស្នាក់នៅទីណាក៏ដោយ។ ច្បាប់ការងារត្រូវអនុវត្តចំពោះបុគ្គលិកទាំងអស់ លើកលែងតែបុគ្គលិកដែលគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការ ឬលក្ខន្តិកៈទូត ព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈដែលតែងតាំងបណ្តោះអាសន្ន។ ច្បាប់នេះក៏មិនអនុវត្តទៅលើ៖<br>• ចៅក្រមខាងតុលាការ<br>• ជនដែលតែងតាំងឱ្យធ្វើការជាអចិន្ត្រៃយ៍ក្នុងក្របខ័ណ្ឌរាជការសាធារណៈ<br>• បុគ្គលិកនគរបាល កងទ័ព និងកងតម្រួតដែលគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក<br>• បុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រដែលគ្រប់គ្រងដោយច្បាប់ពិសេសផ្សេងទៀត ប៉ុន្តែកម្មករ និយោជិតមានសិទ្ធិអនុវត្តបទប្បញ្ញត្តិស្តីពីសេរីភាពសហជីពនៃច្បាប់ការងារ<br>• អ្នកបម្រើក្នុងផ្ទះលើកលែងតែច្បាប់នេះបានចែងច្បាស់លាស់។ អ្នកបម្រើទាំងនេះមានសិទ្ធិអនុវត្តបទប្បញ្ញត្តិស្តីពីសេរីភាពសហជីពនៃច្បាប់ការងារ។ |
| គ្រូ: យើងដឹងថាប្រភេទការងាររបស់កម្មករនិយោជិតមានពីរ តើប្អូនណាខ្លះបានអានមេរៀន ហើយដឹងអំពីប្រភេទការងាររបស់កម្មករនិយោជិតទាំងពីរនេះដែរឬទេ? |
| **ចម្លើយរំពឹងទុក:**<br>បាទ/ចាស លោក/អ្នកគ្រូ គឺកម្មករនិយោជិតជាប់លាប់ និងកម្មករនិយោជិតម្តងម្កាល។ កម្មករនិយោជិតជាប់លាប់ សំដៅដល់ជនដែលធ្វើការទៀងទាត់ក្នុងមុខការអ្វីមួយដែលមានលក្ខណៈជាអចិន្ត្រៃយ៍។ ចំណែកឯកម្មករនិយោជិតម្តងម្កាលសំដៅលើជនដែលចុះកិច្ចសន្យា ធ្វើការអ្វីមួយជាប្រាកដ តាមធម្មតាត្រូវតែឱ្យហើយក្នុងរយៈពេលយ៉ាងខ្លី និងជនដែលធ្វើការមួយពេលៗ ធ្វើឈប់ៗ និងធ្វើការមួយរដូវ។ |
| គ្រូ : ល្អណាស់ប្អូន។ ចុះតើប្អូនណាដឹងថាការបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតត្រូវបានបែងចែកយ៉ាងដូចម្តេច? |
| **ចម្លើយរំពឹងទុក:**<br>បាទលោក/អ្នកគ្រូ ការបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតត្រូវបានបែងចែកជា៖<br>១) កម្មករនិយោជិត ធ្វើការយកប្រាក់ឈ្នួល តាមពេលដូចជាប្រចាំខែ ប្រចាំថ្ងៃ ប្រចាំម៉ោង គេត្រូវបើកប្រាក់ឈ្នួលឱ្យរាល់ថ្ងៃ ឬរាល់រយៈពេលមិនហួសពី១៥ថ្ងៃ ឬមួយខែ<br>២)កម្មករនិយោជិតធ្វើការយកប្រាក់ឈ្នួលតាមបរិមាណផលិតផល ឬតាមរបៀបម៉ៅការ<br>៣) កម្មករនិយោជិតធ្វើការយកកម្រៃជើងសា។ |

| |
|---|
| គ្រូ: ឥឡូវយើងនឹងផ្លាស់ប្តូរបរិយាកាសដោយការលេងល្បែងសិក្សាមួយ។ យើងនឹងបែងចែកគ្នាជា៤ក្រុម។ ល្បែងសិក្សានេះ ជាល្បែងដែលក្រុមនីមួយៗត្រូវប្រកួតគ្នាបង្កើតសំណួរបន្ទាប់ពីលោក/អ្នកគ្រូអានចម្លើយឱ្យហើយ។ក្រុមណាបង្កើតសំណួរត្រូវនឹងទទួលបានពិន្ទុ។ប្រសិនបើបង្កើតមិនត្រូវនឹងកាត់ពិន្ទុ ហើយក្រុមបន្ទាប់ជាអ្នកឆ្លើយបន្តរហូតដល់ទទួលបានចម្លើយសមស្រប។ប៉ុន្តែបើក្រុមទាំងអស់ឆ្លើយមិនត្រូវទេ យើងនឹងរំលងទៅវគ្គមួយទៀត។សំណួររបស់យើងមានបួនប្រភេទ គឺប្រភេទទី១ ការហ្វឹកហ្វឺនកូនជាង ប្រភេទទី២កិច្ចសន្យាការងារ ប្រភេទទី៣លក្ខខណ្ឌចូលបម្រើការងារ និងប្រភេទទី៤ គ្រោះថ្នាក់ការងារ។ក្នុងប្រភេទនីមួយៗមានអត្ថបទខ្លីៗចំនួន៥ ដែលក្រុមនីមួយៗអាចជ្រើសរើសតាមចិត្ត ពោលគឺអាចជ្រើសនៅក្នុងប្រភេទតែមួយក៏បាន ឬឆ្លងទៅប្រភេទផ្សេងក៏បាន។ ក្នុងអត្ថបទខ្លីទាំងនោះមានពិន្ទុ៥ ១០ ១៥ ២០ និង២៥។ ក្រុមណាជ្រើសរើស និងឆ្លើយត្រូវអត្ថបទដែលបានពិន្ទុ១០ នឹងបានទទួល១០ពិន្ទុ ប៉ុន្តែបើឆ្លើយខុសនឹងបាត់បង់១០ពិន្ទុវិញ។ |

តារាងពិន្ទុ

| ប្រភេទទី១<br>ការហ្វឹកហ្វឺនកូនជាង | ប្រភេទទី២<br>កិច្ចសន្យាការងារ | ប្រភេទទី៣<br>លក្ខខណ្ឌនៃការចូលបម្រើការងារ | ប្រភេទទី៤<br>គ្រោះថ្នាក់ការងារ |
|---|---|---|---|
| ៥ | ៥ | ៥ | ៥ |
| ១០ | ១០ | ១០ | ១០ |
| ១៥ | ១៥ | ១៥ | ១៥ |
| ២០ | ២០ | ២០ | ២០ |
| ២៥ | ២៥ | ២៥ | ២៥ |

តារាងកត់ត្រាពិន្ទុក្រុមនីមួយៗ

| ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ |
|---|---|---|---|
| | | | |
| | | | |

តារាងអត្ថបទខ្លីៗនិងចម្លើយរំពឹងទុកៈ

| **ប្រភេទទី១: ការហ្វឹកហ្វឺនកូនជាង** | |
|---|---|
| គ្រូអាន: ការអប់រំបណ្តុះបណ្តាល ដើម្បីឱ្យគេមានជំនាញដែលអាចយកទៅបំពេញការងារឬក៏ក្លាយ | **ចម្លើយរំពឹងទុក**: ហេតុអ្វីចាំបាច់ត្រូវមានការហ្វឹកហ្វឺនកូនជាង ? |

| | |
|---|---|
| ទៅជាមេជាងបន្ត។ | |
| គ្រូអាន: កិច្ចសន្យាត្រូវបញ្ជាក់៖<br>-ឈ្មោះ អាយុ វិជ្ជាជីវៈ ទីលំនៅរបស់គ្រូ និង ឈ្មោះទីលំនៅរបស់កូនជាង<br>-ឈ្មោះទីលំនៅរបស់មាតាបិតាឬអាណាព្យាបាល<br>-កាលបរិច្ឆេទនិងរយៈពេលកិច្ចសន្យាព្រមទាំងមុខរបរ<br>-លក្ខខណ្ឌនៃការផ្តល់កម្រៃ ភស្តុភារ អាហារ លំនៅ និងវត្ថុឯទៀតដែលមានការព្រមព្រៀងទាំងសងខាង<br>-មុខវិជ្ជាដែលនាយកសហគ្រាស បានចុះកិច្ចសន្យាបង្រៀន<br>-ប្រាក់បំណាច់ដែលត្រូវចេញឱ្យក្នុងករណីរំលាយកិច្ចសន្យា<br>-កាតព្វកិច្ចសំខាន់ៗរបស់គ្រូ និងកូនជាង។ | **ចម្លើយរំពឹងទុក**: តើកិច្ចសន្យាហ្វឹកហ្វឺនកូនជាងត្រូវបញ្ជាក់អ្វីខ្លះ? |
| គ្រូអានៈជនដែលបានចុះកិច្ចសន្យាសិក្សាវិជ្ជាជីវៈជាមួយនឹងនិយោជកឬសិប្បករណាម្នាក់ដោយសន្យាគ្នាថានិយោជកត្រូវបង្រៀនឬប្រើឱ្យគេបង្រៀនវិជ្ជាជីវៈដល់ខ្លួន ចំណែកឯខ្លួនក៏ត្រូវធ្វើការឱ្យនិយោជកតាមលក្ខខណ្ឌ និងក្នុងរយៈពេលនៃកិច្ចសន្យា។ | **ចម្លើយរំពឹងទុក**: តើកូនជាងសំដៅលើនរណា? |
| គ្រូអាន: ការធ្វើកិច្ចសន្យាកូនជាងមិនឱ្យលើសពី ២ឆ្នាំទេ។ | **ចម្លើយរំពឹងទុក**: តើថិរវេលានៃការហ្វឹកហ្វឺនកូនជាងមិនឱ្យលើសរយៈពេលប៉ុន្មាន? |
| គ្រូអាន: អ្នកបង្រៀនត្រូវមានអាយុលើសពី២១ ឆ្នាំ និងមានបទពិសោធន៍បង្ហាត់ចំនួន២ឆ្នាំ។ | **ចម្លើយរំពឹងទុក**: តើគ្រូដែលទទួលបន្ទុកហ្វឹកហាត់កូនជាងត្រូវមានអាយុនិងបទពិសោធន៍បង្ហាត់ប៉ុន្មានឆ្នាំ? |

| ប្រភេទទី២: កិច្ចសន្យាការងារ | |
|---|---|
| គ្រូអាន: កិច្ចសន្យាការងារមានការកំណត់ថិរវេលាពិតប្រាកដ តាំងពីពេលចាប់ផ្តើម និងបញ្ចប់កិច្ចសន្យា។វាអាចរំលាយមុនកាលកំណត់បានប្រសិនបើមានកិច្ចព្រមព្រៀងពីភាគីទាំងសងខាង ប៉ុន្តែក្នុងករណីមានកំហុសធ្ងន់ធ្ងរអាចរំលាយបានដោយពុំចាំបាច់មានការព្រមព្រៀងក៏បាន។ចំពោះកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ពុំកំណត់ថិរវេលាពិតប្រាកដទេ។ ប្រសិនបើមានហេតុផលសមរម្យ ភាគីខាងណាក៏អាចរំលាយកិច្ចសន្យានោះបានដែរ ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន។ | **ចម្លើយរំពឹងទុក**: តើកិច្ចសន្យាការងារដែលមានការកំណត់ថិរវេលា មានលក្ខណៈខុសគ្នាពីកិច្ចសន្យាការងារមិនមានការកំណត់ថិរវេលាដូចម្តេចខ្លះ? |
| គ្រូអាន: កម្មករ និយោជិត និងនិយោជកត្រូវចុះកិច្ចសន្យាមុននឹងធ្វើការអ្វីមួយ ដើម្បីឱ្យមានការទាក់ទងផ្នែកការងារទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា និងដើម្បីចៀសវាងមានការកែប្រែដោយឆន្ទៈឯកឯងរបស់ភាគីណាមួយដែលនាំឱ្យមានបញ្ហាទៅថ្ងៃក្រោយ។ ម្យ៉ាងទៀតកិច្ចសន្យានេះគឺជាភស្តុតាង និងជានិយាមសម្រាប់ឱ្យភាគីទាំងសងខាងអនុវត្តក្នុងទិសដៅស្របគ្នា។ | **ចម្លើយរំពឹងទុក**: ហេតុអ្វីបានជានិយោជិតនិងនិយោជកត្រូវចុះកិច្ចសន្យាមុននឹងធ្វើការងារអ្វីមួយ? |
| គ្រូអាន: កិច្ចសន្យាការងារដែលធ្វើឡើងរវាងកម្មករ និយោជិត និងនិយោជកមានបីករណី គឺកិច្ចសន្យាការងារមានកំណត់ថិរវេលា កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ និងកិច្ចសន្យាសាកល្បងការងារ។ | **ចម្លើយរំពឹងទុក**: តើកិច្ចសន្យាការងារដែលធ្វើឡើងរវាងកម្មករនិយោជិតនិងនិយោជកមានប៉ុន្មានករណី? គឺអ្វីខ្លះ? |
| គ្រូអាន: កិច្ចសន្យាសាកល្បងមានរយៈពេលមិនលើសពី៣ខែចំពោះនិយោជិត ២ខែចំពោះកម្មករឯកទេសនិង១ខែចំពោះកម្មករធម្មតា។ | **ចម្លើយរំពឹងទុក**: តើកិច្ចសន្យាសាកល្បងការងារមានរយៈពេលមិនលើសពីប៉ុន្មានខែសម្រាប់ |

| | |
|---|---|
| | និយោជិត?សម្រាប់កម្មករឯកទេស?និងសម្រាប់កម្មករធម្មតា? |
| គ្រូអាន: នៅក្នុងកិច្ចសន្យាការងារមានកំណត់ថិរវេលា ប្រសិនបើនិយោជករំលាយកិច្ចសន្យាមុនកាលកំណត់ និយោជកត្រូវសងជំងឺចិត្តទៅកម្មករ និយោជិត ប៉ុន្តែប្រសិនបើកម្មករនិយោជិតរំលាយកិច្ចសន្យាដោយឆន្ទៈតែឯកឯងនោះកម្មករ និយោជិតត្រូវសងជំងឺចិត្តទៅនិយោជកវិញដែរ។ | **ចម្លើយរំពឹងទុក**:នៅក្នុងកិច្ចសន្យាការងារមានកំណត់ថិរវេលា ប្រសិនបើភាគីខាងណាមួយចង់រំលាយកិច្ចសន្យាមុនកាលកំណត់ខុសពីមូលហេតុដើម តើភាគីនោះត្រូវមានទំនួលខុសត្រូវអ្វី? |
| **ប្រភេទទី៣: លក្ខខណ្ឌនៃការចូលបម្រើការងារ** | |
| គ្រូអាន: កុមារអាចធ្វើការងារក្នុងសិប្បកម្ម ឬរោងចក្ររបស់ខ្លួន ប៉ុន្តែសម្រាប់តែការងារស្រាលៗ មិនប៉ះពាល់ដល់សុខភាព និងមិនប៉ះពាល់ដល់ការសិក្សានិងការចូលរួមក្នុងកម្មវិធីតម្រង់ទិសនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ | **ចម្លើយរំពឹងទុក**:តើនិយោជកអាចឱ្យកុមារដែលមានអាយុ១៥ឆ្នាំធ្វើការងារអ្វីខ្លះនៅក្នុងសិប្បកម្មឬរោងចក្ររបស់ខ្លួន? |
| គ្រូអាន:ដើម្បីអាចចូលធ្វើការជាកម្មករ និយោជិតបាន ត្រូវមានអាយុ១៨ឆ្នាំ មានសុខភាពល្អ សន្តិសុខ និងសីលធម៌ល្អរបស់អ្នកទាំងនោះត្រូវបានធានាដោយពេញលេញ។ គេត្រូវទទួលបានការអប់រំពិសេស និងត្រឹមត្រូវឬការបណ្តុះបណ្តាលវិជ្ជាជីវៈពាក់ព័ន្ធនឹងការងារដែលខ្លួនចង់ធ្វើ។ | **ចម្លើយរំពឹងទុក**: ដើម្បីអាចធ្វើជាកម្មករនិយោជិតបាន តើគេត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ? |
| គ្រូអាន: ក្មេងមានអាយុតិចជាង១៨ឆ្នាំ ភេទណាក៏ដោយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយឬអាណាព្យាបាលមិនអាចចុះកិច្ចសន្យាការងារដោយគ្មានការយល់ព្រមពីជនដែលខ្លួននៅក្រោមការគ្រប់គ្រងឡើយ។ | **ចម្លើយរំពឹងទុក**: តើក្មេងអាយុតិចជាង១៨ឆ្នាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុក ម្តាយ ឬអាណាព្យាបាលអាចចុះកិច្ចសន្យាការងារដោយខ្លួនឯងបានដែរឬទេ? |
| គ្រូអាន: ស្ត្រីសម្រាលកូនមានសិទ្ធិឈប់សម្រាក ៩០ថ្ងៃ។ ក្រោយពីឈប់សម្រាករួចហើយ ក្នុង | **ចម្លើយរំពឹងទុក**:តើស្ត្រីដែលសម្រាលកូនបានទទួលសិទ្ធិអ្វីខ្លះ |

| | |
|---|---|
| អំឡុងពេលចូលធ្វើការរយៈពេល២ខែដំបូង និយោជកត្រូវឱ្យស្ត្រីនោះធ្វើការងារណាស្រាលៗ នៅក្នុងអំឡុងពេលឈប់សម្រាកនេះ ប្រសិនបើស្ត្រីនោះធ្វើការនៅក្នុងសហគ្រាសបានយ៉ាងតិចមួយឆ្នាំ គាត់នឹងទទួលបានប្រាក់ឈ្នួលពាក់កណ្តាលរួមទាំងប្រាក់បន្ទាប់បន្សំ។ | ពីកន្លែងធ្វើការងាររបស់ខ្លួន? |
| គ្រូអាន: និយោជកគ្រប់រូបមិនអាចយកបញ្ហាដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយ ជាតិកំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីធ្វើជាលេសបដិសេធការជួយ ការកំណត់ និងការបែងចែកការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដំឡើងថ្នាក់ ការដំឡើងឋានន្តរសក្តិ ការផ្តល់កម្រៃ ការផ្តល់អត្ថប្រយោជន៍សង្គម វិន័យ ឬការផ្តាច់កិច្ចសន្យាការងារបានឡើយ។ | **ចម្លើយរំពឹងទុក**: តើច្បាប់ការងារបានហាមឃាត់និយោជកមិនឱ្យរើសអើងអ្វីខ្លះដល់កម្មករនិយោជិត? |
| **ប្រភេទទី៤: គ្រោះថ្នាក់ការងារ** | |
| គ្រូអាន: កម្មករនិយោជិត ត្រូវមានកាតព្វកិច្ចជូនដំណឹងដល់និយោជក ឬអ្នកតំណាងពេញច្បាប់របស់និយោជក អំពីគ្រោះថ្នាក់ការងារដែលបានធ្លាក់មកលើខ្លួន ក្នុងរយៈពេលយ៉ាងយូរបំផុត ២៤ម៉ោងបន្ទាប់ពីឧប្បត្តិហេតុកើតឡើង។ | **ចម្លើយរំពឹងទុក**: តើនៅពេលមានគ្រោះថ្នាក់ការងារ កម្មករនិយោជិតត្រូវធ្វើដូចម្តេចខ្លះ? |
| គ្រូអាន: ក្រសួងទទួលបន្ទុកការងារត្រូវមានភារកិច្ចធ្វើទំនាក់ទំនងជាបន្ទាន់ទៅសហគ្រាសកើតហេតុ ដើម្បីឱ្យជួយរក្សាស្ថានភាពដើមនៃកន្លែងគ្រោះថ្នាក់ ជូនដំណឹងជាបន្ទាន់ទៅនាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានអធិការកិច្ចការងារ ដើម្បីសុំមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងការអង្កេតលើករណីគ្រោះថ្នាក់កើតឡើងពាក់ព័ន្ធ | **ចម្លើយរំពឹងទុក**: តើនៅពេលមានគ្រោះថ្នាក់ការងារក្រសួងទទួលបន្ទុកការងារត្រូវធ្វើដូចម្តេចខ្លះ? |

| | |
|---|---|
| នឹងលក្ខខណ្ឌបច្ចេកទេសស្មុគស្មាញ។ រាល់ការចុះអង្កេតគ្រោះថ្នាក់ការងារ គេត្រូវធ្វើកំណត់ហេតុបញ្ជាក់ឱ្យបានច្បាស់លាស់ពីមូលហេតុនៃគ្រោះថ្នាក់ និងកំណត់វិធីសាស្ត្រសម្រាប់បង្ការគ្រោះថ្នាក់កុំឱ្យកើតមានជាថ្មីម្តងទៀត។ | |
| គ្រូអាន: គ្រោះថ្នាក់ដែលកើតឡើងចំពោះកម្មករ និយោជិត សិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី នៅពេលពួកគេបំពេញការងារ ទោះបីជាកើតឡើងដោយសារកំហុសរបស់កម្មករ និយោជិត ឬមិនមែនជាកំហុសរបស់ពួកគេក្តី។ គ្រោះថ្នាក់ដែលកើតឡើង នៅពេលដែលកម្មករនិយោជិតធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ឬដោយគ្មានវាងទៅកន្លែងផ្សេងទៀតជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។ | **ចម្លើយរំពឹងទុក**: តើអ្វីជាគ្រោះថ្នាក់ការងារ? |
| គ្រូអាន: អ្នករងគ្រោះថ្នាក់ការងារមានសិទ្ធិទទួលបានការពិនិត្យព្យាបាល ការវះកាត់និងការផ្តល់បន្ថែមនូវវត្ថុណាមួយដែលចាំបាច់។ ពួកគេក៏ទទួលបានប្រាក់បំណាច់ ប្រសិនបើមិនអាចធ្វើការងារបានរយៈពេល៤ថ្ងៃឡើង ប៉ុន្តែមិនទទួលបានប្រាក់បំណាច់ទេ ប្រសិនបើពួកគេមិនអាចធ្វើការបានតិចជាង៤ថ្ងៃ។ប្រសិនបើគ្រោះថ្នាក់រហូតដល់ស្លាប់ ឬគ្រោះថ្នាក់រហូតបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ និយោជកត្រូវបើកប្រាក់បំណាច់ឱ្យជនរងគ្រោះ។ | **ចម្លើយរំពឹងទុក**: តើអ្នករងគ្រោះថ្នាក់ការងារទទួលបានសិទ្ធិអ្វីខ្លះ? |
| គ្រូអាន: ក្នុងករណីដែលជនរងគ្រោះ ទទួលរងគ្រោះរហូតដល់ស្លាប់ ឬបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ដែលបង្កគ្រោះថ្នាក់ដោយ | **ចម្លើយរំពឹងទុក**: តើនៅក្នុងករណីណាដែលជនទទួលរងគ្រោះថ្នាក់រហូតដល់ស្លាប់ឬបាត់បង់ |

<table>
<tr><td>ចេតនាខ្លួនឯង ជនរងគ្រោះនោះមិនបានទទួលប្រាក់បំណាច់អ្វីទេ។</td><td>សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ មិនអាចទទួលបានប្រាក់បំណាច់?</td></tr>
<tr><td colspan="2">ការពង្រឹងពុទ្ធិ<br>បន្ទាប់ពីលេងល្បែងសិក្សាខាងលើហើយ គ្រូឱ្យសិស្សសរសេរតែងសេចក្តីទាក់ទងទៅនឹង«គុណប្រយោជន៍នៃច្បាប់ការងារចំពោះកម្មករ និយោជិត និងនិយោជក»។ សិស្សត្រូវពន្យល់ថា តើច្បាប់ការងារមានគុណប្រយោជន៍អ្វីខ្លះចំពោះកម្មករនិយោជិត និងនិយោជក ហើយប្រសិនបើពុំមានច្បាប់ការងារ តើកម្មករនិយោជិត និងនិយោជកមានបញ្ហាអ្វីខ្លះ?</td></tr>
<tr><td colspan="2">កិច្ចការផ្ទះ<br>ចូរជ្រើសរើសចម្លើយត្រឹមត្រូវនៃសំណួរខាងក្រោម ៖<br>១.គេចាំបាច់ហ្វឹកហាត់កូនជាងដើម្បីៈ<br>ក.ឱ្យក្លាយជាពលរដ្ឋល្អ<br>ខ.ឱ្យមានជំនាញដែលអាចយកទៅបំពេញការងារ<br>គ.យកទៅប្រកួតប្រជែងជាមួយកូនជាងនៅកន្លែងផ្សេងទៀត ។<br>២.នៅក្នុងកិច្ចសន្យាវិជ្ជាជីវៈ និយោជកសន្យាថា<br>ក.នឹងរកការងារឱ្យកូនជាងធ្វើបន្ទាប់ពីរៀនចប់<br>ខ.ត្រូវបង្រៀនឬប្រើឱ្យគេបង្រៀនវិជ្ជាជីវៈដល់កូនជាង<br>គ.ផ្តល់ប្រាក់ខែខ្ពស់ជាងកន្លែងផ្សេងៗទៀតពេលកូនជាងហ្វឹកហាត់ចប់ ។<br>៣.ថិរវេលានៃការហ្វឹកហ្វឺនកូនជាងមិនឱ្យលើសពី<br>ក.៤ឆ្នាំ<br>ខ.៣ឆ្នាំ<br>គ.២ឆ្នាំ<br>ឃ.១ឆ្នាំ ។<br>៤.គ្រូបង្វឹកត្រូវមាន<br>ក.អាយុលើសពី២០ឆ្នាំ និងមានបទពិសោធន៍១ឆ្នាំ<br>ខ.អាយុលើសពី២១ឆ្នាំ និងមានបទពិសោធន៍២ឆ្នាំ<br>គ.អាយុលើសពី១៩ឆ្នាំ និងមានបទពិសោធន៍៣ឆ្នាំ ។<br><br>៥.កិច្ចសន្យាការងារមានកំណត់ថិរវេលា សំដៅទៅលើកិច្ចសន្យាដែល</td></tr>
</table>

ក.កំណត់ម៉ោងចូលនិងចេញពីធ្វើការឱ្យបានត្រឹមត្រូវ
ខ.កំណត់ថិរវេលាពិតប្រាកដតាំងពីចាប់ផ្តើមនិងបញ្ចប់កិច្ចសន្យា
គ.កំណត់ពេលបើកប្រាក់ខែ ។

៦. កម្មករនិយោជិតនិងនិយោជកត្រូវចុះកិច្ចសន្យាជាមុន
ក.ដើម្បីចៀសវាងការកែប្រែដោយឆន្ទៈឯកឯងរបស់ភាគីណាមួយ
ខ.ដើម្បីចៀសវាងកុំឱ្យក្រសួងការងារប្តឹងនិងពិន័យ
គ.ដើម្បីចៀសវាងកម្មករធ្វើបាតុកម្ម ។

៧.កិច្ចសន្យាការងារមាន៣ប្រភេទគឺ
ក.កិច្ចសន្យាការងារមានកំណត់ម៉ោងធ្វើការ កិច្ចសន្យាមិនមានកំណត់ម៉ោងធ្វើការ និងកិច្ចសន្យាស្ម័គ្រចិត្តធ្វើការមិនយកប្រាក់
ខ.កិច្ចសន្យាមានកំណត់ប្រាក់ខែគោល កិច្ចសន្យាមិនមានកំណត់ប្រាក់ខែគោល និងកិច្ចសន្យាដំឡើងប្រាក់ខែ
គ.កិច្ចសន្យាការងារមានកំណត់ថិរវេលា កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ និងកិច្ចសន្យាសាកល្បងការងារ ។

៨.កិច្ចសន្យាសាកល្បងការងារមានថិរវេលាមិនលើសពី
ក. ៣ខែចំពោះនិយោជិត ២ខែចំពោះកម្មករឯកទេស ១ខែចំពោះកម្មករធម្មតា
ខ. ១ខែចំពោះនិយោជិត ២ខែចំពោះកម្មករឯកទេស៣ខែចំពោះកម្មករធម្មតា
គ. ២ខែចំពោះនិយោជិត ៣ខែចំពោះកម្មករឯកទេស ១ខែចំពោះកម្មករធម្មតា ។

៩.កុមារអាយុ១៥ឆ្នាំអាច ៖
ក.ធ្វើការងារស្រាលៗមិនប៉ះពាល់ដល់សុខភាព ការសិក្សានិងការបណ្តុះបណ្តាលវិជ្ជាជីវៈ
ខ.ធ្វើការដូចមនុស្សធំបានប្រសិនបើមានកំពស់ខ្ពស់និងកម្លាំងដូចមនុស្សពេញវ័យ
គ.ធ្វើការ និងបានប្រាក់ខែស្មើគ្នានឹងមនុស្សធំពេញវ័យដែរ។

១០.កម្មករនិយោជិតត្រូវមាន ៖
ក.អាយុ២១ឆ្នាំ មានសុខភាព និងសីលធម៌របស់អ្នកទាំងនោះត្រូវបានធានាដោយពេញលេញនិងមានការអប់រំឬការបណ្តុះបណ្តាលពាក់ព័ន្ធការងារដែលខ្លួនចង់ធ្វើ
ខ.អាយុ១៨ឆ្នាំ មានសុខភាពល្អ អត្តចរិតល្អ មិនចេះសេពគ្រឿងស្រវឹង និងមានការអប់រំឬការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារដែលខ្លួនចង់ធ្វើ
គ.មានអាយុ១៩ឆ្នាំ មានសុខភាព និងសីលធម៌របស់អ្នកទាំងនោះត្រូវបានធានា

ដោយពេញលេញ និងមានការអប់រំ ឬការបណ្តុះបណ្តាលពាក់ព័ន្ធការងារដែលខ្លួនចង់ធ្វើ។

១១.មនុស្សអាយុតិចជាង១៨ឆ្នាំអាច ៖

ក.ចុះហត្ថលេខាលើកិច្ចសន្យាការងារ ប្រសិនបើមេឃុំឬចៅសង្កាត់ចេញលិខិតបញ្ជាក់ថាជាពលរដ្ឋល្អនៅក្នុងឃុំ/សង្កាត់

ខ.ចុះហត្ថលេខាលើកិច្ចសន្យាការងារបាន ប្រសិនបើអាណាព្យាបាលយល់ព្រម

គ.ចុះហត្ថលេខាលើកិច្ចសន្យាការងារបាន ប្រសិនបើជាការងារស្រាលៗ។

១២.ពេលសម្រាលកូន កម្មករនិយោជិតជាស្ត្រីមានសិទ្ធិឈប់សម្រាក៖

ក.៣០ថ្ងៃ

ខ.៥០ថ្ងៃ

គ.៦០ថ្ងៃ

ឃ.៩០ថ្ងៃ។

១៣.នៅពេលមានគ្រោះថ្នាក់ការងារ កម្មករនិយោជិតត្រូវជូនដំណឹងដល់កន្លែងធ្វើការមិនឱ្យលើសពី៖

ក.១២ម៉ោង

ខ.១៤ម៉ោង

គ.២៤ម៉ោង

ឃ.៣២ម៉ោង។

១៤.អ្នកមានគ្រោះថ្នាក់ការងារមានសិទ្ធិទទួល៖

ក.ការពិនិត្យព្យាបាលនិងប្រាក់កាសសម្រាប់ចំណាយនៅក្នុងគ្រួសារនិងការថែទាំកូនៗពីកន្លែងធ្វើការ

ខ.ការពិនិត្យព្យាបាល ការវះកាត់ និងការផ្តល់បន្ថែមវត្ថុណាមួយចំនួនដែលចាំបាច់

គ.ការពិនិត្យព្យាបាល ការវះកាត់ ការឈប់សម្រាក ការលើកទឹកចិត្តឱ្យទៅរៀនយកជំនាញនិងការតម្លើងតួនាទីបន្ទាប់ពីជាសះស្បើយ។

<table>
<tr><td>ជំពូក៣</td><td colspan="2">ការចូលរួមអភិវឌ្ឍសហគមន៍</td></tr>
<tr><td>មេរៀនទី</td><td colspan="2">៩</td></tr>
<tr><td>ចំណងជើងមេរៀន</td><td colspan="2">ច្បាប់ភូមិបាល</td></tr>
<tr><td>ពណ៌នាអំពីមេរៀនដោយសង្ខេប</td><td colspan="2">ច្បាប់ភូមិបាលមានគោលដៅកំណត់របបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅកម្ពុជាដើម្បីធានាការពារសិទ្ធិនៃកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ។ អចលនវត្ថុដែលបានកំណត់នៅក្នុងច្បាប់មានបីប្រភេទគឺអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់។ ច្បាប់បានកំណត់ពីសិទ្ធិកម្មសិទ្ធិរបស់បុគ្គល របស់សមូហភាពដើម្បីទទួលស្គាល់ឱ្យមានភាពស្របច្បាប់ដូចជា កម្មសិទ្ធិឯកជន កម្មសិទ្ធិសមូហភាព កម្មសិទ្ធិសាធារណៈ។ ការលក់ ការដូរ និងការជួលអចលនវត្ថុត្រូវធ្វើឡើងដោយអនុវត្តតាមច្បាប់។</td></tr>
<tr><td rowspan="3">វត្ថុបំណង</td><td>១</td><td>- ប្រាប់បានគោលបំណងនៃច្បាប់ភូមិបាល និងប្រភេទផ្សេងៗនៃអចលនវត្ថុ<br>- ពណ៌នាសិទ្ធិ និងលក្ខខណ្ឌដែលទាក់ទងនឹងការលក់ ការដូរ និងការជួលអចលនវត្ថុ។</td></tr>
<tr><td>២</td><td>- បង្ហាញភាពខុសគ្នារវាងកម្មសិទ្ធិឯកជន កម្មសិទ្ធិសមូហភាព និងកម្មសិទ្ធិសាធារណៈ<br>- បង្ហាញការផ្តន្ទាទោសចំពោះជនដែលបំពាន ឬរំលោភបំពានចំពោះកម្មសិទ្ធិឯកជននិងកម្មសិទ្ធិសាធារណៈ។</td></tr>
<tr><td>៣</td><td>ប្រកាន់ខ្ជាប់ការគោរពច្បាប់ មិនប៉ះពាល់កម្មសិទ្ធិនិងផលប្រយោជន៍អ្នកដទៃ។</td></tr>
<tr><td rowspan="2">សម្ភារៈ</td><td colspan="2">សៀវភៅសិស្ស</td></tr>
<tr><td colspan="2">សៀវភៅច្បាប់ភូមិបាល</td></tr>
<tr><td>រយៈពេល</td><td colspan="2">៣ម៉ោង</td></tr>
</table>

| ដំណើរការបង្រៀន |
|---|
| **ការចាប់ផ្តើមមេរៀន**<br>គ្រូ: ថ្ងៃនេះលោក/អ្នកគ្រូសង្ឃឹមថា ប្អូនៗមានសុខភាពធម្មតាទេ។ មែនដែរឬទេ?<br>សិស្ស: ចាស/បាទ លោក/អ្នកគ្រូ។ |
| គ្រូ: ល្អណាស់ប្អូនៗ។ ឥឡូវមុននឹងចាប់ផ្តើមមេរៀនថ្មី គ្រូសួរសំណួរខ្លះសិន។ នៅឃុំរបស់យើង យើងឃើញមានទីកន្លែងផ្សេងៗគ្នាជាច្រើនដូចជាផ្ទះសម្បែងដែលយើងស្នាក់នៅ វត្តអារាម សាលារៀន ផ្សារ កន្លែងធ្វើការរបស់អាជ្ញាធរជាដើម។ តើប្អូនណាដឹងទេថា តើទីកន្លែងទាំងនេះជាប្រភេទអចលនវត្ថុអ្វី? តើកន្លែងណាជាកម្មសិទ្ធិឯកជន កន្លែងណាជាកម្មសិទ្ធិសមូហភាព កន្លែងណាជាកម្មសិទ្ធិសាធារណៈ? តើកន្លែងណាដែលយើងអាចលក់ដូរឬជួលបាន ហើយកន្លែងណាដែលយើងមិនអាចលក់ ដូរ ឬជួលបាន? តើយើងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះទើបអាចលក់ ដូរ ឬជួលបាន? តើត្រូវមានទោសយ៉ាងណា ប្រសិនបើមានការរំលោភបំពាន? |
| **ចម្លើយរំពឹងទុក:**<br>ចាស/បាទ លោក/អ្នកគ្រូ ខ្ញុំដឹងតែថាផ្ទះសម្បែងដែលយើងរស់នៅ ជាកម្មសិទ្ធិឯកជនដែលយើងអាចលក់ដូរ ឬជួលបានតែខ្ញុំមិនដឹងថាកន្លែងផ្សេងទៀតជាកម្មសិទ្ធិអ្វីទេ ហើយក៏មិនដឹងថាត្រូវមានទោសយ៉ាងណា ប្រសិនបើមាននរណាម្នាក់រំលោភបំពានលើកម្មសិទ្ធិទាំងនោះ។ |
| គ្រូ: ល្អណាស់ប្អូនដែលបានជួយចែករំលែកអំពីចំណេះដឹងរបស់ប្អូន។ចុះប្រសិនបើយើងចង់ដឹងអំពីបញ្ហានេះ តើយើងអាចទៅសាកសួរនរណាបាន? |
| **ចម្លើយរំពឹងទុក:**<br>ចាស/បាទ លោក/ អ្នកគ្រូ ខ្ញុំគិតថាលោកមេឃុំ ជំទប់ឃុំ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងមន្ត្រីការិយាល័យនគរូបនីយកម្មនិងសំណង់អាចឆ្លើយនឹងសំណួរនេះបាន។ |
| គ្រូ: ពិតមែនហើយ យើងអាចទៅសួរព័ត៌មានពីពួកគាត់បាន។ ប៉ុន្តែដើម្បីឱ្យយើងទទួលព័ត៌មានដែលយើងចង់បានទាំងអស់នេះ យើងគួរនាំគ្នារៀបចំសំណួរទាក់ទងនឹងអ្វីដែលយើងចង់ដឹង។ ឥឡូវយើងនាំគ្នាគិតមើលសិនថា តើយើងចង់សួរទាក់ទងនឹងអ្វីខ្លះ រួចយើងរៀបចំសំណួរ។ |
| **ចម្លើយរំពឹងទុកៈ**<br>• ប្រភេទអចលនវត្ថុ កម្មសិទ្ធិឯកជន កម្មសិទ្ធិសមូហភាព កម្មសិទ្ធិសាធារណៈ<br>• លក្ខខណ្ឌនៃការលក់ ការដូរ ការជួល |

| |
|---|
| • ទោសនៃការរំលោភលើកម្មសិទ្ធិអ្នកដទៃ។ |
| គ្រូ: ឥឡូវយើងមើលប្រភេទអចលនវត្ថុសិន ប្រសិនបើយើងចង់ដឹងអំពីបញ្ហានេះ តើយើងត្រូវសួរយ៉ាងដូចម្តេច? |
| **ចម្លើយរំពឹងទុក:**<br>លោក/ អ្នកគ្រូ យើងអាចសួរថា តើអចលនវត្ថុសំដៅលើអ្វី? តើគេចែកអចលនវត្ថុជាប៉ុន្មានផ្នែក? មានអ្វីខ្លះ? |
| គ្រូ: ល្អណាស់ប្អូន។ ចុះទាក់ទងនឹងកម្មសិទ្ធិឯកជន កម្មសិទ្ធិសមូហភាព កម្មសិទ្ធិសាធារណៈ? |
| **ចម្លើយរំពឹងទុក:**<br>យើងអាចសួរថា តើកម្មសិទ្ធិឯកជនមានន័យយ៉ាងដូចម្តេច? តើមានច្បាប់មាត្រាអ្វីដែលនិយាយអំពីកម្មសិទ្ធិឯកជន? ដើម្បីចាត់ទុកជាកម្មសិទ្ធិពេញលេញនិងស្របច្បាប់ តើត្រូវមានលក្ខខណ្ឌអ្វីខ្លះ? តើម្ចាស់កម្មសិទ្ធិឯកជនឬកម្មសិទ្ធិករមានសិទ្ធិអ្វីខ្លះលើកម្មសិទ្ធិឯកជននោះ? តើកម្មសិទ្ធិឯកជនមានបែងចែកជាប្រភេទតូចៗផ្សេងទៀតដែរឬទេ? |
| **ចម្លើយរំពឹងទុកៈ**<br>• ចំពោះសំណួរទាក់ទងនឹងកម្មសិទ្ធិសមូហភាព យើងអាចសួរថា តើកម្មសិទ្ធិសមូហភាពសំដៅលើអ្វី?តើមានច្បាប់មាត្រាអ្វីបានកំណត់អំពីរឿងនេះដែរឬទេ?តើទីតាំងណាខ្លះដែលចាត់ទុកជាកម្មសិទ្ធិសមូហភាព? តើនរណាអាចគ្រប់គ្រងលើកម្មសិទ្ធិទាំងនេះបាន? តើកម្មសិទ្ធិសមូហភាពអាចលក់ ដូរ ឬជួលបានដែរឬទេ?ប្រសិនបើអាច តើផលដែលបានមក ត្រូវបានឬបម្រើឱ្យអ្នកណា?<br>• ចំណែកឯសំណួរទាក់ទងនឹងកម្មសិទ្ធិសាធារណៈ យើងអាចសួរថា តើកម្មសិទ្ធិសាធារណៈសំដៅលើអ្វី? តើអ្នកណាឬអង្គការចាត់តាំងណាជាអ្នកគ្រប់គ្រងឬចាត់ចែង? តើកម្មសិទ្ធិសាធារណៈបែងចែកជាប៉ុន្មានប្រភេទ?គឺអ្វីខ្លះ? តើកម្មសិទ្ធិសាធារណៈលក់ដូរ ឬជួលបានឬទេ ប្រសិនបើបាន តើត្រូវស្ថិតក្នុងលក្ខខណ្ឌអ្វីខ្លះ?<br>• ចំពោះការលក់ដូរឬជួល យើងអាចសួរថា ប្រសិនបើកម្មសិទ្ធិនោះអាចលក់ ដូរ ឬជួល តើកម្មសិទ្ធិករត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បីលក់? ដូរ?ជួល? ក្នុងករណីផ្ទេរកម្មសិទ្ធិ តើត្រូវផ្ទេរយ៉ាងដូចម្តេចទើបចាត់ទុកថាត្រឹមត្រូវតាមច្បាប់? តើការជួលអចលនវត្ថុមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?<br>• ចម្លើយរំពឹងទុកៈទាក់ទងទៅនឹងការរំលោភបំពានកម្មសិទ្ធិ យើងគួរតែសួរឱ្យដឹងជា |

មុនថា តើសកម្មភាពណាជាសកម្មភាពរំលោភបំពានលើកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសាធារណៈ? តើការរំលោភបំពានចាត់ទុកជាបទល្មើសអ្វី? តើត្រូវមានទោសអ្វីខ្លះ?

គ្រូៈ ល្អណាស់ប្អូនៗ។ យើងបានសំណួរដែលផ្តោតលើចំណុចទាំងអស់ដែលយើងចង់យកទៅសួរលោកមេឃុំ ជំទប់ឃុំ ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ/សង្កាត់។

**មេរៀនថ្មី**

គ្រូៈឥឡូវយើងរៀបចំសំណួររបស់យើងតាមលំដាប់លំដោយសិន។

| ល.រ | សំណួរ | ចម្លើយ |
|---|---|---|
| **ក. និយមន័យនិងប្រភេទអចលនវត្ថុ** | | |
| ១ | តើអចលនវត្ថុសំដៅលើអ្វី? | |
| ២ | តើគេចែកអចលនវត្ថុជាប៉ុន្មានផ្នែក?មានអ្វីខ្លះ? | |
| **ខ. កម្មសិទ្ធិឯកជន** | | |
| ៣ | តើកម្មសិទ្ធិឯកជនមានន័យយ៉ាងដូចម្តេច? | |
| ៤ | តើមានច្បាប់មាត្រាណាដែលនិយាយអំពីកម្មសិទ្ធិឯកជន? | |
| ៥ | ដើម្បីចាត់ទុកជាកម្មសិទ្ធិពេញលេញនិងស្របច្បាប់ តើត្រូវមានលក្ខខណ្ឌអ្វីខ្លះ? | |
| ៦ | តើម្ចាស់កម្មសិទ្ធិឯកជនឬកម្មសិទ្ធិករមានសិទ្ធិអ្វីខ្លះលើកម្មសិទ្ធិឯកជននោះ? | |
| ៧ | តើកម្មសិទ្ធិឯកជនមានបែងចែកជាប្រភេទតូចៗផ្សេងទៀតដែរឬទេ? | |
| **គ. កម្មសិទ្ធិសមូហភាព** | | |
| ៨ | យើងអាចសួរថា តើកម្មសិទ្ធិសមូហភាពសំដៅលើអ្វី? | |
| ៩ | តើមានច្បាប់មាត្រាអ្វីបានកំណត់អំពីរឿងនេះដែរឬទេ? | |
| ១០ | តើទីតាំងណាខ្លះដែលចាត់ទុកជាកម្មសិទ្ធិសមូហភាពបាន? | |
| ១១ | តើនរណាអាចគ្រប់គ្រងលើកម្មសិទ្ធិទាំង | |

| | | |
|---|---|---|
| | នេះបាន? | |
| ១២ | តើកម្មសិទ្ធិសមូហភាពអាចលក់ ដូរ ឬជួលបានឬទេ? | |
| ១៣ | ប្រសិនបើបាន តើផលដែលបានមកត្រូវបានឬបម្រើឱ្យនរណា? | |
| **ឃ. កម្មសិទ្ធិសាធារណៈ** | | |
| ១៤ | យើងអាចសួរថា តើកម្មសិទ្ធិសាធារណៈសំដៅលើអ្វី? | |
| ១៥ | តើនរណាឬអង្គការចាត់តាំងណាជាអ្នកគ្រប់គ្រងឬចាត់ចែង? | |
| ១៦ | តើកម្មសិទ្ធិសាធារណៈបែងចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ? | |
| ១៧ | តើកម្មសិទ្ធិសាធារណៈអាចលក់ ដូរ ឬជួលបានឬទេ? | |
| **ង. ការលក់ ការដូរ និងការជួលអចលនវត្ថុ** | | |
| ១៨ | ប្រសិនបើកម្មសិទ្ធិនោះអាចលក់ ដូរ ឬជួលបាន តើកម្មសិទ្ធិករត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បីលក់? ដើម្បីដូរ? ដើម្បីជួល? | |
| ១៩ | ក្នុងករណីផ្ទេរកម្មសិទ្ធិអចលនវត្ថុ តើត្រូវផ្ទេរយ៉ាងដូចម្តេចទើបចាត់ទុកត្រឹមត្រូវតាមច្បាប់? | |
| ២០ | តើការជួលអចលនវត្ថុមានប៉ុន្មានយ៉ាង?គឺអ្វីខ្លះ? | |
| **ច. សកម្មភាពនិងទោសនៃការរំលោភបំពានលើកម្មសិទ្ធឯកជននិងសាធារណៈ** | | |
| ២១ | តើសកម្មភាពណាជាសកម្មភាពរំលោភបំពានលើកម្មសិទ្ធិឯកជន? | |
| ២២ | តើសកម្មភាពណាដែលជាសកម្មភាពរំលោភបំពានលើកម្មសិទ្ធិសាធារណៈ? | |
| ២៣ | តើការរំលោភបំពាននោះត្រូវចាត់ទុកជាបទ | |

| | | |
|---|---|---|
| | ល្មើសអ្វី? | |
| ២៤ | តើការរំលោភបំពាននោះ ត្រូវមានទោសអ្វីខ្លះ? | |

គ្រូ: ឥឡូវយើងបានសំណួរដែលយើងចង់បានហើយ ដូច្នេះយើងនៅតែទាក់ទងទៅសាលាឃុំ/សង្កាត់ ដើម្បីស្នើសុំធ្វើបទសម្ភាសតែប៉ុណ្ណោះ។ ដើម្បីកុំឱ្យគ្រប់ៗគ្នាលំបាកសួរផង កត់ត្រាផង លោក/អ្នកគ្រូបែងចែកប្អូនៗជា៦ក្រុម។ ក្រុមទី១ទទួលបន្ទុកសម្ភាសនិងកត់ត្រាចម្លើយទាក់ទងនឹងនិយមន័យនិងប្រភេទអលចនវត្ថុ។ ក្រុមទី២ទទួលបន្ទុកសម្ភាស និងកត់ត្រាចម្លើយទាក់ទងនឹងកម្មសិទ្ធិឯកជន។ ក្រុមទី៣ទទួលបន្ទុកសម្ភាសនិងកត់ត្រាចម្លើយទាក់ទងនឹងកម្មសិទ្ធិសមូហភាព។ ក្រុមទី៤ទទួលបន្ទុកសម្ភាសនិងកត់ត្រាចម្លើយទាក់ទងនឹងកម្មសិទ្ធិសាធារណៈ។ ក្រុមទី៥ទទួលបន្ទុកសម្ភាសនិងកត់ត្រាចម្លើយទាក់ទងនឹងការលក់ ការដូរ និងការជួលអចលនវត្ថុ។ ក្រុមទី៦ទទួលបន្ទុកសម្ភាសនិងកត់ត្រាចម្លើយទាក់ទងនឹងសកម្មភាព និងទោសនៃការរំលោភបំពានលើកម្មសិទ្ធិឯកជន និងសាធារណៈ។ដូច្នេះក្រុមនីមួយៗត្រូវបែងចែកកិច្ចការគ្នាដោយមានអ្នកចាំកត់ត្រាចម្លើយផងនិងអ្នកសួរផង។ បន្ទាប់មកអ្នកកត់ត្រានៅក្នុងក្រុមក៏ដូចជាសមាជិកផ្សេងៗទៀត ត្រូវពិនិត្យមើល និងជួយថែមថយចម្លើយដែលបានកត់ត្រា ឬស្តាប់បានដើម្បីឱ្យចម្លើយនោះកាន់តែពេញលេញ។ ពេលបានចម្លើយពេញលេញហើយ ចូរប្អូននៅតាមក្រុមនីមួយៗ កត់ត្រាចម្លើយនេះដាក់លើក្រដាសថ្មីមួយទៀត ដោយមានដាក់ឈ្មោះសមាជិកក្រុមទាំងអស់ រួចរៀបចំចាត់ចែងឡើងរាយការណ៍នៅក្នុងថ្នាក់ក៏ដូចជាប្រគល់កិច្ចការនោះឱ្យគ្រូ ។

បន្ទាប់ពីសិស្សបានយល់ពីកិច្ចការដែលក្រុមខ្លួនត្រូវធ្វើហើយ គ្រូឱ្យសិស្សទៅរៀបចំកិច្ចការស្រាវជ្រាវរបស់ខ្លួនបាន។ ប៉ុន្តែគ្រូត្រូវកំណត់រយៈពេលឱ្យសិស្សធ្វើកិច្ចការនេះឱ្យចប់សព្វគ្រប់ក្នុងអំឡុងពេលណាមួយ រួចហើយយកមកធ្វើបទបង្ហាញ។

**ចម្លើយរំពឹងទុកៈ**

| ល.រ | សំណួរ | ចម្លើយ |
|---|---|---|
| ក. និយមន័យនិងប្រភេទអចលនវត្ថុ | | |
| ១ | តើអចលនវត្ថុសំដៅលើអ្វី? | អចលវត្ថុគឺជាដីធ្លី និងសំណង់អគារដែលតាំងភ្ជាប់នឹងដី។ |
| ២ | តើគេចែកអចលនវត្ថុជាប៉ុន្មានផ្នែក? មានអ្វីខ្លះ? | ១) អចលនវត្ថុពីកំណើតមានដីធម្មជាតិដូចជាព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិន |

| | | |
|---|---|---|
| | | អាចដាំដុះ ដីលិចទឹក និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែងកើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន។ |
| | | ២) អចលនវត្ថុពីភ័ព្វវាសនា មានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យមានការខូចខាត ឬមិនដូរសភាពដើមដូចជាដើមឈើ ឧបករណ៍តែងលម្អជាដើម។ |
| | | ៣) អចលនវត្ថុតាមការកំណត់របស់ច្បាប់មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលវត្ថុនិងចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់។ |
| ខ. កម្មសិទ្ធិឯកជន | | |
| ៣ | តើកម្មសិទ្ធិឯកជនមានន័យយ៉ាងដូចម្តេច? | កម្មសិទ្ធិឯកជនជាសិទ្ធិស្របច្បាប់ដែលមានលើអចលនវត្ថុ និងចលនវត្ថុក្នុងការចាត់ចែងការប្រើប្រាស់ និងការអាស្រ័យផល<br>ឧទាហរណ៍ លោកសុខមានផ្ទះផ្ទាល់ខ្លួនដែលមានការទទួលស្គាល់ស្របច្បាប់តាមរយៈឯកសារគតិយុត្តិ។ ពូសៅមានរថយន្តផ្ទាល់ខ្លួនដែលមានលិខិតបញ្ជាក់ពីម្ចាស់កម្មសិទ្ធិ។ |
| ៤ | តើមានច្បាប់មាត្រាណាដែលនិយាយអំពីកម្មសិទ្ធិឯកជន? | ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានកំណត់ថាជនណាក៏ដោយទោះបីជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ បុគ្គលម្នាក់ឬ ជាសមូហភាពដែលមានសញ្ជាតិជាខ្មែរទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ ការដកហូត កម្មសិទ្ធិរបស់នរណាម្នាក់បានលុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ហើយការដកហូតនោះត្រូវធ្វើទៅតាមទម្រង់ |

| | | |
|---|---|---|
| | | ច្បាប់ និង ផ្តល់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌។ |
| ៥ | ដើម្បីចាត់ទុកជាកម្មសិទ្ធិពេញលេញ និងស្របច្បាប់ តើត្រូវមានលក្ខខណ្ឌអ្វីខ្លះ? | លុះត្រាតែកម្មសិទ្ធិករទាំងអស់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬមានប័ណ្ណសម្គាល់កាន់កាប់អចលនវត្ថុ។ |
| ៦ | តើម្ចាស់កម្មសិទ្ធិឯកជនឬកម្មសិទ្ធិករមានសិទ្ធិអ្វីខ្លះលើកម្មសិទ្ធិឯកជននោះ? | កម្មសិទ្ធិករមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល សិទ្ធិចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ។ |
| ៧ | តើកម្មសិទ្ធិឯកជនមានបែងចែកជាប្រភេទតូចៗផ្សេងទៀតដែរឬទេ? | ១) កម្មសិទ្ធិអវិភាគ ជាកម្មសិទ្ធិដែលបុគ្គលច្រើននាក់មានលើទ្រព្យតែមួយ ប៉ុន្តែទ្រព្យនោះមិនអាចពុះចែកគ្នាបានទេ។ |
| | | ២)សហកម្មសិទ្ធិជាកម្មសិទ្ធិដែលបុគ្គលជាច្រើននាក់មានលើអចលនវត្ថុមួយ ប៉ុន្តែពួកគេម្នាក់ៗមានមួយចំណែកជារបស់ផ្ទាល់ខ្លួនដែលបានមកពីការបែងចែកដាច់គ្នាតាមឡូត៍ឬជាអចលនវត្ថុរួមទាំងមូល។ |
| គ. កម្មសិទ្ធិសមូហភាព | | |
| ៨ | តើកម្មសិទ្ធិសមូហភាពសំដៅលើអ្វី? | ដីធ្លីរួមដែលជាកម្មសិទ្ធិរបស់សហគមន៍មួយក្រុម ហើយកម្មសិទ្ធិនេះមិនមែនជាកម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិកសហគមន៍នោះឡើយ។សមាជិកសហគមន៍ម្នាក់ៗគ្មានសិទ្ធិចាត់ចែងដីជាកម្មសិទ្ធិសមូហភាពនោះទេ។ |
| ៩ | តើមានច្បាប់ មាត្រាអ្វីបានកំណត់អំពីរឿងនេះដែរឬទេ? | ច្បាប់ភូមិបាលឆ្នាំ២០០១ |
| ១០ | តើទីតាំងណាខ្លះដែលចាត់ទុកជាកម្មសិទ្ធិសមូហភាពបាន? | ១)អចលនវត្ថុឬទ្រព្យសម្បត្តិរបស់វត្តរួមទាំងដីនិងសំណង់ដែលមាននៅក្នុងនិងក្រៅបរិវេណវត្ត។ |

| | | |
|---|---|---|
| | | ២)អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិចរួមមានដីទាំងអស់ដែលសហគមន៍បានរៀបចំទីលំនៅ និងទីកន្លែងប្រកបរបរកសិកម្មជាក់ស្តែង និងដីបម្រុងចាំបាច់ក្នុងការដូរវេនដាំដំណាំថែមទៀតផង។ |
| ១១ | តើនរណាអាចគ្រប់គ្រងលើកម្មសិទ្ធិទាំងនេះបាន? | សម្រាប់អចលនវត្ថុវត្ត អចលនវត្ថុនេះស្ថិតក្រោមការថែទាំ និងការទទួលខុសត្រូវរបស់គណៈកម្មការវត្ត។ |
| | | សម្រាប់អចលនវត្ថុសហគមន៍ជនជាតិដើមភាគតិច អចលនវត្ថុនេះមិនមែនជារបស់ក្រុមណា ឬបុគ្គលណាម្នាក់ទេ តែវាជារបស់ក្រុមជនជាតិដើមភាគតិចទាំងមូលតែម្តង។ |
| ១២ | តើកម្មសិទ្ធិសមូហភាពអាចលក់ ដូរ ឬជួលបានឬទេ? | សម្រាប់អចលនវត្ថុ វត្តអារាម អចលនវត្ថុនេះមិនអាចលក់ ដូរ ឬធ្វើអំណោយហើយក៏គ្មានកំណត់អាជ្ញាយុកាល មិនអាចកាន់កាប់ដោយប្រជាពលរដ្ឋ និងមិនអាចប្រែក្លាយឱ្យទៅជាកម្មសិទ្ធិឯកជនបានឡើយ។ |
| | | សម្រាប់អចលនវត្ថុសហគមន៍ជនជាតិដើមភាគតិច អចលនវត្ថុនេះមិនអាចលក់ ដូរបានមែន ប៉ុន្តែប្រសិនបើមានសមាជិកណាម្នាក់មានបំណងចង់ចាកចេញពីសហគមន៍ ពីប្រពៃណីជនជាតិខ្លួននោះចំណែកទ្រព្យសម្បត្តិសហគមន៍អាចផ្ទេរជាពិសេសឱ្យសមាជិកនោះបានលើចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍។ |
| ១៣ | ទ្រព្យសម្បត្តិរបស់វត្តអាចជួល ឬប្រវាស់បាន តើផលដែលបានអាចយកមកប្រើប្រាស់ក្នុងកិច្ចការអ្វី? | ផលទុនដែលបានមកពីការជួល ឬការប្រវាស់ត្រូវទុកសម្រាប់កិច្ចការក្នុងសាសនា។ |

| ឃ. កម្មសិទ្ធិសាធារណៈ | | |
|---|---|---|
| ១៤ | យើងអាចសួរថាតើកម្មសិទ្ធិសាធារណៈសំដៅលើអ្វី? | សំដៅលើទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋ។ |
| ១៥ | តើនរណា ឬអង្គការចាត់តាំងណាជាអ្នកគ្រប់គ្រង ឬចាត់ចែង? | កម្មសិទ្ធិសាធារណៈស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែងរបស់រដ្ឋនិងនីតិបុគ្គលសាធារណៈផ្សេងៗដូចជា ក្រសួង មន្ទីរ ខេត្ត ក្រុង មន្ទីរពេទ្យ សាលារៀន។ល។ |
| ១៦ | តើកម្មសិទ្ធិសាធារណៈបែងចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ? | ១) ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋសំដៅលើទ្រព្យដែលជាប់ផលប្រយោជន៍សាធារណៈមិនអាចលក់ ដូរ និងមិនអាចកំណត់អាជ្ញាយុកាលបានទេ។ ទ្រព្យនេះ រដ្ឋអាចអនុញ្ញាតឱ្យគេកាន់កាប់ និងប្រើប្រាស់ជាបណ្ដោះអាសន្ន មិនទៀងទាត់ និងអាចដកហូតវិញបានប្រសិនបើមិនបានបំពេញលក្ខខណ្ឌផ្សេងៗដែលមានកំណត់ក្នុងច្បាប់។ |
| | | ២) ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សំដៅលើទ្រព្យទាំងឡាយណាដែលមិនស្ថិតនៅក្រោមទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងមិនមែនទ្រព្យដែលជាកម្មសិទ្ធិរបស់បុគ្គលឯកជនឬរបស់សមូហភាព។ ទ្រព្យសម្បត្តិនេះអាចលក់ ដូរ បែងចែក ឬផ្ទេរសិទ្ធិបានតាមការកំណត់ដោយច្បាប់។ |
| ១៧ | តើកម្មសិទ្ធិសាធារណៈអាចលក់ ដូរ ឬជួលបានដែរឬទេ? | ចំពោះទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចលក់ ដូរ ឬជួលបានទេ ប៉ុន្តែរដ្ឋអាចអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្ដោះអាសន្នបាន ប៉ុន្តែចំពោះទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រដ្ឋអាចលក់ដូរ បែងចែក ឬផ្ទេរសិទ្ធិបានទៅតាមការកំណត់របស់ច្បាប់។ |

| ង. ការលក់ ការដូរ និងការជួលអចលនវត្ថុ | | |
|---|---|---|
| ១៨ | ប្រសិនបើកម្មសិទ្ធិនោះអាចលក់ ដូរ ឬជួលបាន តើកម្មសិទ្ធិករត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បី លក់ ដូរ ឬដើម្បីជួល? | ដើម្បីលក់ កម្មសិទ្ធិករត្រូវធ្វើកិច្ចសន្យាដែលអនុញ្ញាតឱ្យផ្ទេរសិទ្ធិជាកម្មសិទ្ធិនៃអចលនវត្ថុពីអ្នកលក់ទៅឱ្យអ្នកទិញ ដោយអ្នកទិញត្រូវបង់ប្រាក់ថ្លៃអចលនវត្ថុរួម និងពន្ធនានាទៅឱ្យអ្នកលក់ស្របតាមច្បាប់កំណត់។ បន្ថែមលើនេះទៅទៀត កម្មសិទ្ធិករ និងអ្នកទិញ ត្រូវទៅចុះកិច្ចសន្យាលក់នៅអង្គភាពសុរិយោដីដោយមានបង្ហាញភស្តុតាងថារាល់ពន្ធដារលើទ្រព្យនោះត្រូវបង់រួច។ |
| | | ដើម្បីដូរកម្មសិទ្ធិករទាំងពីរភាគីត្រូវធ្វើកិច្ចសន្យាព្រមព្រៀងគ្នាក្នុងការដោះដូរអចលនវត្ថុ ដើម្បីដូរបានត្រឹមត្រូវតាមច្បាប់ កម្មសិទ្ធិករទាំងពីរក៏ត្រូវទៅចុះកិច្ចសន្យានោះនៅអង្គភាពសុរិយោដីដោយមានបង្ហាញភស្តុតាងថារាល់ពន្ធដារលើទ្រព្យនោះត្រូវបង់រួច។ |
| | | ដើម្បីជួល កម្មសិទ្ធិករនិងអ្នកជួលត្រូវធ្វើកិច្ចសន្យាជួលអចលនវត្ថុ ដែលកម្មសិទ្ធិករជួលទៅឱ្យអ្នកជួលប្រើប្រាស់ក្នុងរយៈពេលមួយ ដោយយកជាប្រាក់ឈ្នួលមកវិញយ៉ាងទៀងទាត់តាមរយៈពេលនៃការប្រើប្រាស់។ |
| ១៩ | ក្នុងករណីផ្ទេរកម្មសិទ្ធិអចលនវត្ថុ តើត្រូវផ្ទេរយ៉ាងដូចម្ដេចទើបចាត់ទុកត្រឹមត្រូវតាមច្បាប់? | ភាគីទាំងពីរ ទាំងអ្នកលក់ ទាំងអ្នកទិញ អ្នកដូរត្រូវទៅចុះកិច្ចសន្យាលក់ទិញ ឬដូរនៅអង្គភាពសុរិយោដីដោយមានបង្ហាញភស្តុតាងថារាល់ពន្ធដារលើទ្រព្យនោះត្រូវបង់រួច។ |
| ២០ | តើការជួលអចលនវត្ថុមានប៉ុន្មានយ៉ាង?គឺអ្វីខ្លះ? | ១) ការជួលរយៈពេលខ្លីដែលអាចបន្តជួលជាថ្មីទៀតបានអាស្រ័យលើការព្រមព្រៀងគ្នារវាងកម្មសិទ្ធិករនិងអ្នកជួល។ |

| | | |
|---|---|---|
| | | ២)ការជួលរយៈពេលវែងដែលមានរយៈពេល ១៥ឆ្នាំឬលើសពីនេះ។ |
| ច.សកម្មភាពនិងទោសនៃការរំលោភបំពានលើកម្មសិទ្ធិឯកជននិងកម្មសិទ្ធិសាធារណៈ | | |
| ២១ | តើសកម្មភាពណាជាសកម្មភាពរំលោភបំពានលើកម្មសិទ្ធិឯកជន? | – ការក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះបីក្នុងរូបភាពអ្វីក៏ដោយ<br>– ការបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី<br>– ការប្រើប្រាស់អំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ។ទាំងអ្នកប្រព្រឹត្តិអំពើហិង្សាផ្ទាល់ ទាំងអ្នកបញ្ជាត្រូវទទួលការផ្តន្ទាទោសដូចគ្នា<br>– ការប្រើប្រាស់កម្លាំងឯកជនដើម្បីធានាចំពោះការគោរពប័ណ្ណកម្មសិទ្ធិឬចំពោះការប្រតិបត្តិសេចក្តីសម្រេចរបស់តុលាការក្នុងការបណ្តេញចេញ<br>– ការលួចលក់ លួចបញ្ចាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួន<br>– ការដាំដុះលើដីរបស់ខ្លួន ឬប្រគល់ដី ឬជួលដីឱ្យគេដាំដុះដោយចេតនានូវមុខដំណាំដែលច្បាប់ហាមឃាត់។ |
| ២២ | តើសកម្មភាពណាជាសកម្មភាពរំលោភបំពានលើកម្មសិទ្ធិសាធារណៈ? | – ការប៉ះពាល់ ឬរំលោភកាន់កាប់សិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ<br>– ការលើកចេញ ឬរំកិលចេញ ឬបំផ្លាញចោលទីតាំងស្លាកសញ្ញាសុរិយោដី។ |

| | | |
|---|---|---|
| ២៣ | តើការរំលោភបំពាននោះត្រូវចាត់ទុកជាបទល្មើសអ្វី? | ការរំលោភបំពានលើកម្មសិទ្ធិអចលនវត្ថុអាចជាបទល្មើសព្រហ្មទណ្ឌប្រសិនបើ៖<br>– រាល់អំពើប្រព្រឹត្តិដោយជាក់ស្តែងរំលោភ កាន់កាប់ អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី<br>– រាល់ការប្រព្រឹត្តិដោយជាក់ស្តែងរារាំងអ្នកកាន់កាប់ដោយសន្តិភាព ឬម្ចាស់ទ្រព្យនៅក្នុងតំបន់ដែលមិនទាន់មានប្លង់<br>– រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ ឬមិនប្រក្រតីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ<br>– រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិលើកលែងតែសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម។ |
| | | សំណងរដ្ឋប្បវេណីផងដែរប្រសិនបើបង្កឱ្យមានការខូចខាតដែលបណ្តាលមកពីការរំលោភបំពាននេះ។ |
| ២៤ | តើការរំលោភបំពាននោះនឹងត្រូវមានទោសអ្វីខ្លះ? | អ្នករំលោភបំពានត្រូវផ្តន្ទាទោសពិន័យជាប្រាក់ផងឬ/និងដាក់ពន្ធនាគារផង។ |

**ការពង្រឹងពុទ្ធិ**

គ្រូ: ឥឡូវយើងបានបញ្ចប់មេរៀនហើយ។ ប៉ុន្តែគ្រូមិនទាន់ឱ្យប្អូនៗចេញទេ។ ប្អូនអាចចេញលេងបានលុះត្រាតែប្អូនសរសេររៀបរាប់ចំណុចមួយដែលប្អូនចេះនៅក្នុងមេរៀននេះចូលទៅក្នុងក្រដាសមួយសន្លឹកយកមកឱ្យគ្រូនិងកត់កិច្ចការផ្ទះដែលគ្រូសរសេរលើក្តារខៀនទុកយកទៅធ្វើនៅផ្ទះ។

| **កិច្ចការផ្ទះ** |
| --- |
| គ្រូៈ ឥឡូវយើងបានសិក្សាយ៉ាងច្បាស់លាស់ទាក់ទងនឹងប្រភេទកម្មសិទ្ធិអចលនវត្ថុ ការលក់ ការដូរ ការផ្ទេរឱ្យស្របទៅតាមច្បាប់កំណត់ ក៏ដូចជាទោសទណ្ឌរំលោភបំពានលើកម្មសិទ្ធិ ប៉ុន្តែដើម្បីឱ្យប្អូនៗអាចយល់ដឹងបានកាន់តែប្រសើរទៀតនោះ គ្រូមានករណីសិក្សាមួយទៀតឱ្យប្អូនៗជួយពន្យល់ថា៖<br>• តើ**បញ្ញា**ក៏ដូចជាអ្នកដទៃទៀតបំពានលើកម្មសិទ្ធិអ្វី និងអាចប្រឈមមុខនឹងទោសអ្វីពេលដែលពួកគាត់ទៅតាំងទីលំនៅតាមច្រាំងទន្លេ?<br>• តើប្អូនយល់ថា ការតាំងទីលំនៅតាមច្រាំងទន្លេ អាចបង្កផលវិបាកអ្វីខ្លះ?<br>• តើអាជ្ញាធរគួរមានវិធានការយ៉ាងដូចម្ដេចដើម្បីកុំឱ្យមានការតាំងទីលំនៅរំលោភបំពានលើកម្មសិទ្ធិអចលនវត្ថុដទៃទៀត?<br>• តើអាជ្ញាធរគួរមានដំណោះស្រាយយ៉ាងដូចម្ដេចចំពោះ**បញ្ញា**និងអ្នកដទៃទៀតដែលមកតាំងទីលំនៅតាមច្រាំងទន្លេ ? |
| ករណីសិក្សារបស់**បញ្ញា** និងគ្រួសារ<br>**បញ្ញា** និងគ្រួសារបានឡើងមកធ្វើការសំណង់នៅក្រុងភ្នំពេញ។ ដោយសារជីវភាពខ្វះខាត **បញ្ញា** និងគ្រួសារមិនមានលទ្ធភាពជួលផ្ទះគេនៅទេ។ ដោយឃើញមានប្រជាជនជាច្រើននាំគ្នាទៅសង់ខ្ទមនៅតាមច្រាំងទន្លេ **បញ្ញា**និងគ្រួសារក៏បានទៅលួចធ្វើខ្ទមតូចមួយនៅក្បែរខ្ទមអ្នកផ្សេងៗទៀតដែរ។ **បញ្ញា** និងអ្នកផ្សេងទៀតមិនបានដឹងថាការតាំងទីលំនៅនៅតាមច្រាំងទន្លេខុសច្បាប់ទេ។ ពួកគាត់គិតថានៅយូៗទៅរដ្ឋនឹងមិនដេញពួកគាត់ចេញទេថែមទាំងចែកដីនោះឱ្យពួកគាត់ជាកម្មសិទ្ធិឯកជនទៀតផង។ពេលអាជ្ញាធរចូលមកប្រាប់ឱ្យរុះរើ ព្រោះពួកគាត់កំពុងកាន់កាប់ខុសច្បាប់នៅលើដីសាធារណៈរបស់រដ្ឋ ពួកគាត់បែរជាមានការខឹងសម្បានិងបង្កជម្លោះទៅវិញ។ |

| | | |
|---|---|---|
| **ជំពូក៣** | **ការចូលរួមអភិវឌ្ឍសហគមន៍** | |
| **មេរៀនទី** | ១០ | |
| **ចំណងជើងមេរៀន** | **រដ្ឋបាលសាធារណៈ** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | រដ្ឋបាលសាធារណៈជាស្ថាប័នដែលមាននៅក្នុងរដ្ឋនីមួយៗមានតួនាទីបម្រើផលប្រយោជន៍សាធារណៈ និងស្ថិតនៅក្រោមការដឹកនាំរបស់អង្គការនីតិប្រតិបត្តិ។ រដ្ឋបាលសាធារណៈជាសេនាធិការដ៏រឹងមាំរបស់រដ្ឋាភិបាលក្នុងការបំពេញ ភារកិច្ចដើម្បីផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។ | |
| **វត្ថុបំណង** | ១ | – ប្រាប់បាននិយមន័យនៃរដ្ឋបាល និងរដ្ឋបាលសាធារណៈ<br>– ពណ៌នាពីប្រវត្តិនៃរដ្ឋបាលសាធារណៈនិងលក្ខណៈនៃរដ្ឋបាលសាធារណៈ។ |
| | ២ | បង្ហាញលក្ខណសម្បត្តិនិងអំណាចនៃរដ្ឋបាលសាធារណៈ។ |
| | ៣ | ចូលរួមគោរពច្បាប់ និងបទបញ្ញាផ្សេងៗរបស់សង្គម។ |
| **សម្ភារៈ** | សៀវភៅសិស្ស | |
| | ក្រដាសផ្ទាំងធំ(Flip chart) | |
| **រយៈពេល** | ៣ម៉ោង | |

**ដំណើរការបង្រៀន**

**ការចាប់ផ្ដើមមេរៀន**

**គ្រូ:** សួស្ដីប្អូនៗទាំងអស់គ្នា! កាលពីមេរៀនមុនយើងបានទៅសាលាឃុំដើម្បីសម្ភាស។ មុនយើងទៅ យើងបានធ្វើលិខិតស្នើសុំទៅដាក់នៅសាលាឃុំ ព្រោះនៅទីនោះមានអ្នកចាំទទួល និងបញ្ជូនឬរាយការណ៍បន្ត។បន្ទាប់ពីមានការសម្រេចចិត្តពីសាលាឃុំហើយទើបយើងអាចទៅសម្ភាសតាមពេលវេលាដែលបានកំណត់យល់ព្រម។នៅសាលាឃុំមានអ្នករៀបចំទីកន្លែងឱ្យយើងអង្គុយស្ដាប់ សួរសំណួរ កត់ត្រាចម្លើយជាដើម។តើប្អូនណាដឹងថាការរៀបចំចាត់ចែងនៅសាលាឃុំនេះគេហៅថាអ្វី?

**ចម្លើយរំពឹងទុក:**

បាទលោក/អ្នកគ្រូ ការគ្រប់គ្រងចាត់ចែងនេះហៅថាកិច្ចការរដ្ឋបាល។

**គ្រូ:** ល្អណាស់ប្អូនដែលបានជួយចែករំលែកចំណេះដឹងរបស់ប្អូនទាក់ទងនឹងកិច្ចការរដ្ឋបាល។ មានមតិខ្លះយល់ថា ដើម្បីរៀបចំកន្លែងមួយឱ្យដំណើរការបានល្អ ប្រព្រឹត្តទៅដោយរលូនគេត្រូវរៀបចំឱ្យមានរដ្ឋបាល តើប្អូនណាដឹងអំពីមូលហេតុនៃការរៀបចំនេះដែរឬទេ?

**ចម្លើយរំពឹងទុក:**

បាទ លោក/អ្នកគ្រូ ព្រោះស្ថាប័នរដ្ឋ ឬក្រុមហ៊ុនមួយត្រូវការចាំបាច់ផ្នែករដ្ឋបាល ដើម្បីជួយរៀបចំទីកន្លែង សម្ភារៈ និងរៀបចំសំណុំលិខិត ក្នុងគោលបំណងបើកស្ថាប័ន ឬក្រុមហ៊ុន ជ្រើសរើសបុគ្គលិកជាដើម។

**គ្រូ:** អរគុណ។ នេះពិតជាចម្លើយត្រឹមត្រូវហើយ។ មិនថានៅក្នុងស្ថាប័នរដ្ឋ ឬក្រុមហ៊ុនឯកជនទេ ការរីកចម្រើន លូតលាស់ និងការមាននិរន្តរភាពរបស់ស្ថាប័នទាំងនោះ គឺអាស្រ័យលើកិច្ចការរដ្ឋបាលដែលសំដៅលើការគ្រប់គ្រង ការងាររៀបចំ ការតាមដាន ការកែលម្អឬកែទម្រង់ និងការងារទំនាក់ទំនងពីស្ថាប័ន ឬក្រុមហ៊ុនរបស់ខ្លួនទៅស្ថាប័នជុំវិញ។ តើប្អូនណាដឹងថា ការងាររដ្ឋបាលរបស់វិស័យឯកជននិងរដ្ឋខុសគ្នាដូចម្ដេច?

បាទ/ចាស:កិច្ចការរដ្ឋបាលរបស់វិស័យឯកជននិងស្ថាប័នរដ្ឋមិនដូចគ្នាត្រង់ថា វិស័យឯកជនបម្រើផលប្រយោជន៍រួមសម្រាប់មនុស្សឬក្រុមតូច ឯស្ថាប័នរដ្ឋវិញសំដៅលើការបម្រើផលប្រយោជន៍ទូទៅជាសាធារណៈដែលមនុស្សទូទៅនៅក្នុងសង្គមអាចទទួល និងយកប្រើប្រាស់លទ្ធផលនោះបាន។ប៉ុន្តែក្នុងមេរៀននេះ យើងនឹងសិក្សាឱ្យស៊ីជម្រៅអំពីកិច្ចការរដ្ឋបាលរបស់ស្ថាប័នរដ្ឋដែលជាទូទៅគេស្គាល់ថារដ្ឋបាលសាធារណៈប៉ុណ្ណោះ។

## មេរៀនថ្មី

**គ្រូ** : រដ្ឋបាលសាធារណៈ មកពីពាក្យថារដ្ឋបាល និងសាធារណៈ។រដ្ឋបាលមានន័យថា ការរក្សា ការគ្រប់គ្រងដឹកនាំ។ ចំណែក សាធារណៈ សំដៅលើអ្វីមួយដែលប្រើសម្រាប់ទាំងអស់គ្នាមិនចំពោះនរណាម្នាក់ឡើយ។ ដូច្នេះ រដ្ឋបាលសាធារណៈ ជាស្ថាប័នទាំងឡាយណាដែលមានតួនាទីបម្រើផលប្រយោជន៍សាធារណៈ ឬបម្រើផលប្រយោជន៍រួមទូទៅ។ជានិច្ចកាល រដ្ឋបាលសាធារណៈស្ថិតក្រោមការដឹកនាំរបស់អង្គការនីតិប្រត្តិបត្តិ និងមានបេសកកម្មគិតគូរបម្រើផលប្រយោជន៍ទូទៅក្នុងការរស់នៅ ឬផ្តល់តម្រូវការជាប្រចាំរាល់ថ្ងៃដល់ប្រជាជនគ្រប់រូបឱ្យកាន់តែប្រសើរ ដូចជាការផ្តល់លិខិតអនុញ្ញាត បញ្ជីអត្រានុកូលដ្ឋាន សំបុត្រកំណើត ប័ណ្ណកម្មសិទ្ធិ អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ ការរក្សាសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម ការដោះស្រាយវិវាទផ្សេងៗតាមរយៈប្រព័ន្ធតុលាការ ការផ្តល់ការអប់រំ ការផ្គត់ផ្គង់សេវាសុខាភិបាលដល់មូលដ្ឋាន ការកសាងប្រព័ន្ធផ្លូវគមនាគមន៍ដឹកជញ្ជូន មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ទូរគមនាគមន៍។ល។

**គ្រូ**: រដ្ឋបាលសាធារណៈ មានដើមកំណើតតាំងពីយូរយារណាស់មកហើយនៅលើពិភពលោកយើងនេះ។ គ្រាន់តែថាពីមួយសម័យទៅមួយសម័យមានការប្រែប្រួល និងការកែទម្រង់ឱ្យកាន់តែមានប្រសិទ្ធភាព។ ដូចនៅប្រទេសអេស៊្បីប គេបង្កើតប្រព័ន្ធរដ្ឋបាល ដើម្បីត្រួតត្រាគ្រប់គ្រងលើការងារកសាងប្រព័ន្ធធារាសាស្ត្រដែលតែងតែជន់លិចពីទន្លេនីលជារៀងរាល់ឆ្នាំ ឬដើម្បីចាត់ចែង និងដឹកនាំការងារសាងសង់ប្រាសាទពីរ៉ាមីត។

នៅប្រទេសចិនក្នុងរជ្ជកាលស្តេចហាន (ឆ្នាំ២០៦មុនគ.សរហូតដល់ឆ្នាំ ២២០ ក្រោយគ.ស) ដោយទទួលឥទ្ធិពលពីលទ្ធិខុងជឺ រដ្ឋបាលរាជការក៏ត្រូវពង្រឹងប្រកបដោយភាពជាមេដឹកនាំ ដែលមានគុណធម៌ និងសមត្ថភាព ធ្វើឱ្យមនុស្សទាំងអស់ដែលរស់នៅក្នុងសង្គមរស់នៅប្រកបដោយសុភមង្គល។នៅឯចក្រភពក្រិច រ៉ូម៉ាំង អេស៉្បាញឯណោះវិញ រដ្ឋបាលសាធារណៈដែលមានស្តេចជាអ្នកគ្រប់គ្រងត្រួតពិនិត្យនោះក៏បានបង្កើតជាច្បាប់ ជានីតិវិធីផ្សេងៗដើម្បីសម្រួលដល់កិច្ចការសាធារណៈដែរ។

**គ្រូ**: ចុះប្រទេសកម្ពុជាយើង តើមានការវិវត្តយ៉ាងដូចម្តេចដែរចំពោះរដ្ឋបាល សាធារណៈ? ដើម្បីចង់ដឹងថាតើមានការវិវត្តយ៉ាងដូចម្តេច គ្រូគ្រាន់តែសរសេរឆ្នាំដាក់ក្រដាសផ្ទាំងធំបិទនៅជញ្ជាំងបន្ទប់។ គ្រូឱ្យប្អូនជួយសរសេរបំពេញនូវព្រឹត្តិការណ៍សំខាន់ៗកើតឡើងនៅពេលនោះ។ លោកគ្រូបែងចែកប្អូនៗជា៤ក្រុមឱ្យទទួលខុសត្រូវ

សរសេរបំពេញលើក្រដាសផ្ទាំងធំ។ប្អូនៗអាចអានសៀវភៅសិក្សា រកព្រឹត្តិការណ៍ឬន័យសេចក្តីសំខាន់ៗកើតឡើងនៅតាមឆ្នាំទាំងនោះបាន។

**ចម្លើយរំពឹងទុកៈ**

| **មុនឆ្នាំ១៨៨៦** | **ឆ្នាំ១៨៨៦** | **ឆ្នាំ១៩៤៧** | **សម័យបច្ចុប្បន្ន** |
| --- | --- | --- | --- |
| -អ្នករាជការចាត់តាំងដោយព្រះមហាក្សត្រ<br>-ព្រះមហាក្សត្រមានអំណាចបីគឺ នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ អំណាចតុលាការ<br>-ទ្រង់គ្រប់គ្រងនិងសម្រេចកិច្ចការនយោបាយក្នុងនិងក្រៅប្រទេសនិងការពារជាតិ<br>-ទោសប្រព្រឹត្តិខុសនឹងច្បាប់រដ្ឋបាលដូចជាទារពន្ធពុំសុចរិតជាដើមត្រូវទទួលទោសតាមច្បាប់កំណត់។ | -រៀបចំឱ្យមាន ស្ថាប័នសាធារណៈ និងការប្រព្រឹត្តិទៅរបស់ស្ថាប័នសាធារណៈរួមគ្នារវាងបារាំងនិងខ្មែរ។ | -បង្កើតរដ្ឋធម្មនុញ្ញខ្មែរដំបូងគេ<br>-អ្នករាជការត្រូវស្មោះត្រង់ចំពោះថ្នាក់ដឹកនាំរបស់ខ្លួន<br>-មានតែបុរសទេដែលអនុញ្ញាតឱ្យបម្រើការងារជាអ្នករាជការ។ | -កំណែទម្រង់រដ្ឋបាលសាធារណៈ<br>-ការប្រយុទ្ធប្រឆាំងអំពើពុករលួយ<br>-កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌<br>-កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ |

គ្រូ: អរគុណប្អូនៗដែលបានជួយបំពេញព្រឹត្តិការណ៍ក្នុងឆ្នាំទាំងនេះ។ ដូចអ្វីដែលប្អូនបានបំពេញ រដ្ឋបាលសាធារណៈបានវិវត្តពីសម័យកាលមួយទៅកាន់សម័យកាលមួយទៀតដើម្បីធ្វើការបម្រើដល់សាធារណជនឱ្យកាន់តែមានប្រសិទ្ធភាព។ ប្រសិនបើយើងសង្កេតឱ្យកាន់តែច្បាស់នោះ យើងនឹងឃើញថារដ្ឋបាលសាធារណៈតាមបែបថ្មី (វង្វង់ធំ)បានបញ្ចូលគ្នាពីរបៀបរបបរដ្ឋបាលបែបបុរាណប៉ុន្តែបានធ្វើកំណែទម្រង់បន្ថែមទៀតឱ្យការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព។




គ្រូ: ឥឡូវយើងបានដឹងទាំងនិយមន័យ ទាំងការវិវត្តនៃរដ្ឋបាលសាធារណៈ។ឥឡូវលោកអ្នក/គ្រូចង់ឱ្យប្អូនៗដែលនៅក្នុងក្រុមទាំងបួន ស្វែងរកលក្ខណសម្បត្តិ និងអំណាចរដ្ឋបាលសាធារណៈ។ ប្អូនអាចបើកសៀវភៅសិក្សាគោលរកមើលចំណុចទាំងនោះបាន។

| ការប្រៀបធៀបរវាង | |
|---|---|
| <u>លក្ខណសម្បត្តិរដ្ឋបាលសាធារណៈ</u> | <u>អំណាចរដ្ឋបាលសាធារណៈ</u> |
| ........................................................................................<br>........................................................................................<br>........................................................................................<br>........................................................................................ | ..............................................................................................................<br>..............................................................................................<br>.............................................................................................<br>............................................................................................ |

**ចម្លើយរំពឹងទុកៈ**

| លក្ខណសម្បត្តិរដ្ឋបាលសាធារណៈ | អំណាចរដ្ឋបាលសាធារណៈ |
|---|---|
| -ទឹកចិត្តបម្រើការងារមោះមុត<br>-ភក្ដីភាពជាមួយរដ្ឋាភិបាល<br>-ផ្ដល់សេវាកម្មឱ្យឆ្លើយតបនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋ<br>-មានសីលធម៌វិជ្ជាជីវៈពោលគឺធ្វើការងារប្រកបដោយសមត្ថភាព គុណភាព តម្លាភាព និងទំនួលខុសត្រូវ។ | - អំណាចនៃការសម្រេចចិត្តដែលមានប្រសិទ្ធភាពចាប់ពីពេលមានបញ្ហាភ្លាម (ចុះហត្ថលេខា)<br>- អ្នករដ្ឋបាលមានសិទ្ធិអំណាចប្រើប្រាស់រាល់ថ្ងៃដូចជាការអនុវត្តច្បាប់ការការពារច្បាប់ការពារផលប្រយោជន៍សាធារណៈ<br>- អំណាចក្នុងកិច្ចសន្យារដ្ឋបាលគឺតែងមានប្រៀបលើភាគីឯកជនជានិច្ច<br>- អំណាចរដ្ឋបាល ជាបុព្វសិទ្ធិនៃអំណាចរដ្ឋឬអំណាចសាធារណៈដែលអ្នករាជការឬអ្នករដ្ឋការប្រើប្រាស់បុព្វសិទ្ធិដើម្បីធ្វើការឱ្យបានសម្រេច។ |

**ការពង្រឹងពុទ្ធិ**

**គ្រូ**: យើងបានបញ្ចប់មេរៀនទាក់ទងនឹងរដ្ឋបាលសាធារណៈហើយ។ លោក/អ្នកគ្រូចង់ដឹងថា តើប្អូនៗមានសំណួរឬចម្ងល់អ្វីទាក់ទងនឹងមេរៀនដែលយើងបានរៀនដែរឬទេ? (ប្រសិនបើសិស្សមានចម្ងល់ គ្រូឆ្លើយរាល់ចម្ងល់ទាំងនោះ បន្ទាប់មកគ្រូឱ្យសិស្សសរសេរតែងសេចក្ដី មុនអនុញ្ញាតឱ្យសិស្សចេញលេងបាន)។

**ប្រធាន**

មានមតិមួយបានពោលថា«ការជូនសគុណដល់មន្ត្រីធ្វើការនៅរដ្ឋបាលសាធារណៈជាទម្លាប់របស់ខ្មែរក្នុងការដឹងគុណចំពោះមន្ត្រីរដ្ឋបាលទាំងនោះដែលបានខំប្រឹងប្រែងធ្វើការជួយដល់ប្រជាជន ដូច្នេះគ្មានអ្វីខុសទេគ្រាន់តែជូនលុយជូនកាក់បន្តិចបន្តួចនោះ»។ តើប្អូនយល់ស្រប ឬមិនយល់ស្រប? ចូរពន្យល់ហេតុអ្វីប្អូនយល់ស្រប ឬហេតុអ្វីប្អូនមិនយល់ស្រប។

**កិច្ចការផ្ទះ**

**គ្រូ** : ដោយសារថ្ងៃនេះ ប្អូនធ្វើសកម្មភាពរៀនសូត្រច្រើន យើងមិនមានកិច្ចការផ្ទះអ្វីលំបាកទេ ពេលគឺគ្រាន់តែប្អូនៗអានមេរៀនបន្ទាប់។ ពេលជួបគ្នាលើកក្រោយ យើងនឹងលេងល្បែងសិក្សាមួយ ប៉ុន្តែប្អូនៗអាចលេងល្បែងសិក្សានេះបានល្អ លុះត្រាតែប្អូនៗយល់មេរៀនបន្ទាប់នេះសិន។ ដូច្នេះចូរអានមេរៀនកុំខាន។

<table>
<tr><td>ជំពូក៣</td><td colspan="2">ការចូលរួមអភិវឌ្ឍសហគមន៍</td></tr>
<tr><td>មេរៀនទី</td><td colspan="2">១១</td></tr>
<tr><td>ចំណងជើងមេរៀន</td><td colspan="2">គណបក្សនយោបាយនិងតួនាទី</td></tr>
<tr><td>ពណ៌នាអំពីមេរៀនដោយសង្ខេប</td><td colspan="2">ក្នុងសង្គមប្រជាធិបតេយ្យ គណបក្សនយោបាយជាច្រើនចូលរួមប្រកួតប្រជែងគ្នាតាមរយៈការបោះឆ្នោតដើម្បីដឹកនាំរដ្ឋាភិបាល។ ប្រទេសខ្លះមានគណបក្សតែមួយហៅថាប្រព័ន្ធឯកបក្ស ប្រទេសខ្លះមានគណបក្សពីរ ហៅថាប្រព័ន្ធទ្វេបក្ស និងប្រទេសខ្លះទៀតមានបក្សច្រើន ហៅថាប្រព័ន្ធពហុបក្សចូលរួមបោះឆ្នោត។ ប្រទេសកម្ពុជាបាន អនុវត្តប្រព័ន្ធពហុបក្សឬប្រជាធិបតេយ្យសេរីពហុបក្សចាប់តាំងពីឆ្នាំ១៩៩៣។ ប្រព័ន្ធពហុបក្សបានផ្តល់ប្រយោជន៍ និងជម្រើសយ៉ាងច្រើនដល់ម្ចាស់ឆ្នោតក្នុងការជ្រើសរើសគណបក្សឬតំណាងដែលខ្លួនពេញចិត្ត។ ប្រជាពលរដ្ឋមានសិទ្ធិបង្កើតគណបក្សនយោបាយហើយក៏ត្រូវរៀបចំរចនាសម្ព័ន្ធនិងមានការទទួលស្គាល់គណបក្សនយោបាយតាមផ្លូវច្បាប់។</td></tr>
<tr><td rowspan="3">វត្ថុបំណង</td><td>១</td><td>• ពណ៌នាប្រភេទផ្សេងៗនៃប្រព័ន្ធគណបក្សនយោបាយ<br>• រៀបរាប់រចនាសម្ព័ន្ធនិងភាពស្របច្បាប់នៃការបង្កើតគណបក្សនយោបាយ។</td></tr>
<tr><td>២</td><td>បង្ហាញពីដំណើរការនៃការបង្កើតគណបក្សនយោបាយ និងតួនាទីគណបក្សនយោបាយនៅកម្ពុជា។</td></tr>
<tr><td>៣</td><td>ចូលរួមគោរពសិទ្ធិនយោបាយរបស់អ្នកដទៃ។</td></tr>
<tr><td rowspan="4">សម្ភារៈ</td><td colspan="2">សៀវភៅសិក្សាគោល</td></tr>
<tr><td colspan="2">ក្រដាសផ្ទាំងធំ(Flip chart)</td></tr>
<tr><td colspan="2">តារាង(ការបំពេញពាក្យសុំ)</td></tr>
<tr><td colspan="2">ច្បាប់ស្តីពីគណបក្សនយោបាយ</td></tr>
<tr><td>រយៈពេល</td><td colspan="2">៣ម៉ោង</td></tr>
</table>

| ដំណើរការបង្រៀន |
| --- |
| **ការចាប់ផ្ដើមមេរៀន**<br>គ្រូ: យើងបានសិក្សាអំពីសិទ្ធិ អំពីប្រជាធិបតេយ្យរួចហើយ។ នៅក្នុងនោះ យើងបានស្វែងយល់និងដឹងថា យើងម្នាក់ៗមានសិទ្ធិនៅក្នុងផ្នែកនយោបាយ ជាពិសេសគឺ ការបង្កើតគណបក្សនយោបាយ។ នៅក្នុងពិភពលោកយើងនេះមានប្រទេសខ្លះដូចជាប្រទេសចិននិងប្រទេសវៀតណាម មានប្រព័ន្ធឯកបក្សគឺមានគណបក្សតែមួយប៉ុណ្ណោះ ។ ប្រទេសខ្លះដូចជាសហរដ្ឋអាមេរិកមានប្រព័ន្ធទ្វេបក្សមានគណបក្សតែពីរប៉ុណ្ណោះ ឯប្រទេសកម្ពុជាយើងមានប្រព័ន្ធពហុបក្ស គឺមានគណបក្សច្រើន។ លោក/អ្នកគ្រូចង់ឱ្យប្អូនៗជួយពន្យល់ពីភាពខុសគ្នារវាងប្រព័ន្ធឯកបក្ស ទ្វេបក្ស និងពហុបក្ស ប៉ុន្តែដោយសារយើងពុំមានពេលគ្រប់គ្រាន់ គ្រូបែងចែកជាក្រុមតូចៗដែលមានសមាជិក៥នាក់ដើម្បីស្វែងរកភាពដូចគ្នា និងភាពខុសគ្នានៃប្រព័ន្ធគណបក្សទាំងនេះ។ ឥឡូវ ចូរប្អូនរាប់ពី១ដល់១០(សន្មតថាមានសិស្សចំនួន៥០នាក់នៅក្នុងថ្នាក់)រួចហើយនរណាមានលេខដូចគ្នាចាត់ចូលជាសមាជិកក្រុមតែមួយ។យើងមាន៤ដំណាក់កាល។ ដំណាក់កាលទី១គឺប្រមូលព័ត៌មានដែលទាក់ទងនឹងសំណួរ ដំណាក់កាលទី២រៀបចំព័ត៌មានឱ្យមានសណ្ដាប់ធ្នាប់ យើងអាចប្រើតារាងបាន ដំណាក់កាលទី៣ ប្អូនសរសេរព័ត៌មានដែលប្រមូលផ្ដុំនោះពន្យល់ឱ្យយល់ច្បាស់ និងដំណាក់កាលទី៤ ប្អូនៗត្រូវពន្យល់នូវអ្វីដែលប្អូនបានរកឃើញ។ |
| **ចម្លើយរំពឹងទុក៖**<br>ភាពខុសប្លែកគ្នារវាងប្រព័ន្ធឯកបក្ស ទ្វេបក្ស និងពហុបក្ស |

| | | ឯកបក្ស | ទ្វេបក្ស | ពហុបក្ស |
| --- | --- | --- | --- | --- |
| ១ | ចំនួនគណបក្ស | មានតែគណបក្សមួយគត់សម្រាប់ដឹកនាំរដ្ឋាភិបាល | មានគណបក្សតែពីរគត់ប្រកួតប្រជែង | មានគណបក្សច្រើនចូលរួមប្រកួតប្រជែង |
| ២ | លទ្ធិដែលប្រកាន់យក | លទ្ធិកុម្មុយនីស្តឬលទ្ធិផ្ដាច់ការ | ប្រជាធិបតេយ្យ | ប្រជាធិបតេយ្យ |
| ៣ | អ្នកអាចឈរឈ្មោះបាន | បេក្ខជនដែលមកពីគណបក្សនោះតែប៉ុណ្ណោះ | បេក្ខជនដែលមកពីគណបក្សទាំងពីរ | បេក្ខជនដែលមកពីគណបក្សទាំងអស់ |

| | | | | |
|---|---|---|---|---|
| ៤ | តួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋការ | ចាំតែអនុវត្តតាមសេចក្ដីសម្រេចចិត្តរបស់គណបក្សតែប៉ុណ្ណោះ | បំពេញមុខងារទៅតាមភារកិច្ចដែលច្បាប់បានកំណត់ | បំពេញមុខងារទៅតាមភារកិច្ចដែលច្បាប់បានកំណត់ |
| ៥ | គណបក្សប្រឆាំង | គ្មាន | មាន | មាន |
| ៦ | ផលវិបាក | អាចបង្កឱ្យកើតជារបបផ្ដាច់ការដោយសារគ្មានបុគ្គលណាម្នាក់អាចរិះគន់កែលម្អការអនុវត្តការងាររបស់រដ្ឋាភិបាល។ | អាចមានការរាំងខ្ទប់មតិយោបល់ឬទស្សនៈរបស់ក្រុមតូចៗបានប្រសិនបើក្រុមទាំងនោះមិនទទួលបានការគាំទ្រឬជាសមាជិកនៅក្នុងគណបក្សទាំងពីរនោះទេ។ | សំឡេងឆ្នោតបានបែងចែកទៅឱ្យគណបក្សជាច្រើនដែលមិនអាចឱ្យគណបក្សណាមួយរកសំឡេងគាំទ្រ៥០%+១បានដើម្បីបង្កើតរដ្ឋាភិបាលបាន លុះត្រាតែធ្វើការចរចាច្របាច់បញ្ចូលឬចងសម្ព័ន្ធជាមួយគណបក្សដទៃ។ ប៉ុន្តែប្រសិនបើមិនអាចចរចាគ្នាបានទេការបោះឆ្នោតថ្មីមួយទៀតត្រូវធ្វើឡើងដែលធ្វើឱ្យខាតបង់ថវិកាជាតិនិងពេលវេលាជាច្រើន។ |

**មេរៀនថ្មី**

បន្ទាប់ពីសិស្សធ្វើបទបង្ហាញរួចហើយគ្រូនាំសិស្សលេងល្បែងសិក្សាដែលបែងចែកជាបីដំណាក់កាល។ដំណាក់កាលទី១ សិស្សទាំងអស់បង្កើតជាក្រុមតូចៗប្រកួតគ្នាទាយចម្លើយជ្រើសរើស។ ក្នុងដំណាក់កាលនេះ គ្រូនឹងជ្រើសរើសសិស្ស៤ក្រុមដែល

| |
|---|
| បានពិន្ទុច្រើនជាងគេ។ដំណាក់កាលទី២ ក្រុមទាំង៤ប្រកួតបំពេញចន្លោះ ជ្រើសរើសយកក្រុមឈ្នះ២ក្រុម។ ដំណាក់កាលទី៣ សិស្សទាំង២ក្រុមអនុញ្ញាតឱ្យមើលចម្លើយរួចហើយទទួលបានប័ណ្ណបំពេញ។ បើក្រុមណាមួយបំពេញបានច្រើន និងត្រឹមត្រូវច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។ |
| សំណួរជ្រើសរើស (គ្រូសរសេរសំណួរដាក់លើក្រដាសផ្ទាំងធំ ឬចែកក្រដាសសំណួរទៅក្រុមនីមួយៗ)។ គ្រូជ្រើសរើសបួនក្រុមដើម្បីចូលវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ។<br>១.តើការប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្សបានផ្ដល់ប្រយោជន៍អ្វីខ្លះ?<br>ក. ការរស់នៅចុះសម្រុងគ្នារវាងក្រុមប្រជាពលរដ្ឋដែលមាននិន្នាការនយោបាយឬទស្សនៈខុសៗគ្នា<br>ខ. ការទប់ស្កាត់របបផ្ដាច់ការឬរបបគ្រប់គ្រងឯកបក្ស<br>គ. ការផ្លាស់ប្ដូរមេដឹកនាំប្រទេសតាមរយៈការបោះឆ្នោត<br>ឃ.ប្រជាពលរដ្ឋជាម្ចាស់អំណាច<br>ង. ប្រជាពលរដ្ឋមានសិទ្ធិបង្កើតគណបក្សនយោបាយ<br>ច. ចម្លើយខាងលើទាំងអស់។<br>២.តើត្រូវមានប្រជាពលរដ្ឋជាសមាជិកប៉ុន្មាននាក់ទើបបង្កើតគណបក្សនយោបាយបាន?<br>ក.៥០០នាក់<br>ខ.៤០០នាក់<br>គ.៣០០នាក់<br>ឃ.២០០នាក់។<br>៣.តើប្រជាពលរដ្ឋត្រូវមានអាយុប៉ុន្មានឆ្នាំ ទើបបង្កើតគណបក្សនយោបាយបាន?<br>ក.១៩ឆ្នាំឡើងទៅ<br>ខ.២០ឆ្នាំឡើងទៅ<br>គ.២២ឆ្នាំឡើងទៅ<br>ឃ.១៨ឆ្នាំឡើងទៅ ។<br>៤.បន្ទាប់ពីធ្វើលិខិតជាលាយលក្ខណ៍អក្សរជូនដំណឹងទៅក្រសួងមហាផ្ទៃដើម្បីបើកគណបក្ស តើគេត្រូវរង់ចាំការឆ្លើយតបពីក្រសួងមហាផ្ទៃវិញប៉ុន្មានថ្ងៃ?<br>ក.២០ថ្ងៃ<br>ខ.១៧ថ្ងៃ |

គ. ១៥ថ្ងៃ

ឃ. ៣០ថ្ងៃ។

៥.ក្រោយពីការជូនដំណឹងសុំបើកគណបក្សហើយ តើគេត្រូវចាប់ផ្តើមបោះឆ្នោតជ្រើសរើសគណៈកម្មាធិការបណ្តោះអាសន្នយ៉ាងតិចប៉ុន្មានរូបសម្រាប់រៀបចំលិខិតនិងបំពេញលក្ខខណ្ឌនៃការសុំចុះបញ្ជីគណបក្សនយោបាយ?

ក.១០រូប

ខ. ៧រូប

គ. ១៥រូប

ឃ. ៨រូប។

៦. តើសមាជិកគណៈកម្មាធិការបណ្តោះអាសន្នទាំងនោះត្រូវមានអាយុប៉ុន្មានឆ្នាំ?

ក.២៥ឆ្នាំ

ខ. ២៦ឆ្នាំ

គ. ២៧ឆ្នាំ

ឃ.២៨ឆ្នាំ។

សំណួរបំពេញចន្លោះ (ជ្រើសរើសពីរក្រុម)

១.ដើម្បីរៀបចំឱ្យមានដំណើរការល្អ គណបក្សនយោបាយនីមួយៗត្រូវរៀបចំលក្ខ.......... និងគោ..........................សំខាន់ៗជាលាយលក្ខណ៍អក្សរដោយក្នុងនោះមានឈ្មោះជាអក្សរ..........អក្សរកាត់ និងសញ្ញាសម្គាល់ អា...............ដ្ឋាននៃទីស្នាក់..............សិទ្ធិ និងភារកិច្ចរបស់សមាជិកបក្ស រចនា..................ថ្នាក់ជាតិ និងថ្នាក់ក្រោមបន្តបន្ទាប់ បែបបទនៃការជ្រើស..............គណៈ..................នាយក ហិ......វត្ថុទ្រព្យសម្បត្តិរបស់.............. បក្ស..................បាយ។

២.អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗមានក)មហាសន្និបាត ឬស............. ខ)ក្រុមប្រឹក្សាជាតិឬគណៈ...........កណ្តាល គ) គណៈកម្មាធិការ.............ឬគណៈកម្មាធិការអ..........................ឃ) គណៈកម្មាធិការអាជ្ញា..............................ឬគណៈកម្មាធិការត្រួត................................។

៣.នៅថ្នាក់កណ្តាល ក្រុមប្រឹក្សាជាតិឬគណៈកម្មាធិការកណ្តាលដែលដឹកនាំគណបក្សមានក)ប្រ.........គណបក្សមួយរូប ខ)អនុប្រធាន គ)អគ្គ..........ញ្ញិកមួយរូប ព្រមទាំង ឃ) ....................ស្សរជនសំខាន់ៗជាច្រើនរូបទៀត។

៤.នៅតាមបណ្តារាជធានី ខេត្តនីមួយៗ រចនាសម្ព័ន្ធនៃ....................មានគណៈកម្មាធិការ

...............យករាជធានី ខេត្ត ឬគណៈ.........កណ្តាលរាជធានីខេត្ត ក្រុម............វិន័យ ឬ ក្រុមប្រឹក្សាវិវាទកម្មរាជធានីខេត្ត នៅថ្នាក់ស្រុកវិញក៏ត្រូវមានយ៉ាងហោចណាស់ គណៈ...............ប្រតិ.................ស្រុក ខណ្ឌ។

សំណួរចងចាំ(ជ្រើសរើសយកក្រុមឈ្នះ)

សិស្សទាំងពីរក្រុមត្រូវអនុញ្ញាតឱ្យមើលចម្លើយរួចហើយសរសេរទៅតាមការចងចាំរបស់ខ្លួន។ ក្រុមណាសរសេរបានច្រើនជាង និងត្រឹមត្រូវជាងជាអ្នកឈ្នះ។

គ្រូ: ដើម្បីទទួលបានសុពលភាពឬទទួលបានភាពស្របច្បាប់ពេញលេញដែលទទួលស្គាល់ជាផ្លូវការ គណបក្សនយោបាយនីមួយៗត្រូវចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃដោយត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ពាក្យសុំចុះបញ្ជីគណបក្ស អក្សរកាត់ និងសញ្ញាសម្គាល់គណបក្ស
- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្ស
- លក្ខន្តិកៈគណបក្សនយោបាយ
- បទបញ្ជាផ្ទៃក្នុងគណបក្សនយោបាយ បើមាន
- សេចក្តីថ្លែងការណ៍របស់គណបក្សនយោបាយ ស្តីពីការគោរពច្បាប់ផ្សេងៗរបស់ជាតិ
- បញ្ជីឈ្មោះសមាជិកយ៉ាងតិច៤០០០នាក់មកពីរាជធានី ខេត្តមួយចំនួនដោយបញ្ជាក់អាយុ ទីលំនៅ ប័ណ្ណសមាជិកគណបក្សដែលមានបញ្ជាក់កាលបរិច្ឆេទនៃការចូលជាសមាជិកគណបក្ស
- ជីវប្រវត្តិសង្ខេបរបស់ប្រធានឬស្ថាបនិកចំនួន៣នាក់យ៉ាងតិច
- សេចក្តីប្រកាសអំពីគណនីធនាគារ
- បង្កាន់ដៃថ្លៃអាករចុះបញ្ជីគណបក្សនយោបាយ។

**តារាងសិស្សត្រូវបំពេញ**

គ្រូឱ្យសិស្សបំពេញឃ្លាដូចខាងក្រោម៖

ដើម្បីទទួលបានសុពលភាព ឬទទួលបានភាពស្របច្បាប់ពេញលេញដែលទទួលស្គាល់ជាផ្លូវការ គណបក្សនយោបាយនីមួយៗ ត្រូវចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដោយត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

-ពាក្យសុំ..................................................................................................

-អាសយដ្ឋាននៃ.........................................................................................

-លក្ខន្តិកៈ..................................................................................................

| |
|---|
| -បទបញ្ហាផ្ទៃក្នុង......<br>-សេចក្តីថ្លែងការណ៍របស់......<br>-បញ្ជីឈ្មោះសមាជិកយ៉ាងតិច......<br>-ជីវប្រវត្តិសង្ខេប......<br>-សេចក្តីប្រកាស......<br>-បង្កាន់ដៃ ...... |
| **ការពង្រឹងពុទ្ធិ**<br>គ្រូឱ្យសិស្សសរសេរសង្ខេបមេរៀន។<br>**ចម្លើយរំពឹងទុកៈ**<br>យើងជាពលរដ្ឋម្នាក់ៗមិនមែនត្រឹមតែអាចបោះឆ្នោតជ្រើសរើសគណបក្សដែលយើងស្រលាញ់ឱ្យដឹកនាំរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែយើងក៏មានសិទ្ធិក្នុងការបង្កើតគណបក្សរបស់ខ្លួនដែរ។ប៉ុន្តែការបង្កើតគណបក្សនេះ ត្រូវគោរពទៅតាមលក្ខន្តិកៈ និងច្បាប់ដែលមានចែងដូចជាត្រូវមានអាយុចាប់ពី១៨ឆ្នាំ មានប្រជាពលរដ្ឋ៨០នាក់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការបណ្តោះអាសន្នយ៉ាងតិច៧រូបដែលមានអាយុចាប់ពី២៥ឆ្នាំ ត្រូវមានរចនាសម្ព័ន្ធដឹកនាំ មានលក្ខន្តិកៈ មានសញ្ញាសម្គាល់ មានអាសយដ្ឋានត្រឹមត្រូវជាដើម។ ការបង្កើតគណបក្ស គឺជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមចំណែកទាំងកម្លាំងកាយ ទាំងកម្លាំងបញ្ញាចូលរួមការប្រកួតប្រជែងតាមបែបប្រជាធិបតេយ្យនិងអភិវឌ្ឍជាតិ។ប្រសិនបើឈ្នះនោះគណបក្សអាចពាំនាំគោលនយោបាយល្អៗដែលខ្លួនមានដើម្បីដឹកនាំប្រទេសឱ្យកាន់តែរីកចម្រើន។ប៉ុន្តែប្រសិនបើមិនឈ្នះក៏នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើលការដឹកនាំរបស់គណបក្សឈ្នះឆ្នោត និងផ្តល់អនុសាសន៍ក្នុងការកែលម្អធ្វើយ៉ាងណាឱ្យប្រទេសជាតិមានការរីកចម្រើននិងអភិវឌ្ឍន៍។ |
| **កិច្ចការផ្ទះ**<br>១.តើការបង្កើតគណបក្សនយោបាយចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតមានសារៈសំខាន់អ្វីខ្លះដល់សង្គមជាតិ?<br>២.តើហេតុអ្វីបានជាប្រទេសកម្ពុជាលះបង់លទ្ធិកុម្មុយនីស្ត ឬរបបផ្តាច់ការដូចមាននៅក្នុងសម័យខ្មែរក្រហម មកជ្រើសរើសយកលទ្ធិប្រជាធិបតេយ្យវិញ?<br>៣.ប្រសិនបើប្អូនៗជ្រើសរើសបង្កើតគណបក្ស តើប្អូនចង់ឱ្យគណបក្សប្អូនធ្វើអ្វីខ្លះដល់ភូមិ ឃុំដែលប្អូនកំពុងរស់នៅ? |

| | | |
|---|---|---|
| **ជំពូក៣** | **ការចូលរួមអភិវឌ្ឍសហគមន៍** | |
| **មេរៀនទី** | **១២** | |
| **ចំណងជើងមេរៀន** | **ការឈរឈ្មោះនិងការបោះឆ្នោត** | |
| **ពណ៌នាអំពីមេរៀនដោយសង្ខេប** | ការបោះឆ្នោតជាសិទ្ធិនយោបាយនិងជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋគ្រប់រូប។ ប្រជាពលរដ្ឋអនុវត្តសិទ្ធិនៃការគ្រប់គ្រងអំណាចរបស់ខ្លួនតាមរយៈការបោះឆ្នោត ព្រោះក្នុងសង្គមប្រកាន់លទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋជាម្ចាស់អំណាច ប្រជាពលរដ្ឋត្រូវទៅចុះឈ្មោះបោះឆ្នោតឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទើបមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។ ការបោះឆ្នោតសកលមានលក្ខណៈខុសគ្នាពីការបោះឆ្នោតអសកលដែលមានតែតំណាងប៉ុណ្ណោះគឺមានសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់។ | |
| **វត្ថុបំណង** | ១ | - កំណត់និយមន័យនៃការបោះឆ្នោត<br>- ពណ៌នាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត ការឈរឈ្មោះឱ្យគេបោះឆ្នោត ការចុះឈ្មោះបោះឆ្នោតនិងដំណើរការបោះឆ្នោត។ |
| | ២ | - រៀបរាប់ភាពខុសគ្នារវាងការបោះឆ្នោតសកលនិងអសកល<br>- បង្ហាញសារប្រយោជន៍នៃការបោះឆ្នោតនៅក្នុងសង្គមដែលអនុវត្តលទ្ធិប្រជាធិបតេយ្យ។ |
| | ៣ | ចូលរួមអនុវត្តសិទ្ធិបោះឆ្នោតក្នុងនាមជាពលរដ្ឋល្អ។ |
| **សម្ភារៈ** | រូបភាពក្នុងសៀវភៅសិស្ស | |
| | ហិបឆ្នោត(ធ្វើពីក្រដាស) | |
| | ក្រដាសផ្ទាំងធំ(Flip chart) | |
| | ក្រដាសA4 ប៊ិកហ្វឺត ដបទឹកខ្មៅ ក្រដាសឡាំង | |
| | ច្បាប់ស្តីពីគណបក្សនយោបាយ | |
| **រយៈពេល** | ៣ម៉ោង | |

| ដំណើរការបង្រៀន |
| --- |
| **ការចាប់ផ្តើមមេរៀន**<br>គ្រូៈពីមេរៀនមុន គ្រូបានឱ្យប្អូនៗរកឈ្មោះដាក់គណបក្សនយោបាយរបស់ប្អូននិងសរសេរអំពីគោលនយោបាយរបស់គណបក្សរបស់ប្អូនដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍសហគមន៍។ គោលនយោបាយនោះ ត្រូវផ្សារភ្ជាប់ទៅនឹងដំណោះស្រាយអំពីបញ្ហាដែលមាននៅក្នុងសហគមន៍។ឥឡូវយើងនឹងសម្តែងតួអំពីការបោះឆ្នោតឃុំ/សង្កាត់ ប៉ុន្តែប្អូនមិនអាចឈរឈ្មោះបោះឆ្នោតទាំងអស់គ្នាបានទេ ដូច្នេះគ្រូត្រូវការអ្នកដើរតួនាទីជាអ្នកឈរឈ្មោះឱ្យគេបោះឆ្នោតចំនួន៥នាក់ អ្នករៀបចំការបោះឆ្នោត៣នាក់ អ្នកសង្កេតការណ៍៣នាក់ និងអ្នកបោះឆ្នោតគឺសិស្សទាំងអស់គ្នា។<br>**ការរៀបចំបោះឆ្នោតមាន៤វគ្គៈ**<br>***វគ្គទី១***: តួជាប្រជាពលរដ្ឋ មិនចង់ទៅចុះឈ្មោះ និងទៅបោះឆ្នោតទេ ដោយយល់ថាការចុះឈ្មោះនិងការបោះឆ្នោតគ្មានតម្លៃ ឬប្រយោជន៍អ្វីសម្រាប់ពួកគាត់។ អ្នករៀបចំការបោះឆ្នោតក៏ចូលទៅជួយពន្យល់ ទើបពួកគាត់យល់ និងព្រមទៅបោះឆ្នោត។<br>***វគ្គទី២***: អ្នករៀបចំការបោះឆ្នោតបានរៀបចំឱ្យអ្នកឈរឈ្មោះឱ្យគេបោះឆ្នោតចេញមកឃោសនាអំពីគោលនយោបាយរបស់បក្សខ្លួនទៅតាមពេលវេលាដែលបានកំណត់ស្មើៗគ្នា។ វគ្គនេះក៏មានអ្នកសង្កេតការណ៍ចូលរួមផងដែរ។<br>***វគ្គទី៣***: ប្រជាជនចូលទៅមើលឈ្មោះនិងបោះឆ្នោត។ អ្នកសង្កេតការណ៍ក៏ចូលរួមសង្កេតការណ៍ដែរ។<br>***វគ្គទី៤***: អ្នករៀបចំការបោះឆ្នោត រាប់សន្លឹកឆ្នោត រួចហើយប្រកាសលទ្ធផលបណ្តោះអាសន្ន។បន្ទាប់មកអ្នករៀបចំការបោះឆ្នោតស្នើឱ្យមានការប្តឹងតវ៉ាប្រសិនបើមាន។ អ្នកសង្កេតការណ៍ឡើងថ្លែងពីលទ្ធផលនៃការសង្កេតរបស់ខ្លួនថា ការបោះឆ្នោតប្រព្រឹត្តទៅត្រឹមត្រូវឬទេ។ប្រសិនបើគ្មានបញ្ហាអ្វីទេ គណៈកម្មការរៀបចំការបោះឆ្នោតប្រកាសលទ្ធផលជាផ្លូវការ រួចអ្នកឈ្នះឡើងថ្លែងអំណរគុណនិងសន្យាថាខ្លួននឹងគោរពធ្វើតាមអ្វីដែលបានសន្យា ហើយចាប់ដៃជាមួយបេក្ខជនដែលចាញ់បង្ហាញពីមិត្តភាព និងសេចក្តីស្រលាញ់។ |
| **តួរបស់អ្នកឈរឈ្មោះឱ្យគេបោះឆ្នោតៈ**<br>អ្នកទាំងប្រាំត្រូវឃោសនាពន្យល់គោលនយោបាយរបស់គណបក្សខ្លួនដើម្បីដោះស្រាយបញ្ហានិងអភិវឌ្ឍភូមិឃុំ/សង្កាត់របស់យើង។ |

**ចម្លើយរំពឹងទុក៖**

ខ្ញុំបាទឈ្មោះ**ចាន់**មកពីគណបក្សផ្លែក្រូចដែលមានរូបសញ្ញាផ្លែក្រូចជាតំណាង។ បន្ទាប់ពីការធ្វើបទសម្ភាសជាមួយមនុស្សជាច្រើនរួមទាំងអាជ្ញាធរភូមិ ឃុំរបស់យើងមក ខ្ញុំឃើញថាកុមារជាច្រើនមានសុខភាពមិនសូវល្អ និងពុំមានលទ្ធភាពទៅរៀនសូត្របាន ដោយសារឪពុកម្តាយក្រីក្រ។ គោលនយោបាយគណបក្សរបស់ខ្ញុំ គឺខំប្រឹងប្រែងជំរុញឱ្យមានការសាងសង់មណ្ឌលសុខភាពឱ្យបាន៥ក្នុងឃុំនីមួយៗ។ គណបក្សខ្ញុំនឹងខំប្រឹងធ្វើការជំរុញលើកទឹកចិត្តឱ្យបុគ្គលិកមណ្ឌលសុខភាពចុះណែនាំប្រជាជនពីការបង្ការជំងឺ និងថែទាំសុខភាព ព្រោះកាលណាយើងចេះថែទាំសុខភាពនិងបង្ការជំងឺបានល្អ នោះអាចជួយកាត់បន្ថយជំងឺដែរ។ ម្យ៉ាងទៀត ដោយសារតែជីវភាពខ្វះខាតធ្វើឱ្យឪពុកម្តាយខ្លះមិនមានលទ្ធភាពបញ្ជូនកូនទៅរៀន ដូច្នេះដើម្បីឱ្យគាត់អាចបញ្ជូនកូនទៅរៀនបានលុះត្រាតែពួកគាត់មានជីវភាពសមរម្យ។ ដើម្បីឱ្យជីវភាពគាត់សមរម្យលុះត្រាតែពួកគាត់អាចផលិត និងលក់ដូរផលិតផលកសិកម្មរបស់ខ្លួនបានឬមានការងារធ្វើ។ ដូចនេះ គោលនយោបាយរបស់គណបក្សខ្ញុំ នឹងព្យាយាមបង្កើតទីផ្សារ និងផ្តល់កម្ចីឥតការប្រាក់ដល់ប្រជាជនក្រីក្រ ផ្តល់អ្នកបច្ចេកទេសនិងពូជល្អៗ ឱ្យពួកគាត់ដាំដុះ និងលក់បានតម្លៃថ្លៃ។ ចំពោះការបង្កើតការងារ យើងនឹងស្វែងរកឪពុកម្តាយដែលមានជីវភាពក្រីក្រហើយផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យគាត់អាចស្វែងរកការងារធ្វើបានទៅតាមតម្រូវការទីផ្សារ។ គណបក្សយើងខ្ញុំ ព្យាយាមទាក់ទាញអ្នកវិនិយោគទុនឱ្យមកវិនិយោគនៅតាមខេត្តនានាឱ្យបានកាន់តែច្រើន ដើម្បីបង្កើតការងារដល់ប្រជាជនដែលរស់នៅតាមខេត្ត។ ចំពោះកូនអ្នកក្រីក្រដែលគ្មានលទ្ធភាពនឹងទទួលបានអាហារូបករណ៍រៀនរហូតដល់បញ្ចប់ថ្នាក់ទី១២ផងដែរ។ដោយសារគណបក្សយើងខ្ញុំមានគោលនយោបាយល្អជួយដល់ប្រជាជនឱ្យមានជីវភាពរស់នៅសម្បូរសប្បាយ និងសង្គមជាតិរីកចម្រើន ខ្ញុំសូមឱ្យបងប្អូនពុកម៉ែយាយតាជួយបោះឆ្នោតឱ្យខ្ញុំដែលជាតំណាងគណបក្ស។ ខ្ញុំសូមសន្យាថា គោរពនិងធ្វើតាមការសន្យានៅពេលដែលខ្ញុំនិងគណបក្សខ្ញុំបានជាប់ឆ្នោត។

**តួរបស់អ្នករៀបចំការបោះឆ្នោត៖**

ពួកគេទាំងបីមានតួនាទីណែនាំប្រជាជនឱ្យយល់ដឹងពីសារៈសំខាន់នៃការប្រើសិទ្ធិក្នុងការបោះឆ្នោត មកចុះឈ្មោះបោះឆ្នោត លក្ខខណ្ឌនិងនីតិវិធីបោះឆ្នោត។ ពេលបេក្ខជនឈរឈ្មោះបោះឆ្នោតឡើងឃោសនា ត្រូវកំណត់រយៈពេលស្មើៗគ្នាដល់អ្នកទាំងនោះ(៧នាទី) ក្រុមនេះប្រកាសលទ្ធផលបណ្តោះអាសន្ន និងស្នើឱ្យមានការតវ៉ាប្រសិនបើមាន។

សូមអញ្ជើញបងប្អូនដែលមានអាយុ១៨ឆ្នាំឡើងទៅទាំងអស់អញ្ជើញមកចុះឈ្មោះ និងបោះឆ្នោតឱ្យបានគ្រប់ៗគ្នា។ ការបោះឆ្នោតនេះមានសារៈសំខាន់ណាស់សម្រាប់អនាគតរបស់បងប្អូន កូនចៅរបស់បងប្អូននិងជាតិយើងទាំងមូល។ការចុះឈ្មោះនិងការបោះឆ្នោតអត់ត្រូវការបង់ប្រាក់អ្វីទេឱ្យតែបងប្អូនមាន១)សញ្ជាតិខ្មែរ ២)មានអាយុ១៨ឆ្នាំឡើងទៅគិតមកទល់ថ្ងៃបោះឆ្នោត ៣)មានទីលំនៅក្នុងឃុំ/សង្កាត់ដែលសាមីខ្លួនកំពុងចុះឈ្មោះ ៤)ត្រូវទៅចុះឈ្មោះដោយខ្លួនឯងផ្ទាល់ ៥)មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ៦)ពុំមែនជាជនវិកលចរិតឬជនដែលស្ថិតក្រោមអាណាព្យាបាលដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។ពេលបងប្អូនអញ្ជើញមកចុះឈ្មោះ សូមយកមកជាមួយនូវសំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណ ឬឯកសារផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

នៅថ្ងៃបោះឆ្នោតសូមបងប្អូនមកពិនិត្យឈ្មោះនៅតាមមណ្ឌល និងចូលក្នុងកន្លែងបោះឆ្នោតដោយមានលិខិតបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ជាពិសេសគឺអត្តសញ្ញាណប័ណ្ណ ហើយរង់ចាំស្តាប់ការណែនាំពីបុគ្គលិកគណៈកម្មការរៀបចំការបោះឆ្នោត និងជូនក្រដាសសន្លឹកឆ្នោត។ បងប្អូនត្រូវចូលទៅបោះឆ្នោតនៅបន្ទប់សម្ងាត់ដើម្បីបោះឆ្នោត រួចហើយជ្រលក់ទឹកខ្មៅសម្គាល់ថាបានបោះឆ្នោត។ ខ្ញុំសូមជម្រាបបងប្អូនថាការបោះឆ្នោតជាសិទ្ធិ និងជាសេរីភាពរបស់បងប្អូន គ្មាននរណាបង្ខំ គំរាម លួងលោមឬទិញទឹកចិត្តពីបងប្អូនឡើយ។ ការបោះឆ្នោតនោះមានលក្ខណៈសម្ងាត់ យុត្តិធម៌ សេរី និងត្រឹមត្រូវ។ បងប្អូនអាចបោះឆ្នោតឱ្យគណបក្សណាដែលបងប្អូនបានយល់ថាអាចដឹកនាំឱ្យបងប្អូន និងសង្គមជាតិមានការរីកចម្រើននិងសុខសន្តិភាពបាន។

**តួអ្នកអង្កេតការណ៍**

អ្នកសង្កេតការណ៍ ត្រូវតាមដានរាល់ការផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនីមួយៗ តើមានភាពស្មើគ្នាដែរឬទេ? តើការរៀបចំការបោះឆ្នោតប្រកបដោយសេរីត្រឹមត្រូវនិងយុត្តិធម៌ដែរឬទេ? តើការបោះឆ្នោតរបស់ប្រជាពលរដ្ឋត្រឹមត្រូវទៅតាមនីតិវិធី និងរក្សាការសម្ងាត់ដែរឬទេ?

**តួប្រជាពលរដ្ឋ**

**មីងសំ ពូសុច** និង**អ៊ំថែម**អង្គុយជជែកគ្នា។

**មីងសំ**: បងសុច ខ្ញុំឮគេប្រកាសឱ្យទៅចុះឈ្មោះបោះឆ្នោតស្អីគេទៀតហើយ។ ខ្ញុំធុញណាស់មិនដឹងជាស្អីជាស្អីទេ ឮតែបោះឆ្នោតៗ។ កាលពីលើកមុនខ្ញុំមិនទៅទេ នៅផ្ទះដាំបាយឱ្យប្តីហូបប្រសើរជាង។

**ពូសុច**: អើ សំអើយ កំពុងតែរវល់ គេឱ្យដឹកជីយកទៅឱ្យគេផង។ ខ្ញុំក៏មិនទៅដែរ នរណាជាប់ក៏ជាប់ទៅ ខ្ញុំនៅតែលក់ជីបានអញ្ចឹង មែនទេលោកបងថែម។

**អ៊ំថែម**: មែនហើយប្អូនសំ និងប្អូនសុច ខ្ញុំឯណោះក៏រវល់រឿងវត្តរឿងវ៉ា រឿងការផងបុណ្យខ្មោចផងមើលទៅមិនបានទៅចុះឈ្មោះបោះឆ្នោតស្អីនឹងគេទេ។ អ្នកទាំងបីលើកទឹកតែហូប។រំពេចនោះអ្នករៀបចំការបោះឆ្នោតដែលនៅក្បែរនោះ ក៏ចូលទៅជម្រាបសួរ និងបញ្ចេញយោបល់។

**អ្នករៀបចំការបោះឆ្នោត**: ជម្រាបសួរអ្នកមីង លោកពូ និងលោកអ៊ំ។ ខ្ញុំឮអ្នកមីងលោកពូ និងលោកអ៊ំជជែកគ្នារឿងបោះឆ្នោត។ ចុះបានអញ្ជើញទៅចុះឈ្មោះហើយឬនៅ?

**អ៊ំថែម**: អូហ៍! លោកក្មួយ ពួកខ្ញុំគិតថាមិនបានទៅទេ ព្រោះរវល់តែរៀងៗខ្លួន ហើយបោះជាប់នរណាក៏ដូចនរណាដែរ មានគេមួយគំនរទៅបោះហើយ ពួកខ្ញុំមិនបាច់ទៅក៏បានដែរ។

**អ្នករៀបចំការបោះឆ្នោត**: អ្នកមីង លោកពូ និងអ៊ំសម្រេចចិត្តអញ្ចឹងក៏បានដែរ ព្រោះនេះជាសិទ្ធិសេរីភាពរបស់លោកទាំងអស់គ្នា ប៉ុន្តែខ្ញុំសុំសួរអ្នកមីង លោកពូ និងអ៊ំពីរបីសំណួរបានឬទេ?

**មីងសំ ពូសុច និងអ៊ំថែម**: បានៗក្មួយ អញ្ជើញសួរមកចុះ !

**អ្នករៀបចំការបោះឆ្នោត**: អ្នកមីងសព្វថ្ងៃ ធ្វើការអ្វីដែរ?

**មីងសំ**: មិនធ្វើការអ្វីទេក្មួយអើយ។មីងរៀនមិនបានច្រើន ការប្តីហើយមើលតែកូនចៅ ដាំបាយធ្វើម្ហូបហ្នឹងឯង។ មីងស្តាយដែរបើបានរៀនសូត្រ ប្រហែលមានចំណេះជំនាញអ្វីជួយធ្វើការសម្រាលបន្ទុកប្តីខ្លះអាណិតគាត់ ខំទៅធ្វើការគ្មានស្គាល់សៅរ៍ អាទិត្យអីទេ។

**អ្នករៀបចំការបោះឆ្នោត**: ចុះកូនចៅមីងរៀនដល់ណាហើយ។ កូនស្រីខ្ញុំរៀនចប់ថ្នាក់ទី១២ហើយ។គ្នារៀនពូកែដែរ តែខ្ញុំគ្មានលទ្ធភាពឱ្យគ្នាទៅរៀនបន្ត ប្រហែលជាត្រូវចូលរោងចក្ររោងអីហើយក្មួយ។

**អ្នករៀបចំការបោះឆ្នោត**: អ្នកមីងដឹងទេ តាមពិតទៅអ្នកមីងអាចជួយខ្លួនឯងឱ្យទទួលបានចំណេះឬជំនាញ និងអាចជួយដល់កូនស្រីអាចមានលទ្ធភាពទៅរៀនបន្តបាន ប្រសិនបើមីងអាចជ្រើសរើសគណបក្សដែលមានគោលការណ៍ជួយផ្តល់ចំណេះ ជំនាញដល់មនុស្សស្រករមីង និងផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រឱ្យបន្តការសិក្សាបាន។

**មីងសំ**: អញ្ចឹងមែន លោកក្មួយ? មីងមិនដែលដឹងរឿងនេះសោះ។

**អ្នករៀបចំការបោះឆ្នោត**: ជាការពិតណាស់ អ្នកមីង។ការបោះឆ្នោតជាការពិនិត្យជ្រើសរើសនិងតាមដានគណបក្សណាមួយដែលយើងពេញចិត្តដែលអាចជួយដោះស្រាយបញ្ហារបស់យើងបាន។កាលណាគណបក្សណាមួយដែលយើងពេញចិត្តបោះឆ្នោតឱ្យបានជាប់ទៅដឹកនាំឃុំ ស្រុក ខេត្ត ខណ្ឌ និងរដ្ឋាភិបាល គណបក្សនោះនឹងអនុវត្តទៅតាមការសន្យារបស់ខ្លួន ដើម្បីដោះស្រាយបញ្ហារបស់ប្រជាជន ព្រោះគេខ្លាចថាបើគេមិនធ្វើតាមការសន្យាទេ យើងនឹងបោះឆ្នោតឱ្យអ្នកដទៃវិញ។

**មីងសំ**: អញ្ចឹងផងលោកក្មួយ។មីងមិនគួរណាគិតខុសមិនបានទៅបោះឆ្នោតជ្រើសរើសអ្នកតំណាងពីអាណត្តិមុនសោះ។ អញ្ចឹងទោះជារវល់យ៉ាងណា មីងត្រូវតែទៅចុះឈ្មោះបោះឆ្នោតនិងទៅបោះឆ្នោតហើយ។

**ពូសុច**: ចុះក្មួយ តើយើងអាចឱ្យបក្សដែលយើងបោះឱ្យគិតគូរដល់ថ្លៃប្រេងសាំងបានទេក្មួយ។ ដឹកដីឥឡូវ មិនសូវបានចំណេញអីទេ។ បើបានតម្លៃសាំងចុះជាងនេះ ពូច្បាស់ជាសប្បាយចិត្តណាស់។

**អ្នករៀបចំការបោះឆ្នោត**: ទាក់ទងនឹងរឿងនេះ ខ្ញុំជូនជាយោបល់លោកពូថា លោកពូត្រូវពិនិត្យមើលលើគោលនយោបាយគណបក្សនីមួយៗ ជាពិសេសពេលគេធ្វើការឃោសនាបោះឆ្នោត។ កាលណាពូរកឃើញថាគណបក្សណាមួយដែលពូទុកចិត្ត ហើយមានគោលនយោបាយបញ្ចុះថ្លៃសាំងតាមដែលលោកពូចង់បាន លោកពូអាចបោះឆ្នោតឱ្យគណបក្សនោះ។

**ពូសុច**: អញ្ចឹងខ្ញុំក៏ទៅចុះឈ្មោះនិងបោះឆ្នោតនឹងគេដែរ។ខ្ញុំនឹងតាមដានមើលគោលនយោបាយបក្សណាដែលបញ្ចុះថ្លៃសាំង ខ្ញុំនឹងបោះឆ្នោតជូនមិនខាន ។

សើចព្រមៗគ្នា

**មីងសំ**: អ៊ំចែម អ៊ំគិតទៅចុះឈ្មោះនិងបោះឆ្នោតអត់? ហើយអ៊ំចង់បានគោលនយោបាយអីដែរអ៊ំ?

**អ៊ំចែម**: បើលោកប្អូនទៅហើយរឿងអីថាចែមមិនទៅ។និយាយតាមត្រង់ទៅដល់ចាស់ដូចអ៊ំ វាឈឺច្រើនហ្នឹង។ អញ្ចឹងហើយចង់ឱ្យមានការគិតគូរដល់ការជួយព្យាបាលជំងឺថែទាំសុខភាព និងជួយថវិកាខ្លះៗគ្រាន់បានធ្វើបុណ្យធ្វើទាននិងកាហ្វេ គុយទាវម្ដងម្កាលហ្នឹងណា។

អ្នកទាំងអស់គ្នាសើចព្រមៗគ្នារួចនិយាយ: អីយ៉ា អ៊ំរកកាហ្វេ គុយទាវផង។

ជម្រាបលាគ្នា ។

| |
|---|
| **មេរៀនថ្មី**<br>គ្រូៈ បន្ទាប់ពីបានចូលរួមសម្តែងតួទាំងអស់គ្នាហើយ។ លោក/អ្នកគ្រូសុំឱ្យជួយទះដៃអបអរសាទរដល់ខ្លួនយើងម្តងទៀត។ការសម្តែងនេះពិតជាអស្ចារ្យណាស់ ប្អូនៗពិតជាមានទេពកោសល្យមែន។ ឥឡូវយើងមកចាប់ផ្តើមរៀនបន្ថែមទាក់ទងនឹងការឈរឈ្មោះ និងការបោះឆ្នោតនេះ។ |
| **ការពង្រឹងពុទ្ធិ**<br>គ្រូៈ ឥឡូវគ្រូសង្ឃឹមថា ប្អូនៗយល់យ៉ាងច្បាស់អំពីការចុះឈ្មោះបោះឆ្នោតក៏ដូចជាការឈរឈ្មោះឱ្យគេបោះឆ្នោត។ វាជាសិទ្ធិដ៏សំខាន់ដែលយើងមាន និងបំពេញដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍភូមិ ឃុំ/សង្កាត់និងប្រទេសរបស់យើង។ ឥឡូវនេះគ្រូឱ្យប្អូនៗយកក្រដាសសឬក្រដាសសៀវភៅមួយសន្លឹកម្នាក់ និងសរសេរអំពីគំនិតរបស់ប្អូនទាក់ទងនឹងសំណួរថា ប្រសិនបើយើងមិនបានទៅបោះឆ្នោត តើយើងបានបំពេញកាតព្វកិច្ចជាពលរដ្ឋល្អដែរឬទេ? ចូរប្អូនៗបកស្រាយពីគំនិតរបស់ប្អូនថា ហេតុអ្វីបានជាប្អូនគិតយ៉ាងដូច្នេះ។ |
| **កិច្ចការផ្ទះ**<br>គ្រូៈ យើងបានសិក្សារៀនសូត្រចប់មេរៀននៅក្នុងមុខវិជ្ជាពលរដ្ឋវិជ្ជាទាំងអស់ហើយ គ្រូមិនដាក់កិច្ចការផ្ទះឱ្យប្អូនធ្វើទេ ប៉ុន្តែប្អូនត្រូវរំឭករាល់មេរៀនទាំងអស់ដែលយើងបានរៀនរួចមកហើយឡើងវិញ ព្រោះយើងនឹងប្រឡងបញ្ចប់ឆមាសឆាប់ៗនេះ។ គ្រូអរគុណប្អូនៗដែលបានសហការ និងខំប្រឹងប្រែងរៀនសូត្ររហូតដល់យើងបានបញ្ចប់មេរៀនទាំងស្រុង។ គ្រូសង្ឃឹម និងជូនពរឱ្យប្អូនៗទាំងអស់ទទួលបានជោគជ័យក្នុងការសិក្សាគ្រប់ៗគ្នា។ |

# រឿងមហាឫស្សីប្រស់ខ្លា

(សម្រាប់មេរៀន ឯករាជភាព)

មាននិទានមួយតំណាលថា មានខ្លាមួយដេកលើរូងពស់ពិស។ ពស់ពិសនោះលូនចេញមកចឹកខ្លានោះស្លាប់នៅមាត់រូង។ ថ្ងៃនោះជួនជាមហាឫស្សីមួយអង្គនិមន្តគោចរទៅឃើញខ្លានោះស្លាប់ក៏មានចិត្តមេត្តាបានប្រស់ខ្លានោះឱ្យរស់ឡើងវិញ។ ខ្លានោះដឹងខ្លួនហើយនិយាយថា « អញកំពុងតែដេកលក់ ជាសុខសប្បាយក្នុងព្រៃជាលំនៅរបស់អញ ម្ដេចឡើយក៏ព្រះស្តែងហ៊ានមកធ្វើឱ្យអញភ្ញាក់ ម្លោះហើយអញខាំព្រះស្តែងស៊ីពុំលែងឡើយ »។ មហាឫស្សីឆ្លើយថា « ព្រះស្តែងដេកលើរូងពស់ពិសចឹកស្លាប់ អញប្រស់ព្រះស្តែង ឱ្យរស់ឡើងវិញ គួរតែព្រះស្តែងសងគុណអញ ម្ដេចឡើយក៏ព្រះស្តែងគិតខាំអញវិញ »។ មហាឫស្សីនិងខ្លាប្រកែកជជែកគ្នាមិនអស់មិនហើយ ទើបនាំគ្នាទៅប្ដឹងចចកទៅដល់ជួបចចកថ្លែងប្រាប់តាមដំណើររៀងៗខ្លួន។ ចចកជញ្ជឹងគិតថា« អញរស់ក្នុងព្រៃសព្វថ្ងៃនេះ ពឹងពាក់អានុភាពខ្លា បើអញកាត់ក្ដីឱ្យខ្លាចាញ់ សមអញនឹងពឹងពាក់ខ្លានៅនាព្រៃនេះពុំបានឡើយ »។ ចចកគិតដូច្នេះហើយ ក៏កាត់ក្ដីឱ្យខ្លាស៊ីមហាឫស្សី។ ការកាត់ក្ដីយ៉ាងនេះហៅថា ឆន្ទាគតិ ។

មហាឫស្សីមិនសុខចិត្ត ប្រកែកគ្នាទៅវិញទៅមក ហើយនាំគ្នាទៅប្ដឹងគោ ពេលទៅជួបគោ ខ្លានិងមហាឫស្សីថ្លែងប្រាប់គោតាមដំណើរតែរៀងៗខ្លួនដូចមុន។ គោគិតថា « បើអញកាត់ក្ដីឱ្យខ្លាចាញ់ សមខ្លានេះស្អប់អញ វានឹងខាំអញមិនខានឡើយ »។ ទើបគោកាត់ក្ដីឱ្យខ្លាស៊ីមហាឫស្សី ។ ការកាត់ក្ដីរបស់គោយ៉ាងនេះហៅថា ភយាគតិ ។

មហាឫស្សីមិនសុខចិត្តក៏នាំខ្លាទៅប្ដឹងសត្វស្វា ពេលថ្លែងប្រាប់ស្វាតាមដំណើរតែរៀងៗខ្លួនមក ស្វាគិតថា« កាលមុនមានបុរសម្នាក់ធ្លាក់ក្នុងអណ្ដូង ឪពុកអញខំរកខ្សែយោងយកមកខាងលើមាត់អណ្ដូងបាន មានខ្លាមួយគិតមកស៊ីបុរសនោះ ឪពុកអញក៏នាំបុរសនោះឱ្យឡើងលើដើមឈើបានរួចពីការភិតភ័យ បុរសនោះបែរជាចិត្តអាក្រក់សម្លាប់ឪពុកអញវិញ » ។ ស្វាគិតដូច្នោះហើយក៏កាត់ក្ដីឱ្យខ្លាស៊ីមហាឫស្សី។ ស្វាកាត់ក្ដីយ៉ាងនេះហៅថា ទោសាគតិ។

មហាឫស្សីមិនសុខចិត្តក៏នាំខ្លាទៅប្ដឹងត្មាត។ត្មាតគិតថា«សព្វថ្ងៃនេះអញបានរំពាសំណល់ពីខ្លាជាអាហារចំណីរាល់ថ្ងៃ ជាប្រក្រតីមិនដែលដាច់ឡើយ បើអញកាត់ក្ដីឱ្យខ្លាចាញ់ មុខជាខ្លាខឹងនឹងអញ ម្ដេចឡើយអញនឹងបានស៊ីរំពាសំណល់ពីខ្លាតទៅទៀត »។ ត្មាតគិតដូច្នេះហើយ ក៏កាត់ក្ដីឱ្យខ្លាស៊ីមហាឫស្សី។ត្មាតកាត់យ៉ាងនេះហៅថាលោភាគតិ។

មហាឫស្សីមិនសុខចិត្តក៏នាំខ្លាទៅប្ដឹងទេព្រក្ស។ ទេព្រក្សគិតថា« មនុស្សទាំងឡាយដើរព្រៃអាស្រ័យដោយម្លប់ដើមឈើផងទាំងឡាយ ចេះតែកាច់មែក ហែកស្លឹក ស្ទោះសំបក ឆ្លកកាត់ដើម » ទេព្រក្សគិតដូច្នោះហើយ ក៏កាត់ក្ដីឱ្យខ្លាស៊ីមហាឫស្សី។ ទេព្រក្សកាត់ក្ដីយ៉ាងនេះហៅថាមោហាគតិ គឺការកាត់ក្ដីមិនទៀងត្រង់ឡើយ។

មហាឫស្សីមិនអស់ចិត្តក៏នាំខ្លាទៅប្ដឹងនឹងទន្សាយ ដោយប្រាប់ទន្សាយថា« ខ្លានេះដេកលើរន្ធពស់វែក ហើយពស់វែកលូនចេញមកចឹកខ្លាស្លាប់ទៅ អាត្មាអញបានឃើញហើយ សូត្រមន្តប្រោសពិសពស់នោះចេញអស់ទៅ ខ្លារស់ឡើងវិញ ដោយគិតថាខ្លានេះនឹងតបគុណអាត្មាអញ តែឥឡូវនេះម្ដេចខ្លាប្រាថ្នាស៊ីអាត្មាអញទៅវិញ? តាមតែពិចារណាឱ្យអាត្មាអញផងចុះ ។ ឯខ្លាប្ដឹងថា« ខ្ញុំកំពុងតែដេកសុខស្រួលក្នុងព្រៃ ស្រាប់តែព្រះស្ដេងឫស្សីនេះធ្វើឱ្យខ្ញុំភ្ញាក់ ហេតុនេះត្រូវខ្ញុំសុំស៊ីព្រះស្ដេងឫស្សីនេះ គាត់ពុំសុខចិត្តនាំខ្ញុំប្ដឹងចចកៗកាត់ក្ដីឱ្យខ្ញុំស៊ីឫស្សីនេះ។ គាត់ពុំសុខចិត្តនាំខ្ញុំទៅប្ដឹងគោៗ កាត់ក្ដីឱ្យខ្ញុំស៊ីឫស្សីនេះ គាត់ពុំសុខចិត្តនាំខ្ញុំទៅប្ដឹងស្វាៗ កាត់ក្ដីឱ្យខ្ញុំស៊ីឫស្សីនេះ គាត់ពុំសុខចិត្តនាំខ្ញុំទៅប្ដឹងត្មាតៗកាត់ក្ដីឱ្យខ្ញុំស៊ីឫស្សីនេះៗ ពុំសុខចិត្តនាំខ្ញុំទៅប្ដឹងទេព្រក្សៗ កាត់ក្ដីឱ្យខ្ញុំស៊ីឫស្សីនេះៗ ពុំសុខចិត្តនាំខ្ញុំមកប្ដឹងលោកទន្សាយ សូមលោកតាមតែពិចារណាឱ្យខ្ញុំចុះ »។

ទន្សាយស្ដាប់ពាក្យមហាឫស្សី និងពាក្យខ្លាហើយក៏ពិចារណាដោយប្រាជ្ញាឈ្លាសវៃ ឈ្វេងយល់អាថ៌សេចក្ដីហើយប្រាប់ថា« បើដូច្នោះ ចូរមហាឫស្សីនិងបងខ្លានាំគ្នាទៅដល់ទីដែលកើតហេតុនោះ ហើយឱ្យបងខ្លាដេកលក់ជាសុខសប្បាយដូចពីដើមចុះ គឺឱ្យមហាឫស្សីជូនទៅដល់កន្លែងដែលខ្លាដេកនោះ ឱ្យអញបានយល់ហើយពិចារណាដោយប្រការនោះ »។ ពេលនោះមហាឫស្សី ខ្លានិងទន្សាយនាំគ្នាទៅ។ លុះដល់កន្លែងនោះហើយ ខ្លាក៏ប្រះដេកនៅទីដដែល យូរបន្តិចពស់វែកលូនចេញមកចឹកខ្លាស្លាប់នៅមាត់រន្ធនោះទៅ ។ កាលបើខ្លានោះស្លាប់ហើយ ទន្សាយប្រាប់មហាឫស្សីថា« សូមលោកមើលខ្លានោះចុះ ហេតុតែឥតធម៌ វង្វេងភ្លេចគុណគេ ឥឡូវពុំរំលងនឹងវេរាកម្មឡើយ តាំងពីពេលនេះទៅមុខលោកកុំធ្វើគុណនឹងខ្លាឱ្យសោះ » ទន្សាយកាត់ក្ដីយ៉ាងនេះហៅថាសុគតិគមនំ (ដំណើរល្អ) គឺសុចរិត យុត្តិធម៌៕

# ៤. សេចក្តីសន្និដ្ឋាន



នៅក្នុងសង្គមប្រជាធិបតេយ្យ ការមានតែប្រព័ន្ធប្រជាធិបតេយ្យគឺមិនគ្រប់គ្រាន់ទេ គេទាមទារឱ្យមានប្រជាពលរដ្ឋចេះដឹង ប្រើប្រាស់ និងឱ្យតម្លៃទៅលើសិទ្ធិសេរីភាពដែលជាធាតុសំខាន់នៃលទ្ធិប្រជាធិបតេយ្យផងដែរ។ នៅក្នុងប្រទេសរីកចម្រើននានាដូចជាសហរដ្ឋអាមេរិក អឺរ៉ុប អូស្ត្រាលី និងប្រទេសខ្លះក្នុងតំបន់អាស៊ី ប្រជាពលរដ្ឋបានយល់ច្បាស់ពីហេតុផលនេះហើយទើបមានការជំរុញឱ្យមានការបណ្តុះបណ្តាលប្រជាពលរដ្ឋរបស់គេឱ្យយល់ដឹងអំពីពលរដ្ឋវិជ្ជាដែលជាវិជ្ជាជួយឱ្យប្រជាជនយល់ដឹងអំពីសិទ្ធិសេរីភាព កាតព្វកិច្ច ទំនួលខុសត្រូវចំពោះខ្លួនឯង គ្រួសារ និងសង្គម។ ប្រទេសកម្ពុជាចាប់តាំងពីបានឯករាជ្យមក បានអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងអំពីមុខវិជ្ជានេះដែរ ប៉ុន្តែត្រូវបានអាក់ខានទៅវិញដោយសារភ្លើងសង្គ្រាមនៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។ ការរស់ឡើងវិញពីផេះផង់នេះ រឹតតែធ្វើឱ្យប្រទេសកម្ពុជាត្រូវមានការយកចិត្តទុកដាក់ក្នុងការអប់រំប្រជាជនឱ្យយល់ដឹងពីពលរដ្ឋវិជ្ជាថែមទៀត ដើម្បីឱ្យពួកគាត់បានយល់ដឹង និងចេះការពារសិទ្ធិរបស់ខ្លួន និងអ្នកដទៃផង ព្រមទាំងចូលរួមចំណែកកសាងប្រទេសជាតិតាមបែបលទ្ធិប្រជាធិបតេយ្យផងដែរ។

ចាប់តាំងពីការរស់ឡើងវិញនៃប្រជាជាតិកម្ពុជាមកដល់ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋបានចូលរួមចំណែកក្នុងការជួយឱ្យប្រទេសកម្ពុជាបានទទួលសុខសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ។ ដោយសារមើលឃើញសារៈសំខាន់នៃការអប់រំមុខវិជ្ជាពលរដ្ឋវិជ្ជានេះហើយ ទើបការតាក់តែងសៀវភៅសិក្សាគោលក៏ដូចជាសៀវភៅជំនួយដល់គ្រូក្នុងការប្រើវិធីសាស្ត្របង្រៀន ត្រូវបានកែលម្អជាបន្តបន្ទាប់ដើម្បីជួយឱ្យសិស្សមិនត្រឹមតែយល់ដឹងពីសិទ្ធិសេរីភាព កាតព្វកិច្ច ទំនួលខុសត្រូវតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងហ្វឹកហាត់ អនុវត្តបំណិន និងកិច្ចការនានាដែលពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យត្រូវមានផងដែរ។ នៅក្នុងសៀវភៅជំនួយវិធីសាស្ត្របង្រៀននេះ បានបញ្ចូលវិធីបង្រៀនជាច្រើនដើម្បីជួយឱ្យសិស្សចេះត្រិះរិះពិចារណា វាយតម្លៃ ចេះចែករំលែកចំណេះដឹងនិងធ្វើការងារជាក្រុម ចេះធ្វើការជជែកពិភាក្សាដេញដោល ចេះធ្វើគម្រោងអភិវឌ្ឍន៍ ចេះសម្តែងតួ ចេះធ្វើបទបង្ហាញ ចេះសរសេរសំណើស្នើសុំអ្វីដែលគេចាត់ទុកថាត្រឹមត្រូវ និងចេះសិក្សាស្រាវជ្រាវអ្វីមួយដែលគេមិនយល់ឬមិនដឹង និងចង់ឱ្យមានការបកស្រាយពីភាគីពាក់ព័ន្ធឬអ្នកជំនាញ។ ដើម្បីជួយសម្រួលដល់គ្រូឱ្យកាន់តែយល់ដឹងច្បាស់ពីវិធីបង្រៀននីមួយៗ មេរៀនចម្បងៗនៅក្នុងមុខវិជ្ជាពលរដ្ឋវិជ្ជា ត្រូវបានជ្រើសរើសយកមកបង្កើតទៅជាស្ថានភាពបង្រៀនជាក់ស្តែងដោយរៀបរាប់យ៉ាងលម្អិតតាំងពីការចាប់ផ្តើមមេរៀន ការបង្ហាញបទពិសោធចំណេះដឹងដែលសិស្សមានស្រាប់ ការរៀនមេរៀនថ្មី ការពង្រឹងពុទ្ធិ និងកិច្ចការផ្ទះ។

បន្ទាប់ពីគ្រូអានវិធីបង្រៀនរួចហើយគ្រូអាចអនុវត្តការបង្រៀន និងការប្រើវិធីបង្រៀនជាក់ស្តែងបាននៅក្នុងជំពូកទី៣ទាក់ទងនឹងមេរៀនពលរដ្ឋវិជ្ជានៅថ្នាក់ទី១០ និងទី១១។

ដោយសារការទទួលបានព័ត៌មានពីការសិក្សាស្រាវជ្រាវឯកសារនានា និងយោបល់ត្រលប់មកវិញពីគ្រូបង្រៀន សៀវភៅជំនួយវិធីសាស្ត្របង្រៀននេះ បានបញ្ចូលវិធីសាស្ត្រក្នុងការគ្រប់គ្រងថ្នាក់រៀនដែលមានលក្ខណៈប្រជាធិបតេយ្យ ដោយផ្តោតជាសំខាន់ទៅលើតម្រូវការផ្សេងៗរបស់សិស្ស និងការលើកទឹកចិត្តសិស្សឱ្យខំប្រឹងប្រែងរៀនសូត្រ។ នៅក្នុងការគ្រប់គ្រងថ្នាក់តាមបែបប្រជាធិបតេយ្យ សិស្សមានតួនាទីសំខាន់ក្នុងការជួយធ្វើឱ្យការរៀន និងការបង្រៀនបានទទួលជោគជ័យ។ សិស្សត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការបង្កើតបទបញ្ជាផ្ទៃក្នុង វិន័យ ជ្រើសរើសអ្នកតំណាងរបស់ខ្លួន និងជួយគ្រូក្នុងការកែលម្អវត្ថុបំណងសិក្សា ផ្តល់បទពិសោធន៍ និងចំណេះដឹងដែលមានស្រាប់របស់ខ្លួនម្នាក់ៗ។ សិស្សក៏ទទួលបានការលើកទឹកចិត្តតាមរយៈការគោរពនិងឱ្យតម្លៃទៅលើចំណេះដឹង បទពិសោធដែលពួកគេធ្លាប់មានពីមុន ការអនុញ្ញាតឱ្យចូលរួមផ្តល់យោបល់និងចែករំលែកអ្វីដែលគេចេះដោយគ្មានការរើសអើង ការផ្តល់ឱកាសឱ្យពួកគេធ្វើសកម្មភាពក្រៅសាលារៀនដោយខ្លួនឯង ដូចជាការសម្ភាស ការធ្វើគម្រោងអភិវឌ្ឍន៍នានា(គ្រូគ្រាន់តែដើរតួនាទីជាអ្នកសម្របសម្រួល និងផ្តល់ការណែនាំ ប៉ុន្តែសិទ្ធិសម្រេចជារបស់សិស្ស)។

ការជំរុញសិស្សឱ្យចាប់អារម្មណ៍ចង់រៀន ក៏ជាប់ពាក់ព័ន្ធនឹងការវាយតម្លៃ និងយោបល់កែលម្អដល់សិស្សផងដែរ។ សៀវភៅជំនួយវិធីសាស្ត្របង្រៀននេះ ក៏មានផ្តល់វិធីក្នុងការវាយតម្លៃសមត្ថភាពរបស់សិស្ស។ ការបង្រៀនមុខវិជ្ជាពលរដ្ឋវិជ្ជាតាមវិធីទាំងអស់នេះ នឹងរំពឹងថាសិស្សចេះចូលរួមសកម្មភាពក្នុងថ្នាក់ ចេះធ្វើបទបង្ហាញ ចេះសរសេរវិធីសាស្ត្រវាយតម្លៃ ចេះចូលរួមសកម្មភាពនៅក្នុងថ្នាក់ ចេះស្រាវជ្រាវ សរសេរសង្ខេប និងចេះសរសេរការឆ្លុះបញ្ចាំង។ វិធីវាយតម្លៃត្រូវបានរៀបចំឡើងដើម្បីជួយគ្រូឱ្យមានគំនិតក្នុងការវាយតម្លៃសិស្សនិងផ្តល់យោបល់ត្រលប់ទៅសិស្សវិញដើម្បីកែលម្អផងដែរ។ ប៉ុន្តែការវាយតម្លៃសិស្សតែម្ខាងក៏មិនគ្រប់គ្រាន់ដែរ គ្រូដែលជាបុគ្គលសំខាន់ក្នុងការជួយសម្របសម្រួល និងការបង្រៀនសិស្ស ក៏គួរធ្វើការវាយតម្លៃការបង្រៀនរបស់ខ្លួនផងដែរ។ ក្នុងសៀវភៅនេះ ការវាយតម្លៃលើការធ្វើកិច្ចតែងការបង្រៀន ការលើកទឹកចិត្តសិស្ស ការចែករំលែកបទពិសោធនៃការបង្រៀនដល់គ្រូដទៃឬសមាជិកក្រុមបច្ចេកទេសដទៃក៏ត្រូវបានធ្វើឡើងដែរ។ គ្រូអាចប្រើប្រាស់ការវាយតម្លៃនេះ ដើម្បីកែតម្រូវការបង្រៀនរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។


៥.ពាក្យគន្លឹះ

**សិទ្ធិ** អ្វីៗដែលមនុស្សម្នាក់ៗមានតាំងពីកំណើតមកនិងជាអ្វីៗដែលមនុស្សត្រូវការជាចាំបាច់ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរជាមនុស្ស។ មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីធ្វើសកម្មភាពឬសម្រេចចិត្តធ្វើអ្វីមួយដោយសេរី តែមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ ផលប្រយោជន៍របស់បុគ្គលដទៃនិងច្បាប់ឡើយ។

**ករណីយកិច្ច** កិច្ចការដែលពលរដ្ឋម្នាក់ៗត្រូវចូលរួមធ្វើដើម្បីជាប្រយោជន៍សាធារណៈ

**សេរីភាពក្នុងការសម្តែងមតិ** សេរីភាពក្នុងការប្រកាន់និងបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក គ្មានការបារម្ភភិតភ័យដោយសារមតិរបស់ខ្លួននិងជាសេរីភាពក្នុងការស្វែងរកនិងផ្សព្វផ្សាយព័ត៌មានព្រមទាំងគំនិតរបស់ខ្លួនស្របទៅតាមច្បាប់ដែលបានកំណត់។ប្រទេសកម្ពុជាយើងក៏បានគាំទ្រនូវសេចក្តីថ្លែងការណ៍នេះផងដែរ។

**ដីកា** សេចក្តីសម្រេចដែលចេញដោយចៅក្រមម្នាក់ឯង ឬព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងក្នុងការឃុំខ្លួន លើកលែងការចោទប្រកាន់ឬដោះលែងបណ្តោះអាសន្ន។

**សាលដីកា** សេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ខ្ពស់មានសាលាឧទ្ធរណ៍និងតុលាការកំពូលជាដើម។

**សេរីភាព** សកម្មភាពដែលយើងអាចធ្វើអ្វីបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ដែលបានកំណត់ដើម្បីចៀសវាងការរំលោភលើសិទ្ធិសេរីភាពរបស់អ្នកដទៃ។

**ឯករាជភាព** ការមិនស្ថិតក្រោមចំណុះអ្នកដទៃ ហើយមានសិទ្ធិសេរីភាពពេញលេញអាចធ្វើអ្វីៗដែលគេត្រូវធ្វើឱ្យតែទង្វើនោះមិនប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ហើយស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់។

**ឆន្ទាគតិ** ការលម្អៀងព្រោះស្រឡាញ់។

**ទោសាគតិ** ការលម្អៀងព្រោះស្អប់។

**មោហាគតិ** ការលម្អៀងព្រោះវង្វេង ការមិនយល់ខុសត្រូវ។

**ភយាគតិ** ការលម្អៀងព្រោះភ័យខ្លាច។

**តម្លាភាព** ការបើកចំហ ភាពស្មោះត្រង់ គ្មានការលាក់លៀមដោយបង្កលក្ខណៈឱ្យមានការចូលរួមដោយសុទ្ធចិត្ត និងរីករាយក្នុងគ្រប់ទិដ្ឋភាពសង្គមនយោបាយ សេដ្ឋកិច្ច និងវប្បធម៌។ តម្លាភាពបានបង្ហាញឱ្យឃើញពីការ

និយាយពិត និយាយត្រង់ ការគោរពសិទ្ធិ ការមិនរើសអើង មិននិយម បក្ខពួក មិនបោកបញ្ឆោត ប្រើល្បិចកល មិនមួលបង្កាច់ មិនលាក់លៀម មិនច្រណែនឈ្នានីស មិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួន និងការទទួល ស្គាល់ការពិតនៅក្នុងគ្រប់សកម្មភាពទាំងអស់។

**លទ្ធិប្រជាធិបតេយ្យ** មានន័យថាជាទម្រង់នៃការដឹកនាំប្រទេសដែលផ្តល់អំណាចទាំង អស់ឱ្យប្រជាជន។ ប្រជាជនមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសអ្នក តំណាងរបស់ខ្លួនឱ្យបង្កើតរដ្ឋាភិបាលដែលមានតួនាទីសំខាន់ក្នុងការ ចាត់ចែងការងារជាតិស្របទៅតាមឆន្ទៈនិងប្រយោជន៍របស់ប្រជាជន។

**សេរីភាពសារព័ត៌មាននិងការបញ្ចេញមតិ** គឺសំដៅដល់ការផ្សព្វផ្សាយព័ត៌មាននិងមតិ ដោយគ្មានការជ្រៀតជ្រែក គ្មានការព្រួយបារម្ភ ការភិតភ័យ ការមាន សេរីភាពក្នុងការស្វែងរក និងទទួលព័ត៌មានទូទៅ ដោយគ្មានការរារាំង ស្របទៅតាមច្បាប់ មិនប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់អ្នក ដទៃ។

**ការទទួលខុសត្រូវ** គឺសំដៅទៅលើកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ដែលត្រូវធានារ៉ាប់រងអំពើ របស់ខ្លួន ហ៊ានទទួលសារភាពថាខ្លួនជាអ្នកប្រព្រឹត្ត និងទទួលវិបាកនៃ អំពើទាំងនោះ។

**ច្បាប់ការងារ** គឺជាច្បាប់សម្រាប់គ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញមកពីកិច្ច សន្យាការងាររវាងនិយោជក(ថៅកែ)និងកម្មករ និយោជិត(អ្នកធ្វើការ) ដើម្បីយកមកអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជា កិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយភាគីទាំងសងខាងមាន សញ្ជាតិអ្វីក៏ដោយ ហើយទោះបីជាស្នាក់នៅទីណាក៏ដោយ។

**កម្មករនិយោជិតជាប់លាប់** សំដៅទៅដល់ជនដែលបានធ្វើការទៀងទាត់ក្នុងមុខការអ្វី មួយដែលមានលក្ខណៈជាអចិន្ត្រៃយ៍។

**កម្មករនិយោជិតម្តងម្កាល** សំដៅលើជនដែលចុះកិច្ចសន្យាធ្វើការមួយជាប្រាកដ តាមធម្ម តាត្រូវតែឱ្យហើយក្នុងរយៈពេលខ្លី និងជនដែលធ្វើការមួយពេលៗ ធ្វើ ឈប់ៗ និងធ្វើការមួយរដូវ។

**អចលវត្ថុ** គឺជាដីធ្លី និងសំណង់អគារដែលតាំងភ្ជាប់នឹងដី។

**កម្មសិទ្ធិឯកជន** គឺជាសិទ្ធិស្របច្បាប់ដែលមានលើអចលនវត្ថុ និងចលនវត្ថុក្នុងការចាត់ ចែង ការប្រើប្រាស់ និងការអាស្រ័យផល។

**កម្មសិទ្ធិអវិភាគ** ជាកម្មសិទ្ធិដែលបុគ្គលច្រើននាក់មានលើទ្រព្យតែមួយ ប៉ុន្តែទ្រព្យនោះមិនអាចពុះចែកគ្នាបានទេ។

**សហកម្មសិទ្ធិ** ជាកម្មសិទ្ធិដែលបុគ្គលជាច្រើននាក់មានលើអចលនវត្ថុមួយ ប៉ុន្តែពួកគេម្នាក់ៗមានមួយចំណែកជារបស់ផ្ទាល់ខ្លួនដែលបានមកពីការបែងចែកដាច់គ្នាតាមឡូតិ៍ និងមួយចំណែកនៃអចលនវត្ថុជារបស់រួម។

**កម្មសិទ្ធិសាធារណៈ** សំដៅលើទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋ។

**ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ** សំដៅលើទ្រព្យដែលមានជាប់ផលប្រយោជន៍សាធារណៈ មិនអាចលក់ដូរ និងមិនអាចកំណត់អាជ្ញាយុកាលបានទេ។ ទ្រព្យនេះរដ្ឋអាចអនុញ្ញាតឱ្យគេកាន់កាប់និងប្រើប្រាស់ជាបណ្ដោះអាសន្ន មិនទៀងនិងអាចដកហូតវិញបាន ប្រសិនបើមិនបានបំពេញលក្ខខណ្ឌផ្សេងៗដែលមានកំណត់ក្នុងច្បាប់។

**ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ** សំដៅលើទ្រព្យទាំងឡាយណាដែលមិនស្ថិតនៅក្រោមទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងមិនមែនទ្រព្យដែលជាកម្មសិទ្ធិរបស់បុគ្គលឯកជនឬរបស់សមូហភាព។ ទ្រព្យសម្បត្តិនេះអាចលក់ ដូរ បែងចែក ឬផ្ទេរសិទ្ធិបានតាមការកំណត់ដោយច្បាប់។

**រដ្ឋបាលសាធារណៈ** គឺជាស្ថាប័នទាំងឡាយណាដែលមាននៅក្នុងរដ្ឋនីមួយៗ ហើយមានតួនាទីបម្រើដល់ផលប្រយោជន៍សាធារណៈឬបម្រើផលប្រយោជន៍រួមទូទៅ។រដ្ឋបាលសាធារណៈស្ថិតនៅក្រោមការដឹកនាំរបស់អង្គការនីតិប្រតិបត្តិ។

**ការបោះឆ្នោតសកល** គឺការបោះឆ្នោតដែលប្រជាពលរដ្ឋទាំងអស់មានអាយុ១៨ឆ្នាំចេញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។

**ការបោះឆ្នោតអសកល** គឺការបោះឆ្នោតដែលប្រជាពលរដ្ឋទាំងអស់មិនបានទៅបោះឆ្នោតដោយផ្ទាល់ មានតែអ្នកតំណាងរបស់ខ្លួនជាអ្នកចូលរួមបោះឆ្នោត។ ការបោះឆ្នោតនេះសំដៅលើការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា(២០១៣)ការបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល. ភ្នំពេញៈ ក្រសួងអប់រំ យុវជន និងកីឡា

Asman, M., & Michaela, O. (1997).*Trainer's Handbook: A 14 Days Teaching Methodology Course*. Retrieved October 4, 2017 from http://www.nzdl.org/gsdlmod?

BBC Media Action Research. (2014). *Reaching and Engaging the Cambodian Youth on Issues of Civic Participation*. Cambodia: Phnom Penh.

Calderon, M. T. F. (2012). Effective Classroom Managment. Retrieved October 4, 2017 http://www.cfopso.org.ph/pdf/10thconferencepresentation/1_Effective_Classroom_Management-Dr_Calderon.pdf

Cangelosi, J. S. (). Classroom Management Strategies: Gaining and Maintaining Student's Cooperation. USA.: John Wiley & Sons, Inc.

Crawford, A., Saul, E.W., Mathews, S., & Makinster, J. (2005). *Teaching and Learning Strategies for the Thinking Classroom*. New York: The international Debate Education Association.

Eddington, D., & Ambrose, K.(2010). *Civic & Citizenship Education: Professional Learning Package*. Australia: Education Services Australia

Freire, P. (1970). *The Pedagogy of the Oppressed* (M. Bergman Ramos, Trans.). New York: The Continuum International Publishing Group Ltd.

Guilfoile, L.,& Delander, B. (2014). *Guidebook: Six Proven Practices for Effective Civic Learning*. U.S.,: the Education Commission of the States (ECS).

Gollob, R., Huddleston, E., Krapf, P., Salema, Maria-Helena., & Spajic-Vrkas, V. (2007). *Tool on Teacher Training for Education of Democratic Citizenship and Human Rights Education*. Strasbourg Cedex: Council of Europe.

Gollob, R., Krapf, P., Weidinger, W. (2010). *Educating for Democracy: Background Materials on Democratic Citizenship and Human Rights Education for Teachers*. Strasbourg Cedex: Council of Europe.

Herod , L. (2012). Adult Learning: From Theory to Practice. Retrieved October 4, 2017 from http://en.copian.ca/library/learning/adult_learning/adult_learning.pdf.

Kamp, M. (2011). *Facilitation Skills and Methods of Adult Education*. Uganda: Konrad-Adenauer-Stiftung.

Knowles, M.S. et al., (2005) The Adult Learner: The Definitive Classic in Adult Education and Human Resource Development. California: Elsevier

Leila, B., Dumlao, R., Falk, A., Hollander., Knutson, E., Poehnert, J., Politano, A., & Werner, V. (no date). *Core Competencies in Civic Engagement*. U.S.,:Center for Engaged Democracy.

McCracken, J.R. (No date). *Civic Education*. Retrieved November 12, 2017 from *https://www.civicus.org/documents/toolkits/PGX_B_Civic%20Education.pdf*

Mcleod Joyce et al., (2003). the key elements of classroom Management. USA.: the Association for Supervision and Curriculum Development (ASCD).

Mezirow, J., & Taylor, E.W. (2009). *Transformative Learning in practice: Insights from Community, Workplace, and Higher Education.* U.S.,: Jossey-Bass.

Office of Democracy and Governance, USAID. (2002). *Approaches to Civic Education: Lessons Learned.* Washington: Office of Democracy and Governance, USAID.

Oliver, R. M.& Reschly, D.J. (2007). Effective Classroom Management: Teacher Preparation and Professional Development. Washington, DC.: National Comprehensive Center for Teacher Quality

Peace Corps. (no date). Classroom Management. Wasinton DC: Peace Corps
Prigent, S. (2016).
*Improving Teacher Quality: Maximizing Returns on Investment in Teacher Education in Cambodia*.
Phnom Penh: Ministry of Education Youth and Sports, Kampuchean Action for Primary Education, and Child Fund Cambodia.
Saphier, J., Haley-Speca, M.A., Gower, R. (2008).
*The Skillful Teacher: Building Your Teaching Skills*.
U.S.: Research for Better Teaching, Inc.
Taylor, E.W., Cranton, P., & Associates. (2012). *The Handbook of Transformative Learning: Theory, Research, and Practice.* U.S.,: Jossey-Bass.
TEAL Center staff. (2011).Adult Learning Theories. Retrieved October 4, 2017 from https://lincs.ed.gov/sites/default/files/11%20TEAL_Adult_Learning_Theory.pdf
Vandenberg, L. (no date). Facilitating Adult Learning: How to teach so people learn. Retrieved from
http://www.canr.msu.edu/od/uploads/files/PD/Facilitating_Adult_Learning.pdf
Wiseman, D. G. & Hunt, G.H. (2014). Best Practice in Motivation and Management in the Classroom. USA.: Charles C Thomas Publisher, LTD.